ទស្សនាវដ្តីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត




លេខ ៥៩ ខែវិច្ឆិកា ឆ្នាំ២០០៤

# ស្វែងរកការពិត

លេខ៥៩ ខែវិច្ឆិកា ឆ្នាំ២០០៤


## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆ សំបុត្រៈ ដោះស្រាយបញ្ហាយុត្តិធម៌និងការផ្សះផ្សា........................១

**ផ្នែកឯកសារ**

◆ អតីតប្រធានពាណិជ្ជកម្មស្រុកចម្ការលើ......................................២

◆ ការពិនិត្យការងាររបស់ផ្នែកខាងសួរ..........................................៦

◆ បញ្ជីឈ្មោះជនរងគ្រោះដែលកម្ទេចនៅមន្ទីរ ស-២១.................១០

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ដើម្បីប្រទេសជាតិ...........................................................១២

◆ ខំធ្វើការដើម្បីរស់...........................................................១៤

◆ កង វន និងជំងឺផ្លូវចិត្តដែលបន្សល់ទុកពីរបបខ្មែរក្រហម..............១៧

◆ ឃុំរំលេចៈ ខ្មែរកម្ពុជាក្រោមនៅក្រោមការត្រួតត្រា...............១៩

◆ អ្នកបកប្រែទូរលេខមន្ទីរ៨៧០ .........................................២៥

**ផ្នែកច្បាប់**

◆ ការវិវត្តថ្មីៗនៃដំណើរការបង្កើតតុលាការខ្មែរក្រហម..............២៨

◆ ការប្រល័យពូជសាសន៍ខ្លួនឯង........................................ ២៩

◆ សេចក្តីប្រកាសពត៌មាន..................................................២៩

◆ តុលាការអន្តរជាតិលាតត្រដាងអំពីការកាត់ទោស................. ៣២

**វេទិកាពិភាក្សាសាធារណៈ**

◆ ការដកខ្លួនរបស់សហរដ្ឋអាមេរិក......................................៤៩

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ តើរឿងហ្នឹងវាយ៉ាងម៉េច? ..........................................៥០

◆ ២៩ឆ្នាំក្រោយ បានត្រឹមតែឃើញរូបថត..........................៥៩




នារីពេទ្យខ្មែរក្រហមៈ ឃួន នី, ស៊ី, មិនស្គាល់ឈ្មោះ និង ឃួន គុងហេង (ប្អូនប្រុសរបស់ ឃួន នី), ភ្នំពេញ ឆ្នាំ១៩៧៤ ។ ដកស្រង់ចេញពីសៀវភៅ "ជីវិតក្នុងភាពនឹងថ្កល់" ទំព័រ២ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


**ស្នេរលេខនេះ៖** យិន នាន, ផាន់ សុជា, ញាណ សុជាតិ, អែម សុឃីម, គីម កែវកន្និដ្ឋា, រេម៉ិន ចូហាន់សេន, ស៊ូហ្សាណា លីនតុន, ម៉េង រស្មី **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, សូ ហ្វារីណា **និពន្ធនាយករងៈ** សាន់ កល្យាណ **អ្នកបកប្រែៈ** ផាត រចនា, ជី ទេរិទ្ធិ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ីម សុភ័ក្រ្ត **គ្រប់គ្រងការចែកផ្សាយៈ** មាស ប៊ុនថាន



Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ:*

# ដោះស្រាយបញ្ហាយុត្តិធម៌ និងការផ្សះផ្សា

ដោយសារតែការបង្កើតតុលាការសម្រាប់វិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមកាន់តែខិតមកជិតដល់ខ្ញុំសង្ឃឹមថា ឆ្នាំ២០០៥នឹងក្លាយទៅជាឆ្នាំមួយដែលពោរពេញទៅដោយព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗជាច្រើនសម្រាប់ប្រទេសកម្ពុជា ។ នៅថ្ងៃទី៤ និងទី៥ ខែតុលា ឆ្នាំ២០០៤ រដ្ឋសភាថ្មីនៃព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នទៅលើៈ ១) កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និង ២) ច្បាប់ស្តីពីវិសោធនកម្មច្បាប់បង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មកទៀត នៅថ្ងៃទី២៧ ខែតុលា ប្រមុខរដ្ឋបានប្រកាសឲ្យប្រើប្រាស់ជាផ្លូវការនូវច្បាប់កាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលត្រូវបានធ្វើវិសោធនកម្មឲ្យស្របទៅនឹងកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលជាមួយនឹងអង្គការសហប្រជាជាតិស្តីអំពីការបង្កើតតុលាការខ្មែរក្រហម ។

បើទោះជាមិនមែនមានតែមជ្ឈមណ្ឌលឯកសារកម្ពុជាដែលជាអ្នកជំរុញឲ្យមានការផ្តល់សច្ចាប័ននេះក៏ពិតមែន ក៏ប៉ុន្តែយើងមានអារម្មណ៍ថា កិច្ចខិតខំប្រឹងប្រែងរបស់យើងក្នុងការស្វែងរកយុត្តិធម៌ឲ្យប្រជាជនកម្ពុជាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើព្រឹត្តិការណ៍នេះ ។

លើសពីនេះទៅទៀត កាលពីខែកក្កដា ឆ្នាំ២០០៤កន្លងទៅ យើងបានផ្ញើលិខិតមួយជូនរាជរដ្ឋាភិបាលកម្ពុជាស្នើសុំឲ្យមានការប្រកាសជាផ្លូវការនូវទិវាជាតិមួយអំពីការចងចាំនិងយុត្តិធម៌ដែលនឹងកើតឡើងចំថ្ងៃដំបូងបំផុតនៃការបើកសវនាការរបស់តុលាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ហើយយើងក៏មានក្តីសោមនស្សរីករាយដោយបានឮសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាសជាផ្លូវការកាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៥ ថានឹងអនុម័តឲ្យមានថ្ងៃឈប់សម្រាកនេះ ។

ថ្ងៃឈប់សម្រាកមួយនេះនឹងអាចឲ្យប្រជាជនកម្ពុជាសម្តែងនូវការគោរពរបស់ខ្លួនចំពោះវិញ្ញាណក្ខន្ធរបស់អ្នកដែលបានបាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ហើយក៏ជាថ្ងៃមួយដែលអាចឲ្យជនរងគ្រោះទាំងឡាយដែលនៅរស់រានមានជីវិតបានចែករំលែកនូវការចងចាំរបស់ខ្លួនជាមួយសាច់ញាតិនិងអ្នកដទៃ ។

អស់រយៈពេលជាងមួយភាគបួននៃទសវត្សរ៍មកហើយដែលប្រជាជនកម្ពុជាបានរង់ចាំមើលមេដឹកនាំនៃរបបខ្មែរក្រហមទទួលខុសត្រូវចំពោះទង្វើដែលខ្លួនបានប្រព្រឹត្ត ហើយនិងរង់ចាំមើលការផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ។

បើទោះបីជាយើងមិនរំពឹងថាការទទួលខុសត្រូវតាមផ្លូវច្បាប់ចំពោះបទឧក្រិដ្ឋដ៏ឃោរឃៅនៃរបបខ្មែរក្រហម អាចដោះស្រាយភាពក្រីក្រនិងភាពអយុត្តិធម៌ដែលប្រជាជនកម្ពុជាកំពុងតែជួបប្រទះយ៉ាងណាក៏ដោយ ក៏យើងសង្ឃឹមថា ការបង្កើតតុលាការនេះនឹងផ្តល់ឱកាសមួយក្នុងការដោះស្រាយបញ្ហាយុត្តិធម៌និងការផ្សះផ្សាដែលនៅតែជាដំបៅនៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃនេះ ។ ការកាត់ទោសមេដឹកនាំខ្មែរក្រហមមិនត្រឹមតែអាចជួយឲ្យសាធារណជនទទួលស្គាល់នូវវិធានការយុត្តិធម៌ចំពោះទង្វើដែលបានប្រព្រឹត្តមកលើប្រជាជនកម្ពុជាប៉ុណ្ណោះទេ ថែមទាំងអាចជួយឲ្យកម្ពុជាអាចពង្រឹងនីតិរដ្ឋមួយដែលរឹងប៉ឹងជាងមុន ។ ទន្ទឹមនឹងការក្រឡេកមើលទៅអតីតកាល យើងក៏ត្រូវតែសម្លឹងមើលទៅអនាគតដែរ ។

**ឆាំង យុ**

*(អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាព)*

# អតីតប្រធានពាណិជ្ជកម្មស្រុកចម្ការលើ

ម៉ក់ ហ៊ាង ជាអតីតប្រធានពាណិជ្ជកម្មស្រុកចម្ការលើ តំបន់៤២ ។ ហ៊ាង ចូលបម្រើបដិវត្តន៍នៅឆ្នាំ១៩៦៥ តាមរយៈឈ្មោះ យ៉េង ជាគ្រូបង្រៀននៅសាលាស្ពឺ ហើយក្រោយមកក៏ត្រូវ យ៉េង បញ្ចុះបញ្ចូលឲ្យក្បត់បដិវត្តន៍ ។ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៧ ហ៊ាង ត្រូវអង្គការចាប់ខ្លួន ហើយបញ្ជូនមកមន្ទីរឃុំឃាំង ស-២១ នៅថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៧ ។

ហ៊ាង មានស្រុកកំណើតនៅភូមិស្វាកែត ឃុំក្រវ៉ា ស្រុកបារាយណ៍ ខេត្តកំពង់ចាម ប៉ុន្តែបានទៅរស់នៅជាមួយឪពុកនៅស្ពឺ ហើយចូលរៀននៅសាលាស្ពឺ ។ នៅឆ្នាំ១៩៥៧ ហ៊ាង ឈប់រៀនត្រឹមថ្នាក់ឧត្តមដ្ឋាន ហើយមកជួយធ្វើស្រែចម្ការជាមួយឪពុក ។

អំឡុងពេលរៀននៅសាលា ហ៊ាង បានទទួលការអប់រំអំពីបដិវត្តន៍ពីគ្រូៗនៅទីនោះ ហើយគួបផ្សំនឹងការអប់រំរបស់ យ៉េង ថែមទៀត ហ៊ាង ក៏សម្រេចចិត្តចូលបម្រើបដិវត្តន៍ ។

នៅឆ្នាំ១៩៦៦ យ៉េង បានណែនាំឲ្យ ហ៊ាង ធ្វើការឲ្យសេ.អ៊ី.អា វិញ ដោយសន្យាឲ្យប្រាក់បៀវត្សរ៍១.៨០០រៀលក្នុងមួយខែ និងប្រាក់រង្វាន់ពី១៥០រៀលទៅ៣០០រៀលថែមទៀតទៅតាមសកម្មភាពការងារដែលបានបំពេញ ។ នៅពេលដែល ហ៊ាង យល់ព្រមហើយ យ៉េង បានឧទ្ទេសនាម ឈ្មោះ ឃួន, ហុន និង វ៉ែន ដែលជាអ្នកដឹកនាំឲ្យ ហ៊ាង បានស្គាល់ ។

បន្ទាប់ពីចូលសេ.អ៊ី.អាហើយ ហ៊ាង បានប្រជុំដើម្បីទទួលផែនការៈ ១)ពង្រីកកម្លាំងក្បត់ថ្មីឲ្យបានច្រើន ២)រកកម្លាំងពីរបីនាក់ដែលប៉ិនប្រសប់ឲ្យដើរលក់ដូរទំនិញតាមភូមិតូចៗនៅក្បែរព្រៃ ដើម្បីយកលេសទាក់ទងជាមួយខ្មាំង និងចាត់តាំងមនុស្សបីនាក់ដែលចេះការងារជាងឈើ និងចេះដកស្លឹងឲ្យដើរស៊ីឈ្នួលអ្នកស្រុកនិង៤)ត្រូវកម្ទេចឈ្មោះ លឹម គុច និង ថោង ។

ហ៊ាង រួមជាមួយ ខេ និង ជៀប បានកម្ទេចជម្រកខ្មែរក្រហមនៅចម្ការដូង ហើយរឹបអូសបានអង្ករនិងថ្នាំពេទ្យមួយចំនួន ។

នៅឆ្នាំ១៩៦៧ ហ៊ាង និងកម្លាំងបង្កប់ បានប្រជុំគ្នាដើម្បីជំរុញសកម្មភាពកម្ទេចបដិវត្តន៍ដោយសហការជាមួយប៉ូលិសម្នាក់ឈ្មោះ សឿង ដើម្បីចាប់ឈ្មោះ ថោង សំអាត, រិន, តាទូច, ស៊ីមយុន និង លឹម គុច ។

ហ៊ាង បង្កើនកិច្ចសហការជាមួយប៉ូលិសនិងមេឃុំមួយចំនួននៅក្នុងស្រុកដើម្បីកម្ទេចបដិវត្តន៍នៅព្រៃត្រពាំងល្អក់និងប្រចាំនៅក្នុងសង្កាត់ជយោ ។

នៅឆ្នាំ១៩៦៩ មេឃុំស្ពឺឈ្មោះ ថាវ បានចាត់តាំងឲ្យ ហ៊ាង ធ្វើជាមេ១០ខ្នងនៅភូមិពែងមាសខាងជើង និងដឹកនាំកងជីវពលយាមនៅបន្ទាយស្ពឺ ហើយសន្យាឲ្យប្រាក់ខែដល់ ហ៊ាង ៨០០រៀល ។

សកម្មភាពសំខាន់ៗរបស់ ហ៊ាង នៅឆ្នាំ១៩៦៩ មានពីរធំៗ គឺដឹកនាំកងជីវពលយាមនៅបន្ទាយស្ពឺ និងយកសំណូកជាលុយកាក់ឬឈើពីអ្នកដឹកឈើលក់ ។

**ក្រោយរដ្ឋប្រហារ ឆ្នាំ១៩៧០**

យ៉េង ដែលឡើងជាប្រធានរណសិរ្សស្រុក បានចាត់តាំងឲ្យ ហ៊ាង ធ្វើជាប្រធានភូមិពែងមាសខាងជើង ការងាររបស់ ហ៊ាង គឺកសាងកម្លាំងក្បត់ដើម្បីបង្កប់ក្នុងជួរបដិវត្តន៍ បញ្ចេញស្បៀងទៅឲ្យតំបន់ខ្មាំងដើម្បីឲ្យប្រជាជនខ្វះខាត និងបង្អាក់សកម្មភាពធ្វើស្រែចម្ការរបស់ប្រជាជនដោយផាកមកប្រជុំគ្នាតែពីកិច្ចការជំនួញប៉ុណ្ណោះ ។

**អំពីសកម្មភាពក្បត់ ការទាក់ទងបក្សពួក និងការកសាងកម្លាំងក្បត់**

ហ៊ាង បញ្ចេញស្រូវ អង្ករ ពោត សណ្តែក គោក្របី ទៅឲ្យតំបន់ខ្មាំង និងចេញសំបុត្របញ្ជាក់ឲ្យប្រជាជនដឹកស្ករ អង្ករ ចេក តំណាប់ចេក សណ្តែកដី ទៅជួញដូរនៅតំបន់ដែលលន់ណុលគ្រប់គ្រង ។

នៅឆ្នាំដដែល ហ៊ាង និងកម្លាំងបានបង្កប់ឡើងទៅកម្ទេចបដិវត្តន៍ចំនួនពីរលើក ។ លើកទី១ នៅភ្នំអាសីសិត និងលើកទី២ នៅខាងកើតភូមិអន្លាយ សង្កាត់ស្ពឺ ខេត្តកំពង់ចាម ហើយកសាងកម្លាំងក្បត់បាន២នាក់ថែមទៀតផង ។

ហ៊ាង បានប្រជុំជាមួយ គៀម លេខាស្រុកចម្ការលើដើម្បី

ទទួលផែនការបន្តទៀតគឺ ១) ធ្វើនយោបាយចិត្តសាស្ត្រនៅសមរភូមិ ២) បញ្ជូនកម្មាភិបាលក្បត់ទៅសមរភូមិ ៣) បញ្ចេញស្រូវចំនួន ១ពាន់ថាំង និងគំណាប់ចេក៦បាវ ហើយនៅខែ៧បញ្ចេញស្រូវចំនួន៥រយថាំង និងខែ៨បញ្ចេញស្រូវចំនួន៥រយថាំង ៤) រៀបឲ្យប្រជាជនដួញដូរតាមកង់ម៉ូតូដែលជាឱកាសឲ្យគិញអាចលួចបន្លំខ្លួនចូលមកក្នុងស្រុកភូមិបាន ។

ចាប់ពីខែ៥ដល់ខែ១០ កម្លាំងរបស់ ហ៊ាង បានកម្ទេចកម្មាភិបាលម្នាក់ឈ្មោះ យន់ ប្រធានយោធាស្រុកចម្ការលើ និងនិរសារពីរនាក់ទៀតរបស់ យន់ ហើយបានបញ្ចេញស្រូវ៣រយថាំងនិងគំណាប់ចេក៦បាវទៅឲ្យខ្មាំង ព្រមទាំងកាប់ជ្រូកយកសាច់លក់ឲ្យប្រជាជន នៅសល់ប៉ុន្មានទុកសម្រាប់ក្មែងស្រា ។

នៅឆ្នាំ១៩៧២ ហ៊ាង បានកសាងកម្លាំងក្បត់បាន៥នាក់ដែលជាមនុស្សមានធាតុសេរីចូលចិត្តសប្បាយ ។ ហ៊ាង បានបង្កទំនាស់រវាងបដិវត្តន៍និងប្រជាជនពីស្រុកមួយទៅស្រុកមួយទៀត ដូចជា ចាប់អ្នកលក់ដូរបន្លែបង្ការនិងអង្ករ ហើយឃាត់ខ្លួនទុកពី២ទៅ៣យប់ ឬជួនកាលឃាត់ខ្លួនពី១៥ថ្ងៃទៅ១ខែក៏មាន ។ បន្ទាប់មកទៀតធ្វើឲ្យប្រជាជនមានការច្របូកច្របល់ ដោយសារតែខ្វះដីធ្វើស្រែហើយគ្មានអង្ករ ពោត សណ្តែក សម្រាប់បរិភោគ ព្រោះតែ របស់ទាំងអស់នេះត្រូវដឹកយកទៅឲ្យខ្មាំងអស់ទៅហើយ ។ ហេតុដូច្នេះហើយ ប្រជាជនមួយចំនួនធំបានសម្រេចចិត្តរើផ្ទះទៅរស់នៅដីថ្មីវិញ ។

នៅឆ្នាំដដែល ហ៊ាង រួមជាមួយកម្លាំងបក្កប់ បានបំផ្លាញមូលដ្ឋានទ័ពវៀតណាមនៅក្នុងស្រុក៤កន្លែង ប៉ុន្តែក្រោយមកទ័ពវៀតណាមបានសម្រុកចូលមកក្នុងភូមិ ហើយខាង ហ៊ាង បំផុសប្រជាជនមិនឲ្យតដៃជាមួយទ័ពវៀតណាមទេ ។ នៅខែ៥ ហ៊ាង បានបញ្ចេញជ្រូកនិងមាន់៦០ក្បាលទៅឲ្យខ្មាំងនៅតាំងគោក ហើយមិនព្រមដោះស្រាយជីវភាពរស់នៅរបស់ឪពុកម្តាយយុទ្ធជនដែលនៅស្រុកកំណើតឡើយ ។ ជានេះទៅទៀត ហ៊ាង យកលេសធ្វើផ្លូវ ហើយកាប់ដើមដូងរបស់ប្រជាជន ព្រមទាំងចាប់ចងម្ចាស់ដូងថែមទៀត ។ បន្ទាប់ពីនោះ ហ៊ាង បានកេណ្ឌប្រជាជនឲ្យទៅគាស់រានដីថ្មីនៅអូរនាងនង់ បណ្តាលឲ្យប្រជាជនកើតជំងឺគ្រុនចាញ់ ហើយស្លាប់អស់៨នាក់ ។ ហ៊ាង បានទាក់ទង គៀម អំពីបញ្ហារុះរើផ្ទះសម្បែងនិងរឹបអូសយកជយភណ្ឌ ហើយបានដឹកនាំកម្លាំងទៅធ្វើផ្លូវថ្នល់ជំនួសឲ្យទៅលើកទំនប់ ។

នៅរវាងខែ១១-១២ អង្គការបានចាត់តាំងឲ្យ ហ៊ាង នាំកម្លាំងពិសេស៥០នាក់ទៅជួយផ្តាច់ផ្លូវ ប៉ុន្តែ ហ៊ាង បែរជាបញ្ជូនកម្លាំងទៅតែ៣០នាក់ ហើយមានសុខភាពមិនសូវល្អ ។ ក្រៅពីនេះ ហ៊ាង បានទាក់ទងបក្សពួកក្បត់ ហើយទទួលផែនការពី គៀម ដែលឲ្យខិតខំកសាងកម្លាំងក្បត់ឲ្យបានច្រើននិងរកឧបាយកលដើម្បីបង្អត់បាយប្រជាជនផង ។

នៅពេលដែលអង្គការឲ្យរកកម្លាំងឬសមាសភាពល្អៗ ដូចជាអ្នកក្រឬកសិករកណ្តាលថ្នាក់ក្រោម ដើម្បីបញ្ជូនទៅសមរភូមិឬធ្វើការនៅតាមមូលដ្ឋាន ហ៊ាង បែរជារកមនុស្សមានបងប្អូនធ្វើទាហានឬប៉ូលិសដែលត្រូវអង្គការកម្ទេចចោល ឬលើសពីនេះទៅទៀត មនុស្សដែល ហ៊ាង ណែនាំឲ្យអង្គការគឺជាប៉ូលិសឬទាហានលន់ណុលតែម្តង ។

នៅឆ្នាំ១៩៧៣ ហ៊ាង កសាងកម្លាំងក្បត់បាន៣នាក់សុទ្ធតែជាមនុស្សចូលចិត្តសប្បាយ ។ ចំណែក គៀម បានចាត់តាំងកម្លាំងឲ្យធ្វើនយោបាយចិត្តសាស្ត្រនៅសមរភូមិកំពង់ចាមនៅពេលដែលខេត្តនេះហៀបនឹងរំដោះបាន ។ កម្លាំងមួយចំនួនឃោសនាថាទាហានលន់ណុលបាក់ទ័ពហើយ ចំណែកមួយចំនួនទៀតបាញ់សន្ធប់ទៅលើប្រជាជននិងកងទ័ពបដិវត្តន៍ដែលធ្វើឲ្យប្រជាជនជ្រួលច្របល់រត់ខ្ចាត់ខ្ចាយ ។ បន្ទាប់មកទៀត កម្លាំងរបស់ ហ៊ាង បានទម្លាយទំនប់បង្ហូរទឹកចោលអស់ ធ្វើឲ្យខ្វះទឹកធ្វើស្រែនិងបណ្តាលឲ្យស្រូវស្កកងាប់ខ្ទេចគ្មានសល់ ។

នៅឆ្នាំដដែល អង្គការទុកពេលវេលាឲ្យ ហ៊ាង កន្លះខែដើម្បីជម្លៀសក្រុមគ្រួសារអ្នកដែលត្រូវកម្ទេច និងអ្នកដែលជាប់សាច់ញាតិជាមួយ អ៊ិន តាំ ទៅតំបន់ជនបទ ព្រមទាំងដឹកជញ្ជូនក៏ប៉ុន្តែ ហ៊ាង ចំណាយពេលដល់ទៅ៣ខែដើម្បីធ្វើកិច្ចការនេះ ។

នៅឆ្នាំដដែល ហ៊ាង បានធ្វើឲ្យខូចខាតសន្ទូងរបស់ប្រជាជនយ៉ាងច្រើន ។ ក្រោយមក ហ៊ាង ចូលរួមដាក់ផែនការថ្មីទៀតមានពិនិត្យមើលពេលវេលាដែលត្រូវបាញ់បង្អើល គប់គ្រាប់បែក ឬដាក់គ្រាប់បែកនៅតាមមន្ទីរយោធា ។ ចំពោះដំណាំចម្ការ កម្លាំងរបស់ ហ៊ាង បានគាស់ដើមចេកល្អៗរាប់ម៉ឺនដើមទៅដាំនៅតាម

ចិញ្ចឹមផ្ទាល់ដោយគ្មានការថែរក្សាហើយបណ្តោយឲ្យគោក្របីស៊ីដើមចេកទាល់តែអស់ ។

នៅឆ្នាំ១៩៧៤ អង្គការចាត់តាំងឲ្យ ហ៊ាង ធ្វើជាប្រធានពាណិជ្ជកម្មស្រុកចម្ការលើ ។ ហ៊ាង កសាងកម្លាំងបាន៦នាក់ ហើយដាក់ភារកិច្ចឲ្យអនុវត្ត ដោយបញ្ជាឲ្យទិញផ្លែចេកណាំវ៉ាពីប្រជាជនដើម្បីលក់ជូនរដ្ឋ ប៉ុន្តែនៅពេលដឹកចេកទៅដល់កន្លែងបែរជាមិនអើពើបណ្តោយឲ្យគោសេះស៊ីខ្ទេច ។ ឆ្លៀតពេលដែលប្រជាជនដំបូងជួបគ្រោះទុរ្ភិក្ស កម្លាំងមួយចំនួនរបស់ ហ៊ាង បាននាំប្រជាជនចូលព្រៃកាប់ឈើធ្វើផ្ទះនិងរទេះ ។ បន្ទាប់មក ហ៊ាង បញ្ចេញអង្ករ៦តោនទៅឲ្យខ្មាំងតាមរយៈ គុល ដែលជាមន្ត្រីពាណិជ្ជកម្មស្រុកចម្ការលើ និង៥តោនតាមរយៈ ធិន ដែលជាមន្ត្រីពាណិជ្ជកម្មស្រុកកំពង់សៀម ។ ហ៊ាង ឆ្លៀតឱកាសដែលអង្គការចេញបញ្ជាឲ្យដាក់ជីក្នុងស្រែនិងរើសពូជស្រូវឲ្យបានសមស្របនឹងស្ថានភាពដី បែរជានាំគ្នាបង្វែរមាគ៌ាបង្កើនផលរបស់បក្ស “ស្រូវធ្ងន់ស្ទូងដីខ្ពស់ ស្រូវស្រាលស្ទូងដីទំនាបទឹកលិច” ហើយយកជីទៅដាក់តែក្នុងស្រែណាដែលល្អស្រាប់ ដើម្បីឲ្យផាប់សន្ទូង ។ ជាលទ្ធផលប្រជាជនកើតទោមនស្សនឹងអង្គការ ដោយសារពូជស្រូវ ដែលអង្គការផ្តល់ឲ្យយកទៅសាបមិនដុះ ។

ហ៊ាង និងកម្លាំងបាននាំប្រជាជនទៅធ្វើត្រីប្រហុក រហូតដល់ពាក់កណ្តាលខែ១បណ្តាលឲ្យហួសពេលច្រូតស្រូវ ។

នៅឆ្នាំ១៩៧៥ កម្លាំងរបស់ ហ៊ាង បាននាំកម្លាំងប្រជាជនទៅកាស់រានដីថ្មីនៅអូរនាងនង់ និងអន្លង់ពេជ្រ បណ្តាលឲ្យប្រជាជនកើតជំងឺគ្រុនចាញ់ហើយស្លាប់អស់មួយចំនួន ។

នៅខែ២ ឆ្នាំ១៩៧៥ ហ៊ាង ដើរនិយាយជាមួយប្រជាជនថា ដីវាលធ្វើស្រែមិនអស់ អង្គការបែរជាឲ្យទៅកាស់ដីព្រៃវិញ ។

ហ៊ាង រួមជាមួយកម្លាំងបាននាំគ្នាដាក់ផែនការចិត្តសាស្ត្រគឺនៅពេលដែលឮសំឡេងយន្តហោះភ្លាម ត្រូវនាំគ្នាធ្វើជាភ័យខ្លាចចង់រត់បន្តិចចង់ពួនបន្តិចដើម្បីឲ្យប្រជាជនផ្អើលរត់ចេញពីភូមិទៅកន្លែងផ្សេង ។ ហ៊ាង មានផែនការដឹកអង្ករ៥តោនទៅឲ្យ ធិន មន្ត្រីពាណិជ្ជកម្មស្រុកកំពង់សៀម ប៉ុន្តែទើបតែដឹកបាន២តោនកន្លះផែនការក៏ខកខាន អង្ករពីរតោនកន្លះទៀត ក៏យកទៅចែកប្រជាជនជម្លៀស ។ អង្គការក៏វាយឈ្នះ គ្រប់គ្រងប្រទេសទាំងស្រុង ។



ហ៊ាង ទទួលផែនការថ្មីពី គុល ឲ្យឃ្លាំមើលប្រជាជនដែលជម្លៀសមកពីភ្នំពេញនិងកំពង់ចាម ដកសម្ភារជាម៉ូតូ ជយភណ្ឌលាក់ទុកខ្លះ ដើម្បីបង្កទំនាស់រវាងប្រជាជន កងទ័ព ក្រសួង មន្ទីរជាមួយរដ្ឋអំណាច ។ ហ៊ាង បានចាត់តាំងតែប្រជាជនមូលដ្ឋានឲ្យធ្វើស្រែ ហើយប្រជាជនថ្មីចាំតែហូបស្រាប់ ។ ឃើញដូចនេះប្រជាជនមូលដ្ឋានខឹងសម្បានឹងអង្គការហើយក៏បន្ថយការងាររបស់ខ្លួន ។ ក្នុងឆ្នាំដដែល ហ៊ាង លាក់ទុកពួកអ្នករដ្ឋការនិងអ្នកដែលមានបណ្តាស័ក្តិមួយចំនួន ។ នៅចុងឆ្នាំ១៩៧៥ សកម្មភាពរបស់ ហ៊ាង និងបក្ខពួកកន្លងមក បានធ្វើឲ្យប្រជាជនជាច្រើនស្លាប់ដោយសារជំងឺហើមនិងអត់បាយ ។ នៅឆ្នាំ១៩៧៦ ហ៊ាង កសាងកម្លាំងបាន៥នាក់ទៀត ។ អង្គការណែនាំឲ្យត្រៀមដី ជ្រើសរើសពូជស្រូវនិងឧបករណ៍ធ្វើស្រែឲ្យរួចរាល់ ព្រោះជិតដល់រដូវដកស្ទូងហើយ ប៉ុន្តែកម្លាំងរបស់ ហ៊ាង បានដាក់ពូជស្រូវធ្ងន់លាយជាមួយពូជស្រូវស្រាលធ្វើឲ្យស្រូវលូតលាស់មិនស្មើគ្នា ហើយនៅពេលស្រូវទុំ ក៏ពន្យារពេលច្រូតធ្វើឲ្យស្រូវខូចអស់ជាច្រើន ។



នៅឆ្នាំដដែល អង្គការបានចាត់តាំងឲ្យ ហ៊ាង ទទួលខុសត្រូវខាងផ្គត់ផ្គង់ស្បៀងដល់យុវជន-យុវនារី ដែលធ្វើប្រឡាយនៅកំពង់ថ្ម ។ ដោយសារតែ ហ៊ាង មិនបានផ្គត់ផ្គង់ស្បៀងតាមតម្រូវការ នាំឲ្យយុវជន-យុវនារីមួយចំនួនទ្រាំមិនបាន ក៏ត្រឡប់មកផ្ទះ ហើយមួយចំនួនទៀតក៏ឈប់ធ្វើការ ។ កម្លាំងរបស់ ហ៊ាង បានប្រមូលកង់ វិទ្យុ និងនាឡិកា ទុកសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ចំណែក អំបិល ទឹកត្រី ទឹកប្រហុក ក៏មិនបានផ្តល់ឲ្យប្រជាជនភ្លាមៗដែរ ធ្វើឲ្យប្រជាជនគ្មានម្ហូបបរិភោគ ហើយស្លាប់អស់មួយចំនួន ។

អង្គការចេញបញ្ជាឲ្យចែកចាយថ្នាំសម្លាប់សត្វល្អិតដល់ប្រជាជន ប៉ុន្តែ ហ៊ាង បែរជាយកថ្នាំស្តុកទុកក្នុងឃ្លាំងធ្វើឲ្យសត្វល្អិតស៊ីស្រូវអស់មួយចំនួនធំ ។

នៅឆ្នាំ១៩៧៧ ក្រោយពីទទួលផែនការបដិវត្តន៍ ហ៊ាង រឹបអូសឈើពីប្រជាជនយកមកសង់ផ្ទះ ឃ្លាំង និងមន្ទីរ ។ នៅពេលអង្គការត្រូវការកម្លាំងដើម្បីលើកទំនប់ ហ៊ាង បានបញ្ជូនកម្លាំងដែលមិនស៊ាហាប់និង ទុរន់ទុរាទៅឲ្យអង្គការ ហើយពេលដែលអង្គការចាត់តាំងឲ្យទទួលខុសត្រូវខាងផ្គត់ផ្គង់ម្ហូបដល់ប្រជាជន ហ៊ាង ធ្វើព្រងើយកន្តើយមិនព្រមផ្គត់ផ្គង់ស្បៀងឲ្យប្រជាជនទាន់ពេលវេលាឡើយ ។

នៅខែ២ ឆ្នាំ១៩៧៧ ហ៊ាង បានទទួលម៉ាស៊ីនដេរចំនួន១០០ គ្រឿងដែលយកមកពីសង្កាត់ស្តីដាក់ក្នុងពាណិជ្ជកម្មស្រុក ហើយបានបញ្ចុះបញ្ចូលម្ចាស់ម៉ាស៊ីនដេរឲ្យលាក់ទុកផ្នែកណាមួយនៃម៉ាស៊ីនដេរ ធ្វើយ៉ាងណាកុំឲ្យប្រើការកើត ។ ការរៀបចំទុកដាក់ម៉ាស៊ីនដេរក៏មិនបានស្រួលបួលដែរ ដោយម៉ាស៊ីនដេរខ្លះទុកនៅក្រៅឃ្លាំងហាលភ្លៀងហាលថ្ងៃខូចអស់ ។

សកម្មភាពក្បត់របស់ ហ៊ាង ត្រូវអង្គការតាមដាននិងរកឃើញ ។ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៧ ហ៊ាង ត្រូវអង្គការចាប់ខ្លួនហើយបញ្ជូនមកមន្ទីរឃុំឃាំង ស-២១ នៅថ្ងៃទី១ ខែមីនា ឆ្នាំ១៩៧៧ ។ ហ៊ាង បានសារភាពទាំងអស់នូវសកម្មភាពបំផ្លាញបដិវត្តន៍កន្លងមក និងបញ្ជាក់ឈ្មោះអ្នកពាក់ព័ន្ធជាមួយខ្លួនជាច្រើននាក់ផង ។ អ្នកសួរចម្លើយឈ្មោះ សេង ។

**សូ ហ្វារីណា**

*(ឯកសារសន្តិបាល)*

# ការពិនិត្យការងារចាស់ផ្នែកខាងសួរ

(អត្ថបទដកស្រង់ចេញពីឯកសារលេខD៣៩៥)

**អំពីការកិច្ចបោសសម្អាតខ្មាំង**

សូមចែកជា២ផ្នែកគឺៈ

១) ការបោសសម្អាតខ្មាំងដែលនៅក្នុងអង្គភាព

២) ការបោសសម្អាតខ្មាំងដែលជាភារកិច្ចសួរចម្លើយរបស់យើង ។

**១) ខ្មាំងនៅក្នុងអង្គភាព**

**ក) គុណសម្បត្តិៈ**

យើងបោសសម្អាតខ្មាំងក្នុងអង្គភាពបានជាហូរហែ ដោយឈរលើទស្សនៈមហាជននិងឯកសារមហាជន ។ ជារួម យើងបានខិតខំបោសសម្អាតខ្មាំងក្នុងអង្គភាពយើងផង និងខំកម្ចាត់នូវជំងឺអត្តនោមតិឆ្វេងនិងស្តាំផង ។ យើងធ្វើបានល្អជាបឋម ។

**ខ) គុណវិបត្តិ**

គុណវិបត្តិយើងមាន២គឺៈ

១) យើងបានទទួលការណែនាំពីអង្គការជាគោលការណ៍ ។ តែក្នុងការអនុវត្ត ក្នុងការចាប់ ជួនយើងបានសុំអនុញ្ញាតពីអង្គការ ជួនកាលយើងមិនបានសុំអនុញ្ញាតពីអង្គការ ។

២) កម្មាភិបាលយើងខ្លះចាប់អារម្មណ៍មិនសូវជាប់នឹងការងារបោសសម្អាតនេះទេ ។ ដូចនេះហើយបានជាមានការធ្វេះធ្វោយ មានពេលខ្លះខ្មាំងរត់រួច ។

**គ) មូលហេតុ**

១) ចំពោះការខ្វះខាតទីមួយឆ្លុះបញ្ចាំងឲ្យយើងឃើញសតិអារម្មណ៍ អង្គការវិន័យរបស់យើងមិនទាន់រឹងប៉ឹងដល់កម្រិត យើងច្រើនប្រើសេចក្តីរាយការណ៍មាត់ទទេនៅពេលសភាព-ការណ៍ទុំហើយ ។

២) យើងភ្ជាត់ខ្លះមកពីកម្មាភិបាលយើងអត្តនោមតិ មិនតាមដានឲ្យបានសព្វជ្រុងឲ្យឃើញទាំងផ្នែករីកចម្រើនទាំងផ្នែកមិនចម្រើន ទាំងផ្នែកបដិវត្តនិងផ្នែកប្រឆាំងបដិវត្តន៍នៅឡើយ ។ កម្មសិទ្ធិមនោសញ្ចេតនាវាបាំង វាឃើញត្រឹមតែអំពើល្អ ។

**ឃ) ទិសដោះស្រាយ**

យើងត្រូវរៀនធ្វើសេចក្តីរាយការណ៍ជាលាយលក្ខណ៍អក្សរក្នុងនាមពួកសួរចម្លើយឬក្រុមយុវកក យើងនឹងធ្វើសេចក្តីរាយការណ៍ឲ្យកាន់តែត្រឹមត្រូវឡើងដើម្បីសុំអនុញ្ញាតពីអង្គការ ។ ក្នុងរយៈកាលរង់ចាំសេចក្តីសម្រេច ក៏យើងត្រូវម្ចាស់ការការពារគ្រប់យថាហេតុឲ្យជាប់ ។

**២) ខ្មាំងដែលជាប់នឹងភារកិច្ចសួរចម្លើយរបស់យើង**

**ក) គុណសម្បត្តិ**

ក្នុងរយៈ៦ខែនេះ យើងមានគុណសម្បត្តិខាងទស្សនៈ ប្តេជ្ញាចិត្តបំពេញភារកិច្ចសួរចម្លើយយើងឲ្យបានល្អដើម្បីរួមចំណែកក្នុងការបោសសម្អាតភ្នាក់ងារខ្មាំងដែលបង្កប់នៅក្នុងបក្សយើងនិងក្នុងកងទ័ពយើង ។ មកពីយើងឯកភាពគ្នាជាទស្សនៈគឺគោលបំណង "បោសសម្អាតខ្មាំង" ឲ្យបានស្អាតយ៉ាងដូចនេះ ការងារយើងវាពង្រីកបានត្រឹមត្រូវច្រើនគួរសម ។

យើងមានជំហរខំសួរ ។ សួរឲ្យចេញប្រវត្តិរូបវា ខ្មាំងដែលប្រឆាំងបដិវត្តន៍ពីដើមដល់ចប់ ។ ដូចនេះក្នុងសំណុំរឿងនីមួយៗ ខ្មាំងវានិយាយអំពីសកម្មភាពក្បត់របស់វាជាមូលដ្ឋាន ។ សំណុំរឿងបែបនេះយើងក៏ខំសម្រិតសម្រាំងឲ្យមានគុណភាពល្អជាបន្តបន្ទាប់ ។ ដូចនេះធានាបានកម្រិតជាបឋមដល់មនុស្សដែលវាឆ្លើយដាក់ ។

**ខ) គុណវិបត្តិ**

យើងបំពេញភារកិច្ចបានយឺត ។ យឺតខ្លាំង ។

ជំហរវិភាគយើងមិនទាន់រឹងប៉ឹង ។ បានន័យថា ជួននឹកឃើញចង់វិភាគឲ្យម៉ត់ចត់ក៏វិភាគទៅ ជួនមិននឹកឃើញទេក៏គ្រវាសចោលទៅ ។ ដូចនេះពេលខ្លះឯកសារយើងស្រមេមស្រមាមវែងអន្លាយ ចម្រុះរឿងចាំបាច់ផងនិងរឿងមិនចាំបាច់ផង ចម្រុះរឿងខ្មាំងប្រឌិតលើគោកខ្លះផងនិងរឿងពិតផង ។

គោលជំហររុករកខ្សែខ្មាំងមិនទាន់សកម្មខ្លាំងក្លា ។ នៅ

ពេលខ្លះយើងមិនបានគិតវិភាគ និងវិភាគថាតើខ្សែនេះជាប់នឹងខ្សែណា? ជាប់ពីកាលណា? ជាប់បែបណា? ហើយរិះរកយល់ហេតុផលម៉េចបានជាជាប់? ហេតុម៉េចបានជាមិនជាប់ ។ សរុបទាំងគុណសម្បត្តិនិងគុណវិបត្តិមក ការងារយើងចម្រើនចលនាបាន តែបានយឺត ។ យឺតហើយជួនពេលខ្លះឯកសារយើងយើងមិនទាន់កក់ក្ដៅឲ្យដល់កម្រិត ។

**គ) មូលហេតុនៃគុណវិបត្តិៈ**

◆ កត្តាបក្សដឹកនាំៈ លេខាសាខាជាពិសេសពុំមានជំហរមាគ៌ាសកម្មភាព មាគ៌ាប្រយុទ្ធឲ្យមានប្រសិទ្ធភាព ។ ដូចនេះដើមទុនគោលជំហរវិភាគនិងគោលជំហររុករកស្រាវជ្រាវខ្សែខ្មាំងរបស់មហាជនដែលមានវាកប់មិនបានយកមកប្រើប្រាស់ឲ្យអស់លទ្ធភាព មិនបានពង្រឹងថែមនិងពង្រីកថែម ។

◆ មិត្តយើងម្នាក់ៗក៏នៅសល់ជំហរខ្ជិលគិតគូរ ខ្ជិលវិភាគជំហរបណ្ដែតបណ្ដោយពន្យារ បានន័យថា មិត្តយើងមិនទាន់សុខចិត្តយកដើមទុនដែលមាននោះមកប្រើប្រាស់តាមគោលជំហរទទួលខុសត្រូវចំពោះមុខបក្ស ។

**ឃ) ទិសដោះស្រាយ**

យើងបានភ្ញាក់រឭករៀបចំទស្សនៈគោលជំហរ រៀបចំអង្គភាពខាងចាត់តាំង ដើម្បីបម្រើសំណូមពរបដិវត្តន៍ឲ្យកាន់តែមានប្រសិទ្ធភាព ។ ការងារតទៅមុខគឺៈ

១) ត្រូវពង្រឹងគណៈមេបញ្ជាការអំពីមាគ៌ាប្រយុទ្ធឲ្យកាន់តែមានប្រសិទ្ធភាពដោយកែលម្អជាប់ ។

២) ជំរុញមហាជនឲ្យចូលរួមត្រិះរិះ វិភាគឲ្យសកម្មដោយឈរលើគោលជំហរទទួលខុសត្រូវចំពោះមុខបក្សដាច់ខាត ហើយជំរុញមហាជនឲ្យស៊ុះស្រួក្នុងសន្ទុះតាមដានរុករកខ្មាំងបង្កប់ឲ្យខ្លាំងក្លានិងសកម្មថែមទៀត ។

៣) ពង្រឹងពង្រីកការងារវិភាគតាមគោលការណ៍ដូចតទៅៈ

ក) វិភាគប្រវត្តិសកម្មភាពក្បត់របស់ខ្មាំងឲ្យបានជាខ្សែសង្វាក់តាំងពីដើមដល់ចប់ ដោយយកប្រវត្តិសកម្មភាពខាងដើមឲ្យច្បាស់សម្រាប់ជាតម្រាយឲ្យស្គាល់កាន់តែច្បាស់នូវសកម្ម-ភាពជាខ្សែសង្វាក់បច្ចុប្បន្ន ។ ប៉ុន្តែសំខាន់បំផុតគឺត្រូវលម្អិតសកម្មភាពបច្ចុប្បន្នឲ្យមានលក្ខណៈជាខ្សែសង្វាក់ស៊ីជម្រៅ និងឲ្យអស់រលីង ។

ខ) យើងវិភាគប្រវត្តិរូបខ្មាំងម្នាក់ៗដែលយើងសួរតាមឥទ្ធិពលនយោបាយនៃមជ្ឈដ្ឋានរស់នៅ សេពគប់ រកស៊ី និងគ្រួសារ ហើយយើងវិភាគឥទ្ធិពលដែលវាទទួលនេះតាមគោលការណ៍ដែលវាពង្រីកពីតិចទៅច្រើន ពីរាក់ទៅជ្រៅ ពីបរិមាណទៅគុណភាព ពីមិនទាន់ជាសេ.អ៊ី.អាទៅជាសេ.អ៊ី.អា ហើយគ្រប់សកម្មភាពរបស់វាក៏យើងវិភាគតាមគោលការណ៍ពីតិចទៅច្រើន ពីបរិមាណទៅគុណភាពនេះដែរ ។

គ) មនុស្សម្នាក់ៗដែលខ្មាំងវាឆ្លើយដំពាក់ ក៏យើងពិនិត្យមើលមូលហេតុដែលនាំឲ្យប្រវត្តិរូបឯករាជ្យទាំងពីរនេះដំពាក់គ្នាហើយជាប់គ្នាជាខ្សែសង្វាក់ ។ ជាប់ហើយ យើងពិនិត្យសកម្មភាពរួមដែលវាពង្រីកពីតិចទៅច្រើន ពីបរិមាណទៅគុណភាពនោះតទៅទៀត ។

ឃ) គ្រប់បញ្ហាទាំងអស់ដែលយើងជួបប្រទះ យើងគ្រោងទិដ្ឋភាព២ជានិច្ចគឺបដិវត្តន៍និងប្រឆាំងបដិវត្តន៍ រឿងប្រឌិតនិងរឿងពិត ។ យើងត្រូវចេះរកចំណុចណាជាគន្លឹះដែលនាំឲ្យយើងហ៊ានសន្និដ្ឋានថាទិដ្ឋភាពណាមួយមានលទ្ធភាពជាងគេ ។

ង) គ្រប់ពេលវេលា យើងត្រូវរិះរកទិដ្ឋភាពដែលខ្មាំងវាទាក់ទងគ្នាជាសម្ងាត់ពីម្នាក់ទៅម្នាក់ ពីខ្សែមួយទៅខ្សែមួយទៀត និងពីក្នុងទៅក្រៅ ។

ច) ដើម្បីបម្រើសំណូមពរបដិវត្តន៍ឲ្យទាន់ពេលវេលា យើងក៏បានសម្រេចចិត្តកម្ចាត់របៀបរបបធ្វើការងារចាស់ដែលមានលក្ខណៈគម្ពីរនិយមជងនិងទម្រន់ស្ទក់ជង ។ ដូចនេះ ខ្មាំងណាត្រូវធ្វើកំណត់ហេតុបានអាចយកចម្លើយបឋមបាន យើងយកភ្លាម ។ ត្រូវថតសំឡេងបើឆាប់ជាងសរសេរក៏យើងថត ជួនពេលខ្លះក៏ឲ្យវាសរសេរដែរ ព្រោះថតនៅកកកុញដោះស្រាយមិនទាន់ឲ្យវាសរសេរវាឆាប់ជាង ។

ទន្ទឹមនេះយើងប្ដេជ្ញាចិត្តឈប់ប្រើសេចក្ដីសារភាពរបស់ខ្មាំងណាដែលមានលក្ខណៈជាសេចក្ដីរ៉ាយរ៉ាប់វែងឥតប្រយោជន៍នាំឲ្យខាតពេល ។ ឈប់ប្រើសេចក្ដីរាយការណ៍ដែលមានលក្ខណៈជាសេចក្ដីសរុបដែលខ្មាំងវាចេះតែយកៗព្រោះមិនធានា ។ ឈប់ប្រើសេចក្ដីរាយការណ៍បែបបូកប៉ាន់ដែលមានធានាដែរ ។

យើងធ្វើដូចនេះបាន យើងយកបានសេចក្ដីរាយការណ៍ដែលខ្លីល្មម តែមានខ្លឹមសារជ្រាលជ្រៅ ហើយធានាផង ។

៦) យើងប្រមូលនិងរៀបចំសភាពការណ៍ចំហរបស់អង្គភាពនីមួយៗ ឬភូមិភាគនីមួយៗ ដើម្បីឲ្យស្រួលយល់ស្រួលក្ដាប់សភាពការណ៍ខ្មាំងនៅទីនោះ ។

**អំពីការកិច្ចកសាងអង្គភាពនិងបច្ចេកទេស**

ទិសកំណត់ច្បាស់មានៈ

១) ពីនេះរហូតដល់ចុងឆ្នាំ១៩៧៧ អង្គភាពយើងត្រូវស្អាតបរិសុទ្ធដោយសម្រិតសម្រាំងភ្នាក់ងារខ្មាំងឲ្យអស់ ក្ដាប់ប្រវត្តិរូប ក្ដាប់សតិអារម្មណ៍ និងដំណើរការបដិវត្តនៃការកសាងខ្លួនរបស់អង្គការយើងឲ្យជាប់ក្នុងដៃ ហើយកសាងអង្គភាពយើងតាមលក្ខណៈសម្បត្តិ“៥ ខ” ដែលបក្សបានផ្សាយហើយ ។

២) ជាបច្ចេកទេសឃុំឃាំងខ្មាំង ពេលសួរ ពេលបណ្ដើរខ្មាំងយកមកសួរ ពេលទុកឲ្យវានិយាយថតសំឡេង ត្រូវបន្តពង្រឹងនិងពង្រីកឲ្យជាប់ អប់រំឲ្យជាប់ តាមដានការអនុវត្តជាប្រចាំរាល់ពេលរាល់ម៉ោង ចៀសវាងកុំឲ្យខ្មាំងធ្វើសកម្មភាពអីប្រឆាំងនឹងយើងបាន ។

៣) ជាបច្ចេកទេសធ្វើទារុណកម្មក៏ត្រូវពិនិត្យផ្នែកពិសោធន៍ធ្វើម៉េចលុបបំបាត់ការវាយនោះឲ្យបានជាស្ថាពរ ។

៤) មិត្តអ្នកទទួលភារៈប្រធានរបៀបត្រូវខិតខំគិតគូរពង្រឹងពង្រីកបច្ចេកទេស ឯកសារទាំងស្ថិតិការងារសន្តិបាលគ្រប់យ៉ាងដើម្បីជួយដល់លេខា សាខាក្នុងការក្ដាប់រួមឲ្យជាប់ជាប្រចាំ ។

៥) បន្តពង្រីកវប្បធម៌ទូទៅជាបន្តបន្ទាប់ដល់មិត្តអ្នកសួរចម្លើយ ដើម្បីបម្រើការងារសួរនេះឲ្យកាន់តែស៊ីជម្រៅថែមទៀត ។

## វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរនឹងរៀបចំកម្មវិធី “វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ” លើកទី២ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៥ ។ កម្មវិធីនេះសូមអំពាវនាវដល់សិស្ស និស្សិត ប្រជាជនកម្ពុជា និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងរស់នៅទាំងក្នុងនិងក្រៅប្រទេសឲ្យសរសេរអត្ថបទស្ដីអំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពត៌មានទាំងឡាយស្ដីអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលលោកអ្នកបានដឹងឮនិងទស្សនៈផ្ទាល់ខ្លួនចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីរួមចំណែកចងក្រងប្រវត្តិសាស្ត្រនៃរបបនេះឲ្យកាន់តែពិស្ដារ ។

វេទិកានេះមានគោលបំណងសំខាន់ៗដូចតទៅ÷

◆ រួមជាចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់កូនចៅជំនាន់ក្រោយឲ្យបានដឹងនិងសិក្សារៀនសូត្រ ។

◆ ជាវិធីមួយដើម្បីរំដោះអារម្មណ៍ដោយយកហេតុការណ៍ សេចក្ដីទុក្ខការខឹងគុំកួនមកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជ-សាសន៍កើតឡើងជាថ្មីម្ដងទៀតនៅក្នុងសង្គមមនុស្ស ។

◆ ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរនឹងមានកិត្តិយសចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្ដីស្វែងការរកការពិត ព្រមទាំងផ្ដល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ លោកអ្នកអាចផ្ញើអត្ថបទមកសមាគមអ្នកនិពន្ធខ្មែរដែលមានទីស្នាក់ការនៅវត្តបទុមវតី ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១១០ភ្នំពេញ ឬតាមរយៈអ៊ីមែលៈ dccam@online.com.kh ។

សូមទាក់ទងពត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬ ០១២ ៨៨៣ ០៧២ ។ សូមអរគុណ ។







មីន និង ស្រេង មិត្តរួមការងាររបស់ អ៊ីង មុត

ណុប ម៉ៃ ជាកូនប្រុសរបស់ អ៊ីង មុត បាននិយាយថា÷

«ពេលដែលគេយកឪពុកខ្ញុំទៅ ខ្ញុំទើបតែមានអាយុ១០ឆ្នាំប៉ុណ្ណោះ ដូច្នេះហើយទើបខ្ញុំមិនបានដឹងថាមានរឿងអ្វីកើតឡើងចំពោះគាត់ទេ ។ ខ្ញុំបានសួរដំណឹងរបស់ឪពុកខ្ញុំពីចាស់ៗដែលរស់នៅក្នុងភូមិ ហើយអ្នកទាំងនោះបានប្រាប់ខ្ញុំថា កាលពីឆ្នាំ១៩៧៥គាត់ជាចៅហ្វាយស្រុកមួយនៅក្នុងខេត្តសៀមរាប ។ ខ្មែរក្រហមបានកុហកថាឲ្យគាត់ទៅចូលរួមក្នុងសន្និសីទមួយ ប៉ុន្តែបែរជាចាប់ខ្លួនគាត់និងអង្គរក្សរបស់គាត់ទៅវិញ ។ មានលេចឮពាក្យចចាមអារ៉ាមថា កម្មាភិបាលមកពីភូមិភាគឦសានបានចោទប្រកាន់ឪពុកខ្ញុំថាបានក្បត់ជាតិនិងក្បត់ប្រជាជន ។ ពាក្យចចាមអារ៉ាមនោះនិយាយទៀតថា ទាហានខ្មែរក្រហមបានចងដៃរបស់គាត់ទៅក្រោយខ្នង ហើយដឹកគាត់តាមយន្តហោះទៅ ។ អ្នកខ្លះបានប្រាប់ខ្ញុំថា ឪពុករបស់ខ្ញុំត្រូវគេទម្លាក់ចូលទៅក្នុងទន្លេ ប៉ុន្តែប្រហែលជាពួកគេនិយាយបញ្ឆោតខ្ញុំ ព្រោះខ្ញុំជាកូនរបស់ អ៊ីង មុត ។ អ្នកបន្ទាប់មកទៀតដែលត្រូវបាត់ខ្លួននោះគឺម្តាយនិងប្អូនស្រីរបស់ខ្ញុំដែលទើបតែមានអាយុ៨ខែ ហើយខ្ញុំត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅក្នុងសហករណ៍មួយក្នុងខេត្តសៀមរាប» ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

## រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ១៦៦៦ | យូ ណន ហៅ ផាត | យុទ្ធជន | ពាណិជ្ជកម្មរដ្ឋ | ១១-៩-៧៦ | ១៨-២-៧៧ |
| ១៦៦៧ | ឈុំ ឆាត ហៅ ឆាន់ | អនុសេនាធំ | កងពល៣១០ | ៦-១២-៧៦ | ១៨-២-៧៧ |
| ១៦៦៨ | អ៊ូច វៃ ហៅ ហ៊ឹម វ៉ាន់ឌី | យុវជនចល័ត | តំបន់២៥ | ១៤-១១-៧៦ | ១៨-២-៧៧ |
| ១៦៦៩ | អ៊ូជ ជា ហៅ ស៊ីណា | យុទ្ធជន | ស្រែអំបិល | ២៥-១១-៧៦ | ១៨-២-៧៧ |
| ១៦៧០ | អួង សំអឿន ហៅ សែម | យោធាកងតូច | កងពល១៧០ | ២៦-១-៧៧ | ១៨-២-៧៧ |
| ១៦៧១ | ហម សុគុង | វិស្វករ | ស្រុកបារាំង | ១៥-១២-៧៦ | ១៨-២-៧៧ |
| ១៦៧២ | លឹម គុងផេង | និស្សិត | ស្រុកបារាំង | ២៨-១០-៧៦ | ១៨-២-៧៧ |
| ១៦៧៣ | ស្រី រឿន ហៅ មឿន | ប្រជាជន | កំពង់ធំ | ១៨-១០-៧៦ | ១៨-២-៧៧ |
| ១៦៧៤ | គង់ ប៊ុនសិរី | សាស្ត្រាចារ្យ | ស្រុកបារាំង | ២៨-១០-៧៦ | ១៨-២-៧៧ |
| ១៦៧៥ | ផាន់ ឈឹម ហៅ ឆើត | យុទ្ធជន | កងពលទី៣ឧត្តរ | ២៩-១២-៧៦ | ១៨-២-៧៧ |
| ១៦៧៦ | អុង បែល | និស្សិត | ស្រុកបារាំង | ១០-១១-៧៦ | ១៨-២-៧៧ |
| ១៦៧៧ | ឃួន ដាវិដ | កសិកម្មរដ្ឋបាល | ស្រុកបារាំង | ១២-១២-៧៦ | ១៨-២-៧៧ |
| ១៦៧៨ | ម៉ាន ស៊ឹម ហៅ វៀម | យុទ្ធជន | កងពល៣១០ | ៤-១២-៧៦ | ១៧-៣-៧៧ |
| ១៦៧៩ | ទុយ សាន ហៅ ត្រាយ | យុទ្ធជន | កងពល៣១០ | ១១-១២-៧៦ | ១៧-៣-៧៧ |
| ១៦៨០ | អ៊ឹង គឹមសុង ហៅ ភាគ | មេក្រុម | កងពល៣១០ | ១១-១២-៧៦ | ១៧-៣-៧៧ |
| ១៦៨១ | ឡេង ឃាម ហៅ សារ៉ាក់ | យុទ្ធជន | កងពល២៩០ | ១៨-១០-៧៦ | ១៧-៣-៧៧ |
| ១៦៨២ | ខៀវ ហឿន | យុទ្ធជន | កងពល២៩០ | ១៨-១០-៧៦ | ១៧-៣-៧៧ |
| ១៦៨៣ | សៀ ហ៊ឹម | យុទ្ធជន | កងពល១៦៤ | ១៨-១២-៧៦ | ១៧-៣-៧៧ |
| ១៦៨៤ | ឃុត ដៃ ហៅ ធីន | យុទ្ធជន | មន្ទីរពិការ៦២ | ១១-៩-៧៦ | ១៧-៣-៧៧ |
| ១៦៨៥ | ស្វាយ យ៉ត ហៅ សែម | យុទ្ធជន | មន្ទីរពិការ៦២ | ?-៩-៧៦ | ១៧-៣-៧៧ |
| ១៦៨៦ | គី សុវណ្ណ ហៅ រុន | មេក្រុម | វរសេនាធំ៣៧៧ | ២៧-១១-៧៦ | ១៧-៣-៧៧ |
| ១៦៨៧ | កែ កេងស៊ុ ហៅ ដន | ពេទ្យ | ព-៩៨ | ១១-១២-៧៦ | ១៧-៣-៧៧ |
| ១៦៨៨ | ប៉ក់ សារិន | យុទ្ធជន | ២១យ | ១៩-១-៧៧ | ១៧-៣-៧៧ |
| ១៦៨៩ | អ៊ុក ភឿន ហៅ ថុន | មេក្រុម | កងពល៥០២ | ១៨-២-៧៧ | ១៧-៣-៧៧ |
| ១៦៩០ | ពត ឆន ហៅ វណ្ណា | យុទ្ធជន | កងពល៥០២ | ១៨-២-៧៧ | ១៧-៣-៧៧ |
| ១៦៩១ | ចាប ចន ហៅ ជិន | យុទ្ធជន | កងពល៥០២ | ១៨-២-៧៧ | ១៧-៣-៧៧ |
| ១៦៩២ | នូ អុល | យុទ្ធជន | កងពល៥០២ | ១៨-២-៧៧ | ១៧-៣-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ១៦៩៣ | កែវ ឈុំ ហៅ ផាន | យុទ្ធជន | កងពល៥០២ | ១៨-២-៧៧ | ១៧-៣-៧៧ |
| ១៦៩៤ | សន សេង | យុទ្ធជន | កងពល៥០២ | ១៨-២-៧៧ | ១៧-៣-៧៧ |
| ១៦៩៥ | ឃឹម ឡុម | យុទ្ធជន | កងពល៥០២ | ១៨-២-៧៧ | ១៧-៣-៧៧ |
| ១៦៩៦ | អៀង ថន | យុទ្ធជន | កងពល៥០២ | ១៨-២-៧៧ | ១៧-៣-៧៧ |
| ១៦៩៧ | កុក ដាំ | យុទ្ធជន | កងពល៥០២ | ១៨-២-៧៧ | ១៧-៣-៧៧ |
| ១៦៩៨ | ឈន ហ៊ំ ហៅ វ៉ាន់ | យុទ្ធជន | កងពល៥០២ | ១៨-២-៧៧ | ១៧-៣-៧៧ |
| ១៦៩៩ | អ៊ុន អាន | យុទ្ធជន | កងពល៥០២ | ១៨-២-៧៧ | ១៧-៣-៧៧ |
| ១៧០០ | ហុង ហេង ហៅ យ៉ែម | យុទ្ធជន | កងពល៥០២ | ១៨-២-៧៧ | ១៧-៣-៧៧ |
| ១៧០១ | អ៊ុម លក | យុទ្ធជន | កងពល៥០២ | ១៨-២-៧៧ | ១៧-៣-៧៧ |
| ១៧០២ | ម៉ី ជឹម | យុទ្ធជន | កងពល៥០២ | ១៨-២-៧៧ | ១៧-៣-៧៧ |
| ១៧០៣ | ញ៉ៀង សារ៉ាត់ ហៅ វ៉ាន់ | យុទ្ធជន | កងពល៥០២ | ១៨-២-៧៧ | ១៧-៣-៧៧ |
| ១៧០៤ | ហែល ណន ហៅ ភាព | យុទ្ធជន | កងពល៥០២ | ១៨-២-៧៧ | ១៧-៣-៧៧ |
| ១៧០៥ | ដួន រ៉ុង ហៅ សឿន | យុទ្ធជន | កងពល៥០២ | ១៨-២-៧៧ | ១៧-៣-៧៧ |
| ១៧០៦ | ង៉ែត ចន ហៅ ឃួន | យុទ្ធជន | កងពល៥០២ | ១៨-២-៧៧ | ១៧-៣-៧៧ |
| ១៧០៧ | អ៊ុង ស៊ិន | មេក្រុម | កងពល៥០២ | ១៨-២-៧៧ | ១៧-៣-៧៧ |
| ១៧០៨ | គង់ សាន់ ហៅ វ៉េន | មេក្រុម | វរសេនាធំ៣៧៧ | ៧-៣-៧៧ | ១៧-៣-៧៧ |
| ១៧០៩ | ភឿង វឿន ហៅ ដូ | យុទ្ធជន | វរសេនាធំ៣៧៧ | ៧-៣-៧៧ | ១៧-៣-៧៧ |
| ១៧១០ | អ៊ីន ហឿន | យុទ្ធជន | វរសេនាធំ៣៧៧ | ៧-៣-៧៧ | ១៧-៣-៧៧ |
| ១៧១១ | សួយ ទ្រី ហៅ ទី | យុទ្ធជន | វរសេនាធំ៣៧៧ | ៧-៣-៧៧ | ១៧-៣-៧៧ |
| ១៧១២ | ឈីវ សារឿន ហៅ មឿន | យុទ្ធជន | វរសេនាធំ៣៧៧ | ៧-៣-៧៧ | ១៧-៣-៧៧ |
| ១៧១៣ | រដ្ឋ សារ៉ែន | អនុក្រុម | កងពល៧០៣ | ៣-៣-៧៧ | ១៧-៣-៧៧ |
| ១៧១៤ | ព្រុំ ស៊ីម | យុទ្ធជន | កងពល៣១០ | ៩-៣-៧៧ | ១៧-៣-៧៧ |
| ១៧១៥ | ឈន វ៉េន ហៅ យ៉េន | យុទ្ធជន | កងពល៣១០ | ៩-៣-៧៧ | ១៧-៣-៧៧ |
| ១៧១៦ | ម៉ិល ញ៉ឹល | យុទ្ធជន | កងពល៧០៣ | ៩-៣-៧៧ | ១៧-៣-៧៧ |
| ១៧១៧ | ឆាយ ឡុត ហៅ ផា | យុទ្ធជន | កងពល២៩០ | ៩-៣-៧៧ | ១៧-៣-៧៧ |
| ១៧១៨ | មៀប ប្រឹង | យុទ្ធជន | កងពល៧០៣ | ៩-៣-៧៧ | ១៧-៣-៧៧ |
| ១៧១៩ | ប៉ាញ់ នី ហៅ ភី | យុទ្ធជន | កងពល៣១០ | ៩-៣-៧៧ | ១៧-៣-៧៧ |
| ១៧២០ | រដ្ឋ ឋុល ហៅ ថៃ | យុទ្ធជន | កងពល៣១០ | ៩-៣-៧៧ | ១៧-៣-៧៧ |
| ១៧២១ | លាក់ ប៊ិន | យុទ្ធជន | កងពល៧០៣ | ៩-៣-៧៧ | ១៧-៣-៧៧ |
| ១៧២២ | មើន ខេង | យុទ្ធជន | កងពល៣១០ | ២៥-២-៧៧ | ១៧-៣-៧៧ |
| ១៧២៣ | ផា ឆយ ហៅ ពេជ | យុទ្ធជន | កងពល៣១០ | ២៥-២-៧៧ | ១៧-៣-៧៧ |

(នៅមានត)

# ដើម្បីប្រទេសជាតិ

ខាត់ យាន នៅភូមិពងទឹក ស្រុកជុំគីរី ខេត្តកំពត បាននិយាយថា "កាលមុនជំនាន់ខ្មែរក្រហម ពេលមានការឃោសនាឲ្យចូលធ្វើទ័ពដើម្បីរំដោះប្រទេសជាតិបានធ្វើឲ្យយុវជនជាច្រើនជ្រួលច្រាល់ ហើយស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍ដោយគ្មានរួញរា ។ ទោះបីឪពុកម្ដាយមិនពេញចិត្តនឹងឲ្យទៅក៏ដោយ ក៏នៅតែមិនអាចឃាត់ចិត្តយុវជនបានដែរ ។ មិនមែនតែយុវជនទេ សូម្បីតែព្រះសង្ឃក៏លាចាកសិក្ខាបទចូលច្បាំងដើម្បីរំដោះប្រទេសជាតិដែរ" ។


ខាត់ យាន

ខាត់ យាន ក៏ដូចយុវជនដទៃទៀត ដែលមានស្រុកកំណើតនៅភូមិស្រុកជាមួយគ្នាបានស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍ បន្ទាប់ពីបានឮការអំពាវនាវរបស់ ហ៊ូ នឹម និង ហ៊ូ យន់ ដែលឲ្យយុវជនទាំងអស់រត់ចូលព្រៃតស៊ូដើម្បីច្បាំងរំដោះប្រទេសជាតិ ។ នៅឆ្នាំ១៩៧៣ យាន បានចូលបម្រើបដិវត្តន៍នៅស្រុកជុំគីរី ។ យាន ហាត់រៀនក្បួនយុទ្ធសាស្ត្របាន៣ខែ ក៏ត្រូវអង្គការបំពាក់អាវុធឲ្យចូលសមរភូមិកំពត ។ នៅពេលចូលសមរភូមិលើកដំបូង យាន មានការភ័យខ្លាចខ្លាំងណាស់ ប៉ុន្តែក្រោយៗមក យាន អាចសម្របខ្លួននឹងជីវិតនៅក្នុងសមរភូមិ ហើយក៏លែងភ័យខ្លាចដូចមុន ។ ការចូលប្រយុទ្ធដំបូងរបស់ យាន គឺវាយខ្សែក្រវាត់ការពារខេត្តកំពតចាប់ពីកំពង់ត្រាចរហូតដល់រោងចក្រចក្រីទីង ។

នៅឆ្នាំ១៩៧៥ ក្រោយពេលទ័ពខ្មែរក្រហមទទួលជ័យជម្នះលើទាហានលន់ណុលនៅតាមខេត្តខ្លះៗហើយ មេបញ្ជាការរបស់ យាន បានជ្រើសរើសយុទ្ធជន១០០នាក់នៅក្នុងកងវរសេនាតូចលេខ១២ ដើម្បីវាយបុកចូលទីក្រុងភ្នំពេញ ។ កងថ្មីនេះចំណុះឲ្យកងពលលេខ២ភូមិភាគនិរតីដែលមានមេដឹកនាំឈ្មោះ សាន ជាកូនប្រសាររបស់ តាម៉ុក ។ ពេលកម្លាំងរបស់ យាន វាយសម្រុកចាប់ពីអូរពោមរាំងរហូតដល់វត្តចំបក់មាស ក៏ទទួលដំណឹងថាខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញជាស្ថាពរហើយ ។

កងរបស់ យាន បានចូលទីក្រុងភ្នំពេញ៣ថ្ងៃដើម្បីជួយរៀបចំសម្ភារនិងរក្សាសន្តិសុខទីក្រុង ។ ៣ថ្ងៃក្រោយមក អង្គការសម្រេចបញ្ជូនកងរបស់ យាន មកជុំគីរីវិញដើម្បីរៀបចំពិធីបុណ្យជ័យជម្នះ ១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ឪពុកម្ដាយ របស់ យាន និងប្រជាជនជាច្រើននាក់ទៀតសប្បាយនឹងជ័យជម្នះនេះណាស់ ហើយសង្ឃឹមថាប្រទេសជាតិនឹងមានសន្តិភាព ប៉ុន្តែបន្ទាប់ពីចប់ពិធីនេះភ្លាម ខ្មែរក្រហមបានអនុវត្តគោលនយោបាយបោសសម្អាតអ្នករដ្ឋការនិងអភិជនរបស់របបសង្គមចាស់ជាបន្ទាន់ ។ តាយ៉េវ ដែលជាមេបញ្ជាការចាស់របស់ យាន ត្រូវអង្គការចោទថាក្បត់ ហើយបញ្ជូនទៅបាត់មិនឃើញវិលត្រឡប់មកវិញ ។ ក្រោយពីចាប់មេៗក្បត់អស់ហើយ អង្គការចាប់ផ្ដើមសើរើថ្នាក់ក្រោមម្ដង ។ យាន ត្រូវចោទថាមានខ្សែស្រឡាយជានាយទុន ហើយត្រូវអង្គការទម្លាក់ឋានៈមកនៅត្រឹមយុទ្ធជននិងបញ្ជូនឲ្យទៅជួសជុលផ្លូវជាតិលេខ៣ ។ បងប្អូននិងសាច់ញាតិរបស់ យាន ត្រូវខ្មែរក្រហមចាប់យកទៅសម្លាប់ចោលស្ទើរតែទាំងអស់ ។ យាន បញ្ជាក់ថា គាត់វេទនាណាស់នៅពេលមកលត់ដំខ្លួននៅផ្លូវជាតិលេខ៣នេះ ព្រោះការងារក៏លំបាកយ៉ាប់យ៉ឺន ហើយរបបអាហារក៏មិនគ្រប់គ្រាន់ទៀត ។

នៅឆ្នាំ១៩៧៦ អង្គការបានបញ្ជូន យាន ឲ្យទៅធ្វើការនៅភ្នំដិន ក្នុងខេត្តតាកែវ ។ ដោយសារភាពរហ័សរហួនរបស់ យាន អង្គការបានតែងតាំងគាត់ជាប្រធានកងឈ្លបប្រចាំការនៅព្រំដែនកម្ពុជាវៀតណាម ។ ក្នុងអំឡុងពេលនោះ ទាហានវៀតណាមបានវាយបុកមកព្រៃសណ្ដែក ខេត្តតាកែវ ប៉ុន្តែត្រូវទ័ពខ្មែរក្រហមវាយរុញច្រានទៅវិញ ។

នៅឆ្នាំដដែល យាន ត្រូវអង្គការដកឲ្យមកកាន់ខាងទ័ពជើងទឹកនៅកោះពូលូវៃ ខេត្តកោះកុង ស្ថិតក្នុងកងពល៣៦០ ។ ការងារនៅលើកោះវៃគឺចាំទទួលសម្ភារពីចិន ហើយសម្ភារទាំងនោះច្រើនតែគ្រាប់រំសេវ ។

ការងារគ្រប់កន្លែងទាំងអស់សុទ្ធតែលំបាក ប៉ុន្តែ យាន នៅតែស៊ូទ្រាំធ្វើដើម្បីរស់ ។ យាន បញ្ជាក់ប្រាប់ថា ពេលគាត់មកលេងស្រុកកំណើតនៅឆ្នាំ១៩៧៦ ប្រធានសហករណ៍ឈ្មោះ ហោង សុខ និយាយថា អង្គការត្រៀមដាក់កសិករវណ្ណៈកណ្តាលថ្នាក់ក្រោមឲ្យធ្វើជាមេកង មេក្រុម មេភូមិ។ អង្គការបានបោសសម្អាតសមាសភាពមិនល្អជាហូរហែ ហើយដាក់អ្នកថ្មីជំនួសវិញ ។ តាចាប គណៈតំបន់៣៥ ត្រូវអង្គការចាប់ខ្លួន ហើយតែងតាំង តាដែន ជំនួស ។ ក្រោយមក តាដែន ត្រូវអង្គការស៊ើបដឹងថាក្បត់ ហើយក៏ចាប់ខ្លួនគាត់និងប្រពន្ធកូនយកទៅសម្លាប់ចោល ។ ចំណែក ចាន់ ជឿន ដែលជាអង្គរក្សរបស់ តាចាប ក៏ត្រូវអង្គការចាប់ខ្លួន ហើយ យាន បានឃើញការចាប់ខ្លួន ជឿន នេះដោយផ្ទាល់ភ្នែក ។ ជឿន ត្រូវចោទថាជាសមាសភាពមិនល្អ ។

នៅឆ្នាំ១៩៧៧ យាន ត្រូវអង្គការដកឲ្យទៅភូមិដូង ខេត្តស្វាយរៀងក្នុងឋានៈជាយុទ្ធជនកងពល៣៧០ ។ យាន នៅតែមាននាទីប្រចាំការតាមព្រំដែនកម្ពុជា-វៀតណាមដដែល ។ ជារឿយៗ យាន បានទទួលការអប់រំដើម្បីឲ្យទាន់សភាពការណ៍បដិវត្តន៍ ហើយត្រូវស្មោះត្រង់នឹងបក្ស ។

នៅពេលដែលរបបខ្មែរក្រហមត្រូវវាយបណ្តេញចេញពីប្រទេស យាន ក៏រត់ចូលព្រៃបន្តការតស៊ូជាមួយកងកម្លាំងខ្មែរ-ក្រហមដែលសេសសល់ ប៉ុន្តែមិនយូរប៉ុន្មាន គាត់ក៏ធុញទ្រាន់នឹងការធ្វើសង្គ្រាម ហើយក៏ចូលសារភាពខាងរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ យាន រៀបការជាមួយ ជា សែ នៅឆ្នាំ១៩៧៩ ។ បន្ទាប់ពីរស់នៅក្នុងស្រុកកំណើតអស់មួយរយៈមក យាន និងគ្រួសារបានទៅរស់នៅព្រំដែនកម្ពុជា-ថៃ នៅឆ្នាំ១៩៨៣ ។ នៅទីនោះ យាន ប្រកបរបរដឹកឈើលក់ និងធ្វើជាប្រធានពាណិជ្ជកម្មស្រុក ។ ដោយមានការនឹករឭកឪពុកម្តាយបងប្អូនញាតិមិត្ត យាន បានវិលត្រឡប់មកស្រុកកំណើតវិញនៅឆ្នាំ១៩៩១ ។

សព្វថ្ងៃនេះ យាន រស់នៅជួបជុំប្រពន្ធនិងកូន៦នាក់ ។ យាន តែងតែនិយាយរឿងរ៉ាវរបស់គាត់ប្រាប់កូនៗជារឿយៗ ព្រោះគាត់មិនចង់ឲ្យពួកគេយកគំរូតាម ។ យាន បញ្ជាក់ថា «ខ្ញុំឆ្អែតឆ្អន់នឹងជីវិតជាកងទ័ព និងគោលនយោបាយរបស់ខ្មែរក្រហមដែលតែងតែចោទប្រកាន់មនុស្សថាជាជនក្បត់ ហើយចាប់ទៅបាត់ៗ និងត្រូវសម្លាប់ចោលឃើញនឹងភ្នែកស្រស់ៗ ។ តើនេះជាបដិវត្តន៍ដើម្បីរំដោះប្រទេសជាតិឬជាបដិវត្តន៍ដើម្បីសម្លាប់ជនរួមជាតិឯង?» ។

**សុ ហ្វារីណា**

## សេចក្តីជូនដំណឹងស្តីអំពីការបើកឱ្យប្រើប្រាស់ “ការិយាល័យពត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ការិយាល័យពត៌មានសាធារណៈរបស់មជ្ឈមណ្ឌលយើងនឹងចាប់បើកទ្វារបម្រើសាធារណជនពីថ្ងៃនេះតទៅហើយ ។ ការិយាល័យពត៌មានសាធារណៈគឺជាទីតាំងសម្រាប់អានឯកសារដែលទាក់ទងនឹងរបបខ្មែរក្រហម ទស្សនាខ្សែភាពយន្តឯកសារខ្មែរក្រហម និងចូលរួមកម្មវិធីពិភាក្សាជាមួយអ្នកច្បាប់និងអ្នកសិក្សាស្រាវជ្រាវអំពីប្រធានបទខ្មែរក្រហមយុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួមជាតិ និងប្រធានបទដទៃទៀត ។ ទិសដៅសំខាន់ពីររបស់ការិយាល័យពត៌មានសាធារណៈគឺ ១) ផ្តល់ពត៌មាននិងអប់រំប្រជាជនខ្មែរអំពីរបបខ្មែរក្រហម ២) ផ្សព្វផ្សាយពត៌មានអំពីដំណើរការអង្គជំនុំជម្រះក្តីអតីតមេដឹកនាំខ្មែរក្រហមជូនសាធារណជនឲ្យបានទូលំទូលាយ ។

ការិយាល័យពត៌មានសាធារណៈរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានទីតាំងនៅផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ។ ពត៌មានបន្ថែមស្តីអំពីការិយាល័យពត៌មានសាធារណៈ សូមទាក់ទង **សុភ្ខា អ៊ីវ៉ែន** ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។

សូមអរគុណ ។

# ខំធ្វើការដើម្បីរស់

សេង មានភូមិកំណើតនៅក្នុងភូមិកោះទៀវ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល ។ គាត់បាននិយាយប្រាប់ថា គាត់មិនត្រឹមតែមានជំងឺទឹកនោមផ្អែមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានជំងឺបាក់កម្លាំង និងដេកមិនលក់ទៀតផង ។




សេង កើតនៅថ្ងៃព្រហស្បតិ៍ ឆ្នាំ១៩៥៥ ។ ឪពុករបស់គាត់ឈ្មោះ អ៊ុក ហម ម្តាយឈ្មោះ ម៉ៅ អុន ។ មុនឆ្នាំ១៩៧៥ ឪពុកម្តាយរបស់គាត់ ប្រកបរបរចិញ្ចឹមជីវិតដោយពឹងផ្អែកទៅលើដីស្រែចម្ការ ហើយដោយសារតែមានកូនរហូតដល់១០នាក់នោះបានធ្វើឲ្យកម្រិតជីវភាពគ្រួសារនេះខ្វះខាតខ្លះៗ ។ គ្រួសាររបស់គាត់ត្រូវបានអង្គការចាត់ទុកថា ជាកសិករកណ្តាលថ្នាក់ក្រោម ។

អង្គការខ្មែរក្រហមបានចូលមកគ្រប់គ្រងនៅក្នុងភូមិស្រុករបស់គាត់ពេញទំហឹងក្រោយពេលរដ្ឋប្រហារទម្លាក់សម្តេចសីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។ សេង បាននិយាយថា នៅយប់ថ្ងៃរដ្ឋប្រហារឆ្នាំ១៩៧០នោះ គាត់បានឮស្នូរផ្ទុះអាវុធនៅទីរួមស្រុកកោះធំពេញមួយយប់ ដល់ព្រឹកឡើងគាត់ឃើញទាហានខ្មែរក្រហមនិងទាហានយៀកកុងនៅពាសពេញក្នុងភូមិរបស់គាត់ ។

នៅក្នុងជំនាន់សង្គ្រាមប្រាំឆ្នាំ (ឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥) យុវជនក្នុងស្រុកភូមិដែល សេង រស់នៅ ចាប់ពីអាយុ១៦-១៧ ឆ្នាំ ត្រូវបានអង្គការបំផុសនិងបង្ខំឲ្យចូលបម្រើកងទ័ព ។ អ្នកណាធំល្មមកាន់កាំភ្លើងបាន ត្រូវទៅសមរភូមិ ចំណែកអ្នកនៅតូចៗ មិនអាចកាន់កាំភ្លើងបាន អង្គការឲ្យទៅសែងអ្នករបួសឬរែកបាយស្មុកទៅសមរភូមិ ។ មានយុវជនមួយចំនួនតូចត្រូវអង្គការបញ្ជូនឲ្យមកផ្ទះវិញ ដោយសារតែនៅតូចពេក ប៉ុន្តែបើអ្នកណាស្ម័គ្រចិត្តនៅគឺអង្គការអនុញ្ញាតឲ្យនៅ ។ គាត់បាននិយាយបញ្ជាក់ថា «អ្នកដែលចូលបម្រើតាំងពីឆ្នាំ១៩៧០រហូតដល់ឆ្នាំ១៩៧២ ឬ១៩៧៣ ភាគច្រើនគឺចូលដោយសារការស្ម័គ្រចិត្តតាមការឃោសនារបស់រណសិរ្ស តែចំពោះអ្នកដែលចូលបម្រើទ័ពចាប់ពីឆ្នាំ១៩៧៣មក ភាគច្រើនដោយសារការបង្ខំរបស់ប្រធានភូមិប្រធានឃុំ ហើយគ្មានក្រុមគ្រួសារណាមួយចៀសផុតពីកាតព្វកិច្ចនេះឡើយ» ។ នៅឆ្នាំ១៩៧៣ក្នុងវ័យប្រហែល១៨ឆ្នាំ សេង និងបងប្រុសពីរនាក់ទៀត ឈ្មោះអ៊ុក ហ៊ិន និង អ៊ុក សុង រួមជាមួយយុវជនស្រុករគាត់ជាច្រើនទៀតនៅក្នុងភូមិកោះទៀវ ត្រូវបានប្រធានសមាគមយុវជនឃុំសំពៅពូន ឈ្មោះ អ៊ីន បង្ខំឲ្យចូលបដិវត្តន៍ ។ អ្នកទាំងនេះត្រូវបានអង្គការបញ្ជូនទៅហ្វឹកហាត់នៅក្នុងវត្តទួលសង្កែក្នុងឃុំកំពង់កុង ស្រុកកោះធំ ខេត្តកណ្តាល ។ បងប្រុសរបស់គាត់ម្នាក់ឈ្មោះ អ៊ុក ហ៊ិន ដែលទៅជាមួយគាត់នោះ ត្រូវបានអង្គការអនុញ្ញាតឲ្យមកភូមិវិញបន្ទាប់ពីរៀនចប់ ព្រោះថាក្នុងគ្រួសាររបស់គាត់មានបងប្អូនចូលបម្រើទ័ពពីរនាក់គ្រប់គ្រាន់ហើយ ។ ពេលនោះឪពុកម្តាយរបស់គាត់មានការបារម្ភយ៉ាងខ្លាំងពីកូនទាំងពីរដែលនៅក្មេង ហើយមិនដែលបែកពីក្រុមគ្រួសារទាល់តែសោះ ។

ក្រោយពីបានហាត់ហ្វឹកហ្វឺនអស់រយៈពេលកន្លះខែ អង្គការបានបញ្ជូន សេង និងយុវជនប្រហែល៦០នាក់ ឲ្យទៅបម្រើការនៅក្នុងកង២៦០ ឈរជើងនៅតាមដងទន្លេមេគង្គ ។ ពេលទៅដល់ដំបូង សេង បានសុំអង្វរអង្គការនៅបម្រើក្នុងកងសែងរបួស និងរែកបាយស្មុក ហើយអង្គការបានឲ្យគាត់នៅដាំបាយនៅក្នុងភូមិអន្លង់ស្វាត ឃុំលើកដែក ស្រុកកោះធំ ខេត្តកណ្តាល ។ នៅពេលគាត់ឡើងយកបាយស្មុកនិងសែងអ្នករបួសលើកដំបូងគាត់មានអារម្មណ៍ភ័យតក់ស្លុតជាខ្លាំង សេងបាននិយាយថា «ខ្ញុំខ្លាចសង្គ្រាមណាស់ ពេលខ្ញុំទៅដល់ទន្លេមេគង្គ កប៉ាល់ហោះបាញ់ពីលើដង ទ័ពលន់ណុលបាញ់ពីក្រោមដង ខ្ញុំសឹងតែស្រែកឃំ ពេលត្រឡប់មកវិញត្រូវសែងអ្នករបួសមកទៀត ។ ខ្ញុំបានសែងមនុស្សដាច់ក្បាលម្នាក់ឈាមពេញអង្រឹង ឃើញគេដាច់ក្បាល

បែបនេះ អារម្មណ៍របស់ខ្ញុំគានតឹងសឹងធ្លាយទ្រូងទៅហើយ នឹកថាខ្ញុំគ្មានរស់ទេដឹងតែស្លាប់ ឃើញគេដាច់ក្បាលពីខ្លួនអីចឹង ខ្លួនឯងបែបដាច់អីចឹងដែរហើយមើលទៅ» ។

ប្រហែលដើមឆ្នាំ១៩៧៤ អង្គការបានដកគាត់ឲ្យមកធ្វើជានិរសារកងកាំភ្លើងធំ នៅម្តុំព្រែកប៉ាវខាងត្បូងតាខ្មៅ កៀកនឹងទីក្រុងភ្នំពេញ ។ នៅទីនោះ សេង ត្រូវនាំបញ្ជាពីប្រធានកងអនុសេនាធំឈ្មោះ ភាព ទៅប្រាប់អ្នកកាន់កាំភ្លើងធំដេកា៧៥ នោះឲ្យបាញ់ទៅតាមគោលដៅកំណត់របស់ទីបញ្ជាការនៅខាងក្រោយ ឬក៏ឲ្យដកថយមកវិញ ។ សមរភូមិនៅទីនោះមានគ្រាប់កាំភ្លើងច្រើនណាស់ ការងាររបស់ សេង ត្រូវរត់កាត់គ្រាប់រំសេវរាល់ថ្ងៃ ។ ថ្ងៃមួយនៅពេល សេង ស្ថិតនៅសមរភូមិម្តុំសិត្បូ គាត់បានឮដំណឹងតាមរយៈមិត្តភក្តិរួមក្រុមថា ខាងកងទ័ព លន់ ណុល កំពុងតែរៀបចំទ័ពនិងរថក្រោះចំនួន១០០គ្រឿងដើម្បីវាយបកមកលើមុខព្រួញរបស់គាត់នៅខាងត្បូងក្រុងតាខ្មៅនេះ ។ ឮដូចនេះ សេង ដែលមានអាការៈគ្រុនញាក់ក្តៅខ្លួន ហើយក៏សុំប្រធានមកដេកពេទ្យ ហើយដេកនៅមន្ទីរពេទ្យបានតែមួយយប់ គាត់ក៏សុំអង្គភាពមកលេងផ្ទះទៀត ។ ពេលមកដល់ផ្ទះ បងប្អូនរបស់គាត់ឃាត់មិនឲ្យគាត់ទៅអង្គភាពវិញទេ និងដោយក្នុងចិត្តរបស់គាត់មានការភ័យខ្លាចផងនោះ គាត់បានរត់ទៅនៅមាត់បឹងដើម្បីគេចឲ្យផុតពីកំណែនទ័ពជាលើកទីពីរ ។ ការរត់គេចនេះមិនបានធ្វើឲ្យ សេង រួចខ្លួនទេ នៅដើមឆ្នាំ១៩៧៥ សមាគមយុវជនឃុំសំពៅពូនបានទៅតាមគាត់រហូតដល់បឹងចុងព្រែកតាលីក្បែរជើងភ្នំអង្គរបុរី «អ្នកដែលទៅតាមខ្ញុំនោះបានគំរាមថាបើខ្ញុំមិនទៅ អង្គការនឹងចាប់ឪពុកម្តាយរបស់ខ្ញុំទៅជំនួស» ។ ដោយគ្មានអ្វីអាចប្រកែកបាន សេង ក៏យល់ព្រមមកតាមបញ្ជារបស់សមាគមយុវជនឃុំ ។ បន្ទាប់មក អង្គការបានបញ្ជូនគាត់ឲ្យទៅរៀននយោបាយនៅក្នុងភូមិកំពត ឃុំព្រែកអំបិល ស្រុកស្អាង ម្តងទៀត ក្នុងរយៈពេល១០ថ្ងៃ ។ ការរៀននយោបាយនៅទីនោះ អង្គការបានពន្យល់ឲ្យស្គាល់ពីខ្មាំងនៅក្នុងប្រទេសដែលគេចោទថា សុទ្ធតែពួកក្បត់ជាតិនិងខ្មាំងនៅក្រៅប្រទេសដូចជាវៀតណាមនិងថៃជាដើម ។ ក្រោយមកទៀតគេបានបញ្ជូនគាត់ឲ្យទៅហាត់បាញ់នៅលើកោះឧញ្ញាច់ទន្លាក្នុងឃុំទឹកវិល ស្រុកស្អាង ។ សេង ហាត់រៀននៅទីនោះមិនទាន់ចប់ស្រួលបួលផង ស្រាប់តែគាត់ឃើញប្រជាជនជម្លៀសពីភ្នំពេញទៅយ៉ាងច្រើន ។ ពេលអង្គការជម្លៀសប្រជាជនចេញពីទីក្រុងនិងទីប្រជុំជននានាអស់ សេង រួមទាំងយុទ្ធមិត្តរួមក្រុមមួយចំនួនត្រូវបានអង្គការដឹកយកមកឲ្យស្នាក់នៅខាងជើងវិមានឯករាជ្យ ។ សេង បាននិយាយថា «ការចល័តទ័ពចូលទីក្រុងភ្នំពេញត្រូវអង្គការបែងចែកតំបន់ឲ្យស្នាក់នៅដាច់ពីគ្នា ដូចថាបើទ័ពមកពីខាងភូមិភាគបូព៌ា គឺស្នាក់នៅពីត្រឹមថ្នល់ជាតិលេខមួយហ្នឹងទៅខាងកើតទីក្រុងភ្នំពេញ ហើយពេលនោះ ខ្ញុំនៅក្នុងកង៤២ ដូច្នេះគេបញ្ជូនឲ្យទៅនៅខាងជើងវត្តលង្កា ដែលជាអង្គភាពមួយចំណុះឲ្យកងពល១២» ។ នៅទីនោះ អង្គភាពរបស់ សេង មានតួនាទីរៀបចំទុកដាក់ខោអាវ ស្ករស ទឹកដោះគោដែលនៅរប៉ាត់រប៉ាយបញ្ចូលទៅក្នុងឃ្លាំង ។ នៅដើមឆ្នាំ១៩៧៦ សេង ត្រូវបានផ្ទាក់លើដកឲ្យទៅរៀននយោបាយនៅម្តុំវត្តក្រពើហាតាខ្មៅ រយៈពេលកន្លះខែ ។ ការរៀននយោបាយនេះ គឺអង្គការតម្រូវឲ្យកម្មាភិបាលថ្នាក់ខ្ពស់ចាប់ពីវរសេនាធំចុះមកធ្វើស្វ័យទិតៀន ។ យុទ្ធជនណាដែលអង្គការគិតថាមានកំហុសមធ្យម ត្រូវបញ្ជូនឲ្យទៅធ្វើការនៅព្រៃស ហើយកម្មាភិបាលនិងយុទ្ធជនណាដែលមានកំហុសធ្ងន់ធ្ងរត្រូវបញ្ជូនឲ្យទៅកន្លែងផ្សេងដូចជាទួលស្លែងជាដើម ។

ក្រោយពីរៀនវគ្គនយោបាយចប់ សេង ត្រូវអង្គការចោទថាគាត់មានប្រវត្តិរូបមិនល្អ ធ្លាប់រត់ចោលជួរកាលមុនឆ្នាំ១៩៧៥ និងមានបងប្អូនធ្វើការនៅសម័យសង្គមរាស្ត្រនិយម ។ ដូច្នេះហើយទើបផ្ទាក់លើបញ្ជូនគាត់ឲ្យទៅជីកប្រឡាយលើកទំនប់តាមជួរមាត់ស្ទឹងបាគូនៅមន្ទីរព្រៃស ។ កម្រិតទោសនៅព្រៃសត្រូវបែងចែកជាបីប្រភេទ ។ សេង និយាយថា «កងលេខមួយជាកងដែលសប្បាយអាចស៊ីចុកបាន កងលេខពីរមធ្យម ហើយកងលេខបីជាកងលត់ដំខ្លាំង និងមានច្រវាក់ជាប់ជើងសសរទាំងអស់» ។ សេង ជាប់ក្នុងកងលេខបីបានមួយខែ ក៏ត្រូវផ្ទាក់លើបញ្ជូនឲ្យទៅនៅវត្តកុលក្នុងមន្ទីរស-២៤ ក្រោមការគ្រប់គ្រងរបស់ ហ៊ុយ ស្រែ (មន្ទីរស-២៤ជាសាខារបស់មន្ទីរស-២១) ។ ដោយការខិតខំ

កសាងខ្លួនរបស់ សេង អង្គភាពបានដកគាត់ចេញពីកងភ្ជួរទៅនៅក្នុងកងឃ្វាលគោ ។ ចំណែកយុទ្ធជនមួយចំនួនទៀតត្រូវអង្គការបញ្ជូនទៅធ្វើការនៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង ។ សេង មិនត្រូវអង្គការបញ្ជូនទៅទេដោយសារតែគាត់ហើមដៃ ។ យុទ្ធជនដែលទៅធ្វើការនៅខេត្តកំពង់ឆ្នាំងត្រូវអង្គការបញ្ជូនត្រឡប់មកស-២៨វិញបន្ទាប់ពីធ្វើការបានរយៈពេលពីរខែ ហើយមិនយូរប៉ុន្មាន អ្នកទាំងអស់នោះត្រូវបានអង្គការថ្នាក់លើហៅទៅរៀននយោបាយម្តងទៀត ។ សេង ឮថាអ្នកទាំងនោះទៅរៀននយោបាយក៏មានចិត្តចង់ទៅដែរ ប៉ុន្តែមិត្តរួមក្រុមម្នាក់ឈ្មោះ អាន់ ខ្សឺបប្រាប់គាត់ថា «បើឡានដែលមកដឹកនោះបិទជិតឈឹងច្បាស់ជាគេយកទៅសម្លាប់ចោលហើយ ឯងចង់ទៅធ្វើអ្វី» ។

នៅចុងឆ្នាំ១៩៧៨ សេង ត្រូវបានអង្គភាពបញ្ជូនឲ្យមករៀននយោបាយនៅជិតមន្ទីរស-២១ ។ ពេលនោះ សេង ជាប្រធានពួកដែលគ្រប់គ្រងមនុស្ស៣នាក់ ។ សេង មិនបានដឹងថាកន្លែងរៀននោះនៅខាងណាគុកទួលស្លែងទេ ព្រោះកាលអង្គការបញ្ជូនគាត់ពីមន្ទីរស-២៨មកគឺនៅពេលយប់ម៉ោង១២អធ្រាត្រ ។ ការរៀននយោបាយលើកនេះគឺគេជ្រើសរើសចាប់ពីប្រធានពួកឡើងទៅ ហើយរៀនក្នុងរយៈពេលប្រហែលមួយសប្តាហ៍ និងស្ថិតក្រោមការបង្ហាត់បង្ហាញរបស់ សុន សេន រដ្ឋមន្ត្រីក្រសួងការពារជាតិ និង ឌុច ប្រធានមន្ទីរស-២១ ចំណែកអត្ថន័យនិងខ្លឹមសារមេរៀនគឺមិនខុសគ្នានឹងអ្វីដែលសេងបានរៀននៅក្នុងខេត្តកណ្តាលកាលពីដើមឆ្នាំ១៩៧៥នោះទេ គឺគេនិយាយសង្កត់ធ្ងន់តែពីរឿងខ្មាំងក្នុងប្រទេសនិងខ្មាំងក្រៅប្រទេសប៉ុណ្ណោះ ។ ក្រោយពីរៀនចប់ គាត់ត្រូវអង្គការបញ្ជូនមកមន្ទីរស-២៨វិញ ។ សេង បានត្អូញត្អែរថា «ធ្វើការនៅព្រៃសលំបាកណាស់ ព្រោះពីមួយថ្ងៃទៅមួយថ្ងៃខិតខំធ្វើការកសាងខ្លួនដើម្បីឲ្យអង្គការមើលឃើញថាយើងមានការកែប្រែ» ។ ដូច្នេះហើយបានជា សេង គ្រាំគ្រាខ្លួនរហូតមកដល់សព្វថ្ងៃ ។

នៅថ្ងៃដែលកងទ័ពរណសិរ្សរំដោះជាតិកម្ពុជារួមជាមួយនឹងកងទ័ពវៀតណាមចូលមកដល់ក្រុងភ្នំពេញនាដើមឆ្នាំ១៩៧៩ សេង និងមិត្តភក្តិនៅក្នុងអង្គភាពស-២៨មួយចំនួនបានរត់ចេញទៅទាំងយប់ កាត់ផ្លូវជាតិលេខ៤ ឡើងទៅដល់ស្រុកកំពង់ត្រឡាចខេត្តកំពង់ឆ្នាំង ហើយបន្តទៅដល់លាច ខេត្តពោធិសាត់ ។ នៅតាមដងផ្លូវដែល សេង រត់ទៅនោះ មានប្រជាជនជាច្រើនក៏រត់ទៅជាមួយដែរ ។ នៅក្នុងព្រៃ សេង បានរត់ទៅជួប ឌុច និងបក្សពួកដែលកំពុងតែសម្លាប់មនុស្ស ។ សេង បាននិយាយប្រាប់ថា «ពេលខ្ញុំរត់ចូលទៅក្នុងព្រៃភ្នំ ម្តុំខេត្តពោធិ៍សាត់ខ្ញុំបានឃើញ ឌុច និងកូនចៅវាច្បាស់តែម្តង កំពុងតែអារ-កនិងដុតដែករុកប្រមុះរុកមាត់ប្រជាជន ។ ទិដ្ឋភាពទាំងនេះ ធ្វើឲ្យខ្ញុំមានការភ័យខ្លាចណាស់ ហើយម្យ៉ាងទៀតកងទ័ពវៀតណាម ចេះតែតាមខ្ញុំប្រកិត» ។ ដោយសារការរស់នៅក្នុងព្រៃជួបនឹងការលំបាក ហើយចេះតែរត់គេចពីការប្រយុទ្ធគ្នារវាងកងទ័ពប៉ុល ពត និងកងទ័ពរណសិរ្សរំដោះជាតិរួមជាមួយកងទ័ពវៀតណាមផងនោះ នៅក្នុងឆ្នាំ១៩៧៩ដដែល សេង បានចុះពីលើភ្នំដើរសំដៅមកស្រុកកំណើតវិញ ។ ដោយមានការហេវហត់អស់កម្លាំងគ្មានអ្វីនៅក្នុងពោះបន្តិចសោះនោះ សេង ក៏ដាច់ចិត្តលួចនំក្រូចប្រជាជននៅទីនោះបានពីរយកមកបរិភោគ ។ ក្រោយពីបានទទួលការអប់រំពីសំណាក់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាម សេង ត្រូវបានអ្នកទាំងនោះធ្វើលិខិតអនុញ្ញាតឲ្យត្រឡប់មកផ្ទះកំណើតវិញ ។ នៅពេលមកដល់ផ្ទះ គាត់បានជួបជុំឪពុកម្តាយបងប្អូន តែអកុសលបងរបស់គាត់ពីរនាក់បានបាត់ខ្លួន ។

តាំងពីពេលចេញទៅធ្វើបដិវត្តន៍រហូតដល់ត្រឡប់មកផ្ទះវិញ សេង គ្មានគិតថាគាត់បានផលចំណេញអ្វីបន្តិចទាល់តែសោះ ថែមទាំងត្រូវទទួលរងទុក្ខវេទនានិងការព្រាត់ប្រាសបងប្អូនថែមទៀត ។ សេង មានការសោកស្តាយជាខ្លាំងចំពោះការបាត់បង់បងទាំងពីររបស់គាត់ ។ គាត់យល់ថា «តុលាការមួយដែលរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបម្រុងនឹងបង្កើតនៅក្នុងពេលឆាប់ៗខាងមុខនេះ គឺសក្តិសមទៅនឹងអ្វីដែលមេដឹកនាំខ្មែរក្រហមបានប្រព្រឹត្តនៅក្នុងរយៈពេលដែលអ្នកទាំងនោះកាន់អំណាចហើយ ។ គាត់រំពឹងថា តុលាការនេះនឹងជួយរកយុត្តិធម៌ជូនប្រជាជនកម្ពុជាទាំងអ្នកស្លាប់ទៅនិងអ្នកនៅរស់» ។

**ផាន់ សុជា**

# កង វន និងជំងឺផ្លូវចិត្តដែលបន្សល់ទុកពីរបបខ្មែរក្រហម

របបកម្ពុជាប្រជាធិបតេយ្យ ដែលបានធ្វើឲ្យបាត់បង់ជីវិតមនុស្សជិតពីរលាននាក់ដោយសារការសម្លាប់ ការអត់ឃ្លាន ជំងឺ និងការធ្វើការហួសកម្លាំង បានផុតរលត់ទៅហើយ ក៏ប៉ុន្តែ កេរដំណែលនៃរបបនេះមិនទាន់សាបរលាបនៅឡើយទេ ។ គ្រួសារកម្ពុជាទាំងអស់យ៉ាងហោចណាស់ក៏មានសមាជិកម្នាក់បានស្លាប់ឬទទួលរងទារុណកម្មនៅក្រោមរបបនេះ ។ ចំណែកអ្នកដែលបានរួចផុតជីវិត ក៏មិនមានន័យថាសុទ្ធតែជាអ្នកមានភ័ព្វសំណាងពេញលេញដែរ ។ ដោយសារការធ្វើពលកម្មធ្ងន់ធ្ងរ ការព្រាត់ប្រាស និងទារុណកម្ម ជនរងគ្រោះពីរបបនេះនៅជួបប្រទះភាពគ្រាំគ្រាផ្នែករាងកាយ និងផ្លូវចិត្តតិចឬច្រើនចៀសមិនផុត ។

ការសិក្សាតាមរយៈ “គម្រោងជួយជនរងគ្រោះដោយអំពើទារុណកម្ម” របស់មជ្ឈមណ្ឌលឯកសារកម្ពុជា យើងបានរកឃើញថា ជនរងគ្រោះដែលទទួលរងនូវផលប៉ះពាល់ផ្លូវចិត្តខ្លាំងបំផុត គឺអ្នកដែលធ្លាប់ជាប់គុក ធ្លាប់ត្រូវខ្មែរក្រហមធ្វើទារុណកម្ម និងអ្នកដែលមានសមាជិកគ្រួសារស្លាប់នៅក្រោមរបបខ្មែរក្រហម ។

ខាងក្រោមនេះជាប្រវត្តិរបស់ជនរងគ្រោះម្នាក់ឈ្មោះ កង វន ដែលរស់នៅឃុំគុស ស្រុកត្រាំកក់ ខេត្តតាកែវ ។


កង វន

កង វន ត្រូវខ្មែរក្រហមចាប់ឃុំឃាំងនៅមន្ទីរ២០៨អស់រយៈពេល១ឆ្នាំ គឺពីឆ្នាំ១៩៧៣ ដល់ឆ្នាំ១៩៧៤ ដោយចោទប្រកាន់គាត់ថាជាគិញ (វន ខ្លួនឯងផ្ទាល់ក៏មិនធ្លាប់ស្គាល់អ្វីដែលហៅថាគិញនោះទេ ។ វន បានឲ្យដឹងថា កាលណោះ ដោយសារសន្តិសុខនៅក្នុងភូមិមិនសូវល្អ គាត់បានយកប្រាក់ដែលមានទាំងអស់ទៅកប់ទុកក្នុងដី ។ នៅពេលគាត់កាយដីយកប្រាក់មកវិញ ហើយដាក់ហាលនៅក្នុងផ្ទះ ឈ្លបខ្មែរក្រហមមើលឃើញក៏ទៅរាយការណ៍ថាគាត់ជាគិញ ហើយយកគាត់ទៅដាក់គុកតែម្តង ។ គាត់បញ្ជាក់ថា “មូលហេតុគេថាខ្ញុំហ្នឹង មានលុយហាលនៅលើផ្ទះហ្នឹង ។ លុយបន្តិចបន្តួចកាលយើងរត់ យើងយកទៅកប់ដីទៅវាសើមណា៎ អ៊ីចឹងយកមកហាលទៅ ។ គេថា យើងគិញបានមានលុយណា៎ ។...គេថា ខ្ញុំមានដែលស្គាល់គិញពីកាលណា? ឃើញលុយខ្ញុំហាលលើផ្ទះ... លុយបន្តិចបន្តួចដែលខ្ញុំខំរកស៊ីលក់គោអំពៅ ធ្វើស្រែលក់បានប៉ុន្មានហ្នឹង វាចេះតែចោទថាយើង ទាល់តែគិញបានមានលុយអ៊ីចឹង បើអ្នកឯងគ្មានប្រាក់ខែស៊ីទេបានលុយហ្នឹងមកពីណា? ខ្ញុំក៏ឆ្លើយថា លុយអស់នេះ ខ្ញុំរកស៊ីលក់ទឹកត្រីអីហ្នឹង ហើយខ្ញុំមិនទាន់មានកូនចាយ នៅពីរនាក់ប្តីប្រពន្ធចេះតែសល់ខ្លះហើយ ។ គេថាមិនមែនទេ លុយប៉ុណ្ណេះហើយ បើសិនណាជាយើងមិនធ្វើការរកស៊ីមិនបានប៉ុណ្ណឹងទេ ទាល់តែយើងហ្នឹងមានប្រាក់ខែស៊ី” ។ នៅក្នុងគុក វន ត្រូវខ្មែរក្រហមដាក់ខ្នោះជើងទាំងពីរ ហើយផ្តល់អាហារឲ្យហូបតិចតួចបំផុត ។ វន បានចេញក្រៅតែពេលព្រឹកប៉ុណ្ណោះ គឺពេលដែលគាត់យកបំពង់ទឹកនោមទៅចាក់ចោល ។

ឈ្លបខ្មែរក្រហមនៅមន្ទីរ២០៨ចូលចិត្តសម្លាប់អ្នកទោសនៅចំពោះមុខអ្នកទោសដូចគ្នាជាច្រើននាក់ ។ ឈ្លបប្រើដែកកាប់ទៅលើបំពង់កអ្នកទោសឲ្យដួលស្លាប់នៅនឹងកន្លែង ។ វន និងអ្នកទោសផ្សេងទៀត សម្លឹងមើលហេតុការណ៍ទាំងនោះដោយក្តីរន្ធត់តក់ស្លុតបំផុត ។ គាត់រំឭកឡើងវិញថា “សម្លាប់ចោលអ៊ីចឹងកាប់ចោលតែមួយដៃៗទេ ជួនអីក៏គេសម្លាប់នៅនឹងមុខហ្នឹង ជួនអីក៏គេឲ្យឈ្លបយកទៅវាលទៅ ។ ឃើញផ្ទាល់ៗភ្នែក ។ ខ្ញុំធ្លាក់ទឹកចិត្ត ខ្ញុំបាត់ការចងចាំតាំងពីពេលហ្នឹងមក ដូចថាវង្វេងគ្រប់ដប់តាំងពីហ្នឹងតែម្តង” ។ ការដែលឃើញទិដ្ឋភាពទាំងនោះជាញឹកញយបានធ្វើឲ្យ វន បាក់ស្បាត ។

ទាក់ទងនឹងគុក២០៨នេះ វន បាននិយាយថា គុកនេះបាន

ប្តូរទីតាំង២ដង ។ ទីតាំងទីមួយនៅម្តុំត្រពាំងជ្រៃ ហើយដោយសារទីនោះជាកន្លែងដែលមានការប្រយុទ្ធគ្នាជាញឹកញាប់ជាមួយទាហានលន់ណុល និងម៉ារ៉ាងដោយសារខ្លាចអ្នកទោសរត់ចូលខាងលន់ណុលផង ខ្មែរក្រហមបានប្តូរទីតាំងគុកទៅនៅក្នុងព្រៃក្តួចម្តុំត្រពាំងអណ្តើកវិញ ។ វន បាននិយាយថា "ចូលទាល់តែដល់ព្រៃក្តួច ។ អូរអានោះទៅដល់ក៏ងាប់ស្តែងដែរ ។ ចាញ់កាន់តែខ្លាំងឡើង ។ រឿងវាសម្លាប់គិតតួចដែរទេកាលហ្នឹង ងាប់នឹងអត់បាយហើយនិងចាញ់ហ្នឹងតែម្តង ទៅដំបូងមិនទាន់អីទេ រវាងប្រហែលពីរបីខែបានចាប់ផ្តើមស្លាប់ ។ ស្លាប់អឺចឹង ដេកជាមួយគ្នាទន្ទឹមគ្នា អត់ដឹងថាអ្នកហ្នឹងស្លាប់ទេណា៎ ទាល់តែអ្នកហ្នឹងស្រមោចរោម ខ្ញុំឆ្ងល់ថាហេតុអីបានជាមានស្រមោចរោមខ្ញុំម្ល៉េះ ដល់តែស្ទាបមើល រុញទៅវឹង មិនដឹងងាប់តាំងពីថ្មើរម៉ានទេ" ។

បន្ទាប់ពីខ្មែរក្រហមវាយដណ្តើមបានទីរួមខេត្តតាកែវនៅក្នុងឆ្នាំ១៩៧៤ ខ្មែរក្រហមបានដោះលែង វន និងអ្នកទោសមួយចំនួនដើម្បីយកបន្ទប់គុកដាក់ឈ្លើយសឹក ដែលជាទាហានលន់ណុល ។ បន្ទាប់ពីដោះលែងហើយ អង្គការមិនអនុញ្ញាតឲ្យ វន និងអ្នកទោសដទៃទៀតវិលត្រឡប់ទៅស្រុកកំណើតវិញទេ បែរជាបញ្ជូនឲ្យទៅរស់នៅតំបន់មួយដែលហៅថា តានៀក អស់មួយរយៈទៀត ទើបដោះលែងឲ្យវិលត្រលប់មកស្រុកកំណើតវិញ ។ ដោយសារធ្លាប់មានប្រវត្តិជាអ្នកទោស វន ខិតខំធ្វើការណាស់ ហើយមិនដែលហ៊ានឲ្យមានកំហុសទេ ព្រោះខ្លាចអង្គការយកទៅសម្លាប់ចោល ។

ដោយឡែកនៅក្នុងក្រុមគ្រួសាររបស់ វន ឪពុករបស់គាត់ឈ្មោះ អៀង កង បានស្លាប់ដោយខ្វះអាហារហូបនៅក្នុងរបបខ្មែរក្រហម ។ ចំណែកម្តាយរបស់ វន ឈ្មោះ ទៀត ហ៊ុម បានស្លាប់ដោយអត់អាហារនិងគ្រាំគ្រាចិត្តនៅពេលដែល វន ត្រូវខ្មែរក្រហមចាប់ទៅដាក់ក្នុងមន្ទីរឃុំឃាំង ។ ក្នុងចំណោមបងប្អូនបង្កើតរបស់ វន ទាំង៧នាក់ មាន២នាក់បានចូលបម្រើទ័ពខ្មែរក្រហម ។ ក្នុងនោះម្នាក់បានបាត់ខ្លួន រីឯម្នាក់ទៀតបានវិលត្រឡប់មកភូមិកំណើតវិញ ប៉ុន្តែបានក្លាយជាជនពិការ ។

បច្ចុប្បន្ននេះ វន ជាមនុស្សមានសភាពផ្លូវចិត្តមិនប្រក្រតីទេ ។ គាត់មានទឹកមុខស្រពាប់ស្រពោនជាប់ជានិច្ច ឆាប់ខឹង ឆាប់ភ័យខ្លាចចូលចិត្តសម្ងំតែម្នាក់ឯង មិនចង់ចូលទៅក្នុងជំនុំចំណោមមនុស្ស ហើយមិនដែលសើចសប្បាយដូចអ្នកដទៃទាំងពួងឡើយ ។ វន និយាយថា "អត់ដែលមានសើចដងរាល់ថ្ងៃហ្នឹង អត់មានពាក្យអីសើចនឹងគេទេ អត់ទេ ។ វាដូចតាំងពីហ្នឹងមកចេះតែទៅបន្តិចម្តងៗណា៎ ។ យើងពីដើមជួបគ្នានិយាយពីនេះពីនោះអីសើចណា៎ ឥឡូវអាសើចហ្នឹងបាត់ឈឹង ចេះតែញញឹម បើជួបនឹងគេញញឹមអ៊ីចឹង ទៅអត់សួរគេទៅហួសអ៊ីចឹងទៅ" ។ ពេលខ្លះ វន ភ្លេចភ្លាំងសូម្បីតែពាក្យសម្តីដែលត្រូវប្រើប្រាស់ប្រចាំថ្ងៃ ។ គាត់លើកឧទាហរណ៍ថា "អាហូបហ្នឹងភ្លេចហូបអស់រលីងទៅហើយ ភ្លេចពាក្យថាហូបអត់ដឹងទេ វង្វេងអស់ហើយ មិនថាធ្មើខ្ញៀវៗហ្នឹងគេហៅថាអីវាមិនដឹងអាហ្នឹងហូបណា៎ ។ ហើយចង់ភ្លេចចេះភាសាយើង ដូចថាទៅរែកទឹកអ៊ីចឹង និយាយអត់ចប់ទេ ថាទៅរែកអីៗអ៊ីចឹងទៅ ភ្លេចអាទឹកភ្លេចអីហ្នឹង និយាយរួមទៅថាវាអត់គ្រប់ដប់ណា៎ និយាយអត់ចប់ឃ្លា" ។ វន ជួបនឹងបញ្ហាដេកមិនលក់ជាញឹកញាប់ ហើយបើដេកលក់គឺយល់សប្តិអាក្រក់ ។ "វាហាក់ដូចជានៅដក់ជាប់នឹងខួរក្បាលដូចជាឆ្កួតទៅ ហើយអត់ភ្លេចសោះ ដេកយប់ណាក៏ដូចយប់ណាដែរ ភ្ញាក់ឡើងត្រូវនឹកឃើញតែម្តង ។ ហើយបើយល់សប្តិទៀតមិនដឹងខ្មោចទាញអី យល់សប្តិឃើញតែទ័ពអាពតហ្នឹងឯង ចាប់ឃុំចាប់ឃាំង ចាប់វាយចាប់ដំ ឃើញតែអ៊ីចឹង ឃើញតែអាពតចាប់មនុស្ស ឃើញតែគេដេញចាប់ខ្ញុំយកទៅដាក់គុកអ៊ីចឹងទៅ អត់មានឃើញអីខុសហ្នឹងទេ" ។

ឆ្នាំនេះ វន មានអាយុ៦៨ឆ្នាំហើយ ។ គាត់បានទៅវត្តសុំសីលដើម្បីរម្ងាប់អារម្មណ៍អាក្រក់ទាំងនោះ ប៉ុន្តែហាក់ដូចជាមិនមានប្រសិទ្ធភាពទាល់តែសោះ ។ គាត់បានទៅពិគ្រោះជំងឺនៅមន្ទីរពេទ្យដែរ ប៉ុន្តែសភាពផ្លូវចិត្តរបស់គាត់នៅតែមិនបានប្រសើរឡើយ ។ ពេលដែលក្រុមស្រាវជ្រាវរបស់យើងទៅជួបគាត់ជាលើកដំបូង វន មានអារម្មណ៍ភ័យខ្លាចយើងជាខ្លាំង ។ អាកប្បកិរិយារបស់គាត់ហាក់ដូចជាផ្អើលៗ និងមិនចង់ផ្តល់បទសម្ភាសន៍ដល់យើងឡើយ ។ បន្ទាប់ពីក្រុមស្រាវជ្រាវណែនាំពីគោលបំណងនិងការងាររបស់យើង និងពន្យល់គាត់ឲ្យយល់អំពីសារសំខាន់នៃការងារនេះ គាត់ក៏សប្បាយចិត្តឡើងវិញ និងមានទំនុកចិត្តខ្លះមក

លើក្រុមស្រាវជ្រាវ ។ បន្ទាប់ពីចប់ការសម្ភាសន៍ វន មាន ប្រសាសន៍ថា ប្រសិនបើយើងអាចផ្តល់ការព្យាបាលជំងឺផ្លូវចិត្ត ដល់គាត់បាន គាត់ពិតជាត្រេកអរខ្លាំងណាស់ ។

ក្រោមកិច្ចសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា អង្គការចិត្តសង្គមអន្តរវប្បធម៌ ហៅកាត់ថា ធីភីអូ(TPO) បាននិង កំពុងផ្តល់ការប្រឹក្សានិងសេវាព្យាបាលផ្លូវចិត្តដល់ជនរងគ្រោះនៃ របបខ្មែរក្រហមនៅក្នុងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ នាពេល ដ៏ឆាប់ខាងមុខនេះ សេវានេះនឹងទៅដល់ខេត្តតាកែវ ហើយ វន នឹងបានទទួលការព្យាបាលនេះជាមិនខាន ។

**ញាណ សុជាតិ**

# ឃុំរំលេច: ខ្មែរកម្ពុជាក្រោមនៅក្រោមការត្រួតត្រារបស់ខ្មែរក្រហម

ក្នុងរជ្ជកាលរបស់ព្រះបាទមុនីវង្ស (១៩២៧-១៩៤១) ខ្មែរកម្ពុជាក្រោមមួយចំនួនបានចូលមកកាប់ឆ្ការព្រៃឈើទាល នៅស្រុកបាកាន ខេត្តពោធិសាត់ ដើម្បីសាងសង់លំនៅឋាន និងពង្រីកទីវាលស្រែចម្ការសម្រាប់ចិញ្ចឹមជីវិត ។ បន្ទាប់ពីដឹង ថាមានដីសម្បូរជីជាតិនៅទំនេរច្រើន ប្រជាជនខ្មែរក្រោមបាន ហូរចូលមកតំបន់នោះកាន់តែច្រើនឡើងៗ ។ ភូមិខ្មែរកម្ពុជា ក្រោមមួយបានកកើតឡើង ។ ខ្មែរកម្ពុជាក្រោមទាំងនេះភាគ ច្រើនមកពីខេត្តព្រះត្រពាំង ។

ឃុំរំលេចមានខ្មែរកម្ពុជាក្រោមមកតាំងទីលំនៅច្រើនជាង ឃុំដទៃទៀតនៃស្រុកបាកាន ។ មុនឆ្នាំ១៩៧៥ មានខ្មែរកម្ពុជា ក្រោមប្រមាណ៥០០គ្រួសារតាំងទីលំនៅក្នុងឃុំរំលេច ។ មកទល់ឆ្នាំ១៩៧៩ ខ្មែរកម្ពុជាក្រោមដែលនៅសេសសល់មាន ត្រឹមតែជាង៤០គ្រួសារប៉ុណ្ណោះ ។ អ្នកក្រៅពីនោះបានបាត់ ខ្លួន និងត្រូវខ្មែរក្រហមសម្លាប់ក្នុងរវាងឆ្នាំ១៩៧៥-១៩៧៩ ។ អត្ថបទនេះនឹងបំភ្លឺអំពីមូលហេតុនិងដំណើរការដែលនាំឲ្យឈាន ដល់ការសម្លាប់ខ្មែរកម្ពុជាក្រោម ។

## ១) ឃុំរំលេច

ឃុំរំលេចលាតសន្ធឹងលើទឹកដីស្រុកបាកាននៃខេត្តពោធិ-សាត់ ។ ក្នុងអំឡុងពេល៥ឆ្នាំនៃសង្គ្រាមស៊ីវិលនិងការតស៊ូ បដិវត្តន៍ខ្មែរក្រហមបានបែងចែកប្រទេសកម្ពុជាជាតំបន់និងភូមិ ភាគផ្សេងៗបន្ថែមពីលើខេត្ត ស្រុក ឃុំ និងភូមិដែលមានរួច ហើយ ។ ការបែងចែកថ្មីនេះមានប្រយោជន៍សម្រួលដល់ការងារ ទំនាក់ទំនងរដ្ឋបាល និងគ្រប់កិច្ចការបដិវត្តន៍ ។ ដោយសារ ដំណើរនេះ ស្រុកបាកានត្រូវស្ថិតនៅក្នុងតំបន់២នៃភូមិភាគពាយ័ព្យ ។ បន្ទាប់ពីជោគជ័យថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហម ក៏នៅតែរក្សាការបែងចែកភូមិសាស្ត្រដូចគ្នានេះដដែល ។

## ២) ការប្រមូលចងក្រងប្រវត្តិរូប

នៅឆ្នាំ១៩៧៧ សមាជិកគណៈកម្មាធិការស្រុកបាកាន បានមកចូលរួមប្រជុំនៅភូមិរូងតាកុក ក្នុងឃុំរំលេច ។ អង្គប្រជុំ មានការចូលរួមពីសំណាក់ប្រជាជន ប្រធានក្រុម ប្រធានកងនិង ប្រធានសហករណ៍ឈ្មោះ យ៉ាន, នឿន នាល និង សាន សឿម ហើយពិភាក្សាអំពីផែនការប្រមូលប្រវត្តិរូបប្រជាជននិងកំណត់ មុខសញ្ញាខ្មែរកម្ពុជាក្រោម ។ នៅក្នុងអង្គប្រជុំគណៈកម្មាធិការ ស្រុកបាកានបានណែនាំថា បន្ទាប់ពីការប្រមូលប្រវត្តិរូបចប់សព្វ គ្រប់ហើយអង្គការនឹងបែងចែកក្រុមជនជាតិនានាឲ្យរស់នៅដាច់ ដោយឡែកពីគ្នា ។ ធ្វើដូច្នេះទើបអង្គការងាយស្រួលត្រួតពិនិត្យ គោលជំហររបស់ក្រុមនីមួយៗ ជាពិសេសគោលជំហរក្នុងការ ធ្វើស្រែមានន័យថាអង្គការនឹងអាចកំណត់បានថាក្រុមណា ធ្វើស្រែបានទិន្នផលច្រើនជាងគេក្នុងពេលយ៉ាងឆាប់បំផុត ។

គណៈសហករណ៍ជាអ្នកស្រង់ប្រវត្តិរូបប្រជាជនតាមបញ្ជា របស់គណៈភូមិភាគឆ្លងកាត់គណៈតំបន់ ។ ប្រធានគណៈកម្មា-ធិការស្រុកបានចេញបញ្ជាដោយផ្ទាល់ទៅគណៈសហករណ៍ ។ គណៈសហករណ៍បានហៅប្រធានកងនិងប្រធានពួកមកប្រជុំ ហើយចាត់ចែងឲ្យប្រមូលប្រវត្តិរូបប្រជាជនដែលនៅក្រោមការ ទទួលខុសត្រូវរបស់ខ្លួន ។ បន្ទាប់ពីប្រមូលប្រវត្តិរូបរួចរាល់ហើយ មេក្រុមរាយការណ៍ទៅមេកងដែលមាននាទីរាយការណ៍បន្តទៅ

ប្រធានសហករណ៍ ។ ជាទូទៅ មិនថាមេកងមេក្រុមទាំងនោះពិតជាបានសាកសួរប្រវត្តិរូបប្រជាជនឬក៏អត់ទេ អ្នកទាំងនោះសុទ្ធតែបានដឹងជាមុនហើយថា អ្នកណាជាខ្មែរកម្ពុជាក្រោម ហើយអ្នកណាមិនមែនដោយសារមេក្រុមមេកងទាំងនោះរស់នៅក្នុងភូមិឃុំនោះជាយូរមកហើយ ។

ប្ដីរបស់ លឿង សុខ ជាខ្មែរក្រោម ។ មេក្រុមរបស់គាត់បានមកសួរអំពីសាវតាររបស់ប្ដីគាត់ ប៉ុន្តែមិនដែលសួរអំពីខ្លួនគាត់ទេ ។ មេកងសួរ លឿង សុខ ថា តើប្ដីរបស់គាត់ជាជនជាតិអ្វី ហើយកើតនៅឯណា ។

ចាយ គីម ធ្លាប់ត្រូវប្រធានអង្គភាពឈ្មោះ តាមឿន សាកសួរពីរបីដងអំពីសាវតាររបស់ប្ដីគាត់ ។ ការសួរពីមួយលើកទៅមួយលើក តាមឿន សួរតែសំណួរដដែលៗ ។ គាត់សួរ ចាយ គីម ថា តើប្ដីរបស់ គីម ជាខ្មែរលើឬក៏ខ្មែរក្រោម ហើយមានកូនប៉ុន្មាននាក់ដែរ ។ ប្រធានអង្គភាពសួរចម្លើយរាល់អ្នកនៅក្រោមបង្គាប់ទាំងខ្មែរលើនិងខ្មែរក្រោម ។ ខ្មែរក្រោមមួយចំនួនដែលមេកងស្គាល់ច្បាស់ មេកងមិនចាំបាច់សួរទេ គឺស្រង់ឈ្មោះចូលក្នុងបញ្ជីតែម្ដង ។ តាមឿន បានប្រាប់ ចាយ គីម ថា អង្គការនឹងឲ្យខ្មែរក្រោមទៅរស់នៅដាច់ដោយឡែកពីប្រជាជនខ្មែរ ។

វ៉ាន់ មុត ក៏និយាយមិនខុសពី ចាយ គីម ដែរ ។ គាត់ថា កម្មាភិបាលខ្មែរក្រហមបានសួរសំណួរដដែលៗជាច្រើនលើកច្រើនសា ។ ជួនកាលពីរខែ ខ្មែរក្រហមប្រជុំប្រជាជនដើម្បីសួរអំពីរឿងនេះម្ដង ។ ជារៀងរាល់លើក កម្មាភិបាលទាំងនោះផ្ទៀងផ្ទាត់ចម្លើយពីលើកមុននិងលើកក្រោយ ដើម្បីរកឲ្យឃើញថាតើដូចគ្នាឬខុសគ្នា ។ វ៉ាន់ មុត មិនយល់ពីហេតុផលចាំបាច់នៃការសាកសួរនេះឡើយ ។ គាត់បានឆ្លើយត្រង់ៗថា គាត់ជាខ្មែរ ឯប្រពន្ធរបស់គាត់ជាខ្មែរកម្ពុជាក្រោម ។ វ៉ាន់ មុត បកស្រាយថា បើទោះបីជាគាត់ចង់លាក់អត្តសញ្ញាណរបស់ប្រពន្ធគាត់ក៏ទៅមិនរួចដែរ ដោយសារសំនៀងរបស់នាង ។ មេកងមួយចំនួនដែលចុះធ្វើការផ្ទៀងផ្ទាត់ស្រង់ប្រវត្តិរូបក៏ជាខ្មែរកម្ពុជាក្រោមដែរ ។

### ៣) ការផ្លាស់ពីឃុំរំលេចមកឃុំខ្នារទទឹង

បន្ទាប់ពីបានប្រមូលប្រវត្តិរូបទាំងអស់ហើយ នៅដើមរដូវវស្សាឆ្នាំ១៩៧៧ អង្គការបានប្រមូលខ្មែរកម្ពុជាក្រោមនៅក្នុងឃុំរំលេចបញ្ជូនឲ្យទៅរស់នៅឃុំខ្នារទទឹងវិញ ។

គណៈសហករណ៍បានបើកការប្រជុំមួយហើយប្រាប់ខ្មែរកម្ពុជាក្រោមឲ្យរៀបចំអីវ៉ាន់ដើម្បីដូរទីលំនៅ ។ អ្នកដែលជាជនជាតិខ្មែរ អង្គការមិនបានបញ្ជាឲ្យប្ដូរទីលំនៅឡើយ ប៉ុន្តែប្រសិនបើអ្នកទាំងនោះចង់ទៅតាមប្ដីឬប្រពន្ធដែលជាខ្មែរកម្ពុជាក្រោមក៏អង្គការមិនថាអ្វីដែរ ។ មានខ្មែរមួយចំនួនធំបានស្ម័គ្រចិត្តផ្លាស់ទីលំនៅទៅឃុំខ្នារទទឹងជាមួយប្ដីឬប្រពន្ធរបស់ខ្លួន ។ នៅព្រឹកថ្ងៃចេញដំណើរខ្មែរកម្ពុជាក្រោមទូទាំងឃុំរំលេចបានធ្វើដំណើរជាមួយគ្នា អ្នកខ្លះបររទេះ ឯអ្នកខ្លះទៀតដើរ ។ វ៉ាន់ មុត ប្រៀបធៀបការធ្វើដំណើរនេះទៅនឹងក្បួនដង្ហែដ៏អធិកអធមមួយ ។ ក្បួនដំណើរបានឈប់សម្រាកហូបបាយថ្ងៃត្រង់នៅភូមិកំប្រាក់កូន ។ នៅទីនេះកម្មាភិបាលខ្មែរក្រហមបានបែងចែកប្រជាជនជាពីរក្រុម ។ មួយក្រុមនៅទៅភ្ជួររាស់ដីស្រែនិងស្ទូងស្រូវនៅភូមិកំប្រាក់កូន និងមួយក្រុមទៀតធ្វើដំណើរបន្តទៅឃុំខ្នារទទឹង ។ ខ្មែរកម្ពុជាក្រោមក្រុមទីពីរមកដល់ភូមិខ្នារទទឹងនៅម៉ោង២រសៀល ។

វ៉ាន់ មុត ដែលមានជំនាញខាងជាងដែក ត្រូវអង្គការបញ្ជូនទៅឃុំខ្នារទទឹង ចំណែកប្រពន្ធរបស់គាត់ធ្វើស្រែនៅភូមិកាំប្រាក់កូន ។ ក្រោយមកទៀត មានពាក្យចចាមអារ៉ាមវិលវល់ទូទាំងភូមិថា ពីដំបូងខ្មែរក្រហមបម្រុងនឹងយកខ្មែរក្រោមទាំងអស់ទៅសម្លាប់ ប៉ុន្តែចៃដន្យចំរដូវធ្វើស្រែទើបអង្គការទុកខ្មែរក្រោមទាំងនោះឲ្យធ្វើស្រែមួយរដូវសិន ។ ក៏ប៉ុន្តែ ខ្មែរក្រោមខ្លះនិយាយថា ពេលចាកចេញពីឃុំរំលេច មានប្រជាជនដែលមិនមែនខ្មែរក្រោមនៅលាយឡំច្រើនពេក ហេតុនេះហើយទើបអង្គការសម្រេចចិត្តទុកអ្នកទាំងនោះនៅខ្នារទទឹងសិនដើម្បីសម្រាំងជាថ្មីម្ដងទៀត ។

### ៤) ការបញ្ជូនទៅបេះពោតនិងដីកដំឡូង

នៅឆ្នាំ១៩៧៧ ខ្មែរក្រោមត្រូវអង្គការបញ្ជូនទៅបេះពោតនិងដីកដំឡូងនៅព្រៃធំ ។ អ្នកដែលជាប្ដីឬប្រពន្ធដែលមិនមែនជាខ្មែរក្រោមប្រធានកងហាមប្រាមមិនឲ្យទៅទេ លើកលែងតែអ្នកណាដែលទទូចចង់ទៅឲ្យខាងតែបាន ។ គណៈសហករណ៍ មេកង

មេក្រុម ដែលជាខ្មែរក្រោមដែរនោះ ក៏ត្រូវបញ្ជូនទៅក្នុងពេលជាមួយគ្នា ។ ក្នុងចំណោមអ្នកដែលទៅបោះពោតនិងជីកដំឡូង គ្មានអ្នកណាម្នាក់មានសំណាងបានត្រឡប់មករាយរ៉ាប់អំពីដំណើរដែលខ្លួនទៅនោះទាល់តែសោះ ។ ទោះបីជាគ្មានអ្នកណាម្នាក់បានឃើញហេតុការណ៍នេះដោយផ្ទាល់ភ្នែកក៏ដោយ ក៏ពាក្យចចាមអារ៉ាមបានលេចឮជុំវិញអ្នកភូមិថា តាមពិតអង្គការបានយកខ្មែរក្រោមទាំងនោះទៅសម្លាប់ចោលអស់ហើយ ។

ការប្រមូលខ្មែរក្រោមឲ្យទៅធ្វើការនៅព្រៃធំនៅតែបន្ត ។ ថ្វីបើមានមន្ទិលសង្ស័យអំពីការសម្លាប់ក៏ដោយ ក៏មានខ្មែរខ្លះជ្រើសរើសទៅស្លាប់ជាមួយប្តីឬប្រពន្ធរបស់ខ្លួនដែរ ។ ពេលទៅដល់ខ្ទារទទឹង ចិន សារុន ត្រូវអង្គការចាត់ឲ្យទៅកាប់ឈើនៅជើងភ្នំ ។ សារុន បានឮពាក្យខ្សឹបខ្សៀវអំពីការបាត់ខ្លួនខ្មែរក្រោម ។ សារុន គ្រោងទុកជាមុនថានឹងវាយតបត ហើយរត់គេចនៅពេលគាត់ត្រូវចេញដំណើរទៅព្រៃធំ ។ សារុន បាននិយាយរឿងនេះប្រាប់ ចាយ គីម ប្រពន្ធរបស់គាត់ ។ ប្រាំថ្ងៃក្រោយមក សារុន បានទទួលការអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះសម្រាក ។ នៅម៉ោង៥រសៀល ប្រធានកងបានមកប្រាប់ សារុន ឲ្យរៀបចំអីវ៉ាន់ទៅប្រជុំនៅម៉ោង៩ព្រឹកស្អែក ដើម្បីទៅបោះពោតនៅព្រៃធំ ។ ដោយហេតុមិនចង់បែកពីប្តី ចាយ គីម បានកុហកមេកងថា គាត់ក៏ជាខ្មែរក្រោមដែរ ។ គាត់មានបំណងស្លាប់ជាមួយប្តីនិងកូនទាំង៧នាក់របស់គាត់ ទោះបីជាប្តីគាត់អង្វរករឲ្យគាត់ប្រាប់មេកងថាគាត់មិនមែនខ្មែរក្រោមក៏ដោយ ។ នៅទីបំផុតថ្ងៃប្រជុំចេញដំណើរទៅព្រៃធំក៏បានមកដល់ ។ សារុន និង ចាយ គីម យកតែបង្វេចដែលមានខោអាវពីរបីប៉ុណ្ណោះពេលចូលរួមប្រជុំជាមួយគ្នា ។ សារុន ប៉ងនឹងរត់គេចទើបមិនចង់យកអីវ៉ាន់ច្រើន ។ ដល់វេលាចុងក្រោយហើយ ក៏ សារុន នៅតែមិនបោះបង់ចោលគម្រោងរត់គេចនេះដែរ ។ ដោយសារគាត់មិនអាចបង្ខំឲ្យប្រពន្ធគាត់សារភាពថា មិនមែនជាខ្មែរក្រោម គាត់ស្រាប់តែក្រោកឈរនៅក្នុងអង្គប្រជុំហើយប្រាប់គណៈសហករណ៍ថា៖ «ប្រពន្ធខ្ញុំមិនមែនជាខ្មែរក្រោមទេ ។ នាងមកពីខេត្តកណ្តាល ។ សូមសមមិត្តបងជួយថែរក្សានាងផង» ។ បន្ទាប់ពីបានដឹងថា ចាយ គីម មិនមែនជាខ្មែរក្រោម គណៈសហករណ៍ក៏ឃាត់ ចាយ គីម មិនឲ្យទៅតាមប្តីផង ។ ក្រោយប្រជុំចប់នៅម៉ោង១០ព្រឹក សារុន និងខ្មែរក្រោមមួយចំនួនទៀត ត្រូវឈ្លបនាំចេញដំណើរទៅ ។ ឈ្លបបានប្រាប់ខ្មែរក្រោមទាំងនោះឲ្យដាក់បង្វេចខោអាវលើរទេះ ហើយប្រាប់ថាចាំបញ្ជូនទៅតាមក្រោយ ក៏ប៉ុន្តែក្រោយពេលដែលក្រុមនោះធ្វើដំណើរបានឆ្ងាយបន្តិច បង្វេចខោអាវទាំងនោះត្រូវបញ្ជូនមកដាក់ឃ្លាំងក្នុងភូមិទៅវិញ ។

ប្តីរបស់ ង៉ែត ឡួយ ជាខ្មែរក្រោម ។ មេកងឈ្មោះយាយដាប់ បានមកប្រាប់ ឡួយ ថា ប្តីគាត់ត្រូវទៅបោះពោតនៅព្រៃធំ ។ ង៉ែត ឡួយ មានការសង្ស័យ ហើយគាត់បានសុំមិនទៅជាមួយប្តីគាត់ទេ ។ ដោយដឹងថា ឡួយ មិនមែនជាខ្មែរក្រោម យាយដាប់ក៏យល់ព្រម ។ កូនៗរបស់ ង៉ែត ឡួយ ក៏មិនចាំបាច់ទៅជាមួយឪពុកដែរ ។

កូនដែលមានឪពុកខ្មែរក្រោមម្តាយខ្មែរឬកូនដែលមានឪពុកខ្មែរម្តាយខ្មែរក្រោម មានជម្រើសពីរ អាចទៅតាមម្តាយក៏បាន តាមឪពុកក៏បាន ។ ប្រសិនបើកុមារណាម្នាក់រើសទៅជាមួយឪពុកឬម្តាយជាខ្មែរក្រោម កុមារនោះនឹងត្រូវចាត់ទុកជាខ្មែរក្រោមដែរ ប៉ុន្តែបើនៅជាមួយឪពុកឬម្តាយជាជនជាតិខ្មែរកុមារទាំងនោះអាចបន្តរស់នៅក្នុងភូមិបាន ។ កូនស្រីរបស់សារុនឈ្មោះ ចិន សុខុម រស់នៅក្នុងកងកុមារ ។ នៅថ្ងៃដែល សារុន ត្រូវអង្គការបញ្ជូនទៅបោះពោតនៅឯព្រៃធំ មេកងរបស់ សុខុម បានប្រកាសថា កុមារណាដែលមានឪពុកឬម្តាយជាខ្មែរក្រោម ត្រូវតែវិលត្រឡប់ទៅផ្ទះវិញ ។ មុនពេលទៅដល់ផ្ទះ ឈ្លបបាននាំកុមារទាំងនោះទៅកន្លែងប្រមូលផ្តុំខ្មែរក្រោម ។ ឃើញ សុខុម មកដល់ សារុន បានឃាត់កូនស្រីគាត់មិនឲ្យទៅជាមួយគាត់ទេ ។

ពេជ្រ បិស និងក្រុមគ្រួសារខាងប្រពន្ធបានរស់នៅឃុំខ្ទារទទឹងអស់រយៈពេលមួយខែមុនពេលដែលមេកងបញ្ជូនប្រពន្ធរបស់គាត់ទៅបោះពោត ។ មុនថ្ងៃចេញដំណើរមួយថ្ងៃ មេកងបានដើរប្រាប់ខ្មែរក្រោមដែលមានឈ្មោះក្នុងបញ្ជីឲ្យរៀបចំខ្លួន ។ ថ្ងៃបន្ទាប់ ប្រពន្ធរបស់ ពេជ្រ បិស និងកូនបីនាក់ ព្រមទាំងម្តាយឪពុកក្មេក របស់ បិស បានតម្រង់ជួរនៅម៉ោង៣រសៀល ។ បន្ទាប់

ពីក្បួនមនុស្សចេញដំណើរមិនយូរប៉ុន្មាន ម្តាយក្មេកអាយុ៧៥ឆ្នាំ និងកូនស្រីទីពីររបស់ បិស អាយុ៧ឆ្នាំ បានបែកចេញពីជួរហើយវង្វេងផ្លូវ ដូច្នេះអ្នកទាំងពីរក៏ត្រឡប់ទៅផ្ទះវិញ ។ ពេលទៅដល់ផ្ទះ ម្តាយក្មេករបស់ បិស និងកូនស្រីពុំបាននិយាយអ្វីទេ ។ មួយម៉ោងក្រោយមក មេកងបានមកតាមយកអ្នកទាំងពីរទៅវិញ ។ ល្ងាចនោះមានឈ្លបប្រាំនាក់កាន់កាំភ្លើងយាមនៅក្រោមផ្ទះរបស់ បិស ។ ពីរថ្ងៃក្រោយមក ប្រធានកងឈ្មោះ ពឹង ដែលជាជនដៃដល់សម្លាប់ខ្មែរក្រោមបានប្រាប់ បិស ថា៖ «ប្រពន្ធឯងស្លាប់បាត់ហើយ កុំអង្គុយកើតទុក្ខទៀត ។» តាំងពីដំបូងយាយកុំ មេកងរបស់ បិស បានឃាត់ បិស មិនឲ្យទៅជាមួយប្រពន្ធទេ ហើយប្រាប់គាត់ថា ខ្មែរក្រោមដែលអង្គការបញ្ជូនទៅបេះពោតនោះត្រូវអង្គការសម្លាប់អស់ហើយ ។ ការប្រមូលផ្តុំពួកខ្មែរក្រោមឲ្យទៅបេះពោតជាលើកចុងក្រោយបង្អស់រួមមានជាង៧០០នាក់ រាប់ទាំងប្រពន្ធកូន និងឪពុកម្តាយក្មេករបស់ ពេជ្រ បិស និងសាច់ញាតិរបស់ប្រពន្ធគាត់៧នាក់ផង ។ អ្នកទាំងអស់នោះបានបាត់ខ្លួនគ្មានដំណឹងរហូតមកទល់សព្វថ្ងៃ ។

ការប្រមូលខ្មែរក្រោមយកទៅវាលពិឃាតនៅឯទួលសេះញ៉ូវក្រោមលេសទៅដឹកដំឡូងនៅព្រៃធំបានបន្តធ្វើជាប់គ្នាអស់បីថ្ងៃ ។ នៅថ្ងៃទីបី វ៉ាន់ មុត បានឮសំឡេងកាំភ្លើងចេញមកពីទួលសេះញ៉ូវ ។ វ៉ាន់ មុត ធ្វើការនៅរោងជាងដែកដាក់ខ្នែងដែលមេឈ្លបឈ្មោះ អាន មកសម្រាកពេលយប់ ។ ក្រុមឈ្លបតែងតែមកផឹកស្រានៅទីនោះ ហើយនៅពេលដែលស្រវឹងក៏ចាប់ផ្តើមនិយាយអំពីរឿងសម្លាប់មនុស្ស ។ វ៉ាន់ មុត បានឮ អាន និយាយថា «ខ្មែរក្រោមខ្វះតដៃ» ហើយឈ្លបបានបង្ក្រាប ។ ការបាញ់កាំភ្លើងធ្វើឲ្យប្រជាជនភ្ញាក់ផ្អើលនិងភិតភ័យ ។ ដោយហេតុនេះហើយបានជាខ្មែរក្រហមប្តូរយកមនុស្សទៅសម្លាប់នៅព្រៃក្រជៅវិញ ។ ខ្មែរក្រោមដែលបញ្ជូនទៅព្រៃក្រជៅត្រូវខ្មែរក្រហមដាក់ក្នុងក្រោលបង្អត់អាហារបីថ្ងៃមុននឹងសម្លាប់ ។ ខ្មែរក្រោមខ្វះព្យាយាមរត់គេចដោយដោះរបងលួសបន្លា ប៉ុន្តែការប៉ុនប៉ងនេះមិនដែលបានសម្រេចឡើយ ព្រោះក្រៅពីពេជ្ឈ-ឃាតនៅមានកងឈ្លបយាមកាមនៅក្បែរៗនោះចាំចាប់អ្នកដែលចង់រត់គេខ្លួនថែមទៀត ។

ចឹក ប៊ុនរឿន កើតនៅស្រុកបាកាន ហើយសព្វថ្ងៃគាត់ជាមេភូមិរំលេច ឃុំរំលេច ស្រុកបាកាន ខេត្តពោធិសាត់ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់រស់នៅក្នុងសហករណ៍រំលេច ។ ប៊ុនរឿន និយាយថា ការសម្លាប់ខ្មែរក្រោមនៅឃុំរំលេចប្រព្រឹត្តទៅបីដំណាក់កាល ។ ដំណាក់កាលទីមួយនិងទីពីរអនុវត្តនៅឆ្នាំ១៩៧៧ ពេលដែលអង្គការយកខ្មែរក្រោមទៅសម្លាប់នៅព្រៃក្រជៅ ឃុំតាលោ ស្រុកបាកាន ។ ដំណាក់កាលទីបីគឺនៅរវាងឆ្នាំ១៩៧៨ អង្គការយកខ្មែរក្រោមទៅសម្លាប់នៅទួលសេះញ៉ូវ ឃុំខ្នារទទឹង ។

### ៥) សេចក្តីសន្និដ្ឋាន
### មូលហេតុដែលនាំឲ្យមានការសម្លាប់
### ចលនាប្រឆាំងខ្មែរក្រហម

តាមរយៈការអានចម្លើយសារភាពរបស់អ្នកទោសនៅមន្ទីរស-២១ ដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំបានរកឃើញមានចលនាមួយចំនួនដែលបង្កើតដោយខ្មែរក្រោមនៅទឹកដីកម្ពុជាក្រោម ដើម្បីប្រឆាំងនឹងខ្មែរក្រហម ។ ភាគច្រើននៃចលនានេះត្រូវបានខ្មែរក្រហមរកឃើញអំឡុងឆ្នាំ១៩៧៦ ។

ថ្ងៃទី១ ខែមិថុនា ឆ្នាំ១៩៧៦ អ្នកទោសមន្ទីរស-២១ ឈ្មោះ ចាន់ សារ៉ាត បានសារភាពថា មានចលនាប្រឆាំងបដិវត្តន៍ខ្មែរក្រហមហៅថា«ខ្មែរសេរី» ។ អង្គការនេះបានបង្កើតនៅខេត្តព្រះត្រពាំង (ត្រាវិញ ប្រទេសវៀតណាម) ដោយខ្មែរក្រោមម្នាក់ឈ្មោះ សឺង ង៉ុកមិញ ។ សមាជិកខ្លះនៃចលនានេះបានបន្ទំចូលក្នុងបដិវត្តន៍ខ្មែរក្រហម ។

ការសារភាពរបស់ នាគ វឹន, សំ ស៊ីម, សាត ស៊ា, កុយ ដាន់, កួង កុសល, ងួន ថុង, ឃុន លី, និង ពេន ង៉ូវ អះអាងថា មានចលនាបង្កើតដោយ សឺង ង៉ុកថាញ់ នៅកម្ពុជាក្រោម ។ ចលនានេះបានបង្កើតកងកម្លាំងដែលហៅថា «កងទ័ពរំដោះខ្មែរក្រោម» ហើយមានគោលដៅរំដោះកម្ពុជាចេញពីការត្រួតត្រារបស់ខ្មែរក្រហម ។

ក្រៅពីនេះ ខ្មែរក្រហមចាប់បានឯកសារមួយចំនួនរបស់

ចលនាមួយឈ្មោះ"ចលនាមហាសាមគ្គី សេរីកាជាតិឥណ្ឌូចិន" ដែលដឹកនាំដោយ ថៅ ដារ៉ា ។ ឯកសារទាំងនោះចុះហត្ថលេខាដោយមេដឹកនាំ ចលនានៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ។

មានខ្មែរក្រោមមួយក្រុមទៀតដែលត្រូវចាប់ឃុំឃាំងនៅមន្ទីរស-២១ បានសារភាពថាខ្លួនជាតិញសម្ងាត់របស់វៀតណាម ។ យឿង កែវ កើតនៅភូមិថ្កុល ឃុំយឿងវ៉ា ស្រុកពាម ខេត្តក្រមួនស កម្ពុជាក្រោម ត្រូវឃុំឃាំងនៅមន្ទីរស-២១ មុនពេលយកទៅសម្លាប់នាថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៧៨ ។ យឿង កែវ បានសារភាពថា គាត់បានទទួលបញ្ជាមកឈ្លបយកការណ៍ពីទីតាំងកងទ័ពបដិវត្តន៍ខ្មែរក្រហម ទីតាំងកាំភ្លើងធំ រថក្រោះ និងនាវាចម្បាំង នៅចន្លោះកំពង់សោមនិងកែប ។

សឺង ស៊ាប អាយុ២៨ឆ្នាំ កើតនៅភូមិពពុះទឹក ឃុំភូមី ស្រុកបាសាក់ ខេត្តឃ្លាំង កម្ពុជាក្រោម ត្រូវខ្មែរក្រហមសម្លាប់នៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧៨ ។ ស៊ាប បានសារភាពថាគាត់បានចូលរួមក្នុងចលនាយុវជនកុម្មុយនិស្តហូជីមិញពីខែសីហា ឆ្នាំ១៩៧៧ រហូតដល់ខែតុលា ឆ្នាំ១៩៧៧ ។ ចៅហ្វាយស្រុក វូ ថាញ់ បានចាត់តាំង ស៊ាប ឲ្យទៅរៀននៅសាលាយោធាអស់រយៈពេលបួនខែ ។ នៅទីនោះគាត់រៀននយោបាយវិទ្យាសាស្ត្រទ័ពនិងរបៀបឈ្លបយកការណ៍ ។

និយាយដោយខ្លី ខ្មែរក្រោមដែលជាប់ឃុំឃាំងនៅមន្ទីរស-២១ សុទ្ធតែសារភាពអំពីការឈ្លបយកការណ៍ក្នុងចេតនាផ្តួលរំលំបដិវត្តន៍ ។ មានរឿងដូចគ្នា២២ករណីកើតឡើងក្នុងឆ្នាំ១៩៧៦ ច្រើនជាងឆ្នាំ១៩៧៥ដល់ទៅ២០ករណី ។

## មូលហេតុនៃការសម្លាប់

ជាទូទៅ ប្រជាជនក្នុងឃុំរំលេចសុទ្ធតែដឹងថាខ្មែរក្រហមសម្លាប់ខ្មែរក្រោម ពីព្រោះអង្គការមិនបានចាត់ទុកខ្មែរក្រោមថាជាជនជាតិខ្មែរពិតប្រាកដទេ គឺចាត់ទុកថាជាជនជាតិវៀតណាម ។ នេះប្រហែលជាលេចចេញមកពីការពិតដែលថាមានចលនាប្រឆាំងខ្មែរក្រហមដូចដែលបានបញ្ជាក់ខាងលើគឺសុទ្ធតែបង្កើតឡើងនៅលើទឹកដីកម្ពុជាក្រោមទាំងអស់ ។ នៅមានចំណុចរួមផ្សំងទៃទៀតដូចជា រូបរាង សម្លៀកបំពាក់ សម្តីសំដៅ និងចរិតបុគពា របស់ខ្មែរក្រោមស្រដៀងទៅនឹងជនជាតិវៀតណាម ហើយខ្មែរក្រោមភាគច្រើនចេះនិយាយវៀតណាមយ៉ាងច្បាស់ ។

នៅក្នុងទិដ្ឋភាពផ្នែកសន្តិសុខនៅមន្ទីរស-២១ វិន័យទាំង៨ ប្រការសម្រាប់អ្នកជាប់ឃុំបានចែងថា៖ "កុំប្រើប្រាស់លេសខ្មែរក្រោមដើម្បីលាក់បាំងមុខមាត់ក្បត់" ។ អ្នកទោសមួយចំនួននៅមន្ទីរស-២១ បានសារភាពថាខ្លួនជាខ្មែរក្រោម ហើយអ្នកទាំងនោះត្រូវអ្នកសួរចម្លើយធ្វើទារុណកម្មរហូតទាល់តែព្រមឆ្លើយថាបានទទួលបញ្ជាពីខាងវៀតណាមមកយកការណ៍នៅកម្ពុជា ។

គីម សូ រស់នៅឃុំរំលេច ប្រាប់យើងថា នៅចុងឆ្នាំ១៩៧៧ អង្គការបានកោះហៅខ្មែរក្រោមទាំងអស់នៅក្នុងឃុំរំលេច មកប្រជុំហើយប្រកាសថា៖ "នៅក្នុងដំណាក់កាលនេះយើងត្រូវតែបោសសម្អាតភ្នាក់ងារយួនឲ្យអស់" ។ បន្ទាប់ពីការប្រកាសនេះ ខ្មែរក្រហមចាប់ផ្តើមយកខ្មែរក្រោមទៅសម្លាប់ ។ គីម សូ ត្រូវចាប់ខ្លួនយកទៅដាក់គុកដោយចោទថាក្បត់នឹងអង្គការ ដែលសូម្បីតែ គីម សូ ខ្លួនឯង មិនដែលដឹងថាពាក្យ "ភ្នាក់ងារយួន" ឬក៏ "ភ្នាក់ងារក្បត់"មានន័យអ្វីឲ្យប្រាកដឡើយ ។

ចឹក ប៊ុនរឿន បាននិយាយថា ខ្មែរក្រហមមិនទុកចិត្តខ្មែរក្រោមហើយបានចោទខ្មែរក្រោមថាជាភ្នាក់ងារយួនជាមួយពាក្យថា "ក្បាលយួនខ្លួនខ្មែរ" ។ នៅឆ្នាំ១៩៧៧ ខ្មែរក្រហមអនុវត្តផែនការសម្លាប់ខ្មែរក្រោមដោយសារខ្លាចថា នៅពេលដែលវៀតណាមចូលឈ្លានពាន ខ្មែរក្រោមទាំងអស់នឹងសហការជាមួយវៀតណាម ។ អ៊ុក ប៊ួន មេឃុំរំលេច និយាយថា ខ្មែរក្រហមចោទខ្មែរក្រោមថាជាវៀតណាម ពីព្រោះខ្មែរក្រោមអាចនឹងបះបោរប្រឆាំងប្រសិនបើមានព្រឹត្តិការណ៍អ្វីកើតឡើង ។ ទេព គីមហួយ រស់នៅភូមិរំលេច ក៏និយាយដែរថា ខ្មែរក្រោមនៅឃុំរំលេចសុទ្ធតែត្រូវខ្មែរក្រហមចោទថាមានជាប់ទាក់ទិននឹងវៀតណាម ហើយក៏យកទៅសម្លាប់ ។

មិនត្រឹមតែនៅស្រុកបាកាននៅខេត្តពោធិសាត់ទេ ខ្មែរក្រោមដែលរស់នៅស្រុកត្រាំកក់ ខេត្តតាកែវ ក៏ត្រូវខ្មែរក្រហមសម្លាប់ដោយសារតែមិនទុកចិត្តដែរ ។ នៅខែមេសា ឆ្នាំ

១៩៧៧ ខ្មែរក្រហមបានចុះបញ្ជីខ្មែរក្រោមនៅក្នុងស្រុកត្រាំកក់ ។ អ៊ីន ញ៉ាន ដែលរស់នៅស្រុកត្រាំកក់តាំងពីរបបកម្ពុជាប្រជាធិបតេយ្យរហូតដល់បច្ចុប្បន្ន និយាយថា អង្គការបានប្រមូលខ្មែរក្រោមមកពីកន្លែងផ្សេងៗ សរុប៧០គ្រួសារ ហើយឲ្យរស់នៅជុំគ្នា ។ ក្រោយមក អង្គការបានហៅខ្មែរក្រោមទៅប្រជុំ ។ នៅក្នុងអង្គប្រជុំនោះ គណៈអង្គប្រជុំបាននិយាយថា÷ «បើបងប្អូនណាចង់វិលត្រឡប់ទៅកាន់ប្រទេសកំណើតវិញ អង្គការនឹងជួយឧបត្ថម្ភជាស្បៀងអាហារសម្លៀកបំពាក់ក្នុងការធ្វើដំណើរ» ។ ផ្ទុយទៅវិញ ខ្មែរក្រោមណាដែលនិយាយថាចង់ត្រឡប់ទៅស្រុកកំណើតវិញ ត្រូវអង្គការយកទៅសម្លាប់ដោយចោទថា ជាខ្មែរបណ្តាញយួន ។

មានសេចក្តីរាយការណ៍មួយនិយាយអំពីការធ្វើបញ្ជីឈ្មោះខ្មែរក្រោមនៅឃុំអង្គតាសោម ស្រុកត្រាំកក់ នៅខែមេសា ឆ្នាំ១៩៧៧ ដែលបានគូសបញ្ជាក់ថា ពេលប្រមូលប្រវត្តិរូបរួចរាល់ហើយ ខ្មែរក្រោមក៏សំណូមពរវិលទៅប្រទេសវៀតណាមវិញ ។

ផាត់ សមុទ្រ ជាអ្នកទទួលភ្ញៀវនៅស្ថានអូឡាំពិកក្នុងរបបកម្ពុជាប្រជាធិបតេយ្យបាននិយាយថា ពេលនោះគឺជាអំឡុងពេលដែលមានការប៉ះទង្គិចគ្នានៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាមរវាងឆ្នាំ១៩៧៧និង១៩៧៨ ។ សមមិត្ត ប៉ុល ពត បានកោះហៅខ្មែរក្រោមជាច្រើនមកប្រជុំសិក្សានយោបាយ ។ ផាត់ សមុទ្រ ក៏មានវត្តមាននៅក្នុងអង្គប្រជុំដែរ ។ ប៉ុល ពត បាននិយាយថា ក្នុងចំណោមខ្មែរក្រោមអ្នកណាតាមអង្គការរស់ អ្នកណាមិនតាម អង្គការមិនទុកទេ ។

សម្តីរបស់ ប៉ុល ពត និងសកម្មភាពរបស់កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោម បានបង្ហាញយ៉ាងច្បាស់ថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានខ្មែរក្រោមច្រើនណាស់ដែលត្រូវអង្គការខ្មែរក្រហមយកទៅសម្លាប់ពីបទសង្ស័យថាជាគិញយកការណ៍ឲ្យវៀតណាមដែលមានបំណងផ្តួលរំលំបដិវត្តន៍ដ៏ក្រហមឆ្អិនឆ្អៅត្រចះត្រចង់និងមហាលោតផ្លោះមហាអស្ចារ្យរបស់ខ្លួន ។

**គីម កែវកន្និដ្ឋា**


ព្រះសង្ឃកម្ពុជាក្រោម

# អ្នកបកប្រែទូរលេខមន្ទីរ៨៧០

ភូមិទទឹងថ្ងៃស្ថិតនៅឃុំដាងទង ស្រុកត្រាំកក់ ខេត្តតាកែវ បានក្លាយជាមូលដ្ឋានបដិវត្តន៍ខ្មែរក្រហម តាំងពីទសវត្សរ៍ឆ្នាំ១៩៦០មកម្ល៉េះ ។ ស៊ៀង សេង ត្រូវគណៈតំបន់ឈ្មោះ សោម បង្ខំឲ្យទៅរែកបាយ ឲ្យកងទ័ពនៅសមរភូមិមុខនៅឆ្នាំ១៩៧១ ។ នៅឆ្នាំ១៩៧៤ សេង បានក្លាយជានារីពេទ្យ តំបន់៣២ ។ ឆ្នាំ១៩៧៧ សេង ជាអ្នកបកប្រែទូរលេខនៅមន្ទីរ៨៧០ ។ នៅឆ្នាំ១៩៧៨ សេង ត្រូវចាប់ខ្លួនបញ្ជូនមកមន្ទីរអប់រំនៅស្វាគូ ។




សេង ជាកូនទោលនៅក្នុងគ្រួសារកសិករមួយនៅក្នុងឃុំដាងទង ។ ឪពុករបស់ សេង ជាអ្នកតស៊ូដើមចាស់មួយរូប ។ ដោយសារគាត់មិនចេះអក្សរ គាត់បានទទួលឋានៈត្រឹមតែប្រធានសេដ្ឋកិច្ចមន្ទីរពេទ្យ៣២ ស្រុកត្រាំកក់ ។

ឆ្នាំ១៩៧១ ពេលដែល សេង ទើបតែមានអាយុ១៨ឆ្នាំ គណៈស្រុកត្រាំកក់ឈ្មោះ ខុម (ជាកូនស្រីរបស់តាម៉ុក) និងគណៈតំបន់១៣ឈ្មោះ សោម បង្ខំចូលឲ្យគាត់ទៅរែកបាយឲ្យកងទ័ពនៅសមរភូមិមុខ ។ រយៈពេល២៨ថ្ងៃនៃការរែកបាយ សេង វេទនាខ្លាំងណាស់ ។ គាត់បានរត់គេចគ្រាប់កាំភ្លើងតូចធំ និងគ្រាប់បែកដែលទម្លាក់ពីលើយន្តហោះ ។ ក្នុងចំណោមកុមារីដែលទៅជាមួយគ្នា មានតែ សេង ម្នាក់ប៉ុណ្ណោះដែលពុំមានរបួស ក្រៅពីនោះសុទ្ធតែត្រូវរបួសនិងស្លាប់ ។ គណៈតំបន់បានចោទប្រកាន់ សេង ថារត់យកប្រាសអាយុ ពុំព្រមជួយមិត្តភក្តិដែលទៅជាមួយគ្នា ហើយមិនអនុញ្ញាតឲ្យ សេង វិលមកភូមិវិញឡើយ ។ ដោយសារទ្រាំទ្រនឹងពាក្យសម្តីនិងការគាបសង្កត់របស់គណៈស្រុកនិងគណៈតំបន់មិនបាន សេង បានស្ម័គ្រចិត្តចូលធ្វើជាកងទ័ព ។ ក្នុងចំណោមនារី៥០០នាក់ដែលចូលបម្រើកងទ័ពក្នុងពេលជាមួយគ្នានោះ ពុំមានអ្នកណាម្នាក់ចេះអាននិងចេះសរសេរឡើយ មានតែ សេង ម្នាក់ប៉ុណ្ណោះដែលចេះអាននិងអាចសរសេរបាន ។ ហេតុដូច្នេះហើយ សេង ត្រូវបានជ្រើសរើសទុកឲ្យធ្វើការនៅមន្ទីរតំបន់១៣ ។ បន្ទាប់ពីសរសេរប្រវត្តិរូបនារីទាំង៥០០នាក់ចប់ សេង ត្រូវសរសេរប្រវត្តិរូបនារីចំនួនបីវរសេនាតូចដែលអង្គការទើបតែជ្រើសរើសថ្មីទៀត ។ បន្ទាប់ពីធ្វើប្រវត្តិរូបរួច នារីទាំងអស់ត្រូវបញ្ជូនទៅហ្វឹកហ្វឺនក្បួនយុទ្ធសាស្ត្រ ។ សេង ពុំបានទៅហាត់នឹងគេទេ ប៉ុន្តែគាត់ត្រូវបានជ្រើសរើសធ្វើជានិរសាររបស់ប្រធាននារីតំបន់ឈ្មោះ យឿន ។ រាល់ថ្ងៃ សេង សរសេរសំបុត្រ នាំយកសំបុត្រពីកន្លែងមួយទៅកន្លែងមួយ និងជិះកង់ឌុបនារី យឿន ទៅគ្រប់ទីកន្លែងតាមតែ យឿន បញ្ជា ។ សេង ទាស់ចិត្តជាខ្លាំងចំពោះអាកប្បកិរិយារបស់ យឿន រហូតដល់អត់ទ្រាំមិនបានក៏ភ្ញាត់មាត់និយាយថា «អួតតែធ្វើបដិវត្តន៍ដើម្បីកសាងប្រទេស ប៉ុន្តែរបបនេះនៅតែមានខ្ញុំបម្រើដូចរបបសក្តិភូមិដដែល» ។ ព្រោះដូច្នេះ នារី យឿន ខឹងយ៉ាងខ្លាំងហើយរាយការណ៍ទៅអង្គការថ្នាក់លើថា សេង មើលងាយគោលនយោបាយរបស់អង្គការ ហើយបញ្ជូន សេង ឲ្យទៅភូមិសង្កែជ្រុំ នៅក្នុងតំបន់៣២ នៅខែ៧ ឆ្នាំ១៩៧៤ ។ សង្កែជ្រុំគឺជាតំបន់សម្បូរជំងឺគ្រុនចាញ់ ។ សេង មានជំងឺគ្រុនចាញ់យ៉ាងធ្ងន់ធ្ងរស្ទើរតែបាត់បង់ជីវិត ។ មូលហេតុដែលធ្វើឲ្យជំងឺ សេង ព្យាបាលមិនជា គឺដោយសារនារីពេទ្យនៅទីនោះមិនចេះអក្សរហើយប្រើថ្នាំច្រឡំ ។ សេង បានសុំអង្គការចូលធ្វើការនៅក្នុងមន្ទីរពេទ្យជីផ្លាំងដែលស្ថិតនៅក្នុងឃុំតាំងសំរោង ។ សេង បានរៀនសូត្រវិជ្ជាពេទ្យនៅមន្ទីរពេទ្យជីផ្លាំងអស់រយៈពេលជិតមួយឆ្នាំ ។ គ្រូពេទ្យជនជាតិចិនដែលធ្វើការនៅក្នុងមន្ទីរពេទ្យនោះបានបង្រៀន សេង អំពីវិធីព្យាបាលជំងឺដោយប្រើម្ជុលវិទ្យាសាស្ត្រ ។ ដោយសារ សេង មានចរិតអត់ធ្មត់និងឧស្សាហ៍ព្យាយាម ប្រធានពេទ្យចូលចិត្តគាត់ និងយក

ចិត្តទុកដាក់ចំពោះគាត់ដែលធ្វើឲ្យនារីពេទ្យដទៃទៀតប្រណែនជាខ្លាំង ។

នៅខែ៨ ឆ្នាំ១៩៧៥ សេង ត្រូវអង្គការផ្លាស់មកធ្វើការនៅមន្ទីរពេទ្យដម្លូវិន ជាពេទ្យរបស់កងពល៦០៣ ។ នារី ហូ (កូនរបស់តាម៉ុក) ធ្វើការនៅពេទ្យនោះ មាននាទីជាប្រធានផ្នែកវះកាត់ ។ ថ្ងៃមួយ ប្រធានពេទ្យឈ្មោះ កាន់ បានហៅ សេង និងនារី៦នាក់ទៀត ឲ្យទៅមើលការពិសោធន៍វះកាត់មនុស្សនៅខាងក្រោយពេទ្យ ។ ទិដ្ឋភាពនៅពេលនោះបានធ្វើឲ្យ សេង ភិតភ័យស្ទើរតែលស់ព្រលឹងស្លាប់ ។ នៅខាងក្រោយពេទ្យមានមនុស្សប្រុសម្នាក់នៅរស់នៅឡើយ ដែលជាប់ចំណងនៅនឹងដើមឈើមួយដើម ។ ប្រធានពេទ្យឈ្មោះ កាន់ យកកាំបិតសស្ត្រាចវះពោះបុរសនោះបន្តិចម្តងៗ និងពន្យល់បណ្តើរអំពីស្រទាប់ខ្លាញ់ពោះ និងអំពីពោះវៀនតូច-ធំ ដែលមិនចាប់អារម្មណ៍នឹងសម្រែកឈឺចាប់ និងការរើបម្រះរបស់បុរសនោះបន្តិចសោះឡើយ ។ ចុងបញ្ចប់ កាន់ បានកាត់បេះដូងបុរសនោះ ហើយបញ្ជាឲ្យនារីពេទ្យឆាថ្លើមនោះបរិភោគជាមួយស្រា ។ កាន់ បានបង្ខំឲ្យនារីទាំងអស់ហូបថ្លើមមនុស្សឆា បើអ្នកណាមិនហូបបានន័យថាក្បត់បដិវត្តន៍ ។ សេង បានចូលរួមហូបថ្លើមមនុស្សជាមួយនឹង កាន់ ដែរ ប៉ុន្តែគាត់និយាយថា គាត់ពុំបានហូបថ្លើមមនុស្សនោះទេ គាត់លួចបោះថ្លើមឆានោះចោលតាមប្រឡោះជើងខោរបស់គាត់ ។

សេង ត្រូវអង្គការបញ្ជូនទៅបំប៉នបច្ចេកទេសពេទ្យនៅពេទ្យ១៧មេសាបានចំនួនពីរវគ្គ ។ លើកទីមួយនៅខែ៨ ឆ្នាំ១៩៧៥ គឺមិនបានយូរប៉ុន្មានបន្ទាប់ពីគាត់ចូលធ្វើការនៅមន្ទីរពេទ្យដម្លូវិន ។ វគ្គបំពាក់បំប៉ននេះមានសិក្ខាកាម២.៥០០នាក់មកពីភូមិភាគផ្សេងៗ និងបណ្តុះបណ្តាលដោយវេជ្ជបណ្ឌិតជំនាញៗដូចជា ដួនជឿន ហៅប៉ែន, អ៊ិន សូកាន, សាត ខាងជំងឺទូទៅ, ថន ខាងឆ្អឹង, នារីនាត, ហន (កូនរបស់ ដួន ជឿន) និង យាយលី (ប្រពន្ធរបស់ ដួន ជឿន) ។ អៀង ធីរិទ្ធ បានចុះមកជួបសិក្ខាកាមមួយសប្តាហ៍ម្តងដើម្បីបំពាក់បំប៉នគោលនយោបាយបដិវត្តន៍ ។ វគ្គសិក្សានេះមានរយៈពេល៩ខែ ។

បន្ទាប់ពីចប់វគ្គសិក្សានេះនៅខែ១២ ឆ្នាំ១៩៧៥ សេង ត្រូវអង្គការបញ្ជូនទៅមន្ទីរពេទ្យអន្លង់ជ្រៃក្នុងស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ជាមន្ទីរពេទ្យទើបបង្កើតថ្មីមានបុគ្គលិក៥នាក់ ។ ក្នុងនោះមានម្នាក់ឈ្មោះ បូរ៉ាត ជាមិត្តស្និទ្ធស្នាលរបស់ សេង ។ ក្រោយមកមន្ទីរពេទ្យនេះមានបុគ្គលិក១៥០នាក់ ស្ថិតក្រោមការគ្រប់គ្រងរបស់វេជ្ជបណ្ឌិតម្នាក់ឈ្មោះ ប៊ុន ដែលទើបតែត្រឡប់មកពីប្រទេសបារាំង ។ ប៊ុន ធ្វើការនៅក្នុងមន្ទីរពេទ្យនេះបានតែ៥ខែក៏ត្រូវអង្គការយកទៅសម្លាប់ ។

នៅដើមឆ្នាំ១៩៧៦ សេង ត្រូវអង្គការបញ្ជូនឲ្យទៅរៀនវគ្គបំប៉នឯកទេសនៅមន្ទីរពេទ្យ១៧មេសាជាលើកទីពីរ ។ ឆ្នាំនេះជាឆ្នាំដែលអង្គការបានចាប់ប្រធានពេទ្យ១៧មេសា ឈ្មោះ សី និងបុគ្គលិកជាច្រើនទៀតដែលមានការពាក់ព័ន្ធយកទៅដាក់គុកទួលស្លែង ។ នារី១៦នាក់ដែលមកពីមន្ទីរពេទ្យអន្លង់ជ្រៃជាមួយ សេង ត្រូវអង្គការចាប់ខ្លួនបន្ទាប់ពីវិលត្រឡប់មកដល់មន្ទីរពេទ្យវិញ មានតែ សេង និង បូរ៉ាត ប៉ុណ្ណោះដែលរួចខ្លួន ។

ដូ ជេត ដែលជាប្រធានភូមិភាគបស្ចិមបានឲ្យ សេង ទៅធ្វើការនៅមន្ទីរ ៤០១ ។ សេង បានក្លាយជាពេទ្យផ្ទាល់របស់ ដូ ជេត និង តាប៉ាល់ ដែលមានជំងឺប្ញសថ្លើម ។ មិនយូរប៉ុន្មាន ដូជេត បញ្ជូន សេង ទៅរៀនបកប្រែទូរលេខសម្ងាត់នៅមន្ទីរ៨៧០ ។ ការបកប្រែទូរលេខ ទាមទារឲ្យមានការប្រយ័ត្នប្រយែងនិងមានការទទួលខុសត្រូវខ្ពស់ណាស់ បើមិនដូច្នេះទេនឹងមានទោស ។ សេង និយាយថា ឯកសារដែលត្រូវបកប្រែជាទូរលេខភាគច្រើនជាកិច្ចការផ្ទៃក្នុងរបស់បក្ស ដូចជាព្រឹត្តិការណ៍ផ្សេងៗ ផ្ញើពីមជ្ឈិមទៅភូមិភាគ ពីភូមិភាគទៅមជ្ឈិម និងរបាយការណ៍អំពីទំនិញចេញចូលជាដើម ។ ក្នុងនោះក៏មានឯកសារមួយចំនួននិយាយពីឈ្មោះមនុស្សដែលបក្សត្រូវចាប់ខ្លួន និងទីកន្លែងដែលអ្នកទាំងនោះរស់នៅ ។ ភាគច្រើននៃឯកសារដែលផ្ញើទៅតំបន់និងភូមិភាគ សុទ្ធតែត្រូវបកប្រែពីអក្សរទៅលេខដើម្បីកុំឲ្យបែកការណ៍ ។

រយៈពេលកន្លះខែនៃការរៀនបកប្រែទូរលេខ សេង ត្រូវរៀនទាំងថ្ងៃទាំងយប់ ហើយមិនបានទទួលការអនុញ្ញាតឲ្យចេញដើរទៅណាមកណាទេ គឺត្រូវស្នាក់នៅក្នុងមន្ទីររហូតពេលបាយមានអ្នកយកបាយឲ្យដល់កន្លែង ។ ក្នុងចំណោមអ្នកដែលមករៀន

ជាមួយគ្នានោះមាននារីតែពីរនាក់ប៉ុណ្ណោះ គឺសេង និងម្នាក់ទៀត មកពីខេត្តកោះកុង ក្រៅពីនោះជាបុរសទាំងអស់ ។ ក្នុងបន្ទប់មួយ ដាក់តែម្នាក់ប៉ុណ្ណោះ ហើយមិនអនុញ្ញាតឲ្យដើបដើរ ឬធ្វើការ សាកសួរគ្នាឡើយ ។ បុគ្គលិកអ្នកបកប្រែទូរលេខមិនត្រូវបាន អនុញ្ញាតឲ្យស្គាល់ប្រធានឡើយ គឺលាក់ការណ៍បំផុត ។

បន្ទាប់ពីរៀនបកប្រែទូរលេខចប់ សេង ត្រូវបានអង្គការឲ្យ ទៅធ្វើការនៅរោងពុម្ពរបស់ មន្ទីរ៤០១ ។ សេង ធ្វើជាគ្រូ បង្រៀនអក្សរ, បកប្រែទូរលេខ, វាយអង្គុលីលេខ និងបង្រៀន ពីរបៀបអូសម៉ាស៊ីនបោះពុម្ព ។ សៀវភៅដែលបោះពុម្ពនៅ ពេលនោះគឺទស្សនាវដ្តីយុវជនយុវនារីបដិវត្តន៍ ។ ក្រុមទស្សនាវដ្តី ដែល សេង ធ្វើការជាមួយមានឈ្មោះ ប៉េន ជាអ្នកគូររូបភាព, ប៉ន មានអក្សរស្អាត ជាអ្នកសរសេរ តាអ៊ុយជាអ្នកកាត់ត ។ ដំណឹងដែលចុះក្នុងទស្សនាវដ្តីគឺអំពីសកម្មភាពការងាររបស់យុវជន យុវនារីនៅភូមិភាគ និងឯកសារផ្ញើមកពីមជ្ឈិម ។ ក្រៅពីការងារ ទាំងនោះ សេង ក៏មាននាទីព្យាបាលជំងឺឲ្យកម្មាភិបាលនៅក្នុងភូមិ ភាគនេះដែរ ។

នៅក្នុងឆ្នាំ១៩៧៦ សេង បានទៅខេត្តកំពង់ឆ្នាំងជាមួយ ដូ ជេត រយៈកន្លះខែដើម្បីចូលរួមប្រជុំជាមួយមជ្ឈិម ។ បន្ទាប់ពី ថ្លែងសុន្ទរកថានៅក្នុងសន្និបាត ប៉ុល ពត បានហៅ សេង ពិនិត្យ ជំងឺឲ្យគាត់ ។ បន្ទាប់ពីពិនិត្យរួច សេង ប្រាប់ ប៉ុល ពត ថា គ្មានជំងឺ អ្វីទេគ្រាន់តែអស់កម្លាំងដោយសារនិយាយច្រើនពេក និងបណ្តាល មកពីមិនដែលធ្វើពលកម្មឲ្យបែកញើស ។ ព្រោះដូច្នេះ ប៉ុល ពត ប្រឡោតឡើងថា «ពេទ្យហ្នឹងមកពីណា បានតែបាញ់ចោល ក្លាហាន ម្ល៉េះ? ។ ព្រោះដូច្នេះ ដូ ជេត បានឆ្លើយកាត់ឡើងថាជាក្មួយរបស់ គាត់ ។

ដើមឆ្នាំ១៩៧៨ បក្សបានផ្ញើទូរលេខ បញ្ជាឲ្យថ្នាក់ក្រោម ចាប់មនុស្សទាំងអស់ដែលធ្វើការនៅមន្ទីរ៤០១ ហើយដែល មានអាយុចាប់ពី៦ឆ្នាំឡើងទៅ ។ ដូច្នេះ ដូជេត និងមនុស្ស ជាច្រើនទៀតត្រូវអង្គការចាប់ខ្លួនបញ្ជូនទៅដាក់គុកទួលស្លែង គុកលង្វែក គុកភ្នំប្រសិទ្ធិ មួយចំនួនទៀតត្រូវយកទៅកម្ទេច ចោល ។ ប្រពន្ធរបស់ ដូ ជេត ឈ្មោះ យាយលី ដែលជាគណៈ ស្រុកខត្តផ្គក៏ត្រូវចាប់បញ្ជូនមកគុកទួលស្លែងដែរ ។ សេង ភិតភ័យ និងប្រហូកប្រហល់ក្នុងចិត្តជាខ្លាំង ។ គាត់ដេកមិនលក់ បក់មិនល្ហើយ គ្មានសង្ឃឹមថាបានរស់ទេ ពីព្រោះគាត់ជាខ្សែរបស់ដូជេតនិង យាយលីដែរ ។ សេង និយាយថា ពេលដែលកងឈ្លបភ្ជង់ យាយលី ហើយទាញកន្ត្រាក់ក្រមាចេញពីករបស់គាត់ យាយលី គ្មានប្រតិកម្ម អ្វីទាំងអស់ ។ គាត់គ្រាន់តែនិយាយថា «ខ្ញុំដឹងហើយថាប្តីរបស់ខ្ញុំ ក្បត់បក្ស» ។ ដោយសារភ័យខ្លាចខ្លាំងពេក សាច់ញាតិមួយចំនួន របស់ ដូជេត និងយាយលី បានលេបថ្នាំសម្លាប់ខ្លួន ។

បន្ទាប់ពីចាប់ ដូ ជេត បានមួយថ្ងៃ តាម៉ុក បានមកមន្ទីរ ៤០១ ជាមួយនិរសារជាច្រើននាក់ ។ មកដល់ភ្លាម តាម៉ុក ចោទ សេង ថាបានរួមដៃជាមួយ ដូ ជេត លាក់ថ្នាំពុលទុកដើម្បីបំពុល គាត់ និងបានចោទ សេង ថាជា «ប្រពន្ធចុងរបស់ដូជេត» ។ សេង បានប្រកែក ប៉ុន្តែ តាម៉ុក គំហកថា «នៅជាមួយអាក្បត់យូរចេះ តមាត់ជងឬ?» ។ តាម៉ុក បម្រុងចាប់ខ្លួន សេង ប៉ុន្តែ តាប៉ាល់ និង តាសឿង ដែលជាប្រធានកងពលទី១ប្រចាំភូមិភាគបស្ចិម បានតេអូមកប្រាប់ តាម៉ុក មិនឲ្យចាប់ខ្លួន សេង ទេ ទុកសម្រាប់ បកប្រែទូរលេខ ពីព្រោះនៅមន្ទីរ៤០១ពុំមានអ្នកណាចេះបកប្រែ ទូរលេខទេ ។ ដូច្នេះ សេង ក៏មានជីវិតរស់និងបន្តការងារបកប្រែ ទូរលេខនៅមន្ទីរ៤១០ ដដែល ។

ពីរបីខែក្រោយមក សេង បានសុំ តាប៉ាល់ ទៅបកប្រែ ទូរលេខនៅមន្ទីរលង្វែកវិញ ។ តាប៉ាល់ ក៏យល់ព្រមតាមសំណើ ហើយគាត់បានផ្តាំផ្ញើ សំណាង ដែលជាអ្នកគ្រប់គ្រងមន្ទីរ ឲ្យជួយមើលការខុសត្រូវ សេង ផង ។ ធ្វើការនៅមន្ទីរនេះ សេង ពុំសូវហ៊ានចេញដើរផ្តេសផ្តាសទេ គាត់ខ្លាចអង្គការថ្នាក់លើខាងលើ ឃើញចាប់គាត់ទៅដាក់គុក ។ ថ្ងៃមួយ បូរាណ ដែលជាកូនប្រសា របស់ តាម៉ុក បានមកមន្ទីរលង្វែក ឃើញ សេង ធ្វើការនៅទីនោះ ក៏ចោទ សេង ថា ជាបក្សពួកក្បត់មកសម្ងំធ្វើធំនៅទីនេះយូរហើយ ដូច្នេះត្រូវចាប់ខ្លួន ។ ទោះបីជា សំណាង ធានា អះអាងយ៉ាងណា ក៏ដោយ ក៏ បូរាណ មិនយល់ព្រម ហើយដែលបានបញ្ជូន សេង មកមន្ទីរអប់រំនៅស្វាគូជាបន្ទាន់ ។

នៅឆ្នាំខែមករា ឆ្នាំ១៩៧៩ នៅពេលដែល សេង និងក្រុម

អ្នកទោសកំពុងតែប្រូតស្រូវ ស្រាប់តែមានរថយន្តដឹកកងទ័ពវៀតណាមនិងកងទ័ពខ្មែរជាច្រើនបើកសំដៅទៅការដ្ឋាន ហើយបានស្រែកប្រាប់អ្នកទោសទាំងអស់ឲ្យវិលត្រឡប់ទៅស្រុកកំណើតវិញ ។ សេង បានត្រឡប់មកជួបជុំឪពុកម្ដាយ នៅឃុំដាងទង ដោយសុវត្ថិភាព ។ រយៈពេលជិត១០ឆ្នាំដែល សេង មិនបានជួបឪពុកម្ដាយទាល់តែសោះ បានធ្វើឲ្យអ្នកទាំងនោះនឹករឭកគ្នាខ្លាំងណាស់ ។

អ្វីដែលធ្វើឲ្យ សេង នៅតែអាក់អន់ស្រពន់ចិត្តនោះគឺថា គាត់ស្មោះត្រង់និងតស៊ូឆ្លងកាត់គ្រប់ឧបសគ្គដើម្បីបម្រើខ្មែរក្រហម ប៉ុន្តែទីបំផុតគាត់បានទទួលផលតបស្នងមកវិញត្រឹមតែការចាប់គាត់យកទៅដាក់គុកប៉ុណ្ណោះ ។

**អ៊ែម សុខឃីម**

# ការវិវត្តថ្មីៗនៃដំណើរការបង្កើតតុលាការខ្មែរក្រហម

ច្បាប់វិសោធនកម្មច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យត្រូវបានអនុម័តដោយរដ្ឋសភាជាតិកម្ពុជាកាលពីថ្ងៃទី៥ ខែតុលា ឆ្នាំ២០០៤ ហើយបីថ្ងៃបន្ទាប់ គឺថ្ងៃទី៨ ព្រឹទ្ធសភាកម្ពុជាក៏បានផ្ដល់សេចក្ដីអនុម័តលើច្បាប់នេះ ។ នៅថ្ងៃទី២៧ ខែតុលា ច្បាប់បង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលបានធ្វើវិសោធនកម្មរួចហើយ ក៏ត្រូវបានប្រកាសឲ្យប្រើប្រាស់ជាផ្លូវការដោយសម្ដេច ជា ស៊ីម ប្រមុខរដ្ឋស្ដីទីនៃព្រះរាជាណាចក្រកម្ពុជា ។

ភ្លាមៗបន្ទាប់ពីការអនុម័តនេះ រាជរដ្ឋាភិបាលកម្ពុជាបានជូនដំណឹងដល់អគ្គលេខាធិការអង្គការសហប្រជាជាតិ កូហ្វី អាណាន់ ហើយនៅថ្ងៃទី១៩ ខែតុលា រាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់សច្ចាប័នលើកិច្ចព្រមព្រៀងជាមួយអង្គការសហប្រជាជាតិ ។ ឥឡូវនេះ រាជរដ្ឋាភិបាលកម្ពុជាកំពុងតែរង់ចាំគណៈប្រតិភូរបស់អង្គការសហប្រជាជាតិមកពិភាក្សាអំពីគម្រោងថវិកានិងពិភាក្សាលម្អិតអំពីបញ្ហាសន្តិសុខនៅក្នុងតុលាការ ។

នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជាបានចេញសេចក្ដីប្រកាសព័ត៌មានមួយបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាបានបំពេញកាតព្វកិច្ចផ្លូវច្បាប់របស់ខ្លួនរួចរាល់ហើយ ហើយសង្ឃឹមថា អង្គការសហប្រជាជាតិនឹងបំពេញកាតព្វកិច្ចរបស់ខ្លួននៅក្នុងដំណាក់កាលសំខាន់បន្តទៀត ។

ដំណាក់កាលសំខាន់ដែលលើកឡើងនៅក្នុងសេចក្ដីប្រកាសព័ត៌មានខាងលើ គឺការរៃអង្គាសថវិកាពីបណ្ដាប្រទេសនានាដែលចាប់អារម្មណ៍ក្នុងការឧបត្ថម្ភដំណើរការសាលាក្ដីខ្មែរក្រហម ។

គួររំឭកថា ច្បាប់ស្ដីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដើម្បីកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមត្រូវបានបង្កើតនៅឆ្នាំ២០០១ តាមការព្រមព្រៀងរបស់រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ក៏ប៉ុន្តែនៅខែកុម្ភៈ ឆ្នាំ២០០២ អង្គការសហប្រជាជាតិបានដកខ្លួនចេញពីដំណើរការនេះដោយសំអាងហេតុផលថា តុលាការខ្មែរក្រហមដែលបង្កើតដោយរាជរដ្ឋាភិបាលកម្ពុជា នឹងមិនធានាបាននូវឯករាជ្យ តម្លាភាព និងបទដ្ឋានយុត្តិធម៌ទេ ។ ភាគីទាំងពីរបានឈានដល់ការព្រមព្រៀងជាថ្មីម្ដងទៀតនៅខែមិថុនា ឆ្នាំ២០០៣ បន្ទាប់ពីរាជរដ្ឋាភិបាលកម្ពុជាយល់ព្រមធ្វើវិសោធនកម្មមាត្រាមួយចំនួននៅក្នុងច្បាប់នេះដើម្បីឲ្យមានតុល្យភាព ។ ការធ្វើវិសោធនកម្មនេះរួមមានអំពីលំដាប់ថ្នាក់តុលាការនិងអំពីចំនួនចៅក្រមនិងព្រះរាជអាជ្ញា ។

ក្នុងពេលដ៏ឆាប់ខាងមុខនេះ តុលាការខ្មែរក្រហមនឹងចេញជារូបរាង ហើយយើងរំពឹងថា មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមួយចំនួននឹងត្រូវប្រឈមមុខនឹងតុលាការនេះ ។

**សង្ខេបដោយសាន់ កល្យាណ**

# ការប្រល័យពូជសាសន៍ខ្លួនឯង

នៅក្នុងការត្រួតពិនិត្យមើលសៀវភៅរបស់ ស៊ូហ្សាណា លីនតុន, លោកបណ្ឌិត អេនឌ្រូ វីដបឺ បានប្រើពាក្យ "ការប្រល័យពូជសាសន៍ខ្លួនឯង" ។ ជាការពិតណាស់ ពាក្យនេះត្រូវបានប្រើច្រើនលើកច្រើនសាដើម្បីពិពណ៌នាអំពីសកម្មភាពរបស់របបខ្មែរ-ក្រហម ក៏ប៉ុន្តែនៅពេលដែលខ្ញុំយល់ដឹងកាន់តែច្រើនអំពីរបៀបដែលខ្មែរក្រហមសម្រេចបាននិងរក្សាបាននូវអំណាចរបស់ខ្លួន ខ្ញុំស្អប់ពាក្យនេះកាន់តែខ្លាំងឡើង ។ គ្មានពាក្យ "ខ្លួនឯង" នៅក្នុងការសម្លាប់រង្គាលដែលបានកើតឡើងនៅក្រោមរបបខ្មែរក្រហមនោះទេ ។ តើយើងអាចនិយាយអំពីបដិវត្តន៍វប្បធម៌ ម៉ៅ របស់ប្រទេសចិនថាជា "ការប្រល័យពូជសាសន៍ខ្លួនឯង" បានដែរឬទេ? តើយើងអាចនិយាយអំពីការកម្ចាត់ចោលរបស់ ស្តាលីន ថាជា "ការប្រល័យពូជសាសន៍ឯង" បានដែរឬទេ? ហេតុអ្វីក៏មិនអាចនិយាយបាន? ខ្ញុំគិតថាប្រហែលពាក្យ "ការប្រល័យពូជសាសន៍ខ្លួនឯង" ដ៏គួរឲ្យអស់សំណើចនេះ ត្រូវបានប្រើប្រាស់ដោយសារហេតុផលយ៉ាងសាមញ្ញថា អ្នកអង្កេតពីខាងក្រៅទៅលើសង្គ្រាមស៊ីវិលកម្ពុជាដែលសាទរចំពោះខ្មែរក្រហមថាជា "អ្នករំដោះជាតិ" បានបដិសេធមិនព្រមទទួលថាអំពើសម្លាប់រង្គាលដែលប្រព្រឹត្តដោយខ្មែរក្រហមគឺជាអ្វីដែលនឹងកើតឡើងយ៉ាងពិតប្រាកដនិងដែលកុម្មុយនិស្តធ្វើជាទូទៅដើម្បីទទួលនិងរក្សាអំណាច ។ ឧក្រិដ្ឋកម្មទាំងអស់នេះ គឺជាលទ្ធផលសមហេតុផលមួយរបស់ផែនការបែបនេះ និងមិនត្រឹមតែកើតឡើងប៉ុណ្ណោះទេ ។ ខ្ញុំគិតថា កិច្ចខិតខំប្រឹងប្រែងប្រកបដោយមនសិការគួរតែធ្វើឡើងដើម្បីលុបបំបាត់ពាក្យនេះ ។ ពាក្យនេះគ្រាន់តែជាពាក្យធ្វើឲ្យមានមន្ទិលសង្ស័យនិងពិបាកយល់តែប៉ុណ្ណោះ ។

**រ៉េម៉ិន ចូហាន់សេន**

## សេចក្តីប្រកាសពត៌មានរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា

កាលពីថ្ងៃទី៤ ខែតុលា ឆ្នាំ២០០៤ សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានផ្ញើលិខិតមួយច្បាប់ទៅឯកឧត្តម កូហ្វី អាណាន់ អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ អំពីសេចក្តីអនុម័តជាឯកច្ឆ័ន្ទរបស់រដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា ទៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។

ក្នុងគោលបំណងបង្កើនល្បឿននៃការបង្កើតតុលាការនេះ សម្តេច ហ៊ុន សែន បានសំណូមពរឲ្យលោកអគ្គលេខាធិការអង្គការសហប្រជាជាតិអំពាវនាវរកជំនួយថវិកាពីបណ្តាប្រទេសនានាដែលចង់ឧបត្ថម្ភដល់ដំណើរការតុលាការខ្មែរក្រហម ។

នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៤ ឯកឧត្តម ហោ ណាំហុង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បានផ្ញើឯកសារស្តីអំពីការអនុម័តកិច្ចព្រមព្រៀងដែលបាននិយាយខាងលើនេះជូនទៅលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

ដូច្នេះរាជរដ្ឋាភិបាលកម្ពុជាបានបំពេញកាតព្វកិច្ចផ្លូវច្បាប់រួចរាល់ហើយ និងសង្ឃឹមថា អង្គការសហប្រជាជាតិនឹងបំពេញតួនាទីរបស់ខ្លួននៅក្នុងដំណាក់កាលសំខាន់នៃដំណើរការនេះ ដើម្បី ឲ្យតុលាការខ្មែរក្រហមចេញបានឆាប់រហ័ស ។

ភ្នំពេញ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០០៤



*សុក វីម ក្នុងឱកាសជូនដំណើរទស្សនកិច្ចរបស់គណៈប្រតិភូស៊ុយអែដចំនួនបួនរូប (1. Gunnar Bergstrom, 2. Hedda Ekerwald, 3. Jan Myrdal, 4. Marita Wikander) ឆ្នាំ១៩៧៨ ។*



# តុលាការអន្តរជាតិលាតត្រដាងអំពីការកាត់ទោសដំបូងចំនួនបីនៅក្នុង "តុលាការពិសេសសម្រាប់ការរំលោភសិទ្ធិមនុស្សនៅទីម័រខាងកើត"

***(តមកពីលេខ៥៧)***

*ការិយាល័យ UNAMET នៅទូទាំងទីម័រខាងកើតបានទទួលរងការបំផ្លិចបំផ្លាញ ហើយបុគ្គលិកមួយចំនួនត្រូវសម្លាប់ ប៉ុន្តែមានតែការវាយប្រហារទៅលើការិយាល័យ UNAMET នៅលីគីកាតែមួយប៉ុណ្ណោះដែលត្រូវបានលើកយកមកចោទប្រកាន់ ហើយការចោទប្រកាន់នោះទៀតសោតធ្វើឡើងតែអំពីបទវាយប្រហារដែលតាមពិតគ្មានការបង្ហាញភស្តុតាងអំពីទមបទ្ទរហេតុនេះនៅក្នុងអង្គជំនុំជម្រះក្តីទាល់តែសោះ ។*

*វាមានតម្លៃតិចតួចណាស់នៅក្នុងដីកាចោទដែលឆ្លុះបញ្ចាំងក្នុងការរកឃើញរបស់ខេភីភីហាំ ឬក៏ទីភ្នាក់ងាររស៊ើបអង្កេតរបស់អង្គការសហប្រជាជាតិចំនួនពីរទៀត អំពីការជាប់ពាក់ព័ន្ធយ៉ាងធំធេងរបស់អាជ្ញាធរឥណ្ឌូនេស៊ីនៅក្នុងការបង្កើតហ្វឹកហ្វឺននិងបំពាក់អាវុធឲ្យកងជីវពលទីម័រខាងកើត ព្រមទាំងការប៉ុនប៉ងជំទាស់លទ្ធផលនៃការធ្វើប្រជាមតិ និងការរៀបចំគម្រោង ឬអនុវត្តគោលនយោបាយឆេះដី ការជម្លៀសប្រជាជនក្នុងទ្រង់ទ្រាយធំ និងការវាយប្រហារយ៉ាងធំសម្បើមប្រឆាំងជនស៊ីវិល ។ អតីតអភិបាលកោះទីម័រខាងកើតឈ្មោះ អាប៊ីលីអូ ស័ររ៉េ ជាអ្នកដែលទទួលខុសត្រូវចំពោះកំហុសនិងសកម្មភាពរបស់អ្នកនៅក្រោមបង្គាប់របស់គាត់ ពោលគឺអភិបាលស្តីទីទាំងពីរ លីអូណេតូ ម៉ាទីន នៅលីគីកា, ហ៊ឺម៉ាន សេដូណូ នៅកូវ៉ាលីមា និង អ៊ីរីកូ គូតេរេស ដែលជាមេបញ្ជាការរងកងជីវពលភីភីអាយ ។ អាប៊ីលីអូ ស័ររ៉េ ថែមទាំងទទួលខុសត្រូវចំពោះសកម្មភាពរបស់អង្គការប៉ាមវ៉ាកាសា ។ ការចោទប្រកាន់បានបន្តថា អាប៊ីលីអូ ស័ររ៉េ មានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះអំពើរបស់អ្នកក្រោមបង្គាប់គាត់ ពីព្រោះថាគាត់បានដឹងឬមានចេតនាមិនអើពើចំពោះព័ត៌មានដែលបង្ហាញយ៉ាងច្បាស់ថាអ្នកក្រោមបង្គាប់គាត់កំពុងតែប្រព្រឹត្ត ឬទើបតែបានប្រព្រឹត្តឧក្រិដ្ឋកម្ម ។ ការចោទប្រកាន់បានបន្តទៀតថា ប៉ុន្តែទោះបីជាអាប៊ីលីអូ ស័ររ៉េ មិនបានបញ្ជាឲ្យអ្នកក្រោមបង្គាប់គាត់ធ្វើដូច្នោះ ប៉ុន្តែគាត់មិនបានសហការជាមួយកងកម្លាំងសន្តិសុខដើម្បីរារាំង ឬបញ្ឈប់សកម្មភាពរបស់អ្នកក្រោមបង្គាប់គាត់ ឬមិនបានប្រគល់ជនដៃដល់ទៅឲ្យអាជ្ញាធរស្របច្បាប់ស៊ើបអង្កេត ចោទប្រកាន់ និងដាក់ទណ្ឌកម្មឡើយ ។ ផ្ទុយទៅវិញ តុលាការមិនបានចោទប្រកាន់ អាប៊ីលីអូ ស័ររ៉េ អំពីករណីទាំងអស់នេះទេ ។ ប្រការនេះគួរឲ្យកត់សម្គាល់ណាស់ ព្រោះថា ដីកាចោទប្រកាន់បានសរសេរបែបផាយៗថា អាប៊ីលីអូ ស័ររ៉េ បានជួបជាមួយអភិបាលស្តីទីរបស់គាត់ដើម្បីបង្គាប់បញ្ជាឲ្យអ្នកទាំងអស់នេះចាត់ការ "តាមគ្រប់លទ្ធភាពទាំងអស់" ដើម្បីបង្កើតអង្គការនយោបាយក្នុងន័យជំរុញឲ្យមានការចូលរួមពីសំណាក់ក្រុមគាំទ្រស្វ័យភាពនៅក្នុងការធ្វើប្រជាមតិ និងដើម្បីបង្កើតក្រុមសន្តិសុខប៉ាមវ៉ាកាសាដែលទទួលបានការអនុញ្ញាតតាមផ្លូវច្បាប់ ។ ជាលទ្ធផល ដីកាបានចោទប្រកាន់ថា អភិបាលស្តីទីបានផ្តល់មូលនិធិឲ្យបង្កើតប៉ាមវ៉ាកាសានៅថ្នាក់ស្រុក ។ ដីកានេះស្រាលខ្លាំងណាស់បើធៀបទៅនឹងអ្វីដែលនិយាយថា លោកអភិបាលបានផ្តល់មូលនិធិនិងគាំទ្រដោយផ្ទាល់ចំពោះក្រុមជីវពលឲ្យប្រព្រឹត្តអំពើហិង្សាទូទាំងខេត្តដើម្បីគំរាមកំហែងអ្នកគាំទ្រឯករាជ្យភាព និងទាត់ចោលលទ្ធផលនៃការធ្វើប្រជាមតិ ។ កិច្ចប្រជុំរវាងលោកអភិបាលនិងអ្នកដែលមានមុខតំណែងសំខាន់ៗនៅទីម័រខាងកើត អាចនឹងត្រូវបានលើកយកមកធ្វើជាភស្តុតាងនៃការរៀបចំគម្រោងរួម ឬការសមគំនិតដើម្បីចាត់វិធានការនានាទាំងស្របច្បាប់និងមិនស្របច្បាប់ដើម្បីធានាថាក្រុមគាំទ្រស្វ័យភាពពិតជាឈ្នះការធ្វើប្រជាមតិ និងដើម្បីរៀបចំវិធានការទប់ស្កាត់នានាក្នុងករណីដែលក្រុមនេះចាញ់ ។*

*វាគួរឲ្យសង្ស័យខ្លាំងណាស់ដែលមានកិច្ចប្រជុំសំខាន់ៗជាច្រើនរវាងអ្នកដើរតួនាទីជាគន្លឹះក្នុងតំបន់ (ដូចជា ធីអិនអាយ ក្រុមប៉ូលិស មន្ត្រីរាជការ និងកងជីវពល) នៅមុនពេលមានការ*

វាយប្រហារធ្ងន់ធ្ងរនៅឯព្រះវិហារលីគ្វីកានិងព្រះវិហារស្វួយ ក៏ប៉ុន្តែដីកាចោទមិនបានចាត់ទុកជំនួបប្រជុំទាំងនេះជាបញ្ហាស្នូលទេ ។ តាមការពិត កសិណសាក្សីដែលនៅក្នុងសំណុំឯកសារចោទប្រកាន់បានលាតត្រដាងឲ្យឃើញថា មេដឹកនាំយោធាកំពូលៗ (រាប់បញ្ចូលទាំងកងកម្លាំងពិសេសរបស់ធីអិនអាយ) និងថ្នាក់ដឹកនាំប៉ូលិស មានវត្តមាននៅលីគ្វីកាក្នុងថ្ងៃដែលមានការវាយប្រហារ ហើយមេបញ្ជាការរងយោធាទីម័រខាងកើតមានវត្តមាននៅក្នុងការិយាល័យធីអិនអាយថ្នាក់ស្រុកក្នុងអំឡុងពេលមានការសម្លាប់រង្គាល ។ នៅក្នុងរឿងក្តីប្រឆាំងនឹងអភិបាលក៏ដូចជាមេប៉ូលិសទីម័រខាងកើត មិនបានបញ្ចូលភស្តុតាងទាំងនេះទេ ។ អ្វីដែលយកមកប្រើប្រាស់នោះគឺគ្រាន់តែមានលក្ខណៈជាទម្រង់បទឧក្រិដ្ឋកម្មមិនផ្ទាល់ ពោលគឺបរាជ័យក្នុងការគ្រប់គ្រងអ្នកក្រោមបង្គាប់ ។ លោកអភិបាលមិនត្រូវបានចោទប្រកាន់ពីបទប៉ុនប៉ង រៀបចំផែនការបញ្ជា ឬជួយឧបត្ថម្ភ ការប្រព្រឹត្តបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

ដីកាចោទ អាប៊ីលីអូ ស័ររ៉េ ក៏មានភាពស្រពេចស្រពិលដែរ ។ ដីកានេះបានអះអាងថា អតីតអភិបាលបានទទួលព័ត៌មានគ្រប់គ្រាន់ដែលបានបង្ហាញយ៉ាងច្បាស់ថាអ្នកក្រោមបង្គាប់របស់គាត់ ពោលគឺអភិបាលស្តីទីនៅលីគ្វីកានិង ស្វួយ ព្រមទាំង អឺរីកូ គូតេរ៉េស ដែលជាមេបញ្ជាការរងរបស់ ភីភីអាយ និងអង្គភាពក្រោមឱវាទរបស់អ្នកទាំងបី កំពុងតែប្រព្រឹត្តឬបានប្រព្រឹត្តការរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ និងបង្ហាញថា អតីតអភិបាលនេះខកខានមិនបានចាត់វិធានការចាំបាច់ដើម្បីទប់ស្កាត់និងបញ្ឈប់ការរំលោភនេះទេ ។ ដីកាចោទមិនបានហៅអភិបាលរូបនេះថាជាមេគំនិតនៅក្នុងអំពើឃោរឃៅទេ ប៉ុន្តែបែរហៅថាជាអ្នកគ្រប់គ្រងដែលមិនយកចិត្តទុកដាក់ទៅវិញ ។ ការចោទប្រកាន់មិនបានបែងចែកឲ្យច្បាស់អំពីការទទួលខុសត្រូវ និងមិនបានបង្ហាញថាតើអាជ្ញាធរស៊ីវិលរបស់ទីម័រខាងកើតទទួលខុសត្រូវរបៀបណាចំពោះបញ្ហាច្បាប់និងសណ្តាប់ធ្នាប់ដែលតាមពិតស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រុមប៉ូលិសនោះ ព្រមទាំងមិនបានលើកអំពីបញ្ហាសន្តិសុខដែលជាការទទួលខុសត្រូវរបស់ធីអិនអាយ ។ ដីកាចោទបានបង្ហាញទៀតថា ឧបទ្ទវហេតុទាំងអស់នោះកើតឡើងដាច់ដោយឡែកពីគ្នា ហើយវាផ្ទុះឡើងដោយឯកឯងចេញពីការប្រយុទ្ធគ្នារវាងប្រជាជនទីម័រខាងកើត ។ មានតែហេតុការណ៍នៅលីគ្វីកាទេ ទើបមានការចូលរួមរបស់កងកម្លាំងសន្តិសុខ ។ នេះជាការបង្ហាញឲ្យឃើញសកម្មភាពបន្តិចបន្តួច ជាជាងបង្ហាញលទ្ធផលនៃការបង្គាប់បញ្ជា ។ តាមពិតគ្មានការពិពណ៌នាគាំទ្រដល់ការចោទប្រកាន់ដែលថាអ្នកក្រោមបង្គាប់របស់ជនជាប់ចោទបានចូលរួមនៅក្នុងការវាយប្រហារបែបប្រព័ន្ធទៅលើប្រជាជនស៊ីវិលនោះឡើយ ។ ការអះអាងដែលថាអ្នកទាំងប៉ុន្មាននាក់នោះមានចំណែកនៅក្នុងឧបទ្ទវហេតុ ហាក់ដូចជាស្រពេចស្រពិល ។ បើពិនិត្យទៅការចោទប្រកាន់ លោកអភិបាលហាក់នាំឲ្យយើងគិតថារឿងក្តីនេះគឺអ្នកក្រោមបង្គាប់បានធ្វើផ្ទុយបទបញ្ជា ។ ផ្ទុយទៅវិញ វាមិនប្រាកដទេថាតើអភិបាលស្តីទីបានប្រព្រឹត្តស្របឬផ្ទុយទៅនឹងបទបញ្ជានោះ ។ ក្នុងករណីសម្លាប់រង្គាលនៅវិហារលីគ្វីកា អភិបាលស្តីទី លីអូណេតូ ម៉ាទីន ភិតភ័យរហូតដល់មិនហ៊ានចូលខ្លួនទៅដោះស្រាយបញ្ហាច្របូកច្របល់ដែលចេះតែកើតមានជាបន្តបន្ទាប់នៅឯព្រះវិហារ ។ ដីកាចោទនេះមិនបានបង្ហាញអ្វីផ្សេងក្រៅតែអំពីឥរិយាបថដ៏កំសាកនេះទេ ។ ផ្ទុយទៅវិញ ដីកាចោទដែលធ្វើឡើងដោយអគ្គរដ្ឋអាជ្ញារងរបស់ UNAMET បានដាក់អភិបាលស្តីទីរូបនេះនៅចំកណ្តាលកងជីវពល បេស៊ី ម៉េរា ពូទី (BMP) ហើយសក្ខីកម្មដែលបានមកពីអ្នកទោសឧក្រិដ្ឋដទៃទៀត ក៏បានបង្ហាញថាអភិបាលស្តីទីរូបនេះមានចំណែកក្នុងការដឹកនាំប្រតិបត្តិការនានាក្នុងអំឡុងមានការវាយប្រហារនៅវិហារស្វួយដែរ ។ ដូច្នេះវាមិនប្រាកដទេថាតើហេតុអ្វីបានជាភាពកំសាករបស់អ្នកក្រោមបង្គាប់អាចធ្វើឲ្យអភិបាលមានកំហុសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ករណីវិហារ ស្វួយ ដីកាចោទប្រកាន់បានបង្ហាញថា អភិបាលស្តីទី ហឺម៉ាន មិនបានធ្វើអ្វីមួយដើម្បីជួយនាំមនុស្សចេញនៅពេលដែលគាត់បានធ្វើដំណើរចុះទៅដល់វាលពិឃាតនៅក្នុងព្រះវិហារ ទោះបីជាដីកានេះបានចោទថា គាត់មានកំហុសពីបទបង្កបង្កើតកងជីវពលនៅស្វួយតាមបញ្ជារបស់អភិបាលក៏ដោយ ។ ផ្ទុយទៅវិញ របាយការណ៍របស់ខេភីភីហាំបានចាត់ទុកថា អភិបាលស្តីទី ហ៊ឺម៉ាន

បានដឹកនាំការវាយប្រហារយ៉ាងខ្លាំងក្លា ទៅលើជនស៊ីវិលនៅឯព្រះវិហារ ។ ដីកានេះក៏មិនបានបង្ហាញឲ្យឃើញពីការចោទប្រកាន់ដែលថាលោកអភិបាលបានដឹងឬគួរតែបានដឹងពីអំពើអាក្រក់របស់អភិបាលស្តីទី ហ៊ីម៉ាន នៅកូវ៉ាលីម៉ា ទេ ។ តាមពិតលោកអភិបាលបានស្ថិតនៅភាគម្ខាងទៀតនៅទីម័រខាងកើតក្នុងទីក្រុងឌីលីក្នុងខណៈពេលដែលទឹកដីនេះកំពុងតែធ្លាក់សន្សឹមៗ ទៅក្នុងភាពចលាចល ហើយរដ្ឋបាលរបស់គាត់បានបែកខ្ញែក ដោយសារតែហេតុការណ៍នេះ ។ ខ្សែទូរស័ព្ទកប់ដីត្រូវបានកាត់ផ្តាច់រួចទៅហើយកាលពីថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៩៩ ។ តាមពិតទៅ វានៅតែស្រពេចស្រពិលអំពីអ្វីដែលគាត់បានធ្វើ ទោះជាគាត់បានដឹងថាអ្នកក្រោមបង្គាប់របស់គាត់បានជាប់ពាក់ព័ន្ធទៅនឹងអំពើឧក្រិដ្ឋដ៏ធ្ងន់ធ្ងរ ហើយគាត់មានសុឆន្ទៈដើម្បីធ្វើអ្វីម្យ៉ាងអំពីរឿងនេះ ។ សម្តីរបស់ អឺរីកូ គូតេរ៉េស នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៩ ដែលញុះញង់ឲ្យមានការប្រមូលផ្តុំអ្នកគាំទ្រស្វ័យភាព ត្រូវបានដកស្រង់មកដាក់នៅក្នុងដីកាចោទនេះ ប៉ុន្តែមិនបាននិយាយអំពីតួនាទីរបស់អតីតអភិបាលនៅក្នុងការវាយប្រហារនេះទេ សូម្បីតែទាក់ទងទៅនឹងការបញ្ជា ការជួយឧបត្ថមគាំទ្រ ការចូលរួមដោយផ្ទាល់ ឬបង្ហាញថាអ្នកវាយប្រហារគឺពិតជាមនុស្សស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ក៏គ្មានដែរ ។ នៅឯការជួបប្រជុំមួយនាថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៩ គូតេរ៉េស បានគំរាមកំហែងអំពី "សមុទ្រឈាម" មួយដែលនឹងកើតឡើងប្រសិនបើប្រព័ន្ធឃោសនារាយការណ៍ថាក្រុមគាំទ្រឯករាជ្យពិតជាឈ្នះ ។ ក៏ប៉ុន្តែ ការចោទប្រកាន់មិនបានភ្ជាប់សម្តីនេះទៅនឹងអំពើហិង្សាដែលបានកើតឡើងឡើយ ។ ដីកាចោទក៏មិនច្បាស់ថាតើមេដឹកនាំកងជីវពលរូបនេះគួរតែនៅក្រោមបង្គាប់របស់អភិបាលទីម័រខាងកើតដែរឬទេ ។

ដីកាចោទ ធីមប៊ុល ស៊ីឡែន លើកឡើងដដែលៗនូវពាក្យមួយឃ្លាថា ជម្លោះរវាងក្រុមគាំទ្រស្វ័យភាពនិងក្រុមប្រឆាំងស្វ័យភាពបានកើតមានឡើងដោយគ្មានការទប់ស្កាត់របស់អាជ្ញាធរសន្តិសុខ ហើយក្បាលម៉ាស៊ីនសន្តិសុខក៏មិនបានចាត់វិធានការដើម្បីរឹបអូសយកអាវុធដែលប្រើប្រាស់នៅក្នុងជម្លោះនោះដែរ ។ អាជ្ញាចោទហាក់ដូចជាមិនចាប់អារម្មណ៍ចំពោះភាពផ្ទុយគ្នារវាងការចោទប្រកាន់នេះជាមួយនឹងការចោទប្រកាន់សំខាន់ៗ ផ្សេងទៀតដែលមានមុនមក ពោលគឺថាមានការវាយប្រហារពាលដាលនិងតាមបែបជាប្រព័ន្ធទៅលើប្រជាជនស៊ីវិលដែលប្រព្រឹត្តឡើងដោយអ្នកដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ជនជាប់ចោទ ។ នៅក្នុងហេតុការណ៍ខ្លះ គ្មានការចោទប្រកាន់ណាមួយបង្ហាញឲ្យបានគ្រប់គ្រាន់តាមរយៈបទបញ្ញត្តិនៃព័ត៌មានពិស្តារស្តីពីការប្រព្រឹត្តខុសរបស់ប៉ូលិសឡើយ ។ ការពិពណ៌នាពីការសម្លាប់រង្គាលនៅលីគ្វីកា គឺជាទីកន្លែងតែមួយគត់ដែលមានការចោទប្រកាន់ពីបទចូលរួមដោយផ្ទាល់របស់ប៉ូលិស ។ បណ្តឹងមូលដ្ឋានទាក់ទងទៅនឹងលីគ្វីកាគឺថា គ្មានការប៉ុនប៉ងទប់ស្កាត់ឬបញ្ឈប់ការវាយប្រហារ ឬដកហូតអាវុធពីភាគីជម្លោះឡើយ ។ ដីកាចោទបានបន្តបង្ហាញឧទាហរណ៍ផ្សេងៗ នៃវិធានការដែលជនជាប់ចោទនិងអ្នកក្រោមបង្គាប់ពិតជាបានធ្វើឡើងប្រាកដមែន ។ ក្នុងពេលមានការវាយប្រហារទៅលើព្រះវិហារលីគ្វីកា ជនជាប់ចោទស្ថិតនៅឯទីក្រុងហ្សាកាតា ។ ក្នុងខណៈដែលមានការអះអាងថាក្រុមប៉ូលិសមិនបានធ្វើអ្វីសោះដើម្បីដោះស្រាយសភាពការណ៍តានតឹងនេះ ដីកាចោទបានពិពណ៌នាមេប៉ូលិសប្រចាំតំបន់ឈ្មោះ អាឌីអូស សាលូវ៉ា ថាបានត្រួតពិនិត្យនិងរាយការណ៍ទៅទីក្រុងឌីលីអំពីសភាពការណ៍នេះ ។ ដីកាចោទបានបន្តថា ក្នុងពេលអវត្តមាន ធីមប៊ុល ស៊ីឡែន អនុរបស់គាត់ឈ្មោះ មូហ្វី សាហុជី បានបញ្ជូនកងជំនួយទៅលីគ្វីកា ហើយបញ្ជាឲ្យក្រុមប៉ូលិស "ទប់ទល់" សភាពការណ៍ឲ្យបានល្អ ។ នៅពេល ធីមប៊ុល ស៊ីឡែន ត្រឡប់មកវិញ គាត់បានទទួលព័ត៌មានអំពីឧបទ្ទវហេតុនៅព្រះវិហារនិងបានបង្គាប់បញ្ជាឲ្យ អាឌីអូស សាលូវ៉ា ស៊ើបអង្កេតរកជនដៃដល់ថាតើជាអ្នកគាំទ្រឯករាជ្យភាពឬអ្នកគាំទ្រស្វ័យភាព ។

ស្រដៀងគ្នានេះដែរ ក្នុងខណៈដែលមានការអះអាងថាជនជាប់ចោទនិងអ្នកក្រោមបង្គាប់មិនបានធ្វើអ្វីសោះដើម្បីទប់ស្កាត់ឬឆ្លើយតបទៅនឹងការវាយប្រហារនៅផ្ទះរបស់ ការ៉ាសកាឡូ ដីកាចោទបានបញ្ជាក់ថា នៅពេលដែល ម៉ានូអែល ការ៉ាសកាឡូ បានធ្វើដំណើរទៅស្ថានីយប៉ូលិសនៅទីក្រុងឌីលី ដើម្បីរាយការណ៍អំពីកងជីវពលដែលកំពុងតែសំដៅមកផ្ទះរបស់គាត់ មន្ត្រីប៉ូលិស

បានរាយការណ៍បញ្ហានេះទៅ មូហ៊ី សាហុជី តាំងពីពេលដែល ធីមប៉ិល ស៊ីម៉្លែន ស្ថិតនៅទីក្រុងហ្សាកាតាម៉្លេះ ។ មូហ៊ី សាហុជី បានចេញបញ្ជាឲ្យទប់ស្កាត់បញ្ហានេះ ក៏ប៉ុន្តែគ្មាននរណាម្នាក់យកចិត្តទុកដាក់អនុវត្តបទបញ្ជានោះទេ ហើយកងជីវពលនៅតែមានលទ្ធភាពវាយប្រហារមកលើផ្ទះរបស់ ការ៉ាំសកាឡូ ដដែល ។ ភ្លាមៗបន្ទាប់ពីមានការវាយប្រហារ ធីមប៉ិល ស៊ីម៉្លែន បានវិលត្រឡប់មកពីទីក្រុងហ្សាកាតា ហើយអនុរបស់គាត់បានប្រាប់គាត់អំពីអ្វីដែលបានកើតឡើង ។ ធីមប៉ិល ស៊ីម៉្លែន គ្រាន់តែបានចេញបញ្ជាថាចាំបាច់ត្រូវតែស៊ើបអង្កេតឲ្យម៉ត់ចត់ទៅលើទាំងអ្នកគាំទ្រស្វ័យភាពនិងអ្នកគាំទ្រឯករាជ្យភាព ។

ការពិពណ៌នាអំពីហេតុការណ៍នេះនៅក្នុងដីកាចោទ ខុសគ្នាទាំងស្រុងពីការពិពណ៌នាដែលធ្វើឡើងដោយ ខេភីភីហាំ ដោយទីភ្នាក់ងារស៊ើបអង្កេតចំនួនពីរទៀតរបស់អង្គការសហប្រជាជាតិ និងខុសគ្នាពីដីកាចោទដែលចេញដោយអគ្គរដ្ឋអាជ្ញាទីម័រខាងកើត ។ ការិយាល័យអគ្គមេធាវីបាននិយាយសម្រាលទម្ងន់អ្វីដែលបានកើតឡើង ហើយជួនកាលធ្វើមិនដឹងមិនឮចំពោះតួនាទីរបស់កងកម្លាំងសន្តិសុខទៀតផង ។ ដូចដែលកត់សម្គាល់រួចហើយ ដីកាចោទប្រកាន់អំពីការសម្លាប់រង្គាលនៅវិហារសួយគឺធ្វើតែចំពោះការស្លាប់របស់មនុស្សតែ២៧នាក់ប៉ុណ្ណោះ ដែលជាទូទៅចំនួនអ្នកស្លាប់អាចមានរហូតដល់១០០នាក់ (សូម្បីតែរបាយការណ៍របស់ខេភីភីហាំក៏បានប៉ាន់ស្មានថាយ៉ាងហោចណាស់មានមនុស្ស ៥០នាក់បានស្លាប់) ។ ទាក់ទងទៅនឹងហេតុការណ៍នៅលីគ្វីកា ដីកាចោទមិនបានទទួលយកតួរលេខជា“ផ្លូវការ”ស្តីពីការស្លាប់ចំនួនប្រាំករណីដែលអាជ្ញាធរតណ្ឌូនេស៊ីបានលើកឡើងពីមុនទេ ប៉ុន្តែបែរជាលើកឡើងអំពីការស្លាប់ចំនួន២២នាក់ និងរបួសចំនួន២១នាក់ ក្នុងការចោទប្រកាន់ អាប៊ីលីអូ ស័ររ៉េ ហើយលើកឡើងអំពីការស្លាប់ចំនួន១៨នាក់និងរបួស៧នាក់ ក្នុងការចោទប្រកាន់ ធីមប៉ិល ស៊ីម៉្លែន ។ ការសម្លាប់រង្គាលដ៏ធ្ងន់ធ្ងរបំផុតមួយនៅទីម័រខាងកើតគឺការសម្លាប់រង្គាលនៅផ្ទះរបស់ ម៉ានូអែល ការ៉ាំសកាឡូ នៅទីក្រុងឌីលី នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៩ ។ ចេញពីការសម្លាប់រង្គាលនេះ ការចោទប្រកាន់ អាប៊ីលីអូ ស័ររ៉េ គឺអំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ដីកាចោទបានបង្ហាញការសម្លាប់រង្គាលមួយផ្សេងទៀតនៅវិហារសួយកាលពីថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៩៩ ដោយពិពណ៌នាថាៈ

បន្ទាប់ពីក្រុមគាំទ្រឯករាជ្យភាពឈ្នះក្នុងការធ្វើប្រជាមតិ សភាពការណ៍កាន់តែក្តៅគគុកនិងកាន់តែតានតឹងឡើងរវាងក្រុមទាំងពីរ ។ ក្រុមគាំទ្រឯករាជ្យភាពបានភៀសខ្លួនទៅព្រះវិហារនៅសួយ ។ នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៩៩ ក្រុមគាំទ្រសមាហរណកម្មដែលជាសមាជិករបស់ក្រុមឡាក់សូ ស្ថិតនៅក្រោមការដឹកនាំរបស់ អូលីវើ ម៉ូរុក បានវាយប្រហារទៅលើទីតាំងព្រះវិហារនេះដោយប្រើកាំបិតនិងកាំភ្លើងផលិតក្នុងស្រុក ។ ជាលទ្ធផល មនុស្សចំនួន២៧នាក់បានស្លាប់ ។

ខាងក្រោមនេះគឺជារបាយការណ៍របស់ខេភីភីហាំអំពីសភាពការណ៍នៅសួយៈ

នៅថ្ងៃទី៤ ខែកញ្ញា កងជីវពលឡាក់សូនិងសមាជិកធីអិនអាយនៅដេបូសហាមឡែតបានបង្កឲ្យមានការបាត់បង់អាយុជីវិតសិស្សវិទ្យាល័យម្នាក់ ។ អ្នកភូមិជាច្រើនបានភៀសខ្លួនទៅជ្រកកោនបណ្តោះអាសន្ននៅឯព្រះវិហារ នូសាសែនហូរ៉ា ឌីហ៊ុាទីម៉ា និងព្រះវិហារ អេវ ម៉ារីយ៉ា នៅសួយ ។ ល្ងាចមួយនៅក្នុងខែកញ្ញា លំនៅឋាននិងអគាររដ្ឋាភិបាលជាច្រើនត្រូវដុតបំផ្លាញដោយកងជីវពលឡាក់សូនិងសមាជិកធីអិនអាយ ។ ចាប់តាំងពីថ្ងៃទី៦ ខែកញ្ញា អ្នកភូមិទាំងអស់ត្រូវបង្ខំឲ្យចាកចេញពីលំនៅឋាន ។ មេបញ្ជាការយោធាប្រចាំឃុំសួយ គឺលោកសក្តិពីរ ស៊ូហ្គីតូ បានចូលរួមក្នុងការដុតបំផ្លាញនិងឆក់ប្លន់ ។

នៅថ្ងៃទី៦ ខែកញ្ញា នៅម៉ោងប្រហែល១៤ៈ៣០នាទី ពួកកងជីវពលមេរាពុទិនិងមាហិឌីរបស់ឡាក់សូ ព្រមទាំងសមាជិករបស់ធីអិនអាយនិងក្រុមប៉ូលិស បានវាយប្រហារទៅលើជនភៀសខ្លួនដែលកំពុងស្នាក់នៅក្នុងបរិវេណព្រះវិហារសួយ ។ ការវាយប្រហារនេះដឹកនាំផ្ទាល់ដោយអភិបាលស្តីទីនៅកូវ៉ាលីម៉ា ឈ្មោះ ហ៊ីម៉ាន សេរីឌីណូ និងមេបញ្ជាការយោធាឃុំសួយ ស៊ូហ្គីតូ ។ មុនពេលមានការវាយប្រហារនេះ កងជីវពលបានគំរាមសម្លាប់បព្វជិតនិងជនភៀសខ្លួនទាំងអស់ ។ នៅពេលនោះមានជន

ភៀសខ្លួនប្រមាណ១០០នាក់ស្ថិតនៅក្នុងព្រះវិហារ ហើយមួយចំនួនទៀតស្ថិតនៅបរិវេណខាងក្រៅ ។ បព្វជិត ហ៊ីឡារូ ត្រូវគ្រាប់កាំភ្លើងមួយគ្រាប់ចំដើមទ្រូង ហើយ អីជីដូ ម៉ាណែក ដែលជាសមាជិកកងជីវពលឡាក់សូ បានដើរជាន់ពីលើសាកសពរបស់គាត់ ។ បព្វជិត ហ្វ្រង់ស៊ីស្កូ ត្រូវសមាជិកម្នាក់របស់កងជីវពលឡាក់សូឈ្មោះ អាមេរីកូ ចាក់សម្លាប់និងកាប់ចិញ្ច្រាំ ។ ភ័ស្តុតាងមួយផ្សេងទៀត ដូមីងគុស ដូសសាន់តូស បានឃើញបព្វជិត ដេវ៉ានតូ ត្រូវសម្លាប់នៅក្នុងព្រះវិហារចាស់ ។ ក្នុងពេលមានការវាយប្រហារ ក្រុមប៉ូលិសកងពលតូចចល័តឡូរូសេរីនិងសមាជិកធីអឹនអាយស្ថិតនៅខាងក្រៅរបងបានបាញ់ប្រហារមកលើជនភៀសខ្លួនដែលព្យាយាមរត់គេចចេញពីបរិវេណព្រះវិហារ ។ យ៉ាងហោចណាស់មនុស្ស៥០នាក់បានស្លាប់នៅក្នុងខបទុវហេតុនេះ ។

រថយន្តធំមួយគ្រឿងនិងរថយន្តតូចចំនួនពីរគ្រឿងបានមកដឹកសាកសពចំនួន២៦យកទៅកប់ចោលនៅក្នុងភូមិអាឡាស ស្រុកវេមាសា បេលុរីជិនស៊ី ។ កិច្ចការនេះបញ្ជាដោយលោកស័ក្តិពីរ ស៊ូហ្គីតូ រួមជាមួយសមាជិកធីអឹនអាយបីនាក់ទៀត និងក្រុមជីវពលឡាក់សូ ។ លោកស័ក្តិពីរ ស៊ូហ្គីតូ និងក្រុមរបស់គាត់ បានដឹកសាកសពចេញពីព្រះវិហារស្វាយនៅម៉ោងប្រហែល៨កន្លះ ឆ្លងកាត់ប៉ុស្តិ៍ប៉ូលិសមេតាម៉ូកនៅទីម័រខាងលិច ។ ការគាស់រណ្តៅសាកសពរួមនៅព្រះវិហារស្វាយបានរកឃើញសាកសពបុរសចំនួន១៦នាក់ ស្ត្រី៨នាក់ និងសាកសពពីរទៀតដែលមិនអាចកំណត់ភេទបាន ។ សាកសពទាំងអស់មានអាយុពី៥ ទៅ៤០ឆ្នាំ ។

## ៧) ការសង្កេតមើលដំណើរការជំនុំជម្រះ

### ក) បរិយាកាសនៅក្នុងតុលាការ

ការជំនុំជម្រះរបស់តុលាការពិសេសសម្រាប់ការរំលោភសិទ្ធិមនុស្សនៅទីម័រខាងកើត បានធ្វើឡើងនៅក្នុងតុលាការខណ្ឌនៅកណ្តាលទីក្រុងហ្សាកាតា ។ អគារគ្មានភាពស័ក្តិសមសម្រាប់ការពារសាក្សីទាល់តែសោះ ឧទាហរណ៍ គ្មានបន្ទប់រង់ចាំដែលមានច្រកចូលដាច់ដោយឡែកនិងដែលអាចធានាសន្តិសុខសម្រាប់សាក្សីឡើយ ។ បង្គន់ដាច់ដោយឡែកក៏គ្មានដែរ ។ បន្ទប់តុលាការក្តៅហប់និងពិបាកទ្រាំ ។ ជាងនេះទៅទៀត បន្ទប់តុលាការបំពាក់ដោយឧបករណ៍អន់ៗដូចជាអំពូលដែលមានបញ្ហាជារឿយៗ ធ្វើឲ្យអ្នកស្តាប់មិនអាចតាមទាន់នូវអ្វីដែលបាននិយាយនៅក្នុងបន្ទប់តុលាការ ។ គ្មានការចម្លងចេញជាផ្លូវការនូវសម្តីនៅក្នុងតុលាការ ។ មានតែការចម្លងជារបៀបមិនផ្លូវការដែលធ្វើដោយអង្គការក្រៅរដ្ឋាភិបាល ចេញពីកំណត់ហេតុ កាសែតថតសំឡេង និងកាសែតវីដេអូ ដែលថតដំណើរការតុលាការ ។ ឯកសារនានាក៏ពិបាករក ហើយរដ្ឋបាលតុលាការក៏មិនបានជូនដំណឹងជាសាធារណៈអំពីពេលវេលានិងទីតាំងនៃការបើកសវនាការ ។ គ្មានការប្រុងប្រយ័ត្នផ្នែកសន្តិសុខទេ សូម្បីតែការឆែកឆេររកអាវុធក៏គ្មានដែរ ។

រាល់ពេលជំនុំជម្រះ កងកម្លាំងធីអិនអាយបានចូលរួមក្នុងចំនួនដ៏ច្រើន ជាពិសេសក្នុងពេលជំនុំជម្រះក្តីករណីសម្លាប់រង្គាលនៅព្រះវិហារស្វាយដែលមានជនជាប់ចោទបួននាក់ជាសមាជិករបស់ធីអិនអាយ ។ ទីប្រឹក្សាច្បាប់មកពីធីអិនអាយនិងក្រុមប៉ូលិសបានចូលរួមតាមដានដំណើរការនេះជាប្រចាំ ។ ផ្តើមចេញពីអង្គភាពធីអិនអាយដែលបានចូលរួមនិងផ្តើមចេញពីការសន្ទនាជាមួយជនជាប់ចោទខ្លះ វាច្បាស់ណាស់ថា ធីអិនអាយ កំពុងតែបញ្ជូនបុគ្គលិកមកចូលរួមស្តាប់ដំណើរការជំនុំជម្រះក្តីដើម្បីសបញ្ជាក់អំពីវត្តមាននិងការគាំទ្រ ។ នេះគឺចង់និយាយអំពីវត្តមានរបស់បុគ្គលិកឯកសណ្ឋានដែលមុខមាត់ប្លែកៗនិងមកពីអង្គភាពផ្សេងៗគ្នាជារៀងរាល់ថ្ងៃ ហើយបុគ្គលដែលប្រឈមមុខនឹងការចោទសួរហាក់ដូចជាមិនបានដឹងអ្វីសោះពីរឿងក្តី ឬមិនមានចំណាប់អារម្មណ៍ទៅលើដំណើរការជំនុំជម្រះនោះទេ ។ អ្នកចូលរួមទទួលទានថ្ងៃត្រង់នៅក្នុងអគារនេះតែម្តង ។ ជនជាប់ចោទដែលជាសមាជិកធីអិនអាយ ធ្វើដំណើរមកតុលាការដោយរថយន្តយោធាដែលមានអ្នកហែហមនិងមានស៊ីរ៉ែន ចំណែកជនជាប់ចោទផ្សេងទៀតមិនមានអាទិភាពបែបនេះទេ ។ ផ្ទុយទៅវិញ ក្រុមប៉ូលិសមិនបានចូលរួមឲ្យបានច្រើននៅក្នុងដំណើរការជំនុំជម្រះក្តី ធីមប៊ុលស៊ីឡែន និង ហ្កាតុត ស៊ុប៊ីយ៉ាកតូរ៉ូ ដូចដែលក្រុមធីអិនអាយបានធ្វើនោះទេ ។ ទោះបីជាយ៉ាងនេះក្តី ក្រុមប៉ូលិសបានចូលរួមនៅក្នុងដំណាក់កាលចុងក្រោយប៉ុន្មានលើក ។ ក្រុមគាំទ្រសមាហរណកម្ម

នៅទីម័រខាងកើតបានចូលរួមស្តាប់សវនាការជាប្រចាំ ដើម្បីផ្តល់ការគាំទ្រចំពោះ អាប៊ីលីអូ ស័ររ៉េ និងចូលរួមតិចតួចនៅក្នុងដំណើរការជំនុំជម្រះរឿងក្តីទាក់ទិននឹងធីអិនអាយនិងជនជាប់ចោទជាប៉ូលិស ។

ជនជាប់ចោទតែងតែចូលរួមស្តាប់សវនាការដទៃទៀតជារឿយៗ ហើយជាធម្មតា សាក្សីចូលទៅនៅក្នុងបន្ទប់តុលាការដើម្បីស្តាប់ភ័ស្តុតាងនានានៅក្នុងរឿងក្តីដែលខ្លួនត្រូវផ្តល់កសិណប្ញអង្គុយនៅច្រករបៀងខាងក្រៅដើម្បីតាមដានដំណើរការរឿងក្តីនោះតាមរយៈប្រដាប់បំពងសម្លេង ។ មន្ត្រីផ្នែកចារកម្មមានវត្តមានជាប្រចាំ ។ ជនបរទេសដែលមានចំនួនតិចតួចនិងដែលចូលស្តាប់យ៉ាងទៀងទាត់ ត្រូវបានសង្ស័យនិងត្រូវថតរូបជាច្រើនសន្លឹកនិងថតវីដេអូទុក ។ ប្រព័ន្ធឃោសនានិងអង្គការក្រៅរដ្ឋាភិបាលមានវត្តមានជារៀងរាល់ថ្ងៃ ។

ក្រៅពីអ្នកសង្កេតការណ៍និងអង្គការក្រៅរដ្ឋាភិបាលចៅក្រមសម្លឹងមើលទៅធីអិនអាយ ប៉ូលិស និងក្រុមជីវពលដែលមានចំនួនដ៏ច្រើនសន្ធឹកសន្ធាប់នៅតាមបន្ទប់សាធារណៈ ។ ចាប់តាំងពីដើមដំបូង ចៅក្រមជម្រះក្តីបរាជ័យក្នុងការប្រើប្រាស់សិទ្ធិអំណាចរបស់តុលាការ ។ មានថ្ងៃខ្លះ ចៅក្រមបណ្តោយឲ្យអង្គជំនុំជម្រះដំណើរការទៅតាមកសិណរបស់សាក្សី ហើយថ្ងៃខ្លះទៀត វាហាក់ដូចជាអង្គការសហប្រជាជាតិនិងអ្នកតំណាងពិសេសរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើត (អៀន ម៉ាទីន) ត្រូវតុលាការនេះកាត់ទោស ។ សវនាការដែលចូលរួមដោយសាក្សីដែលមានមុខមាត់ធំដុំដូចជា វីរ៉ាន់តូ និង អាដាម ដាមីរី បង្កឲ្យមានសម្លេងខ្សឹបខ្សៀវចេញពីបណ្តាទស្សនិកជន ។ នៅក្នុងឱកាសបែបនេះ បន្ទប់សាធារណៈមានមនុស្សពាក់ពូនគួរឲ្យគ្រោះថ្នាក់ ។ សមាជិកធីអិនអាយក្នុងសម្លៀកបំពាក់ប៉ារ៉ាបានចូលរួមម្តងម្កាល ប៉ុន្តែបុគ្គលិកយោធាភាគច្រើនចូលរួមក្នុងឯកសណ្ឋានដូវការ ។ ជាទូទៅក្រៅពីការមិនគោរពបទបញ្ជាផ្ទៃក្នុងរបស់តុលាការដូចជា ការជជែកគ្នានៅក្នុងតុលាការ ការនិយាយទូរស័ព្ទជាដើម សមាជិកធីអិនអាយនិងប៉ូលិសមានវិន័យល្អ ។ ប្រជាជនស៊ីវិលជាអ្នកឡូឡានៅក្នុងតុលាការ ។ ម្តងម្កាលមានបាតុកម្មដែលចូលរួមដោយអ្នកគាំទ្រស៊័យភាព សមាជិកកងជីវពលក្នុងឯកសណ្ឋានប៉ារ៉ា អ្នកចូលរួមដែលស្លៀកសម្លៀកបំពាក់ពណ៌ក្រហមនិងសដែលជាពណ៌ប្រចាំប្រទេស ប្រជាជនទីម័រខាងកើតពាក់អាវយឺតពណ៌ស-ខ្មៅដែលមានសរសេរអក្សរថា "ជនរងគ្រោះនៃអំពើបោកប្រាស់របស់អង្គការសហប្រជាជាតិ" និងអ្នកកាន់បដាប្រឆាំងអង្គការសហប្រជាជាតិ ។ល ។

នៅពេលផ្តល់បទសម្ភាសន៍ ចៅក្រមបាននិយាយថា ខ្លួនចង់ឃើញអ្នកសង្កេតការណ៍អន្តរជាតិចូលរួម ។ ចៅក្រមបានទទួលស្គាល់ថាមានសម្ពាធខ្លះនៅតាមបន្ទប់សាធារណៈ ក៏ប៉ុន្តែបានបដិសេធថា ប្រការទាំងអស់នេះមិនមានឥទ្ធិពលណាមួយទៅលើខ្លួនទេ ។ វាពិបាកក្នុងការវាយតម្លៃពីឥទ្ធិពលដែលគំរាមកំហែងទៅលើចៅក្រម ។ ការប្រព្រឹត្តរបស់ចៅក្រមនៅក្នុងការជំនុំជម្រះមិនមែនជាកត្តាដែលប៉ះពាល់ដោយផ្ទាល់ទៅលើជំនឿទុកចិត្តចំពោះដំណើរការនោះទេ បើទោះជាវាមានចំណែកខ្លះក៏ដោយ ។ នីតិវិធីក្រមព្រហ្មទណ្ឌរបស់ប្រទេសឥណ្ឌូនេស៊ីបានផ្តល់ឲ្យតុលាការនូវការទទួលខុសត្រូវជាសំខាន់សម្រាប់ការពិនិត្យមើលសាក្សី ប៉ុន្តែការយកមកអនុវត្តរបស់ក្រុមចៅក្រមមានភាពខុសប្លែកទៅវិញៈ ចៅក្រមក្នុងក្រុមទីមួយត្រូវចោទសួរសាក្សីមុន ក៏ប៉ុន្តែអ្នកដែលនៅក្នុងក្រុមទីពីរបានឲ្យបក្ខពួកកោះហៅសាក្សីទាំងអស់នោះដើម្បីសួរចម្លើយមុនហ្នឹងទៅទៀត ។ ដូចគ្នានេះដែរ ក្រុមពិនិត្យភ័ស្តុតាងមិនផ្ទាល់ធ្វើកិច្ចការច្របូកច្របល់ ។ ពេលខ្លះចៅក្រមនិងក្រុមប្រឹក្សាបានសាកសួរសាក្សីអំពីអ្វីដែលសាក្សីបានឮអំពីខបទូវហេតុ ហើយនៅពេលខ្លះទៀតចៅក្រមនិងក្រុមប្រឹក្សាតម្រូវឲ្យសាក្សីនិយាយតែអំពីអ្វីដែលខ្លួនបានដឹងផ្ទាល់ប៉ុណ្ណោះ ។ នៅក្នុងបរិបទនេះគួរកត់សម្គាល់ដែរថា នៅក្នុងប្រទេសឥណ្ឌូនេស៊ីមានការហាមឃាត់ភ័ស្តុតាងជាពាក្យចចាមអារ៉ាម ក៏ប៉ុន្តែភ័ស្តុតាងមិនមែនឯកទេសត្រូវតែឈរលើការដឹងដោយផ្ទាល់ ។ ជាទូទៅ ចៅក្រមអនុញ្ញាតឲ្យសាក្សីដែលមិនបានដឹងផ្ទាល់អំពីហេតុការណ៍ និយាយវែងអន្លាយហាក់ដូចជាសាក្សីទាំងអស់នោះបានដឹងពីហេតុការណ៍នោះ ។ បើប្រៀបធៀបទៅនឹងសាក្សីដទៃទៀត សាក្សីដែលមិនបានដឹងដោយផ្ទាល់រង់ចាំតែ

ឆ្លើយសំណួររបស់ចៅក្រមតែប៉ុណ្ណោះ ក៏ប៉ុន្តែសំណួរជាច្រើនសុទ្ធតែចាកប្រធាន។ ចៅក្រមមួយចំនួនបានចូលរួមយ៉ាងសកម្មនិងបានសួរសំណួរល្អៗដែលជារឿយៗប៉ះប៉ូវចំណុចខ្វះខាតនៃការចោទប្រកាន់។ ឧទាហរណ៍ជាច្រើនរាប់បញ្ចូលទាំងការប៉ុនប៉ងភ្ជាប់គ្រឿងសព្វាវុធដែលត្រូវបានប្រើនៅក្នុងការសម្លាប់មនុស្សនៅកន្លែងផ្សេងៗពីគ្នា ដូចជានៅព្រះវិហារលីគីកានិងនៅគេហដ្ឋានរបស់ ការ៉ាសកាឡូ និងរាប់បញ្ចូលសំណួរថាតើហេតុអ្វីបានជាអាជ្ញាធរដែលមានភ្នាក់ងារស៊ើបអង្កេតនៅគ្រប់ទីកន្លែងទាំងអស់ មិនមានលទ្ធភាពដឹងជាមុនពីអំពើហិង្សាក្រោយការធ្វើប្រជាមតិនៅខែកញ្ញា ឆ្នាំ១៩៩៩។ ទោះបីជាយ៉ាងណាក៏ដោយ កម្រមានសំណួរល្អដើម្បីឈានទៅរកការសន្និដ្ឋានសមហេតុផលណាស់ ហើយចៅក្រមមួយចំនួនដែលព្យាយាមដោះស្រាយបញ្ហានៅចំពោះមុខ បានបង្កឲ្យមានប្រតិកម្មអវិជ្ជមាននៅទីកន្លែងសាធារណៈ បូករួមទាំងការនិយាយស្តីក្នុងន័យវាយប្រហារនិងគំរាមកំហែង។ ក្នុងករណីខ្លះ សំណួរមួយចំនួនដែលពាក់ព័ន្ធត្រូវបញ្ចប់ដោយសារតែការប្រទូសរ៉ាយយ៉ាងគឃ្លើនរបស់ទស្សនិកជន។

មិនមែនជាការងាយស្រួលទេក្នុងការវាយតម្លៃថាការប្រព្រឹត្តមិនបានល្អរបស់ចៅក្រមកើតឡើងដោយសារតែមានការគំរាមកំហែង។ មានសេចក្តីរាយការណ៍ជាច្រើនដែលបង្ហាញថារដ្ឋអាជ្ញាបានទទួលទូរស័ព្ទគំរាមកំហែង។ ទោះបីជាយ៉ាងណាក៏ដោយ ទំនាក់ទំនងរវាងដើមចោទនិងចុងចោទមានភាពរាក់ទាក់និងកក់ក្តៅយ៉ាងពិសេស។ ជារឿយៗ គេឃើញសាក្សីខាងដើមចោទនិងជនជាប់ចោទចូលរួមក្នុងការពិភាក្សាយ៉ាងរីករាយមុននិងក្រោយដំណើរការជំនុំជម្រះ ព្រមទាំងក្នុងចន្លោះពេលនីមួយៗ។ ដូចដែលខ្ញុំនឹងបង្ហាញនៅខាងក្រោម គ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេ នៅពេលដែលសាក្សីខាងដើមចោទផ្តល់សក្ខីកម្មគាំទ្រចុងចោទ។

### ១) ការចោទប្រកាន់ដែលធ្វើឲ្យតែបាន

ដូចដែលធ្លាប់បានកត់សម្គាល់រួចមកហើយ ដំណើរការស្វែងរកយុត្តិធម៌សម្រាប់អំពើឃោរឃៅនៅទីម័រខាងកើតមានភាពប្រទាំងប្រទើសយ៉ាងខ្លាំងដោយសារតែព្រំដែននៃច្បាប់ដែលត្រូវយកមកអនុវត្ត និងដោយសារដីកាចោទប្រកាន់មានភាពទន់ខ្សោយយ៉ាងខ្លាំងដែលហាក់ដូចជាធ្វើឡើងដើម្បីបន្ថយឲ្យបានជាអប្បបរមានូវទម្ងន់នៃឧក្រិដ្ឋកម្មនិងការទទួលខុសត្រូវរបស់ជនជាប់ចោទ។ ហេតុដូច្នេះហើយ ការជំនុំជម្រះមួយដែលប្រកបដោយអត្ថន័យប្រែជាមានគុណវិបត្តិយ៉ាងច្រើន។

រដ្ឋអាជ្ញារបស់តុលាការគ្មានភាពប៉ិនប្រសប់ទាល់តែសោះក្នុងការឆ្លើយតបទៅនឹងតម្រូវការនៃភស្តុតាងដាក់បន្ទុក។ ដីកាចោទដ៏ទន់ខ្សោយនេះបានទាមទារថា រដ្ឋអាជ្ញាត្រូវតែបង្ហាញថាភាពសកម្មឬអសកម្មរបស់ជនជាប់ចោទខ្វះបទដ្ឋានជាក់លាក់ពោលគឺបទដ្ឋានដែលបានប្រកាសនៅក្នុងបទបញ្ញត្តិនៃច្បាប់២៦/២០០០ អំពីការទទួលខុសត្រូវលើការបញ្ជាផ្នែកស៊ីវិលនិងយោធា។ ក៏ប៉ុន្តែគ្មានការបង្ហាញបែបនេះទេ។ ដីកាចោទក៏បានទាមទារដែរថា ភាពសកម្មឬអសកម្មរបស់អ្នកក្រោមបង្គាប់ត្រូវតែជាបរាជ័យនៃការគ្រប់គ្រងរបស់ថ្នាក់លើ។ ឧទាហរណ៍ ក្រុមប៉ូលិសត្រូវបានចោទប្រកាន់ពីបទមិនបានចាត់វិធានការចាំបាច់ណាមួយទាក់ទិនទៅនឹងអំពើឧក្រិដ្ឋដែលបានប្រព្រឹត្តនៅទីក្រុងឌីលី លីគីកា និងសួយ។ ក្រុមប៉ូលិសត្រូវតែប្រឈមនឹងការចោទសួរអំពីការប្រព្រឹត្តបែបនោះ។ តើអ្វីដែលក្រុមប៉ូលិសបានធ្វើ ហើយអ្វីដែលមិនបានធ្វើ? តើអ្វីដែលក្រុមប៉ូលិសគួរតែអាចធ្វើបាន? តើអ្វីដែលជាជម្រើស? តើក្នុងសភាពការណ៍បែបនោះអ្វីដែលក្រុមប៉ូលិសអាចធ្វើបាន? រដ្ឋអាជ្ញាមិនបានយកលំហាត់នេះមកអនុវត្តទេ។

### ១-១) សាក្សី

ទិដ្ឋភាពនៃដំណើរការជំនុំជម្រះដ៏គួរឲ្យកត់សម្គាល់បំផុតចាប់តាំងពីដើមដំបូងមកនោះគឺ សាក្សីទាំងអស់របស់ដើមចោទបានផ្តល់សក្ខីកម្មប្រឆាំងនឹងដីកាចោទប្រកាន់។ ក្នុងអំឡុងពេលស៊ើបអង្កេត ខេភីភីហាំធ្វើដំណើរទៅ គូប៉ាង ចំនួនប្រាំមួយដង និងធ្វើទស្សនកិច្ចនៅទីម័រខាងកើតចំនួនបីដង ព្រមទាំងធ្វើអធិការកិច្ចរណ្តៅសាកសពរួមនៅទីម័រខាងលិចជាទីកប់សពជនរងគ្រោះនៃការសម្លាប់នៅឯព្រះវិហារសួយ។ ក្រុមកោសល្យវិច័យ

មួយក្រុមបានអមដំណើរខេភីភីហាំដើម្បីធ្វើអធិការកិច្ចរណ្តៅសាកសពរួមនេះ ។ ខេភីភីហាំបានធ្វើសម្ភាសន៍ជាមួយមនុស្សចំនួន១២៣នាក់នៅទីក្រុងឌីលី, សួយ, លីគីកា, ម៉ាលីយ៉ាណា, ម៉ូបារ៉ា, គូប៉ាំង, អាតាំបួ និង ហ្សាកាតា ។ បន្ទាប់ពីរបាយការណ៍និងភស្តុតាងគាំទ្រត្រូវបានដាក់ជូនទៅកាន់អគ្គមេធាវីរួចរាល់ហើយ មន្ត្រីសមត្ថកិច្ចបានចំណាយពេលពេញមួយខែកក្កដានៅទីម័រខាងកើតក្នុងឆ្នាំ២០០០ ។ *UNTAET* បានផ្តល់សិទ្ធិដល់មន្ត្រីក្នុងការជួបសាក្សី និងធ្វើទស្សនកិច្ចទីកន្លែងកើតហេតុនៅទីក្រុងឌីលី, លីគីកា និងសួយ ។

អាស្រ័យហេតុនេះ វាជាការចម្លែកណាស់ដែលសំណុំឯកសារ អាប៊ីលីអូ ស័រេ៉ ដែលដាក់ជូនតុលាការមិនមានសក្ខីកម្មរបស់ជនរងគ្រោះសូម្បីតែម្នាក់ ។ មនុស្សគ្រប់ៗគ្នាដែលត្រូវបានសម្ភាសក្នុងអំឡុងពេលនៃការស៊ើបអង្កេតនេះ គឺសុទ្ធតែជាអ្នកគាំទ្រយ៉ាងក្លៀវក្លាចំពោះការធ្វើសមាហរណកម្មជាមួយប្រទេសឥណ្ឌូនេស៊ី (អ្នកទាំងអស់នោះមានមន្ត្រីរាជការបុគ្គលិកយោធា និងប៉ូលិស) ។ ដូច្នេះ ក្រុមអ្នកស៊ើបអង្កេតបានកសាងសំណុំរឿងក្តីដោយគ្មានសក្ខីកម្មរបស់ជនរងគ្រោះទាល់តែសោះ ។ សំណុំឯកសារករណី ធីមប៊ុល ស៊ីឡែន ដែលដាក់ជូនទៅកាន់តុលាការ លាតត្រដាងតែសេចក្តីថ្លែងរបស់ជនរងគ្រោះចំនួន៧ករណីទាក់ទងទៅនឹងអំពើសម្លាប់រង្គាលចំនួន៦ ។ សេចក្តីថ្លែងការណ៍ពីរក្នុងចំណោមសេចក្តីថ្លែងការណ៍ចំនួនប្រាំពីរត្រូវបានយកមកធ្វើជាកសិណនៅឯតុលាការទីក្រុងហ្សាកាតា សេចក្តីថ្លែងការណ៍បីត្រូវបានកត់ត្រាបន្ទាប់ពីសាក្សីបានបដិសេធមិនព្រមចូលរួម ហើយសេចក្តីថ្លែងការណ៍ពីរទៀតហាក់ដូចជាត្រូវបានមើលរំលង ។ គ្មានសាក្សីណាម្នាក់ផ្តល់កសិណអំពីការសម្លាប់រង្គាលនៅផ្ទះការ៉ាសកាឡូ, ការសម្លាប់នៅព្រះវិហារសួយឬក៏ការវាយប្រហារទៅលើ *UNAMET* នៅលីគីកាទេ ។ ម្យ៉ាងវិញទៀត រដ្ឋអាជ្ញាបានកសាងសំណុំរឿងក្តីចំនួនបីករណីដោយគ្មានភស្តុតាងទាល់តែសោះ ។

មានសាក្សីនិងជនរងគ្រោះសំខាន់ៗជាច្រើនដែលគួរតែអាចត្រូវបានកោះហៅឲ្យមកធ្វើកសិណសម្រាប់អាជ្ញាចោទប្រកាន់ ក៏ប៉ុន្តែគ្មានអ្នកណានឹកនាដល់ ។ ការបំភ្លេចចោលដ៏គួរឲ្យកត់សម្គាល់មួយគឺបព្វជិត រ៉ាហ្វែល ដូសសាន់តុស នៃព្រះវិហារលីគីកា ដែលបាននិយាយនៅក្នុងសន្និសីទកាសែតអំពីតួនាទីរបស់យោធានិងប៉ូលិសមាននៅក្នុងការសម្លាប់រង្គាលនេះ ។ ខេភីភីហាំ បានធ្វើសម្ភាសន៍ជាមួយគាត់ ប៉ុន្តែទំនងជាមិនបានធ្វើការិយាល័យអគ្គមេធាវីទេ ព្រោះសេចក្តីថ្លែងការណ៍របស់គាត់មិនមាននៅក្នុងសំណុំឯកសារដែលត្រូវដាក់ជូនទៅតុលាការ ។ ទោះជាគាត់មិនត្រូវបានកោះហៅទៅធ្វើសាក្សីនៅក្នុងរឿងក្តីប្រឆាំងអតីតអភិបាល និងមេប៉ូលិសនៅទីម័រខាងកើតក៏ដោយ ក៏ក្រោយមកសាក្សីរូបនេះត្រូវបានកោះហៅទៅផ្តល់កសិណក្នុងរឿងក្តីប្រឆាំងមន្ត្រីថ្នាក់ទាបមួយចំនួនដូចជា លីអូណេតូ ម៉ាទីន, អាឌីអូស សាលូវ៉ា និង អាសេប កូស្វានី (អ្នកទាំងអស់នេះត្រូវបានកាត់ឲ្យរួចទោស) ។ សមាជិកកងជីវពលមួយចំនួនបានប្រាប់ខេភីភីហាំអំពីការកប់ជាសម្ងាត់នូវសាកសពដែលត្រូវសម្លាប់នៅឯព្រះវិហារតាមបញ្ជារបស់ ធីអិនអាយ ប៉ុន្តែសមាជិកកងជីវពលទាំងអស់នេះមិនត្រូវបានកោះហៅមកធ្វើជាសាក្សីទេ ។ សាក្សីដ៏សំខាន់មួយរូបទៀតដែលគួរតែកោះហៅដែរនោះគឺ អាម៉ានដូ ដុសសាន់តូស ។ អតីតកងជីវពលរូបនេះត្រូវក្រុមពិសេសសម្រាប់អំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរកាត់ទោសនៅទីក្រុងឌីលីកាលពីដើមឆ្នាំ២០០២ និងបានផ្តល់សក្ខីកម្មអំពីសកម្មភាពរបស់គាត់ជាមួយ *BMP* ។ គាត់បាននិយាយអំពីការចូលរួមនៅក្នុងការវាយប្រហារទៅលើក្រុមអ្នកគាំទ្រស្វ័យភាពក្នុងតំបន់ ក្រោមបញ្ជាពីក្រុមទាហានធីអិនអាយៈ *“រាល់ពេល យើងត្រូវតែមកជួបជុំគ្នានៅកន្លែងមួយ ហើយក្រុមទាហានធីអិនអាយប្រាប់យើងថាត្រូវចុះទៅកន្លែងណានិងសម្លាប់ប្រជាជន ។ ប្រសិនបើយើងមិនទៅ យើងនឹងត្រូវសម្លាប់ទាំងគ្រួសារ”* ។ នៅមុនពេលមានការសម្លាប់រង្គាលនៅឯព្រះវិហារលីគីកា ដូសសាន់តូស បានអះអាងថា គាត់និងសមាជិកផ្សេងទៀតនៃកងជីវពលត្រូវបាននាំទៅតំបន់ម៉ូបារ៉ាជាទីកន្លែងដែលទាំងអស់គ្នាត្រូវបង្ខំឲ្យចូលរួមក្នុងពិធីផឹកឈាម ។ ឈាមសត្វដែលបូជានោះលាយបញ្ចូលគ្នាជាមួយស្រានិងថ្នាំខាប់ៗ ។ ធីអិនអាយប្រាប់កងជីវពលឲ្យទៅលីគីកាដើម្បីសម្លាប់ប្រជាជននៅទីនោះ ។ បន្ទាប់

មក ទាហាន៤-៥នាក់បានដឹកកងជីវពលទាំងអស់ទៅលីគីកា ។ នៅលីគីកា កងជីវពលបានជួបជាមួយក្រុមទាហានផ្សេងៗទៀត ដែលស្លៀកពាក់ស៊ីវិលទាំងអស់ ។ កងជីវពលមកពីម៉ូបារ៉ាបានធ្វើដំណើរមកដល់លីគីកា នៅពេលព្រឹក ប៉ុន្តែមិនអាចចូលទៅក្នុងព្រះវិហារបានទេ ហើយក៏អង្គុយជុំគ្នានៅទីបញ្ជាការយោធាស្រុក ។ «គ្រាន់តែក្រុម ធីអិនអាយ ដែលបិទមុខជិតបាញ់កាំភ្លើងភ្លាម យើងចូលទៅក្នុងព្រះវិហារ... ។ ពិតហើយមានមនុស្សច្រើនណាស់នៅក្នុងព្រះវិហារនោះ មានទាំងកងជីវពលមានមកពីម៉ូបារ៉ា និងលីគីកា មានទាំងក្រុមទាហាននិងប៉ូលិសបង្ក្រាបកុបកម្ម ។ អ្នកទាំងអស់នោះយកក្រណាត់រុំមុខជិតៗ ហើយយើងក៏ធ្វើតាម» ការវាយប្រហារបានចាប់ផ្តើមដោយការបាញ់កាំភ្លើងនិងខស្ទ័នបង្ហូរទឹកភ្នែក ។ «ក្រុមទាហានជាអ្នកបាញ់ខស្ទ័នបង្ហូរទឹកភ្នែក» ។ ដូសសាន់តូស បានអះអាង ថាគាត់បានសម្លាប់មនុស្សម្នាក់ ហើយបានគេចចេញពីខស្ទ័នបង្ហូរទឹកភ្នែក ប៉ុន្តែបានជួបអភិបាលស្តីទី លីអូណេតូ ម៉ាទីន ហើយ ម៉ាទីនប្រាប់គាត់ឲ្យត្រឡប់ចូលក្នុងឆាកប្រយុទ្ធវិញនិងប្រាប់ឲ្យវាយប្រហារទៅលើបណ្តាអ្នកគាំទ្រឯករាជ្យភាពៈ «យើងជួបគាត់នៅតាមផ្លូវ ហើយគាត់បានណែនាំយើងឲ្យត្រឡប់ទៅវិញ និងឡោមព័ទ្ធក្រុមប្រជាជនដែលនៅក្នុងព្រះវិហារ» ។ បន្ទាប់ពីវិលត្រឡប់ទៅភូមិវិញ កងជីវពលទាំងអស់ត្រូវបានកោះហៅមកទីបញ្ជាការយោធានិងផ្តល់ប្រាក់ចំនួន២៥ម៉ឺនរ៉ូពី ។ អាម៉ានដូ ដូសសាន់តូស គួរតែជាសាក្សីដ៏សំខាន់អំពីការសម្លាប់រង្គាលកាលពីខែមេសា ឆ្នាំ១៩៩៩ នៅផ្ទះរបស់ ម៉ានូអែល ការ៉ាសកាឡូ ។ គាត់បានផ្តល់សក្ខីកម្មនៅចំពោះមុខក្រុមពិសេសនៃតុលាការថ្នាក់ខ័ណ្ឌនៅទីក្រុងឌីលីថា ក្រុមទាហានធីអិនអាយបានប្រមូលគាត់និងសមាជិកកងជីវពលផ្សេងទៀត នៅឯទីបញ្ជាការយោធាឃុំនៅម៉ូបារ៉ា បន្ទាប់មកនាំទៅទីក្រុងឌីលីដើម្បីចូលរួមក្នុងការវាយប្រហារទៅលើផ្ទះរបស់ ម៉ានូអែល ការ៉ាសកាឡូ រួមជាមួយកងជីវពលដទៃទៀត ។ «ក្រុមធីអិនអាយបាននាំយើងទៅទីក្រុងឌីលីនៅថ្ងៃនោះ និងបានជួបជុំគ្នាជាមួយកងជីវពលផ្សេងៗ ។ ចូអៅ តាវ៉ារ៉េស និង អឺរីកូ គូតេរេស ឈរនៅលើផ្លូវហើយបញ្ជាយើង ។ ក្រុមទាហានដែលបិទមុខជិតបាននាំកងជីវពលទៅផ្ទះមួយស្ថិតនៅក្បែរសណ្ឋាគារត្រូពិកខល ។ ប្រសិនបើយើងសម្លឹងមើលមួយភ្លែត អ្នកទាំងនោះដូចជាកងជីវពល ប៉ុន្តែតាមពិតអ្នកទាំងនោះជាទាហាន ។ មានសមាជិកកងជីវពលនិងធីអិនអាយយ៉ាងច្រើនបាញ់កាំភ្លើងនៅជុំវិញផ្ទះនោះ» បន្ទាប់ពីការវាយប្រហារបានបញ្ចប់ ធីអិនអាយ បានដឹកសមាជិកកងជីវពលទៅផ្ទះរបស់ អឺរីកូ គូតេរ៉េស និងធ្វើម្ហូបជប់លៀងអ្នកទាំងនោះរួចទើបដឹកទៅផ្ទះវិញ ។

ក្រុមអ្នកស៊ើបអង្កេតដែលស្វះស្វែងរកការកសាងសំណុំរឿងដ៏រឹងមាំដើម្បីចោទប្រកាន់មេបញ្ជាការប៉ូលិសទីម័រខាងកើតឈ្មោះ ធីមប៊ុល ស៊ីឡែន គួរតែពិនិត្យពិចារណាលើការចោទប្រកាន់របស់ សាន់ត្យាហ្គោ ដូសសាន់តូស កុនសេឡា ជាអ្នកដែលរស់រានមានជីវិតពីការសម្លាប់រង្គាលនៅផ្ទះរបស់ ការ៉ាសកាឡូ ។ គាត់បានប្រាប់អង្គការក្រៅរដ្ឋាភិបាលមួយឈ្មោះ យ៉ាយ៉ាសានហាក់ ថាគាត់និងអ្នកផ្សេងទៀតដែលនៅរស់រានមានជីវិត ត្រូវក្រុមប៉ូលិសនៅទីក្រុងឌីលីចាប់ខ្លួននិងសួរចម្លើយ ។


រូបថតជនរងគ្រោះនៅមន្ទីរស-២១

បន្ទាប់ពីគាត់ប្រាប់ថាគាត់បានឃើញសមាជិកកងជីវពលមកពី BMP និងក្រុមយោធាមកពីម៉ូបារ៉ាំនិងកាមរ៉ា ចូលរួមនៅក្នុងការវាយប្រហារនោះ ក្រុមប៉ូលិសបានគំរាមវាយគាត់ប្រសិនបើគាត់មិនប្តូរចម្លើយ ។ គាត់បានអះអាងថា ប៉ូលិសបានប្រាប់គាត់មិនឲ្យនិយាយថាអ្នកវាយប្រហារមានអាវុធស្វ័យប្រវត្តិ មិនឲ្យនិយាយថាក្រុមយោធាណាមួយបានចូលរួមក្នុងការវាយប្រហារ និងមិនឲ្យលាតត្រដាងថា កាមរ៉ា ជាប់ពាក់ព័ន្ធនៅក្នុងការវាយប្រហារនោះទេ ប៉ុន្តែត្រូវនិយាយថា មានតែកងជីវពលតែប៉ុណ្ណោះបានធ្វើការវាយប្រហារ ហើយការវាយប្រហារនោះប្រើប្រាស់តែកាំភ្លើងផលិតក្នុងស្រុកឬកាំភ្លើងចាស់ៗប្រភេទ G-៣តែប៉ុណ្ណោះ ។ គាត់បន្តទៀតថា ប៉ូលិសបានបង្ខំឲ្យគាត់និងអ្នកដទៃទៀតនិយាយថា កងកម្លាំងតស៊ូទីម័រខាងកើតជាអ្នកបាញ់ចេញពីផ្ទះរបស់ ការ៉ាសកាឡូ មុន ទើបកងជីវពលបើកការវាយប្រហារតបវិញ ។ គ្មានស្ថាប័នមានសមត្ថកិច្ចណាមួយធ្វើសម្ភាសមនុស្សម្នាក់នេះទាល់តែសោះ ។



ការដែលមន្ត្រីមេធាវីជ្រើសរើសសាក្សីដែលមិនមានប្រយោជន៍អ្វីសោះចំពោះដំណើរការក្តី កាន់តែមានផលមិនល្អបន្ថែមទៀតនៅពេលដែលសាក្សីដ៏សំខាន់ដែលបានយល់ព្រមផ្តល់សក្ខីកម្មតាំងពីដំបូង ស្រាប់តែបដិសេធមិនធ្វើដំណើរទៅទីក្រុងហ្សាកាតាបន្ទាប់ពីបានឃើញលទ្ធផលរបស់សាក្សីបីនាក់ដំបូងគឺ ដូមីងហ្គាស ដូស សាន់តូស មូហ្សីនហូ, អេមីឡូ បារេតូ, និង ចូអៅ ប៉េរៀរ ។ ចំណុចសំខាន់ដែលទាក់ទងទៅនឹងការការពារសាក្សីគឺថា ប៉ូលិសបានអនុញ្ញាតឲ្យ អឺរីកូ គូតេរ៉េស និងក្រុមអ្នកច្បាប់របស់ អាប៊ីលីអូ ស័ររ៉េ ចូលទៅក្នុងបន្ទប់រង់ចាំរបស់សាក្សី ហើយនិយាយទៅកាន់សាក្សីម្នាក់ដែលកំពុងតែរង់ចាំនៅទីនោះថា “ផ្ទះដែលមានសុវត្ថិភាព” គឺស្ថិតនៅចំកណ្តាលបរិវេណរបស់ប៉ូលិស ហើយប៉ូលិសឯកសណ្ឋានត្រូវបានដាក់ពង្រាយនៅគ្រប់ទីកន្លែងទាំងអស់ ។ ក្នុងខណៈពេលដែលអគ្គរដ្ឋអាជ្ញាទីម័រខាងកើតមានសុឆន្ទៈយ៉ាងមុតមាំក្នុងការជួយដល់ដំណើរការក្តីដោយនាំយកខ្សែវីដេអូមកពីទីម័រខាងកើត តុលាការបែរជាមិនអនុញ្ញាត ហើយយល់ព្រមឲ្យមានការអានសក្ខីកម្មរបស់សាក្សីតែប៉ុណ្ណោះ ។

សាក្សីមួយចំនួនដែលមានឈ្មោះនៅក្នុងសំណុំឯកសាររបស់រដ្ឋអាជ្ញាដែលបានដាក់ជូនទៅតុលាការ មិនត្រូវបានកោះហៅមកធ្វើជាសាក្សីនៅក្នុងតុលាការទេ ហើយក៏គ្មានការពន្យល់អំពីមូលហេតុណាមួយដែរ ។

ឧទាហរណ៍ នៅក្នុងរឿងក្តីរបស់ ធីមប៊ុល ស៊ីឡែន, វីសិនតេ ដឺ ស៊ូសា ត្រូវបានសម្ភាសន៍និងកត់ត្រាសម្តីរបស់គាត់នៅក្នុងសំណុំឯកសារ ។ គាត់បានចោទប្រកាន់ថា បន្ទាប់ពីការប្រកាសលទ្ធផលប្រជាមតិ ទាហានឥណ្ឌូនេស៊ីនៅទីក្រុងឌីលីបានយាមសណ្ឋាគារម៉ាកូតា ។ ក្រុមទាហានទាំងនោះមិនបានជួយប្រជាជនដែលស្ថិតនៅក្រោមការវាយប្រហាររបស់កងជីវពលទេ ។ គាត់ក៏បានចោទប្រកាន់ទៀតថា កងជីវពលនិងកងទ័ពបានដុតផ្ទះរបស់គាត់និងរបស់ប្រជាជនដទៃទៀត ។ ដឺ ស៊ូសា ស្គាល់អត្តសញ្ញាណយ៉ាងហោចណាស់ក៏មន្ត្រីរាជការម្នាក់ (គឺអតីតប្រធានភូមិហេរ៉ា) ដែលបានបាញ់រះដោយកាំភ្លើងវែងរបស់យោធា រួមជាមួយកងជីវពលអៃតារ៉ាក់ ។ សាក្សីរូបនេះមិនត្រូវបានកោះហៅមកផ្តល់

សក្ខីកម្មទេ ហើយសូម្បីតែកសិណសាក្សីរបស់គាត់ក៏មិនត្រូវបាន អាននៅក្នុងគ្រួសារដែរ ។ ក្រៅពី ដឺ ស៊ូសា គ្មានសាក្សីណាផ្សេងទៀតអាចផ្តល់ភ័ស្តុតាងដ៏ពិស្តារបែបនេះទេ ។

ក្នុងពេលជំនុំជម្រះ មានតែសាក្សីជាជនជាតិទីម័រខាងកើតតែម្នាក់គត់បានផ្តល់កសិណអំពីការសម្លាប់រង្គាលនៅព្រះវិហារសួយ ។ (គាត់គឺ ដូមីងកាស ដូស សាន់តូស ដែលតុលាការបានកោះហៅមកផ្តល់កសិណនៅក្នុងរឿងក្តី ធីមប៊ុល ស៊ីឡែន) ។ សាក្សីពីរនាក់ទៀតបានផ្តល់សក្ខីកម្មផ្ទាល់ភ្នែកអំពីការសម្លាប់រង្គាលនៅព្រះវិហារសួយ ក្នុងពេលដំណើរការកាត់ក្តី ធីមប៊ុល ស៊ីឡែន ហើយនៅទាទីចុងក្រោយ អ្នកទាំងពីរនេះបានបង្ហាញខ្លួននៅក្នុងដំណើរការកាត់ក្តី អាប៊ីលីអូ ស័រវ៉េ ដោយគ្មានការកោះហៅ ។ គ្មានកសិណរបស់ជនរងគ្រោះស្តីអំពីការសម្លាប់និងការវាយប្រហារនៅផ្ទះរបស់ ម៉ានូអែល ការ៉ាសកាឡូ និងការវាយប្រហារនៅលំនៅឋានរបស់អាចារ្យ បេឡូ ដែលជាមូលដ្ឋានគ្រឹះនៃការចោទប្រកាន់ អាប៊ីលីអូ ស័រវ៉េ និង ធីមប៊ុល ស៊ីឡែន ។ ជំនួសឲ្យការយកសាក្សីជាច្រើន រាប់បញ្ចូលទាំងអ្នកនៅរស់រានមានជីវិតពីឧបទ្ទវហេតុ បុគ្គលិកអង្គការសហប្រជាជាតិអ្នកកាសែត និងអ្នកស៊ើបអង្កេតអន្តរជាតិឯករាជ្យ រដ្ឋអាជ្ញាបែរជាចង់កសាងសំណុំរឿងក្តីតាមរយៈមន្ត្រីឥណ្ឌូនេស៊ីដែលបម្រើការងារនៅទីម័រខាងកើត ដូចជា ក្រុមធីអិនអាយ ក្រុមប៉ូលិស និងមន្ត្រីរាជការ ។ ធ្វើដូច្នេះមានប្រយោជន៍ក្នុងការជួយឲ្យជនជាប់ចោទរួចទោស ។ សាក្សីទាំងអស់ដែលរដ្ឋអាជ្ញាបានជ្រើសរើស មានប្រយោជន៍ក្នុងការបិទបាំងកំហុសរបស់ជនជាប់ចោទ ហើយច្រានចោលការចោទប្រកាន់របស់រដ្ឋអាជ្ញា ។ ការពិតដែលថាសាក្សីទាំងនេះកំពុងតែប្រឈមមុខនឹងការកាត់ទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិហាក់ដូចជាមិនអាចទៅរួចទេ ដែលសាក្សីទាំងនេះធ្វើឲ្យខ្លួនឯងមានទោសកំហុសដោយការផ្តល់នូវភ័ស្តុតាងប្រឆាំងមេបញ្ជាការឬមន្ត្រីថ្នាក់ខ្ពស់ ។ ដើម្បីចោទប្រកាន់ ធីមប៊ុល ស៊ីឡែន និង អាប៊ីលីអូ ស័រវ៉េ រដ្ឋអាជ្ញាបានកោះហៅថ្នាក់លើនិងអ្នកក្រោមបង្គាប់របស់ជនជាប់ចោទ ។ ទោះបីជាច្បាប់ឥណ្ឌូនេស៊ីតម្រូវថា សាក្សីដំបូងបង្អស់គឺជាជនរងគ្រោះនៃអំពើឧក្រិដ្ឋកម្មក៏ដោយ ក៏សាក្សីដំបូងបង្អស់ដែលបង្ហាញដោយរដ្ឋអាជ្ញានៅក្នុងករណី ធីមប៊ុល ស៊ីឡែន គឺឧត្តមសេនីយ៍ វីរ៉ាន់តូ រដ្ឋមន្ត្រីក្រសួងការពារជាតិក្នុងអំឡុងខែកញ្ញា ឆ្នាំ១៩៩៩ ។ ក្រៅពីមិនផ្តល់កសិណគាំទ្រដល់ការចោទប្រកាន់ វីរ៉ាន់តូ ថែមទាំងច្រៀងលើកសរសើរដល់ជនជាប់ចោទនិងបដិសេធថា ធីអិនអាយ ប៉ូលិស ឬរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ស្រុកមិនមានពាក់ព័ន្ធអ្វីនឹងអំពើហិង្សានៅទីម័រខាងកើតទេ ។ ឧទាហរណ៍ដ៏ល្អមួយទៀតនៃការជ្រើសរើសសាក្សីរបស់រដ្ឋអាជ្ញា នោះគឺអតីតមេបញ្ជាការយោធាប្រចាំតំបន់យូដាយ៉ាណាទី៩ ឈ្មោះ អាដាម ដាមីរី ដែលមានទោសរួចទៅហើយពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅទីម័រខាងកើត ។ កសិណរបស់ អាដាម ដាមីរី គឺថា ហេតុការណ៍ទាំងអស់គឺជាកំហុសរបស់ប្រជាជនទីម័រខាងកើតដែលឆាប់រំជួលចិត្តនិងជានិច្ចកាលប្រយុទ្ធគ្នាឯង និងជាកំហុសរបស់អង្គការសហប្រជាជាតិដែលធ្វើប្រជាមតិបោកប្រាស់ បានបោកបញ្ឆោតប្រជាជនទីម័រខាងកើតអំពីសិទ្ធក្នុងការបោះឆ្នោតដើម្បីស្ថិតនៅជាផ្នែកមួយនៃប្រទេសឥណ្ឌូនេស៊ី ។ ការផ្តល់កសិណរបស់គាត់ក្នុងរឿងក្តីទាំងបីនេះគឺដូចៗគ្នាៈ "គ្រប់ជនជាប់ចោទទាំងអស់បានប្រឹងប្រែងអស់ពីសមត្ថភាពដែលខ្លួនអាចធ្វើបាន" ។ ពេលដែលរដ្ឋអាជ្ញាកោះហៅគាត់មកធ្វើសាក្សីពីរដង គាត់បាននិយាយឃ្លានេះទាំងពីរដង ។ កសិណរបស់ឧត្តមសេនីយ៍ វីរ៉ាន់តូ និង អាដាម ដាមីរី ដូចគ្នាគឺថា ជនជាប់ចោទមិនបានធ្វើអ្វីខុសទេ ហើយមិនសមទទួលការកាត់ទាល់តែសោះ ។

ខាងក្រោមនេះគឺជាការពិនិត្យមើលឲ្យកាន់តែដិតដល់ជាងមុន ទៅលើការជ្រើសរើសសាក្សីរបស់រដ្ឋអាជ្ញានៅក្នុងសំណុំរឿងក្តីទាំងបីករណី ។

**ករណី ធីមប៊ុល ស៊ីឡែន**

សាក្សីដើមចោទឈ្មោះ កាតុត ស៊ុបីយ៉ាក់តូរ៉ូ គឺជាមេប៉ូលិសនៅសួយដែលស្ថិតនៅក្រោមបញ្ជារបស់ជនជាប់ចោទ ហើយខ្លួនគាត់ផ្ទាល់កំពុងតែប្រឈមមុខនឹងការជំនុំជម្រះទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ នៅពេលត្រូវបានចោទសួរថាតើមេបញ្ជាការរបស់គាត់បានធ្វេសប្រហែសដូចការចោទប្រកាន់មែនឬទេ គាត់បានឆ្លើយថា "មិនពិតទេ នេះជាការកុហក"

*ហើយបានបន្ថែមថា “ជានិច្ចកាល ជនជាប់ចោទចេញសេចក្តីណែនាំច្បាស់ៗអំពីតួនាទីនិងកិច្ចការរបស់ក្រុមប៉ូលិស និងបានទប់ស្កាត់នៅពេលដែលមានជម្លោះ ព្រមទាំងបានបន្តុលក្ខណៈងាយស្រួលដល់រាល់សកម្មភាពនៃការធ្វើប្រជាមតិ ។ គាត់ខឹងយ៉ាងខ្លាំងនៅពេលដែលបុគ្គលិកមិនបំពេញការងារតាមតួនាទី” ។ គាត់ក៏បានផ្តល់ឧទាហរណ៍អំពីការណែនាំរបស់ជនជាប់ចោទអំពីរបៀបចាត់ការជាមួយប្រជាជនទីម័រខាងកើតដែលកំពុងឈ្លោះគ្នានេះថា៖ បញ្ឈប់ឧបទ្ទវហេតុបែបនេះ និងការពារស្ថិរភាពសង្គម...។ បើយោងទៅតាមសាក្សី ប្រជាជនក្នុងតំបន់បានយល់ព្រមមិនបង្កជម្លោះ មិនបង្កការប្រយុទ្ធ រក្សាសន្តិភាព និងពួកដៃគ្នាកសាងសង្គមទោះជាដើម្បីស្វ័យភាពឬឯករាជ្យភាពក្តី ។ “ស៊ីឡែន តែងតែប្រាប់យើងថា យើងត្រូវតែអព្យាក្រឹត មិនគាំទ្រខាងណាមួយ មិនបត់បែនតាមនយោបាយ ។ នោះគឺជាអ្វីដែលគាត់បាននិយាយ ហើយខ្ញុំបានពាំនាំពាក្យសម្តីទាំងអស់នេះទៅប្រាប់បុគ្គលិករបស់ខ្ញុំផ្ទាល់” ។* ក្រុមប៉ូលិសបានបើកការវាយប្រហារយ៉ាងច្រើនដើម្បីរឹបអូសអាវុធ ។ នៅពេលនិយាយអំពីតួនាទីរបស់ខ្លួនគាត់ផ្ទាល់នៅក្នុងការសម្លាប់រង្គាលនៅឯព្រះវិហារស្វួយ សាក្សីរូបនេះបានអះអាងថា គាត់បានប្រញាប់ប្រញាល់ទៅកន្លែងកើតហេតុ បានព្យាយាមបញ្ឈប់ការសម្លាប់រង្គាល និងបានអំពាវនាវសុំកម្លាំងជំនួយពីក្រុមប៉ូលិសចល័ត ។ គាត់បានផ្តល់កសិណថា បន្ទាប់ពីគាត់បានចេញបញ្ជាឲ្យដើរល្បាតដើម្បីធានាសុវត្ថិភាព ដូច្នេះគ្មានការឈ្លោះប្រកែកគ្នានៅកន្លែងផ្សេងទៀតទេ បន្ទាប់មកចាត់ឲ្យមានការស៊ើបអង្កេតឧបទ្ទវហេតុនេះ ប៉ុន្តែពេលនោះមេឃចាប់ផ្តើមងងឹត ហើយក៏មានការបាញ់កាំភ្លើងនិងដុតបំផ្លាញនៅកន្លែងកើតហេតុ ។ គាត់បានផ្តល់កសិណទៀតថា គាត់បានរាយការណ៍ស្តីអំពីឧបទ្ទវហេតុនេះទៅទីក្រុងឌីលី ប៉ុន្តែ ស៊ីឡែន កំពុងតែដោះស្រាយអំពើហិង្សាដែលកំពុងផ្ទុះឡើងនៅក្នុងទីក្រុង ហើយ ស៊ីឡែន មិនអាចមកសួយបានដោយសារសភាពការណ៍រារាំង ។ ស៊ីប៊ីយ៉ាក់តូរ៉ូ បានប្រាប់អនុរបស់ ស៊ីឡែន ។

សាក្សីដើមចោទ អាឌីអូស សាលូវ៉ា ដែលជាជនជាប់ចោទនៅក្នុងរឿងក្តីមួយផ្សេងទៀត គឺជាអតីតមេប៉ូលិសនៅលីគីកាដែលស្ថិតនៅក្រោមបញ្ជារបស់ ស៊ីឡែន ។ សាក្សីរូបនេះបានផ្តល់កសិណអំពីកិច្ចខិតខំប្រឹងប្រែងរបស់គាត់ក្នុងការដោះស្រាយអំពើហិង្សាដែលចេះតែកើនឡើងក្នុងចំណោមប្រជាជននៅក្នុងស្រុក អំពីរបៀបដែលក្រុមប៉ូលិសរបស់គាត់បើកការវាយប្រហារជាច្រើនលើកច្រើនសាដើម្បីរឹបអូសអាវុធ និងអំពីរបៀបដែលក្រុមប៉ូលិសបានព្យាយាមចរចាបញ្ចប់ជម្លោះនៅព្រះវិហារនោះ ។ គ្មានប៉ូលិសណាម្នាក់បានជាប់ពាក់ព័ន្ធនៅក្នុងសកម្មភាពឧក្រិដ្ឋនៅព្រះវិហារនោះទេ ផ្ទុយទៅវិញ ក្រុមប៉ូលិសបានជួយសង្គ្រោះប្រជាជនជាច្រើននាក់ ។ នៅពេលវិលត្រឡប់ពីទីក្រុងហ្សាកាតាវិញនិងបានដឹងអំពីអ្វីដែលបានកើតឡើង ធីមប៊ុល ស៊ីឡែន “បានចេញបញ្ជាថា ត្រូវតែធានាសុវត្ថិភាពនៅកន្លែងកើតហេតុឲ្យបាន ត្រូវតែចាប់ខ្លួនជនដៃដល់ និងត្រូវតែបញ្ជូនអ្នកស៊ើបអង្កេតមួយក្រុមមកពីទីបញ្ជាការប៉ូលិស” ។ មនុស្សចំនួន១១នាក់ត្រូវចាប់ខ្លួន ។

សាក្សីដើមចោទម្នាក់ទៀតឈ្មោះ ហ៊ុលម៉ាន គុលគុម ជាអតីតមេបញ្ជាការប៉ូលិសនៅទីក្រុងឌីលី ក៏ប្រឈមនឹងការជំនុំជម្រះពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ។ គាត់ស្ថិតនៅក្រោមបញ្ជារបស់ជនជាប់ចោទ ធីមប៊ុល ស៊ីឡែន ហើយដែលសកម្មភាពរបស់គាត់គឺជាការទទួលខុសត្រូវរបស់ជនជាប់ចោទ ។ គាត់បានពិពណ៌នាអំពីរបៀបដែល ស៊ីឡែន បញ្ជូនកងកម្លាំងជំនួយទៅគេហដ្ឋានរបស់ ការ៉ាសកាឡូ ភ្លាមៗបន្ទាប់ពីឮថាមានការគំរាមកំហែងនៅទីនោះ ។ ស៊ីឡែន បានចាកចេញទៅទីក្រុងហ្សាកាតាដើម្បីបំពេញភារកិច្ចផ្លូវការ ។ មានតែមនុស្សរបស់គាត់ប៉ុណ្ណោះដែលនៅក្នុងការិយាល័យ “គាត់បានបញ្ជាខ្ញុំឲ្យដោះស្រាយឧបទ្ទវហេតុនោះ និងទប់ស្កាត់កុំឲ្យរាលដាលទៅដល់កន្លែងផ្សេងទៀត ។ *BRIMOB* បានមកដល់កន្លែងកើតហេតុ ហើយបានជួយសង្គ្រោះមនុស្សចំនួន៤២នាក់ ។ ប្រសិនបើយើងមិនធ្វើអ្វីៗសោះនោះម្ល៉េះសមមនុស្សទាំង៤២នាក់ត្រូវសម្លាប់អស់ហើយ ។...ប៉ុន្មានម៉ោងក្រោយមក ខ្ញុំបានធ្វើដំណើរទៅអាកាសយានដ្ឋានដើម្បីជួបជាមួយ ធីមប៊ុល ស៊ីឡែន និងរាយការណ៍លម្អិត

ជូនគាត់អំពីឧបទ្ទវហេតុនាថ្ងៃនោះ ។ គាត់បានប្រាប់ខ្ញុំឲ្យស៊ើបអង្កេត និងធានាសុវត្ថិភាពដល់ផ្ទះរបស់មេដឹកនាំគាំទ្រឯករាជ្យភាព ដើម្បីកុំឲ្យឧបទ្ទវហេតុដដែលកើតឡើងទៀត» ។ សាក្សីនេះបានអះអាងថាបានចាប់ខ្លួនមនុស្សចំនួន១១នាក់ ។

ចំពោះការវាយប្រហារនៅទីក្រុងឌីលី នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៩៩៩ សាក្សី សាលូវ៉ា បាននិយាយថា ស៊ីឡែន បានព្យួតាមវិទ្យុអំពីបញ្ហានេះ ហើយបានបញ្ជូនកម្លាំងទៅជួយដល់កងកម្លាំងក្នុងតំបន់ ។ «ស៊ីឡែន បានចេញបញ្ជាឲ្យខ្ញុំបន្តអនុវត្តភារកិច្ចប៉ូលិស បើទោះជាមានបុគ្គលិកកម្លាំងក៏ដោយ ។ សូម្បីតែយើងមានកម្លាំងតិចតួចក៏ដោយ ក៏យើងធ្វើកិច្ចការបានល្អ ។ នៅថ្ងៃនោះ ស៊ីឡែន បានជិះឧទ្ធម្ភាគចក្រពិនិត្យមើលសភាពការណ៍នៅក្នុងនិងជុំវិញទីក្រុងឌីលី ។ គាត់បានបញ្ជាខ្ញុំតាមវិទ្យុទាក់ទងឲ្យបន្តធ្វើកិច្ចការជាពិសេសកិច្ចការមនុស្សធម៌» ។

## ករណី អាប៊ីលីអូ ស័រេ៉

សាក្សីដើមចោទ ឈ្មោះ តូណូ ស៊ុរ៉ាម៉ាន ជាអតីតមេបញ្ជាការយោធាប្រចាំតំបន់ទីម័រខាងកើត និង អាដាម ដាមីរី មេបញ្ជាការយោធា យូដាយ៉ាណាទី៩ បានប្រឈមមុខនឹងការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ មេធាវីចុងចោទបានសួរសំណួរដូចខាងក្រោមទៅសាក្សីទាំងពីរៈ «លោកត្រូវបាននាំមកធ្វើជាសាក្សីប្រឆាំងជនជាប់ចោទ តើលោកធ្លាប់បានព្យួលទ្ធផលនៃការស៊ើបអង្កេតអំពីការជាប់ពាក់ព័ន្ធរបស់ជនជាប់ចោទដែរឬទេ? តើជនជាប់ចោទបានជាប់ពាក់ព័ន្ធដែរឬអត់?» សាក្សីបានឆ្លើយថាៈ «តាមដែលខ្ញុំដឹង ជនជាប់ចោទមិនមានការជាប់ពាក់ព័ន្ធទេ» ។ សាក្សីបាននិយាយទៀតថា ការចោទប្រកាន់ជនជាប់ចោទគឺមិនត្រឹមត្រូវ ។ នៅពេលចៅក្រមសួរថា តើអ្នកណាវាយប្រហារទៅលើអ្នកណាក្នុងអំឡុងពេលមានការវាយប្រហារ សាក្សីបានឆ្លើយតបទៅវិញថា ហេតុការណ៍ទាំងនោះមិនមែនជាការវាយប្រហារទេ ប៉ុន្តែជាការឈ្លោះប្រកែកគ្នាទៅវិញទេ ។ គាត់មិនដែលបានទទួលសេចក្តីរាយការណ៍ណាមួយថាធីអិនអាយឬជនជាប់ចោទជាប់ពាក់ព័ន្ធនឹងការរំលោភសិទ្ធិមនុស្សនៅទីម័រខាងកើតទាល់តែសោះ ។ អាដាម ដាមីរី បាននិយាយថា គ្មានសេចក្តីរាយការណ៍បង្ហាញថាជនជាប់ចោទបានប្រព្រឹត្តឬបានបង្កឲ្យមានការសម្លាប់នោះទេ ។ «ខ្ញុំសូមអះអាងថា លោកអភិបាលបានធ្វើកិច្ចការជាច្រើនដើម្បីប្រជាជនទីម័រខាងកើត ។ គាត់បានធ្វើលើសពីតួនាទីរបស់អភិបាលទៅទៀតបើប្រៀបជាមួយអភិបាលខេត្តដទៃ ។ ឧទាហរណ៍ គាត់បានទៅទស្សនកិច្ចនៅតំបន់ដាច់ស្រយាលយ៉ាងច្រើនជាមួយថ្នាក់ដឹកនាំមូលដ្ឋាននិងធ្វើការផ្សះផ្សាជាបន្តបន្ទាប់» ។

មេដឹកនាំកងជីវពល អឺរីកូ គូតេរ៉េស ដែលចុងបញ្ចប់ជាប់ទោសពីបទឧក្រិដ្ឋកម្មសង្គ្រាម ត្រូវបានកោះហៅឲ្យមកគាំទ្រការចោទប្រកាន់របស់រដ្ឋអាជ្ញាប្រឆាំង អាប៊ីលីអូ ស័រេ៉ ។ ជនជាប់ចោទជាអ្នកដែលទទួលខុសត្រូវចំពោះសកម្មភាពរបស់ គូតេរ៉េស ។ សំណុំឯកសារចោទប្រកាន់បានបង្ហាញថា សាក្សីរូបនេះមិនត្រូវបានរដ្ឋអាជ្ញាសម្ភាសទាក់ទងទៅនឹងករណីនេះទេ ទោះបីជាគាត់នៅក្រោមបង្គាប់របស់ជាជនជាប់ចោទក៏ដោយ ។ នៅចុងបញ្ចប់នៃសំណុំរឿងក្តី រដ្ឋអាជ្ញាបានចេញសេចក្តីប្រកាសដែលនឹកស្មានមិនដល់ថា ត្រូវកោះហៅ គូតេរ៉េស មកធ្វើជាសាក្សី ។ សាក្សីខ្លួនឯងបានប្រាប់តុលាការថា គាត់គួរតែជាសាក្សីរបស់ចុងចោទជាជាងសាក្សីរបស់ដើមចោទ ។ ទាក់ទិនទៅនឹងការវាយប្រហារនៅលីគ្វីកា សាក្សីបាននិយាយថា គាត់បានចុះទៅដល់ទីនោះក្នុងនាមជាបេសកជនសន្តិភាពរបស់អាចារ្យបេឡូ និងបាននាំយកអង្ករ១០គីឡូក្រាមទៅចែកជូនដល់អ្នកដែលរត់ចេញពីផ្ទះសម្បែងដោយសារការប្រយុទ្ធគ្នាទៀតផង ។ គាត់បានធ្វើដំណើរទៅដល់ម៉ូបារ៉ាដើម្បីពិនិត្យមើលការខូតខាតដែលបណ្តាលមកពីការប្រយុទ្ធគ្នាកាលពីដំបូងៗ ហើយនៅពេលដែលគាត់វិលត្រឡប់មកដល់លីគ្វីកាវិញ ការវាយប្រហារទៅលើព្រះវិហារបានបញ្ចប់ទៅហើយៈ «ខ្ញុំមិនបានដឹងទេ ពីព្រោះនៅពេលដែលខ្ញុំទៅដល់ទីកន្លែងនោះ ឧបទ្ទវហេតុនោះបានបញ្ចប់ទៅហើយ» ។ ព្រះវិហារគ្មានមនុស្សម្នាក់ទេ អ្នកទាំងអស់នោះអាចនៅឯទីបញ្ជាការយោធាស្រុក ឬក៏នៅឯលំនៅឋានរបស់អភិបាលស្តីទី ។ ព្រមពេលជាមួយគ្នានោះ សាក្សីបានអះអាងថាគាត់មិនមានវត្តមានទេនៅពេលដែលមានការវាយប្រហារផ្ទះរបស់

ម៉ានូអែល ការ៉ាសកាឡូ ។ សាក្សីទំនងជានៅវីកូរ៉ាម៉ាតាឡាងដើម្បីដោះស្រាយរឿងផ្ទះម្តាយរបស់គាត់ដែលត្រូវលួចដុតហើយបន្ទាប់ពីវិលត្រឡប់មកទីក្រុងឌីលីវិញទើបគាត់បានឮថាផ្ទះរបស់ ការ៉ាសកាឡូ ទទួលរងការវាយប្រហារ ។ ក្រុមប៉ូលិសបានបិទផ្ទះនោះ ដូច្នេះគាត់មិនអាចចូលទៅខាងក្នុងបានទេ ។ នៅពេលដែលរដ្ឋអាជ្ញាចោទសួរអំពីការវាយប្រហារដោយក្រុមគាំទ្រសមាហរណកម្មទៅលើប្រជាជនស៊ីវិលដែលបានសុះស្វែងរកទីជម្រកនៅទីក្រុងឌីលី នៅថ្ងៃទី៨និងទី៩ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលបណ្តាលឲ្យមានមនុស្សចំនួន៤០នាក់បានស្លាប់នោះ សាក្សីបានឆ្លើយថា «មិនពិតទេ ក្រុមសមាហរណកម្មមិនបានវាយប្រហារទេ» ។ គ្មាននរណាម្នាក់សាកសួរសាក្សីរូបនេះអំពីដំណើរការដែលទីម័រខាងកើតដែលត្រូវបានប្រែក្លាយទៅជា «សមុទ្រភ្លើង» ដូចដែលគាត់បានគំរាមកំហែងនៅឯការជួបប្រជុំស៊ុយភាពជាលើកចុងក្រោយនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៩នោះទេ ។ មេធាវីចុងចោទបានបដិសេធសំណួរចំពោះសាក្សី ដោយសំអាងថា សាក្សីមិនបានដឹងអំពីការចោទប្រកាន់នោះទេ ។

## ករណីសម្លាប់រង្គាលនៅព្រះវិហារស្វួយ

ប៉ូលិសនិងទាហានថ្នាក់ទាបមួយចំនួនដែលមានវត្តមាននៅកន្លែងកើតហេតុនៅឯព្រះវិហារ អេវ ម៉ារីយ៉ា ត្រូវបានកោះហៅមកធ្វើជាសាក្សីខាងដើមចោទ ។ សាក្សី ឈ្មោះ សូនី សានចាយ៉ា គឺជាសមាជិកក្រុមប៉ូលិសចល័តដែលស្ថិតនៅក្រោមបញ្ជារបស់អតីតមេបញ្ជាការប៉ូលិសនៅស្វួយឈ្មោះ កាតុត ស៊ុបីយ៉ាក់តូរូ ។ នៅពេលត្រូវបានចោទសួរថាតើជនជាប់ចោទទាំងប្រាំនាក់នៅក្នុងករណីនេះពិតជាបានធ្វើអ្វីដូចដែលបានចោទប្រកាន់ សាក្សីបានឆ្លើយតបថា «ប្រសិនបើរឿងនោះពិតជាបានកើតឡើងមែន លោកគួរតែចោទប្រកាន់ខ្ញុំផងទៅ ។ ខ្ញុំបានប្រឹងប្រែងអស់ពីសមត្ថភាពរបស់ខ្ញុំ ។ ខ្ញុំមានកំហុសដែលមិនមានលទ្ធភាពទប់ទល់សភាពការណ៍នោះ ប៉ុន្តែខ្ញុំបានព្យាយាមហើយ» ។ ពេលដែលរដ្ឋអាជ្ញាសួរថាៈ «តើជនជាប់ចោទបានប្រព្រឹត្តអំពើដែលរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរដែរឬទេ?» គាត់បានបដិសេធ ។

សាក្សីចោទប្រកាន់ឈ្មោះ អ៊ីវ៉ាយ៉ាន ស៊ីកា អានតារ៉ា គឺជាសមាជិកមួយរូបរបស់ទីបញ្ជាការ១៦៣៥យោធាស្រុករបស់ធីអិនអាយនៅស្វួយ និងជាមនុស្សម្នាក់ដែលខកខានពីដឹកាំ សង្ស័យថាទាក់ទងទៅនឹងការវាយប្រហារទៅលើព្រះវិហារស្វួយ ។ អាជម៉ាត យ៉ាមស៊ុឌីន និង លីលៀក គឺសាដៀនតូ ត្រូវចោទប្រកាន់ពីបទទទួលខុសត្រូវចំពោះសកម្មភាពរបស់ អានតារ៉ា ។ ឆ្លើយតបទៅនឹងសំណួររបស់ចៅក្រមនិងរដ្ឋអាជ្ញា សាក្សីបាននិយាយអំពីកិច្ចខិតខំប្រឹងប្រែងរបស់គាត់និងសហការី ដើម្បីបញ្ឈប់ការប្រយុទ្ធគ្នា និងដើម្បីទប់ស្កាត់មហាជនមិនឲ្យឡើងទៅក្នុងព្រះវិហារ ។ គាត់ក៏បានរៀបរាប់អំពីរបៀបដែលគាត់ សហការីរបស់គាត់ឈ្មោះ សូនី អ៊ីកានដា និងជនជាប់ចោទ អាជម៉ាត យ៉ាមស៊ុឌីន ចូលទៅក្នុងព្រះវិហារដើម្បីសង្គ្រោះប្រជាជន និងនាំប្រជាជនទៅកាន់កន្លែងសុវត្ថិភាពនៅឯទីបញ្ជាការយោធាស្រុក ។ គាត់បានបដិសេធថា ខ្លួនគាត់ ធីអិនអាយ និងក្រុមប៉ូលិសផ្សេងទៀត មិនបានវាយប្រហារព្រះវិហារនោះទេ ថែមទាំងនិយាយថា «*នៅពេលដែលយើងទៅដល់កន្លែងកើតហេតុ មានហ្វូងមនុស្សយ៉ាងច្រើន ។ យ៉ាមស៊ុឌីន បានដេញមនុស្សទាំងអស់នោះចេញ និងឃាត់មិនឲ្យចូលទៅក្នុង*» ។

សាក្សីដើមចោទឈ្មោះ សូនី អ៊ីកានដា គឺជាសមាជិកនៃទីបញ្ជាការយោធាស្រុក១៦៣៥នៅស្វួយ ហើយជាប់ចោទពីបទចូលរួមនៅក្នុងការវាយប្រហារទៅលើព្រះវិហារស្វួយ ។ ថ្នាក់លើរបស់គាត់ អាជម៉ាត យ៉ាមស៊ុឌីន និង លីលៀក គឺសាដៀនតូ ជាប់ចោទទទួលខុសត្រូវចំពោះសកម្មភាពរបស់ អ៊ីកានដា ។ សាក្សីបានផ្តល់ភស្តុតាងយ៉ាងទូលំទូលាយស្តីអំពីឥរិយាបថជាវីរបុរសរបស់ជនជាប់ចោទ អាជម៉ាត យ៉ាមស៊ុឌីន ៖

*នៅក្នុងផ្សារ យ៉ាមស៊ុឌីន បានបញ្ជាឲ្យខ្ញុំឲ្យកាន់អាវុធនិងទៅតាមគាត់ ។ គាត់បាននាំខ្ញុំទៅប៉ុស្តិ៍ប៉ូលិស ។ នៅទីនោះគាត់បានស្រែកខ្លាំងៗ ហើយបានគ្រវីដៃដើម្បីរារាំងមហាជនដែលកំពុងតែព្យាយាមចូលទៅក្នុងព្រះវិហារ ។ ខ្ញុំក៏បានស្រែកដែរ ហើយសមាជិកទីបញ្ជាការយោធាស្រុកដែលទើបតែមកដល់ក៏បានស្រែកឡើងដែរ ។ ធ្វើដូច្នេះមហាជនមិនអាចចូលទៅក្នុងព្រះវិហារបានទេ ។ ដោយសារមានមនុស្សច្រើនលើសលប់ពេក*

យ៉ាស៊ីឌីន និងខ្ញុំ ព្រមទាំងសមាជិកផ្សេងៗទៀត បានចូលទៅក្នុងបរិវេណព្រះវិហារ ។ មានស្ត្រីនិងកុមារកំពុងតែស្រែកយំរកជំនួយ ។ នៅពេលនោះ គឺមានតែ យ៉ាមស៊ីឌីន និងខ្ញុំ ព្រមទាំងសើទុវ៉ាយ៉ាន ។ យ៉ាមស៊ីឌីន បាននាំស្ត្រីនិងកុមារទៅកន្លែងមានសុវត្ថិភាព ហើយបញ្ជា សើទុវ៉ាយ៉ាន ឲ្យយកអ្នកទាំងនោះទៅកូឌីម ។ គាត់បានបញ្ជា សើសានមួស ឲ្យការពារលំនៅឋានរបស់ដូនជីកុំឲ្យមនុស្សចូលទៅក្នុងបាន ។ នៅពេលនោះ យ៉ាមស៊ីឌីន បានឡើងទៅលើលំនៅឋានរបស់ដូនជីហើយស្រែកខ្លាំងៗជាច្រើនដងថា "បងស្រី! នេះគឺកាសឌីម" ប៉ុន្តែគ្មានសម្លេងឆ្លើយតបទេ ។ ...ដូនជីម្នាក់និងអ្នកផ្សេងៗទៀតបីបួននាក់បានបង្ហាញខ្លួនៈ "លោកកាសឌីម អរគុណ" ។ "ខ្ញុំមិនមែនជាអ្នកសង្គ្រោះជីវិតបងស្រីទេ ប៉ុន្តែគឺព្រះយេស៊ូទៅវិញទេ" ។ យ៉ាមស៊ីឌីន បានសួរដូនជីថាតើមានអ្នកណាផ្សេងទៀតនៅខាងក្នុងឬទេ? ដូនជីបានស្រែកឡើងជាភាសាទីម័រ ។ មានបុរសនិងស្ត្រីជាច្រើននៅខាងក្នុង ។

## ១-២) ភ័ស្តុតាងជាក់ស្តែង

ការប្រើប្រាស់ភ័ស្តុតាងឯកសារគឺមិនមានទាល់តែសោះ ។ មានភ័ស្តុតាងសំខាន់ៗប៉ុន្តែមិនត្រូវបានបញ្ចេញទេ ។ រដ្ឋអាជ្ញាដាក់ជូនតុលាការតែភ័ស្តុតាងតិចតួចបំផុតដែលបានមកពីការស៊ើបអង្កេតរបស់ខេភីភីហាំ ហើយមិនបានប្រើប្រាស់ភ័ស្តុតាងទាំងនោះឲ្យអស់ពីលទ្ធភាព ជួនកាលមិនបានប្រើផង ។ សំណុំឯកសារដែលរដ្ឋអាជ្ញាដាក់ជូនទៅកាន់តុលាការ មានជាសំខាន់គឺកិច្ចសម្ភាសន៍ជាមួយជនសង្ស័យនិងសាក្សី ព្រមទាំងឯកសាររបស់អគ្គមេធាវីអំពីភ័ស្តុតាងទទួលបានមកពីទីភ្នាក់ងារមួយចំនួនដូចជាក្រុមធីអិនអាយនិងក្រុមប៉ូលិស ។ មានឯកសារជាច្រើនទៀតដែរ ដូចជាផែនការប្រតិបត្តិការហាណឹងឡូរ៉ូស៊េរីទី១និងទី២, ទិន្នន័យស្តីអំពីការគាស់សាកសពជនរងគ្រោះនៃអំពើសម្លាប់រង្គាលនៅក្នុងព្រះវិហារសួយដែលត្រូវបានកប់នៅទីម័រខាងលិច និងទិន្នន័យស្តីពីការប្រគល់អាវុធរបស់កងជីវពលនៅទីម័រខាងលិច ។ ប៉ុន្តែអ្វីដែលបាត់នោះគឺឯកសារសំខាន់ៗដែលខេភីភីហាំបានបញ្ជូនទៅការិយាល័យអគ្គមេធាវី ។ សេចក្តីរាយការណ៍របស់ខេភីភីហាំ និយាយសំដៅទៅលើឯកសារដូចខាងក្រោមៈ

◆ សារទូរលេខប្រចាំសប្តាហ៍របស់មេបញ្ជាការយោធាឃុំទៅមេបញ្ជាការយោធានៅទីម័រខាងកើត ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ជាទូរលេខសម្ងាត់ ។

◆ សេចក្តីសម្រេចរបស់អភិបាលស្តីទីនៅទីក្រុងឌីលី ដូមីងគូស ស័រេរ៉េ មិនមានកាលបរិច្ឆេទ មិនមានឯកសារយោង ។

◆ ផែនសកម្មភាពដើម្បីប្រឈមមុខទៅនឹងបរាជ័យក្នុងការបញ្ជាក់អំពីទស្សនៈនៅទីម័រខាងកើត ចេញផ្សាយនៅខែសីហា ឆ្នាំ១៩៩៩ ។

◆ សំបុត្រមកពីរដ្ឋមន្ត្រីក្រសួងការពារជាតិ ឬមកពីមេបញ្ជាការធីអិនអាយ ចុះកាលបរិច្ឆេទថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៩ ជាលិខិតសម្ងាត់ ។

◆ សេចក្តីរាយការណ៍របស់មេបញ្ជាការយោធាប្រចាំតំបន់យូដាយ៉ាណាទី៩ ឈ្មោះ អាដាម ដាមិរី ផ្ញើទៅរដ្ឋមន្ត្រីទទួលបន្ទុកសម្របសម្រួលនយោបាយនិងសន្តិសុខ អំពីស្ថានភាពនៅទីម័រខាងកើតមុនពេលមានការធ្វើប្រជាមតិ, ចុះហត្ថលេខានៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៩៩, ជាការសម្ងាត់ ។

◆ ឯកសារ Pol:R/355/IV/1999, ឌីស៊េសេ កាឡូស បឺ តេរ៉ូ

◆ របាយការណ៍របស់ កាណាឌី នៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ១៩៩៩ ផ្ញើទៅរដ្ឋមន្ត្រីទទួលបន្ទុកសម្របសម្រួលនយោបាយនិងសន្តិសុខ អំពីការវាយតម្លៃជាទូទៅប្រសិនបើជម្រើសទី១បរាជ័យ ។

ឯកសារទាំងអស់នេះត្រូវបានដាក់ជូនការិយាល័យអគ្គមេធាវី ក៏ប៉ុន្តែការិយាល័យអគ្គមេធាវីមិនបានដាក់បញ្ចូលទៅក្នុងសំណុំឯកសារចោទប្រកាន់ទេ ហើយក៏គ្មានការរំឭកដល់ឯកសារទាំងអស់នេះនៅក្នុងតុលាការដែរ ។ ក្នុងពេលផ្តល់បទសម្ភាសន៍ដល់ការិយាល័យអគ្គមេធាវី ឧត្តមសេនីយ៍ វីរ៉ាន់តូ បានផ្តល់ឯកសារថតចម្លងរបស់ធីអិនអាយអំពីគម្រោងសម្រាប់ទីម័រខាងកើត និងបទបញ្ជារក្សាសន្តិសុខក្នុងពេលធ្វើប្រជាមតិ ។ ការិយាល័យអគ្គមេធាវីមិនបានដាក់ឯកសារទាំងពីរនេះជូនតុលាការទេ ។ ភ័ស្តុតាងដទៃទៀតដូចជាទិន្នន័យអំពីការប្រគល់អាវុធនៅទីម័រខាងលិចដែលបានបង្ហាញឲ្យឃើញពីកម្រិតនៃ

គ្រឿងសព្វាវុធដែលកងជីវពលមាន ក៏មិនត្រូវបានរដ្ឋអាជ្ញាយកមកប្រើប្រាស់ដែរ បើទោះបីជាសំណុំឯកសារទាំងអស់នេះពិតជាផ្នែកមួយ នៅក្នុងសំណុំឯកសារចោទប្រកាន់ដែលត្រូវដាក់ជូនតុលាការក៏ដោយ ។

រដ្ឋអាជ្ញានៅក្នុងរឿងក្តីទាំងបីខាងលើនេះមិនមានបញ្ហាជាមួយសាក្សីដែលអះអាងថាកងជីវពលមានតែកាំភ្លើងផលិតនៅក្នុងស្រុក ឬក៏កាំភ្លើងដែលសល់មកពីសម័យព័រទុយហ្គេ ។ ខេភីភីហាំបានរកឃើញថា "ការជាប់ទាក់ទងរបស់កងជីវពលជាមួយក្រុមយោធា បានបង្ហាញយ៉ាងច្បាស់តាមរយៈគ្រឿងសព្វាវុធដែលយកមកប្រើប្រាស់ ។ ក្រៅពីអាវុធដែលប្រមូលបាននិងអាវុធដែលបន្សល់ទុកមកពីសម័យព័រទុយហ្គេនោះ វាហាក់ដូចជាថា អាវុធទូទៅដែលកងជីវពលយកមកប្រើគឺប្រភេទអាវុធ អេស-កា-អេស, អឹម-១៦, ម៉ូស៊ើ, ជី-៣, គ្រាប់បែក និងកាំភ្លើងខ្លី ។

រដ្ឋអាជ្ញាមិនបានស៊ើបអង្កេតបន្ថែមទៀតទៅលើព័ត៌មានទាំងឡាយដែលមានសរសេរនៅក្នុងរបាយការណ៍របស់អង្គការក្រៅរដ្ឋាភិបាល ដូចជា យ៉ាយ៉ាសានហាក នៅលីគ្វីកា និងស្វយនិងរបាយការណ៍លម្អិតផ្សេងៗទៀតស្តីពីអំពើហិង្សា នៅមុនពេលរៀបចំការធ្វើប្រជាមតិ ។ ឯកសាររបស់អង្គការសហប្រជាជាតិដែលរាយការណ៍អំពីការឃុបឃិតរបស់រដ្ឋជាមួយកងជីវពល ក្នុងចន្លោះខែមេសានិងខែកញ្ញា ឆ្នាំ១៩៩៩ មិនត្រូវបានយកមកប្រើប្រាស់ដែរ ។ គ្មានការលើកមកនិយាយអំពីការងាររបស់ទីភ្នាក់ងារស៊ើបអង្កេតរបស់អង្គការសហប្រជាជាតិទេ ។ មានការអះអាងជាច្រើនអំពីការស៊ើបអង្កេតរបស់ក្រុមប៉ូលិសទៅលើការសម្លាប់នៅលីគ្វីកានិងនៅផ្ទះរបស់ ការ៉ាសកាឡូ ប៉ុន្តែគ្មានកិច្ចខិតខំប្រឹងប្រែងណាមួយត្រូវបានធ្វើឡើងដើម្បីបង្ហាញភ័ស្តុតាងទាំងនេះតាមរយៈឯកសារទេ ។ ជាការពិតណាស់កំណត់ហេតុជាច្រើនបានឆេះនៅក្នុងការដុតបំផ្លាញនៅឌីលីនិងលីគ្វីកា ប៉ុន្តែគ្មានភ័ស្តុតាងបង្ហាញថា អាជ្ញាចោទប្រកាន់បានធ្វើការខិតខំប្រឹងប្រែងដើម្បីរកឲ្យឃើញកំណត់ហេតុទាំងអស់នេះដែលបានបាត់ពីទីបញ្ជាការប៉ូលិស ឬធីអិនអាយនៅហ្សាកាតាឡើយ ។

បន្ថែមពីនេះទៀត មានឯកសារពាក់ព័ន្ធយ៉ាងច្រើនដែលសេសសល់ពីអំពើហិង្សានៅទីម័រខាងកើត ។ បេសកកម្មរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើតទទួលបានឯកសារមួយចំនួនធំដែលប្រមូលបានពីទីតាំងសំខាន់ផ្សេងៗគ្នា រួមមានទីបញ្ជាការអែតារ៉ាកផង ។ ខេភីភីហាំបានប្រើប្រាស់ឯកសារមួយចំនួន ប៉ុន្តែអាជ្ញាចោទប្រកាន់មិនបានយកមកប្រើនៅក្នុងការជំនុំជម្រះទេ ។ ឯកសារពាក់ព័ន្ធមួយទៀតគឺតារាងដែលបង្ហាញអំពីការចំណាយរបស់រដ្ឋបាលស៊ីវិលទៅឲ្យ ប៉ាមវ៉ាកាសា ។ ឯកសារនេះគួរតែជាឯកសារសំខាន់ក្នុងការកសាងសំណុំរឿងក្តីប្រឆាំង អាប៊ីលីអូ ស័រេ៉ ពីព្រោះឯកសារនេះបានបង្ហាញពីទំនាក់ទំនងរវាងរដ្ឋបាលស៊ីវិលនិងក្រុមជីវពល ហើយជាពិសេសឯកសារនេះបានផ្តល់នូវភ័ស្តុតាងខ្លះគាំទ្រដល់ការអះអាងនៅក្នុងដីកាចោទប្រកាន់ដែលថាលោកអភិបាលគួរតែទទួលខុសត្រូវចំពោះសកម្មភាពរបស់មេបញ្ជាការអែតារ៉ាក អឺរីកូ គូតេរ៉េស ។ ដូចមុនៗដែរ អាជ្ញាចោទប្រកាន់មិនបានប្រើភ័ស្តុតាងបែបនោះនៅឯអង្គជំនុំជម្រះទេ ។

គ្មានការប្រើប្រាស់ហ្វីល គ្មានភាពយន្តឯកសារ គ្មានការបញ្ចាំងខ្សែភាពយន្ត គ្មានការសម្ភាសន៍ថតជាវីដេអូឬថតសម្លេងនិងគ្មានថតរូបទុក ។ ចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៩៩ ការប្រមូលផ្តុំរបស់ពួកកងជីវពលនៅក្នុងទីក្រុងឌីលីត្រូវបានប្រើប្រាស់ជាលេសនៅក្នុងការចោទប្រកាន់ អាប៊ីលីអូ ស័រេ៉ និង ធីមប៊ុល ស៊ីឡែន ។ ដីកាចោទប្រកាន់បានភ្ជាប់ខ្សែភាពយន្តស្តីពីការប្រមូលផ្តុំគ្នានោះដែលមានរួចជាស្រេច ក៏ប៉ុន្តែខ្សែភាពយន្តនេះមិនត្រូវបានយកមកពិនិត្យឡើយ ។ ឯកសារទាំងអស់នេះនឹងបង្ហាញថាសាក្សីជាច្រើនកំពុងតែនិយាយកុហក ។ រូបថតកងជីវពលពាក់សញ្ញាសម្គាល់ មិនត្រូវបានបង្ហាញដើម្បីដេញដោលអ្នកដែលបាននិយាយថា មិនអាចបែងចែកឲ្យដាច់គ្នារវាងក្រុមផ្សេងៗ ។ ខ្សែភាពយន្តមិនត្រូវបានបង្ហាញដើម្បីដេញដោលអ្នកដែលបាននិយាយថាការប្រមូលផ្តុំគ្នានាថ្ងៃទី១៧ ខែមេសានៅក្នុងទីក្រុងឌីលីគឺធ្វើឡើងដោយសន្តិវិធី និងដើម្បីដេញដោលអ្នកដែលនិយាយថាគ្មានការបំពាក់អាវុធ ។ គ្មានការប្រើប្រាស់ខ្សែភាពយន្តអំពីសម្តីរបស់ គូតេរ៉េស កាលពីថ្ងៃទី២៦

ខែសីហា ឆ្នាំ១៩៩៩ ពេលដែលគាត់និយាយទៅមនុស្សចំនួន ១មុឺន៥ពាន់នាក់ថាទីក្រុងនឹងក្លាយទៅជាសមុទ្រភ្លើងប្រសិនបើទីម័រខាងកើតប្រកាសឯករាជ្យភាពពីប្រទេសឥណ្ឌូនេស៊ី ។ អ្នកថតវីដេអូជនជាតិឥណ្ឌូនេស៊ីម្នាក់ថតយកបាននូវរូបភាពខ្វេចខ្វាំនៃការវាយប្រហារនៅព្រះវិហារលីគ្វីកា អ្នករស់រានមានជីវិតប្រកបដោយក្តីរន្ធត់ និងអ្នកបួសដែលជ្រកកោននៅក្នុងលំនៅឋានរបស់លោកអភិបាលស្តីទី ហ៊ីម៉ាន ក៏ប៉ុន្តែទាំងខ្លួនគាត់និងខ្សែវីដេអូរបស់គាត់មិនត្រូវបានដាក់ជាភ័ស្តុតាងទេ ។

គួរកត់សម្គាល់ដែរថា នៅក្នុងករណីសម្លាប់រង្គាលនៅព្រះវិហារស្វយ អដ្ឋធាតុដែលបាននាំយកមកប្រើជាភ័ស្តុតាងគឺជាសាកសពដែលគាស់នៅឯទីម័រខាងលិច ។ គួរឲ្យសោកស្តាយរបៀបដែលយកភ័ស្តុតាងទាំងនេះមកប្រើគឺធ្វើឲ្យតែរួចពីដៃ ។ វត្ថុទាំងអស់មិនត្រូវបានវេចខ្ចប់ឬដាក់ផ្លាកដាច់ដោយឡែកៗពីគ្នាទេ ហើយនៅពេលត្រូវការប្រើ គេបានយកដៃជ្រាវនិងទាញដោយទ្រគោះទ្រោះទ្រោក ។ បំណែកសម្លៀកបំពាក់និងក្រណាត់គ្របសពត្រូវបានបោះចូលទៅក្នុងប្រអប់កាតុងរឹង ហើយអាជ្ញាចោទប្រកាន់បានអូសប្រអប់នោះចេញមកបង្ហាញសាក្សី បន្ទាប់មកសួរសាក្សីអំពីអត្តសញ្ញាណរបស់សាកសពទាំងនោះ ។ នៅទីបញ្ចប់ សាក្សីត្រូវបានប្រាប់ថា អដ្ឋិធាតុទាំងនេះយកមកពីរណ្តៅសាកសពរួម ។

**(នៅមានត)**

**ស៊ូហ្សាណា លីនតុន**



# ការដកខ្លួនរបស់សហរដ្ឋអាមេរិក នឹងមិនរាំងស្ទះដំណើរការតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ

កាលពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០០៤ កន្លងទៅនេះ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ បានមានព្រះបន្ទូលថា ការដកខ្លួនរបស់សហរដ្ឋអាមេរិកចេញពីការផ្តល់ជំនួយដល់ប្រទេសកម្ពុជា នឹងធ្វើឲ្យរាំងស្ទះដំណើរការតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយក៏អាចនឹងបណ្តាលឲ្យប្រទេសដទៃទៀតដកថវិកាឧបត្ថម្ភសាលាក្តីនេះដែរ ។ ដោយក្តីគោរព ខ្ញុំសូមលើកមតិផ្សេងចំពោះចំណុចទាំងពីរខាងលើនេះ ។

ទីមួយ ក្នុងខណៈដែលសហរដ្ឋអាមេរិកមិនឧបត្ថម្ភដោយផ្ទាល់ដល់រាជរដ្ឋាភិបាលកម្ពុជាក៏ដូចជាអង្គការសហប្រជាជាតិក្នុងការបង្កើតឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ក៏សហរដ្ឋអាមេរិកមិនបានដកជំនួយផ្សេងៗដល់កម្ពុជាដែរ ។ សហរដ្ឋអាមេរិកកំពុងផ្តល់ជំនួយដ៏ចាំបាច់ដល់កម្ពុជាក្នុងវិស័យមួយចំនួនដូចជា ការទប់ស្កាត់ការជួញដូរកុមារ ការអភិវឌ្ឍវិស័យអប់រំ សុខភាព និងបញ្ហាស្ត្រី ។ លើសពីនេះ សហរដ្ឋអាមេរិកក៏ចូលរួមជួយឧបត្ថម្ភដោយប្រយោលដល់ដំណើរការតុលាការខ្មែរក្រហមតាមរយៈអង្គការក្រៅរដ្ឋាភិបាលជាច្រើន ។ អង្គការក្រៅរដ្ឋាភិបាលជាច្រើនដែលធ្វើការងារលើបញ្ហាសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ក៏កំពុងតែធ្វើការងារដើម្បីធានាឲ្យមានការផ្តល់ព័ត៌មានក៏ដូចជាការចូលរួមពីសំណាក់ប្រជាជនកម្ពុជាក្នុងដំណើរការតុលាការនេះ ។ មិនថាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមមានលទ្ធផលបែបណានោះទេ វាគឺជាការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិចំពោះមុខប្រជាជនកម្ពុជាក្នុងការបង្ហាញឲ្យឃើញថា តុលាការនេះមានយុត្តិធម៌និងតម្លាភាព ។ វាពុំមានការពិតជាក់លាក់ណាមួយទេ ហើយក៏មិនមែនមានន័យថាមនុស្សគ្រប់រូបពេញចិត្តនឹងសេចក្តីសម្រេចរបស់តុលាការខ្មែរ-ក្រហមដែរ ។ ហេតុដូច្នេះ ហើយ ជោគជ័យនៃដំណើរការតុលាការនេះនឹងពឹងផ្អែកទៅលើចំណេះដឹងអំពីដំណើរការតុលាការនេះ និងការឆ្លើយតបរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះប្រជាជនទាំងអស់ ។

ទីពីរ ការស្ទាក់ស្ទើររបស់សហរដ្ឋមេរិកក្នុងការឧបត្ថម្ភដោយផ្ទាល់ដល់ដំណើរការតុលាការនេះ មិនមែនមានន័យថាប្រទេសដទៃទៀតនឹងធ្វើតាមនោះទេ ។ ម្យ៉ាងទៀត ទោះបីជាសហរដ្ឋអាមេរិកមិនមានសកម្មភាពអ្វីឆ្លើយតបនឹងដំណោះស្រាយរបស់អង្គការសហប្រជាជាតិដែលបង្កើតឲ្យមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមក៏ដោយ ក៏សហរដ្ឋអាមេរិក គឺជាប្រទេសតែមួយគត់ដែលបោះឆ្នោតអនុបវាទខណៈដែលប្រទេសចំនួន១៣៩ទៀតបោះឆ្នោតគាំទ្រ ។ យើងនៅតែសង្ឃឹមថា ប្រទេសជប៉ុននិងបារាំងនឹងផ្តល់ជំនួយសប្បុរសសម្រាប់ដំណើរការតុលាការដ៏សំខាន់នេះ ក៏ដូចជាជួយជំរុញឲ្យប្រទេសដទៃនិងមូលនិធិឯកជនជាច្រើនទៀត (ជាពិសេសមូលនិធិឯកជននៅសហរដ្ឋអាមេរិក) ចូលរួមក្នុងការជួយឧបត្ថម្ភនេះដែរ ។

**ឆាំង យុ**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតដែលចាក់ផ្សាយរៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៣:៣០-៣:៤៥នាទី តាមរយៈវិទ្យុ FM១០២ MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា ។

មជ្ឈមណ្ឌលក៏បានបង្កើតកម្មវិធីដូចគ្នានេះផ្សាយតាមស្ថានីយ៍វិទ្យុ FM៩៣.២៥MHz ខេត្តកំពតជារៀងរាល់ថ្ងៃ នៅម៉ោង៧-៧:៣០នាទីព្រឹក និងម៉ោង៧-៧:៣០នាទីល្ងាចនិងស្ថានីយ៍វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ នៅម៉ោង៧-៧:៣០នាទីព្រឹក និងម៉ោង៦:៣០-៧នាទីល្ងាច ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងផ្សាយកម្មវិធីដូចគ្នានេះនៅគ្រប់បណ្តាស្ថានីយ៍វិទ្យុខេត្តនៃព្រះរាជាណាចក្រកម្ពុជា ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមនិងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**សុ ហ្សារីណា និង លី សុផល**

# តើរឿងហ្នឹងទាយ៉ាងម៉េច?

បុណ្យភ្ជុំបិណ្ឌឆ្នាំនេះខ្ញុំមានឱកាសបានទៅធ្វើបុណ្យនៅស្រុកកំណើតឯភូមិខ្ពបលើ ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្ដាល ។ អ្នកភ្នំពេញនិយមហៅស្រុកខ្ញុំយ៉ាងរត់មាត់ថា “ស្អាងកោះធំ” ដែលតាមការពិតស្រុកស្អាងផ្សេង ស្រុកកោះធំផ្សេង គឺជាស្រុកពីររបស់ ខេត្តកណ្ដាលដែលសណ្ដូកខ្លួនអែនអនពត់ពេនតាមត្រើយទាំងសងខាងនៃទន្លេបាសាក់ ។

ផ្អែកតាមឯកសារនិងរូបថតដ៏ច្រើនសន្ធឹកសន្ធាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជនរងគ្រោះនិងជនដៃដល់មួយចំនួនធំនៅក្នុងគុកទួលស្លែង (ឬមន្ទីរស-២១) មានកំណើតនៅស្អាងកោះធំដែលកាលណោះគឺជាតំបន់២៥ ។ សូម្បីតែអតីតមេដឹកនាំខ្មែរក្រហមក៏ល្បីឈ្មោះគឺលោក ខៀវ សំផន ក៏ធ្លាប់ជាប់ឆ្នោតជាតំណាងរាស្ត្រនៅមណ្ឌលស្អាងកោះធំនេះដែរ ។

ក្នុងចម្ងាយផ្លូវជាងសែសិបគីឡូម៉ែត្រពីភ្នំពេញទៅស្រុកខ្ញុំគឺត្រូវចំណាយពេលប្រមាណសាមសិបនាទី ដោយឆ្លងកាត់ក្រុងតាខ្មៅនិងទំនប់ទួលក្រសាំង ។ ទំនប់ទួលក្រសាំងនេះត្រូវបានកសាងឡើងក្នុងរបបប៉ុលពត ដែលភ្ជាប់ពីផ្លូវជាតិលេខ២១ត្រង់ចំណុចវត្តឈូងលៀបមកកាន់ក្រុងតាខ្មៅត្រង់ចំណុចក្បែររោងចក្រកង់ឡានឆេកូ ។ ទំនប់នេះបានចំណាយជីវិតមនុស្សអស់យ៉ាងច្រើនព្រោះនៅទល់មុខនឹងវត្តឈូងលៀបគឺជាមន្ទីរឃុំឃាំងកោះគរ ឬមន្ទីរ-០៨ ដែលជាគុកសម្លាប់មនុស្ស ។

ហួសពីវត្តឈូងលៀបទៅក្រោមប្រមាណជាប្រាំគីឡូម៉ែត្រគឺដល់ផ្សារព្រែកតូចដែលជាទីរួមស្រុកស្អាង ។ អ្នកដំណើរទូទៅតែងនិយមហៅឈ្មោះផ្សារនិងឈ្មោះស្រុកភ្ជាប់គ្នាទៀតគឺ “ស្អាងព្រែកតូច” ។ ទៅហួសពីស្អាងព្រែកតូចបន្តិចទៀតនឹងដល់សាលារៀនស្វាយតានី ។ នៅខាងស្ដាំដៃក្បែររបងសាលាមានផ្លូវលំមួយឆ្ពោះទៅរមណីយដ្ឋានភ្នំធនមន្ត ស្អាងភ្នំ-ក្រាំងយ៉ូវ ដែលកាលពីកុមារភាព (ឆ្នាំ១៩៧៧) ខ្ញុំធ្លាប់បានទៅចូលរួមកសាងប្រព័ន្ធស្រែថ្មីនៅតំបន់នោះ ។ នៅខាងឆ្វេងដៃគឺជាកំពង់ដឆ្លងទៅចំឃុំត្រើយស្លាដែលជាស្រុកកំណើតរបស់សមមិត្ត ឃឹម វ៉ាត ហៅ ហិ អនុប្រធានមន្ទីរស-២១ ។ ភូមិទាំងអស់របស់ឃុំត្រើយស្លាដែលស្ថិតនៅតាមបណ្ដោយដងទន្លេបាសាក់ សុទ្ធតែមានឈ្មោះហៅត្រឹមត្រូវតាំងពីដើមរៀងមក ដូចជាភូមិព្រែកតាអក ភូមិព្រែកប៉ាន ភូមិព្រែកបាឡាត់ឆឹម ។ល ។ តែមកដល់សម័យមហាលោតផ្លោះ អង្គការបានប្ដូរឈ្មោះភូមិទាំងអស់មកដាក់ជាលេខវិញ គឺភូមិលេខ១ ភូមិលេខ២ រៀងគ្នារហូតដល់ភូមិលេខ៨ ។ សព្វថ្ងៃនេះ អ្នករស់នៅត្រើយស្លាបានប្ដូរទៅហៅឈ្មោះភូមិដើមរបស់ខ្លួនវិញហើយ ។

ហួសពីសាលារៀនស្វាយតានីទៅក្រោមបន្តិចនឹងដល់វិទ្យាល័យព្រះសីហនុដែលស្ថិតនៅក្នុងបរិវេណវត្តសូភី ។ អ្នកស្រុកនិយមហៅវត្តសូភីថាវត្តក្បាលកោះ ព្រោះវត្តនេះស្ថិតនៅចំក្បាលកោះខ្សាច់ទន្លា ។ អគារវិទ្យាល័យព្រះសីហនុដែលពីអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៨០មានឈ្មោះថា “សាលាមធ្យមសិក្សាកម្រិត២ក្បាលកោះ” គឺជាអគារថ្មកម្ពស់ពីរជាន់ សង់ផ្ដេកខ្លួនបណ្ដោយថ្ងៃបែរមុខទៅទិសខាងជើងហាក់ខំសម្លឹងមើលអ្នកដំណើរទាំងឡាយដែលទៅមកឆ្លងកាត់ទីនោះ ។ សម្រាប់ខ្ញុំ ស្រមោលអនុស្សាវរីយ៍ទាំងឡាយកាលពីជាងម្ភៃឆ្នាំមុនបានលេចឡើងដូចជាថ្មីៗនៅឡើយ ...សំឡេងរំភើបអ៊ូអររបស់មិត្តរួមថ្នាក់ក្នុងពេលប្រកាសចំណាត់ថ្នាក់ប្រលងឆមាស ក្លិនបង្កាន់ដៃដណ្ដើរឡើងដែលធំម្ហិះៗនៅពេលព្រឹកព្រលឹម ក្លិនឆ្អួលនៃធូលីដីសនៅពេលវេនបោសសម្អាតថ្នាក់ម្ដងៗ ស្នូរកណ្ដឹងការ៉េមកី និងក្លិនឈ្ងុយនៃអន្សមអាំងដ៏គួរឲ្យចូលចិត្តនៅលើទីធ្លាសាលាពេលចេញលេង... ទាំងអស់នេះគឺជាអ្វីដែលបានកើតឡើងកាលពីឆ្នាំ១៩៨២-៨៣ គឺនៅពេលដែលខ្ញុំរៀនថ្នាក់ប្រលងឌីប្លូមមុននឹងទៅរៀនថ្នាក់ទី៨នៅវិទ្យាល័យតាខ្មៅ ។

ហួសពីវត្តក្បាលកោះគឺវត្តកណ្ដាល ហើយបន្ទាប់មកទៀតគឺជាវត្តទឹកវិលឬវត្តចុងកោះដែលស្ថិតនៅចំចុងកោះខ្សាច់ទន្លា ។

ខ្ញុំចូលចិត្តជិះទូក-ដរវត្តចុងកោះឆ្លងទៅត្រើយខាងកើតចំព្រែកថ្មី ដែលជាព្រែកខណ្ឌចែកដាច់ព្រំប្រទល់រវាងឃុំតាលន់និងឃុំខ្ពប ។ នៅលើទូក-ដ ខ្ញុំឈ្ងោកសម្លឹងមើលទឹកទន្លេបាសាក់ក្នុងរដូវវស្សា ដែលមានសម្បុរដូចកាហ្វេទឹកដោះគោ គឺជាល្បាយដីល្បាប់ដីមានជីជាតិហូរចែករំលែកតាមព្រែកដែលនៅសងខាងទន្លេចាក់ចូលទៅដីស្រែចម្ការបឹងបួតូចធំមុននឹងដល់សមុទ្រ ។

ខ្ញុំបណ្តោយឲ្យអារម្មណ៍ហូរទៅតាមខ្សែទឹក ហើយជ្រមុជគួចនាំយកព្រឹត្តិការណ៍កាលពីឆ្នាំ១៩៧៧ គឺនៅពេលដែលគណៈសហករណ៍ឃុំខ្ពបបញ្ជាឲ្យនាំខ្លួនខ្ញុំតាមទូកពីកងកុមារនៅតំបន់ទំនប់ក្រាំងយ៉ូវ យកមកបញ្ចូលក្នុងកងចល័តយុវជនប្រចាំស្រុក២០ គឺក្រោយពេលដែលអង្គការស្នើយកឪពុកខ្ញុំទៅរៀនសូត្រនៅមន្ទីរសន្តិសុខកោះថ្មី ។



ម៉េង រស្មី

...រឿងរ៉ាវបានកើតឡើងកាលពីម្ភៃប្រាំពីរឆ្នាំមុន គឺក្នុងរដូវទឹកឡើងឆ្នាំ១៩៧៧ ។ កាលណោះខ្ញុំទើបតែមានអាយុ១៣ឆ្នាំ ។ ខ្ញុំគឺជាកុមារម្នាក់ក្នុងចំណោមកុមារជិតដប់នាក់ដែលធ្វើដំណើរតាមទូកពីក្រាំងយ៉ូវ ឡើងមកតាមព្រែកក្តាមវត្តចុងកោះ ហើយឆ្លងទៅត្រើយខាងកើត ។ ដៃខ្ញុំក្តាប់គែមទូកជាប់ ហើយសម្លឹងមើលទឹកទន្លេដ៏ល្អល្ហេវសម្បុរកាហ្វេទឹកដោះគោនេះពោរពេញដោយភាពតក់ស្លុត និងភ័យខ្លាច ។ ដោយសារអ្នកចែវទូកមិនសូវមានកម្លាំង ហើយទឹកទន្លេហូរខ្លាំង ទម្រាំឆ្លងដល់ត្រើយខាងកើត ទូកបានរសាត់ទៅជិតដល់ព្រែកឆ្កែខ្មៀនដែលស្ថិតនៅចន្លោះភូមិខ្ពបលើនិងភូមិបក្សីស្រុក ។ ខ្ញុំបានសុំការអនុញ្ញាតពីមេក្រុមកុមារដើម្បីឆៀងចូលអើតមើលផ្ទះបន្តិចមុននឹងបន្តដំណើរទៅភូមិក្អោតញី ។ ដោយសារ ខ្ញុំមានជំងឺគ្រុនចាញ់នៅពេលធ្វើការឯការដ្ឋានក្រាំងយ៉ូវ ទើបខ្ញុំមានរាងកាយស្គមស្លេកស្លាំងយ៉ាងខ្លាំង ធ្វើឲ្យ អ៊ីញឹង (បងស្រីម្តាយខ្ញុំ) មើលខ្ញុំមិនស្គាល់ ។ គ្រាន់តែដឹងថាខ្ញុំភ្លាម គាត់ស្ទុះមកឱបខ្ញុំ លាយឡំទឹកភ្នែកហូរស្រោចគ្មានឈប់ពីលើក្បាលខ្ញុំ ។ គាត់គ្មាននិយាយចេញមួយម៉ាត់សោះ ។ នៅក្នុងផ្ទះ (តាមពិតជារោងដោល) ខ្ញុំឮប្អូនពៅរបស់ខ្ញុំ (អាភា) ស្រែកយំរក អ៊ីញឹង មិនឈប់សោះ ។ តាមពិតវាឈឺរកាំក្នុងភ្នែកទាំងពីររបស់វា ដែលហើមពោរបើកអត់រួច ។ អ៊ីញឹង ប្រាប់ខ្ញុំថាភ្នែកវាទាំងពីរឡើងបាយជាងពីរខែហើយ ។ គាត់ព្យាយាមឲ្យគ្រូខ្មែរស្តោះផ្លុំឲ្យវាដែរតែមិនធូរស្រាលសោះ មើលទៅថ្ងៃក្រោយប្រហែលជាខ្វាក់ភ្នែកហើយ ។ (ក្រោយឆ្នាំ១៩៧៩ ភ្នែកឡើងបាយរបស់វាទាំងពីរស្រាប់តែជាដោយឯកឯង ។ បច្ចុប្បន្ន អាភា កំពុងធ្វើការនៅក្នុងក្រុមកាត់បន្ថយអត្រាជនរងគ្រោះដោយសារគ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះប្រចាំខេត្តបាត់ដំបងនិងបន្ទាយមានជ័យ ។

បន្ទាប់មកគាត់លាបផ្ទេចក្រមាយកខោអាវជាឌិបខ្មៅមួយកំប្លេថ្មីចែសគឺខោជើងវែងនិងអាវដៃខ្លីហោប៉ៅបី ញាត់ចូលក្នុងកូនបាឡូដ៏សំគមរបស់ខ្ញុំហើយប្រាប់ថានេះជាខោអាវរបបរបស់ឪពុកខ្ញុំដែលគាត់ផ្តាំទុកឲ្យខ្ញុំស្លៀកពាក់ ។ ខ្ញុំឆ្ងល់ហើយសួរទៅអ៊ីញឹង ដួនៗៈ

◆ រួចចុះប៉ាគាត់បានអីស្លៀក? តើឥឡូវគាត់ហើយនិងម៉ែធ្វើការនៅណា? ហើយពួកគាត់មានដែលមកផ្ទះទេ?

នៅនឹងមុខប្រធានក្រុមកុមារ អ៊ីញឹង លាក់មិនឆ្លើយនឹងសំណួររបស់ខ្ញុំទេ ។ គាត់ប្រាប់មកខ្ញុំវិញថាៈ

◆ អង្គការឲ្យគាត់ (ឪពុកខ្ញុំ) ទៅធ្វើការឆ្ងាយណាស់ ។ ឈប់គិតពីគាត់ទៅ ។

តាំងពីពេលនោះមក ខ្ញុំលែងបានជួបឪពុកខ្ញុំរហូត ។



តាន់ ហាងម៉េង

ឪពុកខ្ញុំឈ្មោះ តាន់ ហាងម៉េង មានស្រុកកំណើតនៅទីរួមស្រុកបាកាន ខេត្តពោធិសាត់ ។ ចំណែកឯម្តាយខ្ញុំឈ្មោះ រ៉ា ញឹម កំណើតកើតជា នៅភូមិខ្ពបលើ ឃុំខ្ពប ស្រុកស្អាង ខេត្តកណ្តាល ។ នៅជំនាន់សម្តេចសីហនុ និង លន់ណុល ឪពុកខ្ញុំធ្វើការនៅនាយកដ្ឋានគន្ធារុក្ខាប្រមាញ់ និងនេសាទនៃក្រសួងកសិកម្ម ។ គាត់គឺជាប្រធានក្រុមអនុរក្សព្រៃឈើនិងសត្វព្រៃ (មេព្រៃ) ដែលទទួលខុសត្រូវនៅប៉ែកតំបន់ខ្ពង់រាបល្បសាននៃប្រទេសកម្ពុជា ។ ជារៀងរាល់ឆ្នាំគាត់មានបេសកកម្ម

ចុះទៅប្រចាំការនៅតំបន់នោះរយៈពេលពីបីទៅប្រាំខែ ទើបត្រឡប់មកផ្ទះម្តង ។ ដោយសារគាត់មានចរិតរួសរាយរាក់ទាក់និងស្មោះត្រង់ បងប្អូនជនជាតិភាគតិចគ្រប់សហគមន៍នៅតំបន់ខ្ពង់រាបគ្នាសានចងមិត្តភាពនិងគោរពរាប់អានគាត់ជាភ្ញៀវប្រាក់យ៉ាងស្និទ្ធស្នាល ។

អំឡុងដើមឆ្នាំ១៩៧៣ ពេលដែលសង្គ្រាមស៊ីវិលរីករាលដាលនៅក្នុងប្រទេស ហើយផ្លូវទៅតំបន់ខ្ពង់រាបគ្នាសានត្រូវកាត់ផ្តាច់ ក្រសួងកសិកម្មបានចាត់តាំងគាត់ឲ្យទទួលខុសត្រូវការងារគូរផែនទីប្រទេសកម្ពុជាសម្រាប់ផ្តល់ទិន្នន័យបម្រើឲ្យវិស័យកសិកម្ម ។ ដើមឆ្នាំ១៩៧៥ ក្រសួងកសិកម្មបានចាត់តាំងគាត់ឲ្យទៅអនុរក្សព្រៃឈើនិងសត្វព្រៃនៅតំបន់ព្រៃមាត់សមុទ្រ ខេត្តកោះកុង ។ គាត់បានសម្រេចចិត្តថានឹងនាំក្រុមគ្រួសារទៅរស់នៅខេត្តកោះកុងបន្ទាប់ពីបុណ្យចូលឆ្នាំខ្មែររួច ប៉ុន្តែអ្វីៗទាំងអស់ត្រូវបញ្ចប់នៅថ្ងៃទី១៧ ខែមេសា ។

នៅថ្ងៃ១៧មេសា ក្រុមគ្រួសារខ្ញុំស្ថិតនៅក្នុងបរិវេណក្រសួងកសិកម្មដែលបច្ចុប្បន្នគឺជាក្រសួងមហាផ្ទៃ ។ តាំងពីមុននេះមួយថ្ងៃគឺថ្ងៃទី១៦ ឪពុកខ្ញុំបានយកការិយាល័យធ្វើការរបស់គាត់ធ្វើជាជម្រកការពារគ្រាប់រ៉ុក្កែតដែលកងទ័ពរំដោះបាញ់ផ្ទោងស្រោចដូចភ្លៀងចូលទីក្រុង ។ បន្ទប់ការិយាល័យនោះស្ថិតនៅជាន់ខាងក្រោមប៉ែកខាងកើតជ្រុងខាងត្បូងនៃអគារទទឹងថ្ងៃ ដែលបច្ចុប្បន្នជាអគារនៃអគ្គស្នងការនគរបាលជាតិ (បន្ទប់ទីមួយខាងស្តាំដៃចូលតាមច្រកខាងត្បូងត្រង់ដើមអំពិលបារាំងធំសព្វថ្ងៃ) ។

ដោយប្រើប្រាស់ភាពប៉ិនប្រសប់ក្នុងការទំនាក់ទំនងរបស់គាត់ ពេលដែលកងទ័ពរំដោះមួយក្រុមតូចចូលមកដល់ក្រសួងកសិកម្មភ្លាម ឪពុកខ្ញុំបានទាក់ទងស្គាល់មេបញ្ជាការជាន់ខ្ពស់មួយរូបដែលមកពីមុខព្រួញខាងភូមិភាគបូព៌ា ។ ដោយស្គាល់ក្រុងភ្នំពេញមិនច្បាស់ មេបញ្ជាការរូបនោះបានស្នើសុំឲ្យឪពុកខ្ញុំបើកឡានជូនគាត់និងយោធាបីនាក់ទៀតមើលភ្នំពេញ ។ ខ្ញុំឆ្លៀតលោតគោងចូលទៅអង្គុយក្នុងទ្រុងខាងក្រោយឡានឡង់រ៉ូវែដែលបើកចេញពីក្រសួងកសិកម្មឡើងមកផ្លូវព្រះនរោត្តម ហើយបត់ទៅទិសខាងជើងកាត់ពីមុខវិមានរដ្ឋចំការមនកាត់មុខស្ថានទូតសហរដ្ឋអាមេរិក រួចបរសន្សឹមៗកាត់សាលាចោពញាហុកដែលជាសាលាខ្ញុំរៀន ។ រថយន្តមកដល់វិមានឯករាជ្យក៏បត់ត្រង់ទៅខាងលិចដល់ផ្លូវព្រះមុនីវង្សក៏បត់ទៅទិសខាងជើងត្រង់រហូតដល់ផ្លូវបត់ចូលផ្សារថ្មី ។ នៅជុំវិញផ្សារថ្មីមានសាកសពទាហាននិងស៊ីវិលជាច្រើននាក់បានស្លាប់រាយប៉ាយលើចិញ្ចើមថ្នល់ ។ សម្ភារនិងរបស់របរប្រើប្រាស់គ្រប់មុខ ព្រមទាំងសម្លៀកបំពាក់ចម្រុះពណ៌បានគគ្រួតយ៉ាងគ្មានសណ្តាប់ធ្នាប់ពីមាត់ទ្វារបង្អួចខាងមុខគេហដ្ឋាននិងអគារលក់ដូរទាំងអស់នៅជុំវិញផ្សារថ្មី ។

ឪពុកខ្ញុំឈប់រថយន្តចំពីមុខទិសចស្ថានមួយកន្លែងក្បែរផ្សារថ្មី ហើយនាំមេបញ្ជាការរូបនោះចូលទៅយកថ្នាំពេទ្យដែលជាជយភណ្ឌរបស់អង្គការ ។ គាត់បានណែនាំ បង្ហាញ និងប្រមូលប្រភេទថ្នាំគ្រុនចាញ់ ថ្នាំរាករូស និងថ្នាំផ្សះ ប្រកបានពីរការុងរួចហើយប្រគល់ជូនមេបញ្ជាការនោះមួយការុង បន្ទាប់មកស្រុតវិលត្រឡប់មកក្រសួងកសិកម្មវិញ ។ នៅតាមផ្លូវ មេបញ្ជាការនោះឆ្ងល់ហើយសួរឪពុកខ្ញុំថា៖

◆ បងឯងប្រាប់ខ្ញុំថាជាតែកុងឡានទេ ម៉េចក៏បងឯងស្គាល់ថ្នាំពេទ្យច្រើនមុខម្ល៉េះ?

ឪពុកខ្ញុំសើចតបទៅវិញថា៖

◆ ធម្មតាទេតែកុងឡានរបស់មេព្រៃនោះ កាលបើបើកឡានជូនគេទៅដល់តំបន់គ្រុនចាញ់ហើយ ខ្លួនឯងត្រូវតែរៀនចំណាំចេះប្រើថ្នាំលេប រៀនចាក់ថ្នាំចាក់សេរ៉ូមខ្លួនឯង មិនចាំបាច់ពេទ្យហ្អឺទេ ។ ដូច្នេះ ខ្ញុំចេះតែចំណាំៗថ្នាំតាមគេតាមឯងទៅ ។

ដោយភាពស្និទ្ធស្នាលបន្តិចម្តងៗនេះហើយ ទើបមេបញ្ជាការនោះលួចខ្សឹបប្រាប់ឪពុកខ្ញុំត្រង់ៗថា៖

◆ តាមពិត អង្គការប្រកាសជម្លៀសប្រជាជនចេញតែមួយរយៈបីថ្ងៃនោះគឺមិនប្រាកដថាថ្ងៃណាបានវិលត្រឡប់មកវិញទេ ។ ពេលចេញទៅជនបទកុំយកលុយទៅអី ព្រោះនៅទីនោះគេមិនចាយទេ ។ សូមបងដាក់អង្ករ អំបិល ប្រហុក ឲ្យបានច្រើនតាមដែលអាចយកទៅបាន ។ ម្យ៉ាងទៀត បងឯងជាតែកុងឡានអីចឹងមិនអីទេ តែបើជាទាហាននិងអ្នករដ្ឋការធំៗវិញទើបមានបញ្ហា ។

ដោយដឹងថាឪពុកខ្ញុំមានស្រុកកំណើតនៅខេត្តពោធិសាត់ មេបញ្ជាការនោះបានស្នើមកឪពុកខ្ញុំថា៖

◆ មុខព្រួញអង្គភាពទ័ពខ្ញុំត្រូវធ្វើដំណើរទៅខេត្តបាត់ដំបង ។

បើបងមិនយល់ទាស់ទេ សូមបងធ្វើដំណើរជាមួយយើងខ្ញុំទៅ យើងខ្ញុំនឹងជូនគ្រួសារបងឲ្យទៅដល់ស្រុកកំណើត ។

ប៉ុន្តែ ម្តាយរបស់ខ្ញុំបានបដិសេធបំណងល្អរបស់មេបញ្ជាការរូបនោះ ហើយគ្រាន់តែថ្លែងអំណរគុណគាត់តែប៉ុណ្ណោះ ។ ម្តាយខ្ញុំពិគ្រោះជាមួយឪពុកខ្ញុំថា: បាកានពោធិសាត់ឆ្ងាយណាស់ បើស្អាងជិតជាង ។ ដោយសារម្តាយខ្ញុំមានការនឹករឭកញាតិមិត្តបងប្អូននៅក្នុងតំបន់រំដោះដែលបានបែកគ្នាបី-បួនឆ្នាំចុងក្រោយនេះផង ដូច្នេះឪពុកខ្ញុំមិនហ៊ានជំទាស់នឹងបំណងរបស់ម្តាយខ្ញុំទេ ហើយសម្រេចចិត្តនាំក្រុមគ្រួសារធ្វើដំណើរទៅស្រុកស្អាង ។

ក្នុងជំនន់មនុស្សដែលស្ថិតនៅលើដងផ្លូវព្រះនរោត្តមឆ្ពោះទៅក្បាលថ្នល់ មានគ្រួសារខ្ញុំដែលមានសមាជិកប្រាំបីនាក់នៅក្នុងនោះដែរ ។ ពេលទៅដល់រង្វង់មូលក្បាលថ្នល់ ជំនន់មនុស្សដែលបុកមកពីផ្លូវព្រះនរោត្តមត្រូវកងទ័ពរំដោះបញ្ជាមិនឲ្យវាងរង្វង់មូលទៅខាងតាខ្មៅទេ គឺត្រូវបត់ឆ្វេងឆ្លងស្ពានក្បាលថ្នល់ទាំងអស់គ្នា ដែលធ្វើឲ្យស្ពានភាពនៃការកកស្ទះមនុស្សនៅលើស្ពានគឺមិនអាចពិពណ៌នាបាន ។

នៅក្រោមកំដៅព្រះអាទិត្យដែលកំពុងបណ្តើរកូនព្រិចៗក្នុងខែចេត្រ កងទ័ពរំដោះបានឈរបណ្តាក់គ្នាដូចខ្សែជ្រកនៅក្រោមដើមក្ទោក ដើមត្របែកព្រៃ និងដើមដើងគោ ដែលនៅអមសងខាងផ្លូវព្រះនរោត្តម ។ នៅក្រោមដើមដើងគោក្បែររង្វង់មូលក្បាលថ្នល់ យុទ្ធនារីនៃកងទ័ពរំដោះដ៏ក្មេងល្ហក់ពីរនាក់កាន់កាំភ្លើងវែងគ្រប់ដៃ បានបាញ់សន្ទាប់ឡើងទៅលើ ហើយស្រែកកំហ្ញើញបណ្តេញប្រជាជនឲ្យស្រូតដំណើរទៅមុខ ។ គ្រាប់កាំភ្លើងបានរត់ទៅបំបែកស្លឹកដើងគោដែលនៅពីលើក្បាលជាបំណែកតូចៗធ្លាក់ចុះមកក្រោមរពុយ ហើយចាំងផ្លាតជាមួយនឹងពន្លឺថ្ងៃធ្វើឲ្យខ្ញុំស្រវាំងភ្នែកនិងស្រៀវឆ្អឹងខ្នង ។ ខ្ញុំនៅចងចាំរូបភាពនោះយ៉ាងច្បាស់មិនអាចបំភ្លេចបានរហូតមកដល់សព្វថ្ងៃ ។ ចាប់ពីឆ្នាំ១៩៨៤ ពេលដែលខ្ញុំឡើងមករៀននៅតាខ្មៅ ឲ្យតែដល់ថ្ងៃទី១៧ឬ១៨មេសារៀងរាល់ឆ្នាំ ខ្ញុំតែងទៅឈរមើលដើមដើងគោនោះមិនដែលខានទេ ។ ដើមដើងគោនោះស្ថិតនៅលើចិញ្ចើមផ្លូវចំខាងមុខមន្ទីរពេទ្យបាយ័នសព្វថ្ងៃនេះ ប៉ុន្តែវាត្រូវកាប់ចោលតាំងពីឆ្នាំ១៩៩១បាត់ទៅហើយ ។

ពីក្បាលថ្នល់ទៅព្រែកឯង ក្រុមគ្រួសារខ្ញុំត្រូវបានសម្រាកនៅវត្តនិរោធអស់មួយយប់ បន្ទាប់មកយើងចំណាយពេលស្នាក់នៅក្បែរបងវត្តព្រែកឯងអស់រយៈពេលជិតមួយសប្តាហ៍ទៀត ។ ឪពុកខ្ញុំក៏សម្រេចចិត្តចេញដំណើរពីព្រែកឯងឆ្ពោះទៅភូមិបោះអង្កាញ់រួចបត់ឡើងទៅវត្តចំពុះក្អែក ហើយសម្រាកនៅទីនោះមួយយប់ទៀត ។ ព្រឹកស្អែកឡើង គ្រួសារខ្ញុំក៏បានធ្វើដំណើរសសៀរតាមបណ្តោយដងទន្លេបាសាក់ត្រើយខាងកើតចុះទៅក្រោមឆ្ពោះទៅកាន់ភូមិខ្ពបលើ ឃុំខ្ពប ស្រុក២០ តំបន់២៥ ដែលមានចម្ងាយប្រមាណជាងសែសិបគីឡូម៉ែត្រ ។

ពេលធ្វើដំណើរដល់ព្រែកយាយហ៊ីងក្នុងឃុំត្រើយស្លា ម្តាយខ្ញុំបានជួបនឹងក្មួយសាច់ថ្លៃម្នាក់ឈ្មោះ ប៉េងឡេង ។ បង ប៉េងឡេង គឺជាប្តីរបស់ បងណាន ដែលត្រូវជាបងជីដូនមួយខ្ញុំខាងម្តាយ ។ បងប៉េងឡេង ត្រូវ អ៊ំញីង ប្រើឲ្យធាក់កង់មកត្រើយស្លាស្វាយប្រទាលរាល់ថ្ងៃដើម្បីចាំទទួលក្រុមគ្រួសារខ្ញុំមកពីភ្នំពេញ ។

ស្ថិតនៅក្នុងសម្លៀកបំពាក់កងទ័ពរំដោះ បងប៉េងឡេងកាលណោះគឺជាយុទ្ធជនក្នុងក្រុមសិល្បៈកងទ័ពប្រចាំស្រុក២០ ។ បច្ចុប្បន្ននេះ បងប៉េងឡេង គឺជាអ្នកលេងឧបករណ៍ទ្រសោដ៏ល្បីល្បាញប្រចាំក្រុមវង់ភ្លេងប្រពៃណីនៅភូមិព្រែកតាប្រាក់ ឃុំតាលន់ ស្រុកស្អាង ខេត្តកណ្តាល ។

ពេលទៅដល់ស្រុកកំណើតរបស់ម្តាយខ្ញុំភ្លាម ខ្ញុំបានជួបនឹងបងប្អូនជីដូនមួយយ៉ាងច្រើននាក់ដែលពីមុនមកខ្ញុំមិនសូវបានស្គាល់ ។ សំឡេងអ៊ូអរសាកសួរសុខទុក្ខលាយឡំសំឡេងខ្សឹកខ្សួលនឹករឭករបស់សាច់ញាតិខាងម្តាយខ្ញុំ លាន់ឮទ្រហឹងពេញពីលើផ្ទះជីតាខ្ញុំដែលធ្វើអំពីឈើប្រក់ក្បឿងស្រកាលិញនិងក្រាលរនាបឫស្សីរលោងស្រិល ។ អ្នកចម្ការចូលចិត្តធ្វើផ្ទះក្រាលរនាបឫស្សីដើម្បីងាយស្រួលទុកដាក់ពោតសណ្តែកឲ្យមានខ្យល់ចេញចូល ។ ក្រោយមកនៅឆ្នាំ១៩៧៦ អង្គការបានស្នើសុំរុះផ្ទះជីតាខ្ញុំនោះដើម្បីយកឈើធ្វើរោងបាយសហករណ៍រួម ហើយឲ្យគ្រួសារជីតាខ្ញុំធ្វើរោងដោលមួយទ្រើសជាងរោងចាំចាបបន្តិចនៅលើដីយាយអាំង ក្បែរមាត់ទន្លេ ។ ក្រោយឆ្នាំ១៩៧៩ ទើបក្រុមគ្រួសារជីតាខ្ញុំរើរោងដោលពីដី យាយអាំង មកធ្វើផ្ទះធំសមរម្យ

លើទីផ្ទះចាស់វិញ ។ អ្វីដែលខ្ញុំនៅតែឆ្ងល់គឺថា កាលណោះហេតុអ្វីបានជាខ្មែរក្រហមរុះរើផ្ទះជីតាខ្ញុំ ហើយមិនអនុញ្ញាតឲ្យគ្រួសារខ្ញុំសង់កូនខ្ទមនៅលើទីដីនោះវិញទៀត?

ការជួបជុំនិងការថ្ងៃទុក្ខសោកទៅវិញទៅមករវាងម្តាយខ្ញុំនិងញាតិមិត្តរបស់គាត់ បានប្រព្រឹត្តទៅក្រោមក្រសែភ្នែកអាណិតអាសូរ ខឹង ស្អប់ និងមិនសូវសប្បាយចិត្ត ពីសំណាក់ប្រជាជនមូលដ្ឋានខ្លះដែលរស់នៅជុំវិញទីនោះ ។ បួនថ្ងៃក្រោយមក គណៈភូមិបានមកប្រាប់ អ៊ំញឹង ថា មិនអនុញ្ញាតឲ្យក្រុមគ្រួសារខ្ញុំរស់នៅភូមិនេះទេ តែនៅភូមិរកាលើអាចទទួលឲ្យគ្រួសារខ្ញុំស្នាក់នៅបាន ។ ក្រុមគ្រួសារខ្ញុំក៏រៀបចំអីវ៉ាន់ចេញពីផ្ទះ អ៊ំញឹង ហើយចេញដំណើរទៅភូមិរកាលើដែលស្ថិតនៅខាងត្បូងវត្តខ្ពប ។

គណៈភូមិរកាលើបានជួបនិងណែនាំគ្រួសារខ្ញុំឲ្យទៅរស់នៅជាមួយនឹងគ្រួសារខ្មែរកាត់ចិនមួយឈ្មោះ ទ្រី ចម្ងាយប្រមាណពីររយម៉ែត្រខាងត្បូងវត្តខ្ពប ។ ផ្ទះចឹកទ្រីស្ថិតនៅខាងកើតថ្នល់សង់បែរមុខទៅទិសខាងលិច គឺជាផ្ទះតៀមផ្ទាល់ដីម៉ូដចិនសម័យបារាំង ជញ្ជាំងធ្វើពីក្តារពណ៌ប្រផេះ ដំបូលប្រក់ក្បឿងដែលមានស្លែកាន់ពណ៌ខ្មៅជុំៗ ។ នៅខាងមុខផ្ទះគាត់ប៉ែកខាងជើង ចឹកទ្រីបានសង់កូនរោងមួយបណ្តោយថ្ងៃបែរមុខទៅត្បូង ដែលមានទទឹងបីម៉ែត្រ បណ្តោយប្រាំម៉ែត្រ ខ្ពស់ផុតពីដីតែបន្តិច ហើយធ្វើជណ្តើរឡើងតែបីកាំប៉ុណ្ណោះ ។ នោះគឺជាជង្រុកស្រូវរបស់គាត់ ។ ដោយសារអង្គការកម្ចាត់មិនឲ្យមានកម្មសិទ្ធិសួនតួ ដូច្នេះអតីតជង្រុកស្រូវដ៏ជរារបស់ ចឹកទ្រី ដែលនៅទំនេរ បានក្លាយទៅជាគេហដ្ឋានថ្មីក្នុងសន្តមបដិវត្តន៍របស់ក្រុមគ្រួសារខ្ញុំ ។

ចឹកទ្រី មានកូនបីនាក់ ប្រុសពីរ ស្រីមួយ ប្រពន្ធរបស់គាត់ឈ្មោះ ភិន ។ គ្រួសារនេះស្រឡាញ់រាប់អានគ្រួសារខ្ញុំណាស់ ។ ក្រោយឆ្នាំ១៩៧៩ ចឹកទ្រី បាននាំក្រុមគ្រួសារគាត់រើផ្ទះពីភូមិរការលើមកនៅឯផ្សារព្រែកចឹកជនវិញ ប្រកបមុខរបរលក់គុយទាវ-កាហ្វេ រហូតដល់ឆ្នាំ១៩៩៧ គឺក្រោយពេលដែល មីងភិន ស្លាប់ដោយរោគាពាធ ចឹកទ្រី បាននាំកូនចៅទៅរស់នៅឯភូមិវត្តចុងកោះប្រកបរបរធ្វើស្រែចម្ការរហូតមកដល់សព្វថ្ងៃនេះ ។

នៅភូមិរកាលើ ចរន្តនៃការធ្វើបញ្ជីជំរឿនស្ថិតិ ព្រមទាំងការចាប់ផ្តើមបាត់ខ្លួនស្ងាត់ៗរបស់អ្នក១៧មេសា បានធ្វើឲ្យឪពុកខ្ញុំស្រៀវឆ្អឹងខ្នង ។

ប្រមាណប្រាំខែក្រោយមក ដោយសារតែស្បៀងអាហារមានការខ្វះខាតមិនអាចផ្គត់ផ្គង់អ្នកចំណូលថ្មីបាន និងដើម្បីយកអ្នកជម្លៀសទៅលត់ដំនៅតំបន់អត់ឃ្លានដង អង្គការបានចាប់ផ្តើមជម្លៀសអ្នក១៧មេសាជាលើកទីពីរទៅភូមិភាគពាយ័ព្យនិងភូមិភាគឧត្តរ ។ ឪពុកខ្ញុំលួចសប្បាយចិត្តស្ងាត់ៗ ព្រោះគាត់ដឹងខ្លួនថា នៅទីនេះយូរប្តូឆាប់គាត់នឹងត្រូវស្លាប់ដោយសារអ្នកស្រុកស្គាល់គាត់ ឬដោយសារការច្រណែនឈ្នានីសពីប្រជាជនមូលដ្ឋានមួយចំនួន ។

ការចេញដំណើរបានប្រព្រឹត្តទៅមួយភូមិម្តងៗ ។ អ្នកជម្លៀសទាំងអស់ត្រូវប្រមូលផ្តុំគ្នានៅមន្ទីរឃុំត្រង់ព្រែកចឹកជនដើម្បីឆ្លងទូកទៅវត្តកោះខែលដែលមានរថយន្តតម្រៀបរង់ចាំជាស្រេចនៅទីនោះ ។ ជាចៃដន្យ ដល់ពេលដែលក្រុមគ្រួសារខ្ញុំត្រូវចេញដំណើរពីភូមិរកាលើស្រាប់តែគ្មានរថយន្តរង់ចាំដឹកនៅកោះខែលទៀតទេ គឺមានរថយន្តរង់ចាំឯមន្ទីរស្រុកព្រែកតូចឯណោះ ។ ដូច្នេះគណៈសហករណ៍បានសម្រេចជញ្ជូនគ្រួសារខ្ញុំនិងអ្នកជម្លៀសដែលនៅសេសសល់តាមរទេះគោពីភូមិរកាលើឆ្ពោះទៅវត្តពោធិអណ្តែតក្នុងឃុំត្រើយស្លាដើម្បីឆ្លងទូកនៅទីនោះ ។

ពេលដែលរទេះគោធ្វើដំណើរឆ្លងកាត់ភូមិខ្ពបលើ ម្តាយខ្ញុំបានស្នើអ្នកបររទេះគោឲ្យឈប់នៅមុខផ្ទះជីតាខ្ញុំមួយភ្លែតដើម្បីចូលទៅលាក្រុមគ្រួសារគាត់បន្តិចសិន ។ ពេលនោះហើយដែល អ៊ំញឹង រត់ខ្វែងដៃខ្វែងជើងខ្វះខ្វែងអង្វរករគណៈសហករណ៍ទាំងទឹកភ្នែក សុំឲ្យគ្រួសារខ្ញុំបានស្នាក់នៅទីនោះមិនឲ្យជម្លៀសទៅឯណាទេ ។ ដោយសារក្រុមគ្រួសារខាងម្តាយខ្ញុំសុទ្ធតែអ្នកមូលដ្ឋាននិងមានគុណបំណាច់ជាច្រើនចំពោះបដិវត្តន៍ គណៈសហករណ៍ក៏អនុញ្ញាតឲ្យគ្រួសារខ្ញុំរស់នៅទីនោះតាមការស្នើសុំ ។ ឪពុកខ្ញុំជំទាស់ដាច់អហង្ការមិនព្រមស្នាក់នៅទីនេះទេ ព្រោះគាត់យល់ថាបើនៅត្រូវស្លាប់ បើទៅគាត់អាចមានឱកាសរស់ ។ គាត់ទាមទារឲ្យក្រុមគ្រួសារខ្ញុំចាកចេញជាបន្ទាន់ ប៉ុន្តែ អ៊ំញឹង និងម្តាយខ្ញុំក៏ជំទាស់មិនឲ្យនាំគ្រួសារជម្លៀសទៅដែរ ។ គាត់ទាំងពីរយល់ថា អ្នកជម្លៀសឡើងទៅលើនឹងត្រូវស្លាប់ដោយអត់អាហារឬដោយការសម្លាប់ផុតពូជ ។ ទីបំផុត ឪពុកខ្ញុំទាល់តម្រិះក៏យល់ព្រមរស់នៅជាមួយជីតាខ្ញុំ អ៊ំញឹង និងមីងព្រីង (ប្អូនពៅរបស់ម្តាយខ្ញុំ)

ក្នុងភូមិខ្ពបលើចាប់ពីពេលនោះមក ។ អ៊ីញ៊ីង និងមីងព្រីង មិនមានគ្រួសារកូនចៅអីទេ ។ មីងព្រីង ពិការជើងខាងស្តាំត្រឹមជង្គង់ដោយសារកាណូតបុកតាំងពីឆ្នាំ១៩៦៥មកម៉្លេះ ។ ដោយសារពិការភាពរបស់គាត់នេះហើយបានជាក្រោយមក មីងព្រីង បានក្លាយទៅជាអ្នកផលិតថ្នាំអាចម៍ទន្សាយ (ពេទ្យផលិតឱសថបុរាណ) ប្រចាំសហករណ៍ ដែលអាចជួយសង្គ្រោះជីវិតប្អូនតូចៗពីរនាក់របស់ខ្ញុំ (អារ៉ែណេតនិងអាភា) ឲ្យរួចផុតពីសេចក្តីស្លាប់បាន ។ សព្វថ្ងៃ មីងព្រីង កំពុងបួសជាដូនជីនៅវត្តខ្ពបចាប់តាំងពីឆ្នាំ១៩៩០មកម៉្លេះ ។

ក្រោយឆ្នាំ១៩៧៩ គ្រួសារអ្នកជម្លៀសឡើងទៅលើកាលពីពេលនោះនៅរស់រានមានជីវិតទាំងអស់ហើយត្រឡប់មករស់នៅក្នុងភូមិខ្ពបលើវិញពេញភូមិ ។ អ្នកទាំងនោះភាគច្រើនជាគ្រូបង្រៀន ។ ផ្ទុយទៅវិញ អ្នកដែលក្រាញមិនព្រមជម្លៀសទៅគឺត្រូវស្លាប់ទាំងអស់ ។ អ៊ីញ៊ីង និងម្តាយខ្ញុំ មានវិប្បដិសារីយ៉ាងខ្លាំងដោយគាត់ទាំងពីរយល់ថាខ្លួនបានរួមចំណែកធ្វើឲ្យឪពុកខ្ញុំស្លាប់ ។

នៅភូមិខ្ពបលើ គោលនយោបាយរបស់អង្គការដែលបែងចែកប្រជាជនជាពីរនិន្នាការដាច់ពីគ្នា គឺអ្នកមូលដ្ឋាន និងអ្នក១៧មេសា បានបង្កើតឲ្យមានស្រមោលជញ្ជាំងខណ្ឌចែកដាច់គ្នាជាពីរដែរ គឺរវាងវណ្ណៈអធននិងអតីតវណ្ណៈមូលធននាយទុនដែលខ្មែរក្រហមចាត់ទុកថាជាខ្មាំងរបស់អង្គការ រវាងភាពជាអ្នកឈ្នះសង្គ្រាមនិងអ្នកចាញ់សង្គ្រាម រវាងការរស់នៅត្រាំក្នុងភាពអាម៉ាស់និងការរស់នៅក្នុងភាពក្រអឺតក្រទម រវាងសេចក្តីខ្វះខាតស្រេកឃ្លាននិងភាពសម្បូរហូរហៀរស៊ីឆ្អែត រវាងការខំប្រឹងប្រែងធ្វើការដើម្បីចង់រស់និងការព្យាយាមចាប់កំហុសដើម្បីចង់សម្លាប់ ហើយស្ថានភាពផ្ទុយគ្នានេះបានលេចចេញយ៉ាងច្បាស់នៅក្នុងចំណោមជនរងគ្រោះនិងជនដៃដល់ដែលស្ថិតនៅច្របល់លាយឡំគ្នាក្នុងភូមិខ្ញុំ ។

នៅឆៀងខាងជើងផ្ទះខ្ញុំប្រមាណហាសិបគីឡូម៉ែត្រគឺផ្ទះពូសាត ។ ពូសាត គឺជាប្តី មីងស្រ៊ី និងត្រូវជាកូនប្រសាយាយស្រ៊ិន ។ ក្នុងឋានៈជាប្រធានឈ្លបប្រចាំសហករណ៍ភូមិខ្ពបលើ ពូសាត មានបញ្ជីខ្មៅនៅក្នុងដៃ ហើយអង្គការបានប្រគល់អំណាចគ្មានព្រំដែនដល់គាត់ដើម្បីសម្លាប់មនុស្ស ។ បញ្ជីខ្មៅគឺជាបញ្ជីរាយឈ្មោះប្រជាជន១៧មេសានិងប្រជាជនមូលដ្ឋានខ្លះដែលជាប់ខ្សែស្រឡាយចិននិងខ្មែរកម្ពុជាក្រោម ដែល ពូសាត ជាអ្នកកំណត់ថាតើអ្នកណាត្រូវស្លាប់មុនអ្នកណាត្រូវស្លាប់ក្រោយ ហើយវាសនានៃជនរងគ្រោះទាំងអស់នឹងត្រូវកំណត់ដោយទឹកប៊ិចពណ៌ក្រហមច្រាលដូចឈាមរបស់ ពូសាត ដែលអូសកាត់ពីលើឈ្មោះទាំងអស់នោះ ។

កុងឃុន ដែលរស់នៅខាងជើងជាប់នឹងសំយាបផ្ទះ ពូសាត ធ្លាប់បានឃើញបញ្ជីខ្មៅនោះដែរ ដោយសារ ពូសាត យកមកអួតបង្ហាញ ។ ពេលដែលឃើញឈ្មោះរបស់គាត់នៅក្នុងនោះដែរ កុងឃុន ភ័យណាស់ ហើយអង្វរករ ពូសាត កុំឲ្យធ្វើបាបគាត់ ។ កុងឃុន មានវាសនាបានរួចផុតពីសេចក្តីស្លាប់ហើយសព្វថ្ងៃគាត់កំពុងសំណាក់រៀនធម៌នៅវត្តខ្ពបជាមួយ មីងព្រីង ដែរ ។

កាលណោះប្រហែលជាមានហេតុផលដូច កុងឃុន នេះហើយបានជាអ៊ីញ៊ីង ព្រួយបារម្ភពីការស្លាប់របស់ឪពុកខ្ញុំដែលនឹងត្រូវទាក់ជាប់ដោយរលកនៃការបោសសម្អាតនេះ គាត់ខ្សឹបខ្សៀវទៅអង្វរករ ពូសាត ជារឿយៗកុំឲ្យធ្វើបាបឪពុកខ្ញុំ ។ តំណក់ទឹកភ្នែកដ៏ជោកជាំបូកជាមួយនឹងម្រាមដៃទាំងដប់ដែលលើកផ្គុំទូលលើក្បាលរបស់ អ៊ីញ៊ីង ត្រូវបាន ពូសាត ចាត់ទុកថាមានទម្ងន់ស្រាលស្ទើរមិនអាចធ្វើជាថ្នូរនឹងការស្លាប់របស់ឪពុកខ្ញុំបានទេ ។ អ៊ីញ៊ីង អង្វរញឹកញាប់ពេកទៅ គាត់ក៏ប្រាប់ទៅ អ៊ីញ៊ីង ថា ÷

◆ បងញ៊ីងឯងទៅភ័យអី ខ្ញុំឲ្យបងម៉េងស្លាប់គឺស្លាប់ហើយ ។

ពូសាត និយាយត្រូវណាស់ ។ អ៊ីញ៊ីង មិនយល់ន័យដែល ពូសាត និយាយ គាត់ខំតែជឿ ហើយក្នុងយប់នោះ ឈ្លបចងឪពុកខ្ញុំយកទៅបាត់រហូត ។

ពេលបែកឆ្នាំ១៩៧៩ភ្លាម ពូសាត ដើរទៅមើលរាំវង់នៅភូមិឫស្សីស្រុក ហើយអ្នកស្រុកនៅទីនោះក្រវែងប្រងសម្លាប់គាត់ស្ងាត់ៗ តែគាត់ដឹងខ្លួនទាន់ក៏នាំប្រពន្ធកូនឆ្លងទូកគេចខ្លួនទាំងយប់ទៅលាក់ខ្លួននៅខេត្តតាកែវរហូតដល់សព្វថ្ងៃ ។ បច្ចុប្បន្នឮដំណឹងថាគាត់ឈឺរ៉ាំរ៉ៃជិតស្លាប់ហើយ ។

នៅទល់មុខផ្ទះខ្ញុំគឺជាផ្ទះរបស់ ពូណែម ដែលជាប្រធានសហករណ៍ភូមិខ្ពបលើ ។ ពូណែម មានចរិតស្លូតបូត តែប្រតិបត្តិ

ការងារយ៉ាងម៉ឺងម៉ាត់ជូនអង្គការ ។ ដោយយល់ដល់ អ៊ីញ៉ើង ពូណៃម ក៏មិនបានធ្វើអ្វីប៉ះពាល់ដល់គ្រួសារខ្ញុំដែរ ។

ខ្ញុំនៅចាំបានថា យប់មួយនោះមានពន្លឺខែភ្លឺល្អ ខ្ញុំបានប្រថុយទៅលួចបេះល្ហុតនៅខាងក្រោយចេតិយយាយយ៉ាន់ក្បែរមាត់ទន្លេ ។ ខ្ញុំឡើងវារបេះផ្លែល្ហុតតាមមែកដែលខ្ញុំបានមើលចំណាំទុកតាំងពីពេលថ្ងៃ ។ បន្ទាប់ពីបេះបានមួយកូនការុង ខ្ញុំចុះមកសំងំនៅនឹងគល់ល្ហុតមួយសន្ទុះ ទើបចាប់យួរថង់ល្ហុតដើរវាងទៅមាត់ទន្លេមកចូលពីខាងក្រោយផ្ទះវិញ ។ មកដល់មាត់កំពង់ទឹក ខ្ញុំជួប ពូណៃម ដោយចៃដន្យ ។ គាត់សួរខ្ញុំខ្សឹបៗថា ÷

◆ បានស៊ីយួរហ្នឹង?

ខ្ញុំឆ្លើយទាំងភ័យថា ÷

◆ ល្ហុតទុំ ។

គាត់ក៏សួរបន្ត ÷

◆ រួចចុះថ្មើណឹងម៉េចក៏មានល្ហុតទុំច្រើនម្ល៉េះ?

ខ្ញុំឆ្លើយទាំងបុកពោះទៀតថា ÷

◆ ដឹងអីបើវាទុំច្រើន ។

តាមការពិត ពូណៃម បានលបមើលឃើញគ្រប់សកម្មភាពរបស់ខ្ញុំ ប៉ុន្តែគាត់មិនបានផែកផេរក្នុងការុងរបស់ខ្ញុំទេ ហើយក៏មិនបានរាយការណ៍អំពីខ្ញុំដែរ ។ ខ្ញុំដឹងច្បាស់ថា សិទ្ធិនិងអំណាចរបស់គាត់គឺអាចធ្វើឲ្យគ្រួសារខ្ញុំទាំងមូលស្លាប់បាន ។

ក្រោយឆ្នាំ១៩៧៩ ពូណៃម មិនបានរត់ចោលស្រុកទេ ហើយប្រជាជនក្នុងភូមិទាំងអស់រាប់ទាំងគ្រួសារខ្ញុំផង ស្រឡាញ់រាប់អានគាត់រហូតមកដល់សព្វថ្ងៃ ។

នៅខាងត្បូងផ្ទះខ្ញុំចម្ងាយប្រមាណពីររយម៉ែត្រគឺផ្ទះ ពូឃីង ដែលជាប្រធានឈ្លបសហករណ៍ឃុំខ្ពប ។ ពូឃីង គឺជាកូនបង្កើតរបស់ តាឃី និង យាយខេង ដែលមានផ្ទះនៅក្បែរមាត់កំពង់ទឹកចំខាងក្រោយផ្ទះខ្ញុំ ។ គាត់មានវ័យប្រហាក់ប្រហែលនឹងម្តាយខ្ញុំដែរ ។ កាលពីកុមារ ទាំងម្តាយខ្ញុំ ទាំងពូឃីង ទាំងពូណៃម សុទ្ធតែធ្លាប់បានលេងមីកលោតអន្ទាក់ជាមួយគ្នា ហើយក៏ធ្លាប់ត្រូវរំពាត់ជាមួយគ្នាដែរ ។

ដោយយកលេសមកមើលឪពុកម្តាយគាត់ ពូឃីង ឧស្សាហ៍មកក្រវែលមើលសកម្មភាពរបស់ឪពុកខ្ញុំ ។ ដោយសារគាត់មានស្នាដៃខាងដឹកនាំឈ្លបក្រោមឱវាទទៅចាប់មនុស្ស និងបញ្ជូនមនុស្សយកទៅដាក់មន្ទីរឃុំឃាំង ដូច្នេះសិទ្ធិនិងអំណាចរបស់ ពូឃីង នៅពេលនោះគឺខ្លាំងណាស់ ។ ប្រជាជនក្នុងឃុំខ្ពបទាំងមូលខ្លាចមិនហ៊ានមើលមុខគាត់ចំទេ ។

ពេលរបបខ្មែរក្រហមដួលរលំភ្លាម ពូឃីង បាននាំប្រពន្ធកូនរត់ចោលស្រុកទៅរស់នៅម្តុំផ្សារត្រពាំងក្រឡឹង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ហើយស្លាប់ចោលឆ្អឹងនៅទីនោះកាលពីឆ្នាំ២០០១ កន្លងទៅនេះ ។ អ៊ីញ៉ើង ជាទីគោរពស្រឡាញ់របស់ខ្ញុំក៏បានលាចាកលោកយើងនេះតាំងពីឆ្នាំ២០០១ដែរ ។ កាលពីរដូវបុណ្យចូលឆ្នាំខ្មែរឆ្នាំ២០០១ ពូឃីង ហ៊ានមកអើតមើលស្រុកកំណើតជាលើកទីមួយចាប់តាំងពីគាត់រត់ចោលស្រុកមក ហើយគាត់ក៏មានចិត្តឆ្លៀតទៅសាកសួរសុខទុក្ខ អ៊ីញ៉ើង ដែលកំពុងឈឺនៅនឹងកន្ទេល ។ ពូឃីង ស្រែកសួរពីចម្ងាយ ÷

◆ អ៊ើបងញ៉ើង! ស្គាល់ខ្ញុំឬអត់?

អ៊ីញ៉ើង ដែលឈឺជរាងើបពីកន្ទេលមិនរួច ហើយងងឹតភ្នែកវង្វេងវង្វាន់សូម្បីតែខ្ញុំក៏គាត់មើលមិនស្គាល់ផងនោះ ងាកទៅរកប្រភពសម្លេងហើយនិយាយក្នុងសម្លេងញ័រៗទាំងទឹកភ្នែកថា ÷

◆ អញស្គាល់ ហ្អែងអាឃីង ។

ឱ! ប្រហែលជាអារម្មណ៍របស់ អ៊ីញ៉ើង បានប្រមូលផ្តុំគូសវាសតែទៅលើទម្រង់មុខនិងសម្លេងអ្នកដែលបានចងបណ្តើរឪពុកខ្ញុំយកទៅសម្លាប់តែប៉ុណ្ណោះ ។ ការដែលគាត់ស្រក់ទឹកភ្នែកប្រហែលជាគាត់រំភើបខ្លាំងពេកព្រោះបានឮសម្លេងនិងបានសម្លឹងមុខជនដៃដល់ជាលើកចុងក្រោយក្នុងជីវិតរបស់គាត់ ។

នៅម្តុំផ្ទះខ្ញុំ អ្នករងគ្រោះដែលអង្គការបានស្នើយកទៅមុនគេគឺ ពូម៉ាន់ប្តីមីងព្រេង ។ បន្ទាប់មកគឺ ពូកូវប្តីមីងរឿង ។ តមកគឺ ពូម៉ែបងពូម៉ន ។ បន្ទាប់មកទៀតគឺ ពូស៊ីននិងមីងប៊ុន ប្រពន្ធរបស់គាត់ដែលត្រូវបានអង្គការយកទៅទាំងអស់គ្នាក្នុងយប់តែមួយ ។ ពូស៊ីន មានកូនស្រីដ៏ស្រស់ស្អាតម្នាក់ឈ្មោះ អាពីប ដែលមានអាយុប្រមាណ៥-៦ឆ្នាំ គឺស្របាលគ្នានឹងអាណៃត ប្អូនស្រីខ្ញុំដែរ ។

នៅមុនថ្ងៃបែករបបខ្មែរក្រហមមួយថ្ងៃ គឺក្នុងយប់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ អាពីប ត្រូវមេក្រុមកុមារគឺ មិត្តនារីណាង

មកស្នើសុំបេះយកចេញពីក្នុងរង្វង់ដៃ អ៊ំសៅ (ម្តាយបង្កើតរបស់ពូស៊ិន) ដោយកុហកថាយកទៅឲ្យហូបបាយជាមួយនឹងកុមារមួយចំនួនទៀតនៅក្នុងភូមិឫស្សីស្រុក ដែលតាមការពិតគឺយកទៅប្រគល់ឲ្យឈ្លបសម្លាប់សោះ ។ ស្អែកឡើងអ្នកភូមិបានឮឈ្លបជជែកគ្នាពីការសម្លាប់កុមារដោយបោកក្បាលនឹងគល់ត្នោតនៅជិតភូមិបឹងខ្ទប ។ ក្រោយពេលដែលឈ្លបរត់ចេញពីភូមិអស់ទៅ អ្នកស្រុកបានទៅមើលនៅម្តុំនោះ ឃើញមានស្នាមឈាមថ្មីៗលាយជាមួយនឹងសក់ក្មេងប្រឡាក់ប្រឡាកនៅជាប់នឹងគល់ត្នោតជាច្រើន ។ សព្វថ្ងៃ មិត្តនារី ណាង មានប្តីមានកូន ហើយកំពុងរស់នៅក្នុងភូមិបឹងខ្ទបនៅឡើយ ។

ការបោសសម្អាតនៅតែបន្តធ្វើ ហើយរហូតមកដល់ដើមឆ្នាំ១៩៧៧គឺដល់វេនឪពុកខ្ញុំ ។ កាលណោះខ្ញុំនិងកុមារ១៧មេសាដទៃទៀតត្រូវគណៈសហករណ៍ឃុំខ្ទបបញ្ជូនឲ្យទៅលើកទំនប់និងកសាងប្រពន្ធ័ភ្លឺស្រែថ្មីនៅស្ពានថ្ម-ក្រាំងយ៉ូវ ។ ចំណែកបងស្រីនិងឪពុកខ្ញុំត្រូវអង្គការចាត់តាំងឲ្យដឹកប្រឡាយមេមួយខ្សែនៅទួលតាស្រីរាំងតាអែមស្ថិតនៅខាងកើតភូមិបឹងខ្ទប ។

ក្នុងចំណោមបងប្អូនខ្ញុំទាំងអស់ដែលមានគ្នាប្រាំមួយនាក់ គឺមានតែបងស្រីខ្ញុំបង្អស់ម្នាក់គត់ដែលមានសំណាងបានឃើញឪពុកខ្ញុំជាលើកចុងក្រោយ ។ ក្នុងពេលសម្រាកថ្ងៃត្រង់ដើម្បីហូបបបរវាវកក្អកនៅក្បែរមាត់ប្រឡាយ ឪពុកខ្ញុំក្រឡេកឃើញបងស្រីខ្ញុំញុំញុំញុំនៅក្បែរវង់បបរព្រោះគ្មានស្លាបព្រាហុតទឹកបបរនឹងគេ ក៏ដើរសំដៅមករកបងស្រីខ្ញុំហើយសួរបសួរ ÷

◆ រួចចុះស្លាបព្រានៅឯណា?

◆ ស្លាបព្រាខ្ញុំបាត់តាំងពីយប់មិញ (បងស្រីខ្ញុំឆ្លើយទៅវិញ) អត់ដឹងថានរណាយកដែរ ។

◆ អ៊ីចឹងណោះ (ឪពុកខ្ញុំហុចស្លាបព្រាទៅឲ្យបងស្រីខ្ញុំ) យកទៅហូបឲ្យលឿនប្រយត្ន័មិនទាន់គេ ។

◆ ហើយចុះប៉ាបានអីហូបបបរ? (បងស្រីខ្ញុំសួរទៅគាត់)

◆ មិនអីទេ កូនទុកប្រើចុះ ។

និយាយរួចហើយគាត់ក៏ងើបឈរ ហើយបែរខ្លួនដើរសំដៅទៅវង់បបរចាស់ៗគ្នាគាត់ទៅ ។ ឪពុកខ្ញុំយល់ច្បាស់ណាស់ថាចាន (ប៉ុកាម៉ែល) និងស្លាបព្រា គឺជាសម្ភារផ្ទាល់ខ្លួនដ៏ចាំបាច់មិនអាចខ្វះបាន ។ អង្គការបានកំណត់គោលនយោបាយឲ្យបុគ្គលម្នាក់ៗមានកម្មសិទ្ធិសមរម្យតែមួយកូនស្បោងតូច ហើយនោះគឺគ្មានអ្វីក្រៅពីចានមួយនិងស្លាបព្រាមួយនេះឯង ។

ល្ងាចនោះ បងស្រីខ្ញុំទៅលួចស្លាបព្រានៅឯរោងបាយរួមបានមួយ ហើយគិតថានឹងប្រគល់ស្លាបព្រារបស់ឪពុកខ្ញុំទៅគាត់វិញនៅថ្ងៃស្អែក ។ ព្រឹកស្អែកឡើង បងស្រីខ្ញុំខំសម្លឹងរកមើលឪពុកខ្ញុំប៉ុន្តែមិនឃើញគាត់មកធ្វើការនឹងគេសោះ ។ ដល់ពេលសម្រាកហុតបបរថ្ងៃត្រង់ បងស្រីខ្ញុំក៏ដើរសំដៅទៅរកក្រុមចាស់ៗដើម្បីសួររកពុក ។ ពូមឿន ដែលជាអ្នកដឹកប្រឡាយក្នុងក្រុមជាមួយឪពុកខ្ញុំ បានស្ទុះមកឱបសួរបងស្រីខ្ញុំថា ÷

◆ មករកពុកមែនទេ?

◆ ចាស! ខ្ញុំយកស្លាបព្រាមកឲ្យគាត់វិញ (បងស្រីខ្ញុំឆ្លើយ)

◆ មិនបាច់មករកគាត់ទៀតទេ (ពូមឿននិយាយទាំងមុខស្លូត) គេឲ្យគាត់ទៅធ្វើការឆ្ងាយណាស់ ។

បងស្រីខ្ញុំក៏យល់នូវអ្វីដែល ពូមឿន បានប្រាប់ ។ ស្លាបព្រាដែលបម្រុងយកទៅជូនឪពុកខ្ញុំនោះ ត្រូវបានបងស្រីខ្ញុំរក្សាទុករហូតមកដល់សព្វថ្ងៃ ដោយដាក់នៅលើហ៊ឹងទីគោរពសក្ការៈខាងមុខរូបថតឪពុកខ្ញុំ គឺជាវត្ថុដែលមិនអាចកាត់ថ្លៃបានរបស់គ្រួសារខ្ញុំ ។

ពូមឿន បានរំឭកអំពីព្រឹត្តិការណ៍ដែលខ្មែរក្រហមចាប់ឪពុកខ្ញុំថា ÷

◆ យប់នោះ បងម៉េង កំពុងធ្វើការនៅបាតប្រឡាយ ឈ្លបបានហៅគាត់ឲ្យឡើងមកខាងលើ ។ ពេលនោះអ្នកកាន់ម៉ាស៊ីនភ្លើងបានពន្លត់ម៉ាស៊ីនឲ្យងងឹត រួចហើយឈ្លបចាប់គាត់ចងក្រៀកគ្មានឲ្យស្រែកមួយអឹះ ហើយបណ្តើរយកទៅមាត់ទន្លេបាត់ទៅ ។

ក្រោយពេលសម្រាកពីដឹកប្រឡាយក្នុងយប់នោះ ពូមឿន ជាអ្នកលីប៉ែលរបស់ឪពុកខ្ញុំមកប្រគល់ឲ្យ អ៊ំញឹង នៅឯភូមិ ។

បងស្រីខ្ញុំក៏ដឹងថាយប់មិញមានការពន្លត់ម៉ាស៊ីនភ្លើងដើម្បីចាប់មនុស្សដែរ ប៉ុន្តែគាត់មិននឹកស្មានថាជនរងគ្រោះគឺជាឪពុករបស់ខ្លួនសោះ ។ ជាទម្លាប់របស់ឈ្លបគឺច្រើនតែចាប់មនុស្សនៅពេលយប់តាមការដ្ឋានដែលកំពុងធ្វើការ ។ មុនពេលចាប់ត្រូវពន្លត់ម៉ាស៊ីនភ្លើង ហើយដំឡើងចម្រៀងបដិវត្តន៍តាមម៉េក្រូឲ្យឮខ្លាំងៗដើម្បីកុំឲ្យមានការភ្ញាក់ផ្អើល ។ បន្ទាប់ពីធ្វើការផាររួច

រាល់ហើយ ទើបប្រធានការដ្ឋានបញ្ជាឲ្យបញ្ឆេះម៉ាស៊ីនភ្លើងឡើងវិញដើម្បីបន្តការងារដឹកប្រឡាយតទៅទៀត ។ ដូច្នេះយប់ណាដែលមានការពន្លត់ម៉ាស៊ីនភ្លើងគឺប្រាកដជាមានការចាប់មនុស្សយកទៅសម្លាប់ហើយ ។

លុះដល់ព្រឹកស្អែកឡើង ពូឃឹង បានមកនិយាយប្រាប់អ៊ីញ៉ឹង បែបចំអកថា ÷

◆ យប់មិញខ្ញុំបណ្ដើរម៉េងឡើងទូក គាត់ស្រក់ទឹកភ្នែកដាក់ដៃខ្ញុំក្ដៅខណ្ណៗ ។ នៅលើទូក បងម៉េង ប្រាប់ថាពិបាកអង្គុយណាស់ហើយគាត់អង្វរឲ្យខ្ញុំបន្ធូរចំណងឲ្យគាត់បន្តិច ។ (ពូឃឹង និយាយបណ្ដើរសើចគឃឹកបណ្ដើរ)

អ៊ីញ៉ឹង អង្គុយលេបទឹកភ្នែកដ៏ល្វីងជូរចត់របស់គាត់ ដោយមិនអាចធ្វើអី ពូឃឹង បាន ។

បើតាមសម្ដីរបស់ ពូឃឹង ឪពុកខ្ញុំត្រូវកងសន្តិសុខមន្ទីរឃុំឃាំងកោះថ្មីធ្វើទារុណកម្មនិងសម្លាប់ចោលនៅក្នុងយប់នោះតែម្ដង ។ កោះថ្មី ឬមន្ទីរ-១៥ ស្ថិតនៅទល់មុខឃុំព្រែកអំបិលនិងឃុំពោធិបាន ។

ដោយអនុវត្តតាមទ្រឹស្ដីដឹកស្មៅត្រូវដឹកទាំងឫស បន្ទាប់ពីសម្លាប់ឪពុកខ្ញុំរួច គណៈសហករណ៍ឃុំបានស្រាវជ្រាវនិងបញ្ជាឲ្យនាំខ្លួនខ្ញុំដែលកំពុងធ្វើការឯក្រាំងយ៉ូវត្រឡប់មកឃុំខ្ញុំវិញដើម្បីបញ្ជូនទៅប្រមូលផ្ដុំនិងលត់ដំនៅក្នុងកងចល័តយុវជនប្រចាំស្រុក២០ ងាយស្រួលក្នុងការបោសសម្អាតទៀត ។

សម្លេងម៉ាស៊ីនកាណូតបានបញ្ឈប់ ហើយគែមទូកបានហក់ទៅទង្គិចជាមួយនឹងដែកពំនង់ដត្រើយខាងកើត ប្រៀបដូចជាចាប់កញ្ឆក់ខ្ញុំឲ្យភ្ញាក់ចេញពីអន្លង់រឿងរ៉ាវដ៏សែនសោកសៅនេះ ។

ម្ភៃប្រាំឆ្នាំបានកន្លងផុតទៅហើយ ទឹកទន្លេបាសាក់ក្នុងរដូវវស្សានៅតែហូរចុះទៅសមុទ្រយ៉ាងស្ងៀមស្ងាត់ និងមានសម្បុរដូចកាហ្វេទឹកដោះគោដដែល ។

នៅភូមិរការក្រោម ខ្ញុំឈរសម្លឹងមើលកោះថ្មីហើយធៀបជាមួយនឹងចរន្តទឹកហូរ ខ្ញុំហាក់ដូចជាមានអារម្មណ៍ថាកោះថ្មីកំពុងតែធ្វើចលនាបញ្ច្រាសទឹកយឺតៗ ។ កោះនេះបានបង្កប់នូវសម្រស់ធម្មជាតិដ៏ស្រស់ត្រកាលនិងស្ងប់ស្ងាត់ហាក់ដូចជាកំពុងតែរង់ចាំការស្វែងរកយុត្តិធម៌ជូនដល់ព្រលឹងជនរងគ្រោះទាំងអស់ដែលបានស្លាប់យ៉ាងអយុត្តិធម៌នៅទីនោះ ។

ជនរងគ្រោះទាំងអស់នោះជាស្នាដៃនៃការខិតខំប្រឹងប្រែងរួមគ្នារវាងកងសន្តិសុខ កងឈ្លប និងគណៈសហករណ៍គ្រប់ជាន់ថ្នាក់ក្នុងការអនុវត្តផែនការបោសសម្អាតខ្មាំងរបស់អង្គការ ប្រៀបដូចជាអ្នកទាំងនោះខំប្រឹងចាប់បង្ខិលកង់ប្រលយ័ពូជសាសន៍ឲ្យវិលខ្ទាល់ជាប់រហូតជូនអង្គការក្នុងរយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ គ្មានឈប់សម្រាកដូច្នេះដែរ ។

នៅពេលនេះខ្ញុំមានអារម្មណ៍ដូចអ្នកស្រី ឡូរ៉េង់ពិច ដែរ គឺ "ខ្ញុំមិនភ្លេច ខ្ញុំមិនចង់ភ្លេច ហើយខ្ញុំភ័យខ្លាចភ្លេច" នោះគឺការស្លាប់ដ៏ខ្លោចផ្សារបស់ឪពុកខ្ញុំនិងប្រជាជនខ្មែររាប់លាននាក់ក្រោមរបបខ្មែរក្រហមមហាលោតផ្លោះមហាអស្ចារ្យនេះ ។

ក៏ដូចជាជនរងគ្រោះក្នុងរបបខ្មែរក្រហមឯទៀតៗដែរ ខ្ញុំចង់បានតុលាការឯករាជ្យខ្នាតអន្តរជាតិមួយឲ្យបានឆាប់ ដើម្បីដោះស្រាយរឿងនេះ ។ ខ្ញុំមិនទាមទារឲ្យសងជំងឺចិត្តជាលុយជាកាក់អ្វីទេ ប៉ុន្តែគ្រាន់តែចង់ឲ្យមេដឹកនាំខ្មែរក្រហមទាំងនោះប្រាប់ខ្ញុំមកថា ហេតុដែលឈ្លបហៅឪពុកខ្ញុំពីបាតប្រឡាយចងបណ្ដើរយកទៅបាត់រហូតដល់សព្វថ្ងៃនេះ តើរឿងហ្នឹងវាយ៉ាងម៉េច?

ប្រសិនបើអ្នកទាំងនោះមិនទាន់បានឆ្លើយ ឬឆ្លើយមិនសមហេតុផល ខ្ញុំនៅតែមិនអស់ចិត្តរហូត ។

**ម៉េង រស្មី**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
*Email: dccam@online.com.kh*
*Home page: www.dccam.org*

# ២៩ឆ្នាំក្រោយ បានត្រឹមតែឃើញរូបថត

រសៀលមួយនាចុងឆ្នាំ១៩៧៥ ឈ្លបខ្មែរក្រហមម្នាក់ឈ្មោះ ធន បានមកស្នើ ហៀង ឆួន ទៅជួសជុលម៉ាស៊ីននៅសាលាឃុំ ។ ឆួន ដើរទៅតាមឈ្លបក្រោមការតាមមើលរបស់កូនប្រុសគាត់អាយុ១៥ឆ្នាំឈ្មោះ ឆួន រី ។ ម្តាយរបស់ រី បានរត់តាមដើម្បីយកបារីទៅឲ្យប្តី ។ ហៀង ឆួន និយាយជាមួយប្រពន្ធថា «ឯងនៅផ្ទះថែរក្សាកូនទៅ» ។ តាំងពីពេលនោះមក ឆួន រី មិនបានឃើញមុខឪពុកជារៀងរហូត ។

២៩ឆ្នាំកន្លងផុតទៅហើយ ឆួន រី នៅតែទន្ទឹងរង់ចាំការវិលត្រឡប់មកវិញរបស់ឪពុកគាត់ ។ នៅខែកញ្ញា ឆ្នាំ២០០៤ កន្លងមកនេះ តាមរយៈឯកសារប្រវត្តិរូបរបស់ ហៀង ឆួន ដែលតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ក្រុមអ្នកស្រាវជ្រាវបានចុះទៅសួររកឈ្មោះ ហៀង ឆួន នៅភូមិអំពិល ហើយបានជួប ឆួន រី ដែលជាកូន ។ ឆួន រី សម្តែងសេចក្តីត្រេកអរជាខ្លាំង ព្រោះគិតក្នុងចិត្តថា ក្រុមអ្នកស្រាវជ្រាវច្បាស់ជាពាំនាំដំណឹងឪពុករបស់គាត់នៅរស់ទៅប្រាប់ដល់ក្រុមគ្រួសាររបស់គាត់មិនខាន ។ ផ្ទុយទៅវិញ គាត់ប្រែជាមានទុក្ខព្រួយយ៉ាងក្រៀមក្រំ នៅពេលដែលក្រុមស្រាវជ្រាវប្រាប់ថាមិនបានដឹងដំណឹងឪពុករបស់គាត់ទេ ។


ហៀង ឆួន (រូបថតនៅមន្ទីរស-២១)


ឆួន រី

ឆួន រី បានឲ្យដឹងថា ទោសដែលនាំដល់ការស្លាប់របស់ឪពុកគាត់គឺមកពីឪពុករបស់គាត់បានលួចកាប់គោដែលខ្លួនឯងចិញ្ចឹមដើម្បីយកសាច់បរិភោគ ។ រី រំឭកថា «គ្រាន់តែខុសវាយគោហូបវាឃ្លានពេកណា៎ ដំណាក់កាលហ្នឹងឃ្លានចេះតែលួចវាយ ហើយវាយហ្នឹងមិនមែនរបស់គេទេ របស់ឯងទៀត» ។ ឪពុក របស់ រី ត្រូវអង្គការឃុំឃាំងនៅក្នុងចេតិយមួយនៅវត្តទួលក្រាំងអស់រយៈពេលពីរ-បីថ្ងៃ ហើយក៏បញ្ជូនទៅកន្លែងមួយផ្សេងទៀតដែល រី មិនដឹង (តាមទម្រង់ឯកសារប្រវត្តិរូបរបស់ ហៀង ឆួន យើងសន្និដ្ឋានថា ប្រហែលជាគាត់ត្រូវឃុំឃាំងនិងសម្លាប់នៅមន្ទីរស-២១ ឬមន្ទីរព្រៃស) ។ រី ជឿជាក់ថា អ្នកដែលចេញបញ្ជាឲ្យចាប់ខ្លួនឪពុករបស់គាត់ គឺ តាឡេង ដែលកាលណោះជាគណៈឃុំក្រាំងយ៉ូវ ។ បន្ទាប់ពីសម្លាប់ឪពុករបស់ រី ហើយ អង្គការក៏បញ្ជូនម្តាយរបស់គាត់ទៅកោះខ្សាច់ទន្លា ជាកន្លែងប្រមូលផ្តុំស្ត្រីមេម៉ាយដែលប្តីត្រូវអង្គការសម្លាប់ចោល ។

ឆួន រី ចេះតែសួរម្តងហើយម្តងទៀតអំពីដំណឹងឪពុករបស់គាត់ ។ គាត់រំឭកពីអំពើល្អរបស់ឪពុកគាត់ថា «ឪពុកដែលធ្វើល្អមកលើកូន កូនចាំអត់ភ្លេចទេ ។ ទោះបីខឹងកូនប៉ុណ្ណា ធ្វើម្ហូបឲ្យកូនហូបសិនទើបវាយកូន ។ និយាយទៅវាអួលដើមកនិយាយអត់កើត វាណែនដើមទ្រូងអស់ហើយ ។ អ៊ីចឹងបានជាខ្ញុំសួរបងក្រែងឪពុកខ្ញុំនៅរស់ ។ បើគាត់នៅរស់ ប្អូនឯងឲ្យលុយខ្ញុំមួយលានដុល្លារក៏មិនស្មើនឹងប្រាប់ខ្ញុំដែរ» ។ ទោះជានៅតែទទូចសួរយ៉ាងនេះក្តី ក៏ក្នុងចិត្តរបស់ រី ជឿជាក់ថា ឪពុករបស់គាត់បានស្លាប់បាត់ទៅហើយ ។ បន្ទាប់ពីការរង់ចាំអស់រយៈពេល២៩ឆ្នាំ នៅទីបំផុតអ្វីដែល ឆួន រី បានឃើញគឺរូបថតរបស់ឪពុកគាត់ដែលបិទជាប់នឹងប្រវត្តិរូបមួយសន្លឹកក្នុងនាមជាអ្នកទោសរបស់អង្គការ ។ គាត់បានសុំថតចម្លងរូបថតនេះដើម្បីទុកជាតំណាងរូបឪពុកដែលគាត់គោរពនិងស្រលាញ់ ។

**សាន់ កល្យាណ**

# មេត្តាជួយស្រាវជ្រាវរកចម្លើយសារភាពនិងវិធីសម្លាប់ឪពុកខ្ញុំ

ខ្ញុំបាទបានអានទស្សនាវដ្តីរបស់លោកច្រើនលេខមកហើយ ព្រោះខ្ញុំមានចំណាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការស្វែងរកការពិតអំពីរបបប្រល័យពូជសាសន៍នេះ ។ ខ្ញុំសូមកោតសរសើរដោយស្មោះសរនូវឧត្តមគតិដ៏មហាអស្ចារ្យរបស់លោកដែលបានបង្កើតឡើងនូវទស្សនាវដ្តីនេះ ដើម្បីជីកកកាយនូវរបបដ៏ខ្មៅងងឹតមហាប្រល័យពូជសាសន៍ឯងនិងមហាព្រៃផ្សៃបំផុតអស់រយៈពេលជាង៣ឆ្នាំនាចុងទសវត្សរ៍ឆ្នាំ១៩៧០នេះ ។ ជាងនេះទៅទៀត ទស្សនាវដ្តីនេះថែមទាំងបានស្វែងរកពត៌មានពីអ្នកដែលបានបាត់បង់ជីវិតក្នុងរបបខ្មែរក្រហមប៉ុលពត ជូនដល់បងប្អូនសាច់ញាតិរបស់ជនរងគ្រោះដែលចង់ដឹងការពិតនៃមូលហេតុនិងវិធីសម្លាប់ទៀតផង ។

ខ្ញុំជាក្មេងម្នាក់កើតនៅចុងឆ្នាំ១៩៧៥ក្នុងរបបប្រល័យពូជសាសន៍ មិនបានឃើញមុខឪពុកយ៉ាងម៉េចផង ។ ពេលជម្លៀសចេញពីទីក្រុងភ្នំពេញខ្ញុំទើបតែចាប់កំណើតក្នុងផ្ទៃម្តាយបាន៣ខែតែប៉ុណ្ណោះ ហើយម្តាយនិងឪពុកខ្ញុំបានបែកគ្នាក្នុងពេលធ្វើដំណើរជម្លៀស ។

ឪពុកខ្ញុំឈ្មោះ ហ៊ឹម ហឿន អតីតប៉េអឹមសម័យសាធារណរដ្ឋខ្មែរ ត្រូវបានជម្លៀសរហូតដល់ស្រុកកំណើតរបស់គាត់នៅភូមិផ្អាវ ឃុំផ្អាវ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ។ ក្រោយឆ្នាំ១៩៧៩ ម្តាយខ្ញុំក៏បានទៅរកឪពុកខ្ញុំនៅភូមិផ្អាវ (ផ្លូវជាតិលេខ៨) ។ អ៊ឹមហន (បងស្រីបង្កើតរបស់ឪពុកខ្ញុំ) បានប្រាប់ម្តាយខ្ញុំថា ឪពុកខ្ញុំត្រូវអង្គការចាប់យកទៅនៅអំឡុងឆ្នាំ១៩៧៦ ។ គាត់ឃើញឈ្លបចងឪពុកខ្ញុំអូសបណ្តើរតាមកង់ឆ្ពោះមកទិសខាងលិច (ទិសមកភ្នំពេញ) ប៉ុន្តែគាត់មិនដឹងថាឈ្លបយកឪពុកខ្ញុំទៅសម្លាប់ចោលនៅកន្លែងណាទេ ។ គាត់សន្និដ្ឋានថាឪពុកខ្ញុំស្លាប់ហើយ ព្រោះមិនឃើញត្រឡប់មកវិញទាល់តែសោះ ។ ក្រោយពីបានស្តាប់ការរៀបរាប់នេះ ម្តាយខ្ញុំគិតតែទ្រហោយំ ចំណែកខ្ញុំមិនទាន់ដឹងក្តីនៅឡើយទេ ទើបតែអាយុ៣ឆ្នាំប៉ុណ្ណោះ ។

ឥឡូវនេះខ្ញុំអាយុ២៩ឆ្នាំហើយ ។ ថ្ងៃមួយខ្ញុំបានអានសៀវភៅ "តុលាការប្រជាជនបដិវត្តន៍កម្ពុជា" ជំនុំជម្រះអំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍របស់ពួកប៉ុលពត អៀង សារី ដែលមានប្រធានតុលាការគឺ សមមិត្ត កែវ ចិន្តា សមាជិកក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា និងជារដ្ឋមន្ត្រីក្រសួងឃោសនាការ វប្បធម៌ និងពត៌មាន ។ នៅផ្នែកខាងក្រោយនៃសៀវភៅនេះមានបញ្ជីរាយនាមអ្នកដែលត្រូវបានសម្លាប់នៅក្នុងគុកទួលស្លែង "២-១១" ហើយនៅក្នុងផ្នែកយោធាត្រង់ទំព័រទី៣៣៧ លេខរៀងទី៤៤ មានឈ្មោះ ហ៊ិន ហឿន តំបន់២៥ ប៉េអឹម ថ្ងៃចូល ១៤-០៦-៧៦ ថ្ងៃកម្ទេច ១៦-០៩-៧៦ ។ ខ្ញុំគិតថានេះប្រហែលជាឈ្មោះរបស់ឪពុកខ្ញុំហើយ ប៉ុន្តែឪពុកខ្ញុំឈ្មោះ ហ៊ឹម ហឿន ។ ឬមួយក៏អ្នកសួរចម្លើយស្តាប់មិនច្បាស់ទើបសរសេរ ហ៊ិន ហឿន ឬយ៉ាងណា? សូមលោកនាយកមេត្តាជួយស្រាវជ្រាវរកចម្លើយសារភាពនិងវិធីសម្លាប់ឪពុករបស់ខ្ញុំដោយក្តីអនុគ្រោះ ដើម្បីឲ្យក្រុមគ្រួសារខ្ញុំអស់មន្ទិលសង្ស័យផង ។ ខ្ញុំបាទសូមថ្លែងអំណរគុណលោកនាយកមជ្ឈមណ្ឌលនិងសហការីទាំងអស់ទុកជាមុន ។ **ជឹម ភ័ក្ត្រា**

# សេចក្តីប្រកាសរកបងស្រី

នាងខ្ញុំឈ្មោះ លាវ សាមឿន អាយុ៤៥ឆ្នាំ សព្វថ្ងៃរស់នៅភូមិក្រាំងដូង ឃុំសំរោង ស្រុកបន្ទាយមាស ខេត្តកំពត ។ ឪពុកឈ្មោះ លាវ ឡៃ (ស្លាប់) និងម្តាយឈ្មោះ ណុប សប (ស្លាប់ឆ្នាំ២០០២) ។ នាងខ្ញុំមានបងប្អូនប្រាំបីនាក់ៈ ១)លាវ ស៊ីណៃ ភេទស្រី (បាត់ខ្លួន) ២)រូបនាងខ្ញុំ លាវ សាមឿន ៣)លាវ ប៉ក់ ភេទប្រុស ៤)លាវ ប៉ោក ភេទប្រុស ៥)លាវ ពីន ភេទប្រុស ៦)លាវ ស្រី ភេទស្រី ៧) លាវ ចិន ភេទស្រី និង ៨)លាវ មន ភេទស្រី ។

នាងខ្ញុំសុំសួររកបងស្រីឈ្មោះ លាវ ស៊ីណៃ ដែលបានចូលបដិវត្តន៍ខ្មែរក្រហមនៅខេត្តកំពតក្នុងឆ្នាំ១៩៧៥ ក្រោយមកអង្គការផ្សំផ្គុំគាត់ឲ្យមានគ្រួសារ ។ នាងខ្ញុំក៏បានបែកពីគាត់តាំងពីពេលនោះមក ។ រហូតមកដល់សព្វថ្ងៃនេះនាងខ្ញុំមិនដែលបានទទួលដំណឹងអ្វីសោះពីគាត់ ។ ប្រសិនបើបងប្អូនឬញាតិមិត្តណាបានស្គាល់ឬបានឮដំណឹងអំពីឈ្មោះខាងលើនេះ សូមមេត្តាផ្តល់ពត៌មានមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ ឬតាមទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកកូន

*យើងខ្ញុំដូចដែលមានឈ្មោះខាងក្រោម រស់នៅភូមិអន្លង់តាសេកក្រោម ឃុំព្រៃកអំបិល ស្រុកស្អាង ខេត្តកណ្តាល សូមសួររកកូនៗដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហមហើយបាត់ខ្លួនរហូតមកដល់បច្ចុប្បន្ន ។*

◆ *ឈ្មោះ ប្រាក់ ហុង ភេទស្រី អាយុ៧៤ឆ្នាំ សូមសួររកកូនប្រុស៣នាក់ ៖ ១) ឈ្មោះ កែវ បាន ពេលចូលបដិវត្តន៍អាយុជាង ២០ឆ្នាំ, ២) ឈ្មោះ កែវ ម៉ាន ពេលចូលបដិវត្តន៍អាយុជាង២០ឆ្នាំ និង ៣) ឈ្មោះ កែវ យ៉ត ។*

*ទាំងបីនាក់នេះចូលបដិវត្តន៍អំឡុងឆ្នាំ១៩៧៣ តាមការបង្ហឹរបស់ប្រធានភូមិឈ្មោះ ហម ។*

◆ *ឈ្មោះ ឡាច ហុង ភេទស្រី អាយុ៧៣ឆ្នាំ សូមសួររកកូនប្រុសឈ្មោះ ប៉ុល ឆាង ចូលបដិវត្តន៍អំឡុងឆ្នាំ១៩៧៣ តាមការបង្ហឹរបស់ប្រធានភូមិឈ្មោះ ហម ។*

◆ *ឈ្មោះ ព្រំ សាត ភេទប្រុស អាយុ៨០ឆ្នាំ សូមសួររកកូនប្រុសឈ្មោះ ព្រំ ស ពេលចូលបដិវត្តន៍អាយុ១៨ឆ្នាំ ។*

◆ *ឈ្មោះ ហួន ប៉ែត ភេទស្រី អាយុ៦៥ឆ្នាំ សូមសួររកកូនប្រុសឈ្មោះ ហួន គឹមឡេង ពេលចូលបដិវត្តន៍នៅឆ្នាំ១៩៧៥ មានអាយុ១២ឆ្នាំ ។ ខ្ញុំបានឮថា ហួន គឹមឡេង គឺជានីរសារ ។*

◆ *ឈ្មោះ យឹម យួន ភេទប្រុស អាយុ៦៣ឆ្នាំ សូមសួររកកូនប្រុសឈ្មោះ យឹម ដាត ពេលចូលបដិវត្តន៍នៅឆ្នាំ១៩៧៥ មានអាយុ១៣ឆ្នាំ ។ ពេលដែល ដាត ចេញពីផ្ទះដំបូងបានធ្វើដំណើរទៅកោះខ្សាច់ទន្លា ហើយធ្វើជាកងទ័ពនៅក្នុងកងដឹកជញ្ជូនស្បៀង ។*

*ប្រសិនបើសាមីខ្លួនបានឮឬបងប្អូនណាបានដឹងដំណឹង សូមមេត្តាទាក់ទងយើងខ្ញុំនៅភូមិស្រុកខាងលើឬផ្តល់ព័ត៌មានមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬតាមទូរស័ព្ទលេខ (៨៥៥) ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។*

# តែងតែនឹកឃើញនូវសោកនាដកម្ម

*លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ជាទីរាប់អាន*

*ជាបឋមខ្ញុំសូមថ្លែងអំណរគុណដោយក្តីសោមនស្សរីករាយជាអនេកប្បការ ចំពោះលោកនាយកដែលបានផ្ញើជូនខ្ញុំនូវខ្សែភាពយន្តឯកសារខ្លាតខ្លីមួយ ក្រោមចំណងជើងថា "The Khmer Rouge Rice Field: The Story of Rape Survivor Tang Kim" ដែលបានផលិតឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។*

*លោកនាយកជាទីរាប់អាន ជានិច្ចជាកាល គ្រប់ពេលវេលាខ្ញុំតែងតែនឹកឃើញនូវសោកនាដកម្មគ្រប់បែបយ៉ាងរាល់អំពើឃោរឃៅព្រៃផ្សៃ អមនុស្សធម៌ រយៈពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យរបស់ពួកខ្មែរក្រហម ។*

*នាយកជាទីរាប់អាន រាល់សកម្មភាពក្នុងរបបខ្មែរក្រហមហាក់បីដូចជាក្នុងខួរក្បាលរបស់ខ្ញុំដែលមិនអាចបំភ្លេចបានសោះឡើយ ហើយវាហាក់បីដូចជានៅថ្មីៗជានិច្ច ដូច្នេះយើងទាំងអស់គ្នាដែលបានទទួលនូវការរងគ្រោះក្នុងរបបនេះ ត្រូវតែការពារតស៊ូប្រឆាំងជាដាច់ខាតកុំឲ្យរបបនេះវិលត្រឡប់មកជាថ្មី និងសូមជួយអំពាវនាវដល់អង្គការអន្តរជាតិនានា មេត្តាជួយឧបត្ថម្ភដល់ដំណើរការកាត់ទោសពួកមេដឹកនាំខ្មែរក្រហម ដើម្បីស្វែងរកភាពយុត្តិធម៌ដល់ជនរងគ្រោះ ។*

*ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់លោកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសហការីទាំងអស់ សូមមានសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួន អាយុយឺនយូរ ដើម្បីបំពេញការងារស្វែងរកការពិត និងរកភាពយុត្តិធម៌ដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហមប្រកបដោយជោគជ័យ ។*

**ម៉ុក ម៉ារ៉េត, បណ្ឌិត ជីវវិទ្យា, ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**




The Documentation Center of Cambodia would like to appeal to governments, foundations and individuals [illegible] support of the publication of Searching for the Truth!. For contribution, please contact (855) 23 [illegible] or By Email: dccam@online.com.kh. Thank you.

A magazine of the Documentation Center of Cambodia: Searching for the truth. Number 59, November 2004.
Funded by Germany, Norway, Sweden, and USA.